ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ការលើកកម្ពស់តួនាទីរបស់អាស៊ាននៅក្នុងបញ្ហាសិទ្ធិមនុស្ស
- កូនស្រីអ្នកទោសស-២១ ដឹងពីដំណើរឪពុក

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១២៧ ខែកក្កដា ឆ្នាំ២០១០

# ស្វែងរកការពិត

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១២៧ ខែកក្កដា ឆ្នាំ២០១០

### មាតិកា

◆ការលើកកម្ពស់តួនាទីរបស់អាស៊ាននៅក្នុងបញ្ហាសិទ្ធិមនុស្ស .......................១

**ផ្នែកឯកសារ**

◆គេចពីការសម្លាប់របស់ខ្មែរក្រហម .......................................................៣

◆ណុប ប៊ុណ្ណា ៖ ការចងចាំដែលមិនអាចបំភ្លេចបាន..................................៥

◆កូនស្រីអ្នកទោសស-២១ ដឹងពីដំណឹងឪពុក ........................................៧

◆ខ្មែរក្រហម ៖ ការកេណ្ឌទ័ព និងការជ្រើសរើស ..................................១០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆សំ សុវណ្ណដារ៉ា ៖ គ្រូបង្រៀនមុខសញ្ញារបស់អង្គការ ...........................១៧

◆ធ្វើបដិវត្តន៍ដើម្បីរំដោះប្រទេសជាតិ ...................................................១៩

◆សាំង សារិនៈ ខ្មែរក្រហមសម្លាប់ឪពុកខ្ញុំ ..........................................២១

◆ការរំឭកពីការអប់រំអំពើប្រល័យពូជសាសន៍......................................២៣

◆អ្នកជិតខាងរបស់ឃាតករមិនមានភាពអាម៉ាស់ទេ ...............................២៥

◆នៅតែល្អជាមួយកូនរបស់ជនដៃដល់ ..................................................២៧

◆ជំនួបរវាងសហព្រះរាជអាជ្ញា និងខ្មែរកម្ពុជាក្រោមនៅខេត្តពោធិ៍សាត់.....២៩

◆ទស្សនាខ្សែភាពយន្តអំពីរបបខ្មែរក្រហមនៅមជ្ឈមណ្ឌល .......................៣៥

◆របាយការណ៍អំពីវគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានក្នុងខេត្តស្វាយរៀង .........៣៦

**ផ្នែកច្បាប់**

◆តើមានការជ្រៀតជ្រែកផ្នែកនយោបាយនៅ ..........................................៤០

◆ការបង្ហាញអំពីគោលបំណងនៃអំពើប្រល័យពូជសាសន៍ ...................៤៥

**វេទិកាពិភាក្សាសាធារណៈ**

◆ផលប៉ះពាល់ចំពោះអាយុ និងសុខភាពរបស់ជនត្រូវចោទ ................៥៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆រំឭករឿងឈឺចាប់នៅក្នុងរបបខ្មែរក្រហមដើម្បីអ្វី? .......................៥៨



វគ្គបណ្តុះបណ្តាលគ្រូបង្គោលមូលដ្ឋាន



មេឃុំរំលេចប្រគល់ព្រះពុទ្ធរូប **ទៅឲ្យលោក អេនឌ្រូ ខាលី**

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** ហ្វ្រាំហ្គោរី ប្រកណ្ឌ, កែវ ដាស៊ីល, ឡូរ៉ា វីលីម, ដេឡា សេនទីលឡេស, រីយ៉ាន អ៊ី.ផាក, ស្បេនស៊ើ ខ្រាយឌឺ, ស៊ឹម ទីណា **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែៈ** ជា ផល្លា, ទេស ម៉ារ៉ែម **និពន្ធនាយកទូទៅៈ** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** ទេព ម៉េងឃាន, ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ម៉ម សុជាត

Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ:*

# ការលើកកម្ពស់តួនាទីរបស់អាស៊ាននៅក្នុងបញ្ហាសិទ្ធិមនុស្ស

កាលពីខែតុលាមុននេះ មេដឹកនាំអាស៊ីអាគ្នេយ៍បាន ចាប់ផ្ដើមបង្កើតគណៈកម្មការអន្តររដ្ឋាភិបាលស្ដីពីសិទ្ធិមនុស្សរបស់អាស៊ាន ។ គណៈកម្មការនេះធ្លាប់ទទួលបានប្រតិកម្មចម្រុះនៅក្នុងសហគមន៍សិទ្ធិមនុស្ស ។ អ្នកខ្លះបានសរសើរថា គណៈកម្មការនេះគឺជាជំហានដ៏ត្រឹមត្រូវមួយ ប៉ុន្តែមានមនុស្សជាច្រើនបានបដិសេធនឹងគណៈកម្មការនេះដោយចាត់ទុកថាគណៈកម្មការនេះគ្មានឥទ្ធិពល ឬមិនមានសារសំខាន់ ។ គណៈកម្មការអន្តររដ្ឋាភិបាលស្ដីពីសិទ្ធិមនុស្សមានទាំងតួនាទី និងឱកាសដើម្បីបញ្ជាក់ថា ការរិះគន់នោះគឺមិនត្រឹមត្រូវ ។

គណៈកម្មការគឺជាផ្នែកមួយនៃកិច្ចខំប្រឹងប្រែងដើម្បីបង្កើនភាពជឿជាក់និងសារសំខាន់របស់អាស៊ាន ។ អាស៊ានបានសង្កត់ធ្ងន់ទៅលើការមិនមានការជ្រៀតជ្រែកនិងការដើរយឺតជាងអង្គការក្នុងតំបន់ផ្សេងទៀតចំពោះការផ្ដល់អាទិភាពទៅលើសិទ្ធិមនុស្ស ។ ការមិនចង់ផ្ដោតទៅលើសិទ្ធិមនុស្សនេះបានធ្វើឲ្យបស្ចិមប្រទេសមានការខឹងសម្បានិងអស់សង្ឃឹមចំពោះកិច្ចខំប្រឹងប្រែងរបស់អាស៊ានដើម្បីសម្របទៅនឹងសេដ្ឋកិច្ចពិភពលោក ។ ការមិនយល់ស្របគ្នានៅក្នុងតំបន់ក៏បានកើនឡើងដោយសារតែការផ្លាស់ប្ដូរបទដ្ឋាននៅក្នុងតំបន់និងការអាក់អន់ចិត្តចំពោះតម្លៃរួមដែលសមាជិកអាស៊ានត្រូវបង់សម្រាប់កំហុសរបស់សមាជិកជាបុគ្គល ។

នៅឆ្នាំ២០០៦ ក្រុមជាន់ខ្ពស់នៃមេដឹកនាំអាស៊ីអាគ្នេយ៍បានស្នើឲ្យបង្កើតជាយន្តការសិទ្ធិមនុស្សអាស៊ានមួយដើម្បីគ្រប់គ្រងលើបញ្ហាទាំងអស់នេះ ។ មួយឆ្នាំក្រោយមក មេដឹកនាំទាំងនោះបានចុះហត្ថលេខាលើធម្មនុញ្ញអាស៊ានដែលចែងឲ្យមន្ត្រីធ្វើការបង្កើតជាអង្គភាពថ្មី ដើម្បីធ្វើការ «ជំរុញនិងការពារសិទ្ធិមនុស្ស» នៅក្នុងតំបន់ ។ ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលអាស៊ីអាគ្នេយ៍ភាគច្រើនបានសម្លឹងទៅឃ្លានោះដោយចម្ងល់ ។ រដ្ឋាភិបាលជាច្រើនធ្លាប់មានកំណត់ត្រាមិនល្អស្ដីពីសិទ្ធិមនុស្ស ហើយភាគច្រើននៃអ្នកទាំងនោះនៅតែឆ្ងាយនឹងទទួលឥទ្ធិពលពីការជ្រៀតជ្រែកនោះនៅក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន ។ មានតែរដ្ឋាភិបាលតិចតួចប៉ុណ្ណោះស្វាគមន៍ទស្សនៈនៃអង្គភាពនៅក្នុងតំបន់នេះថាអាចនឹងផ្ដល់ជាពន្លឺដល់ការប្រើប្រាស់សិទ្ធិមនុស្ស ។

ជាលទ្ធផល គណៈកម្មការដែលត្រូវបានបង្កើតឡើងមានឥទ្ធិពលតិចតួចណាស់ ។ ចំពោះទម្រង់បច្ចុប្បន្ន គណៈកម្មការនេះ មើលទៅហាក់ដូចជាមានកិច្ចខំប្រឹងប្រែងមួយដែលធ្វើឡើងដើម្បីឆ្លើយតបនឹងការរិះគន់ពីខាងក្រៅជាជាងធ្វើឡើងដោយហ្មត់ចត់ ។ គណៈកម្មការនេះរួមមានអ្នកតំណាងមកពីប្រទេសនៅក្នុងអាស៊ានដប់ប្រទេស ហើយរាល់សេចក្ដីសម្រេចត្រូវមានការយល់ស្របពីប្រទេសសមាជិកទាំងអស់ ។ ការធ្វើបែបនេះធ្វើឲ្យសមាជិកដែលរឹងទទឹងខ្លះអាចបង្អាក់សកម្មភាពរបស់គណៈកម្មការអន្តររដ្ឋាភិបាលស្ដីពីសិទ្ធិមនុស្សរបស់អាស៊ាន ។ គណៈកម្មការខ្វះខាតអំណាចចាំបាច់សម្រាប់ការពារសិទ្ធិមនុស្ស ពីព្រោះគណៈកម្មការមិនអាចយកព័ត៌មានឬឆ្លើយតបនឹងពាក្យបណ្ដឹងស្ដីពីការរំលោភបំពានជាក់លាក់មួយចំនួននៅក្នុងសង្គមស៊ីវិលឡើយ ។ គណៈកម្មការអាច

ចេញរបាយការណ៍នៅពេលដែលរាល់តំណាងដែលត្រូវបានចាត់តាំងដោយរដ្ឋាភិបាលទាំងអស់យល់ស្របគ្នាទៅលើប្រធានបទណាមួយតែប៉ុណ្ណោះ ។ គណៈកម្មការមានថវិកាឯករាជ្យ ឬការគាំទ្រផ្នែកការិយាធិបតេយ្យបន្តិចបន្តួចប៉ុណ្ណោះ ។ ដូច្នេះ ការរិះគន់ទៅលើរចនាសម្ព័ន្ធរបស់គណៈកម្មការអន្តររដ្ឋាភិបាលស្តីពីសិទ្ធិមនុស្សរបស់អាស៊ានគឺផ្អែកទៅលើការពិត ។

មិនមែនថាអាស៊ានមិនមានភាពរីកចម្រើននោះទេ ។ ការបង្កើតគណៈកម្មការថ្មីគឺជាការទទួលស្គាល់ដ៏មានអត្ថន័យពីសំណាក់អាស៊ានដែលមានគោលបំណងជំរុញសិទ្ធិមនុស្ស និងសិទ្ធិសេរីភាពជាមូលដ្ឋាន ។ មធ្យោបាយដ៏ល្អបំផុតសម្រាប់គណៈកម្មការអន្តររដ្ឋាភិបាលស្តីពីសិទ្ធិមនុស្សរបស់អាស៊ានគឺត្រូវដំណើរការតាមផ្លូវពីរស្របគ្នា ។ ផ្លូវទីមួយគឺ អាស៊ាន ព្រមទាំងរដ្ឋាភិបាលនិងមន្ត្រីផ្សេងទៀតត្រូវស្វែងរកមធ្យោបាយដើម្បីបង្កើតតួនាទីមួយសម្រាប់គណៈកម្មការអន្តររដ្ឋាភិបាលស្តីពីសិទ្ធិមនុស្សរបស់អាស៊ានក្នុងការការពារសិទ្ធិមនុស្ស ។

មានការស្នើឲ្យរដ្ឋាភិបាលទាំងអស់អញ្ជើញគណៈកម្មការអន្តររដ្ឋាភិបាលស្តីពីសិទ្ធិមនុស្សរបស់អាស៊ានឲ្យធ្វើការពិនិត្យនិងធ្វើរបាយការណ៍ស្តីពីស្ថានភាពមួយចំនួន ។ គំនិតនេះពិតជាល្អដែលធ្វើឲ្យរដ្ឋាភិបាលទាំងអស់អាចនឹងយល់ស្របគ្នាក្នុងការមិនកាត់ចោលនូវចំណុចខ្លះចេញពីរបាយការណ៍ដែលត្រូវបានបង្កើតឡើង ។ ការផ្លាស់ប្តូរភាគច្រើននឹងមិនអាចកើតឡើងដោយចៃដន្យទេ ប៉ុន្តែចំនួននៃការកែប្រែអាចកើតមាន ។ ភាពរីកចម្រើនជាមធ្យមអាចបង្កើតនូវដំណាក់កាលកំណែទម្រង់ដ៏មានសារសំខាន់នៅពេលដែលគណៈកម្មការអនុវត្តការត្រួតពិនិត្យដែលបានរៀបចំឡើងនៅក្នុងពិធីរំឭកខួបប្រាំឆ្នាំ ។

គណៈកម្មការមានកិច្ចការសំខាន់មួយទៀតគឺការជំរុញពីសិទ្ធិមនុស្ស ។ ចំណុចនេះអាចមានន័យច្រើនយ៉ាង ប៉ុន្តែអាស៊ានពិតជាមានភាពត្រឹមត្រូវក្នុងការកំណត់ថាការអប់រំគឺជាអាទិភាពសំខាន់ ។ ប្រជាជននៅអាស៊ីអាគ្នេយ៍មានការយល់ដឹងតិចតួចអំពីសិទ្ធិមូលដ្ឋានរបស់ខ្លួនដែលបានចែងនៅក្នុងច្បាប់អន្តរជាតិនិងប្រព័ន្ធក្នុងស្រុកនានា ។ ភាគច្រើននៃអ្នកទាំងនោះក៏ដឹងតែបន្តិចបន្តួចប៉ុណ្ណោះពីអាស៊ានដែលជាអង្គការមួយមានតែឈ្មោះ ប៉ុន្តែជាទូទៅត្រូវបានដាក់កំហិតចំពោះកិច្ចការអន្តររដ្ឋាភិបាលដែរ ។

ការអប់រំពីសិទ្ធិមនុស្សតាមរយៈការអប់រំយុវជនគឺជាមធ្យោបាយមួយសម្រាប់ធ្វើឲ្យអាស៊ានមានទំនាក់ទំនងច្រើនជាងមុនជាមួយប្រជាជនអាស៊ីអាគ្នេយ៍និងរួមចំណែកក្នុងការអនុវត្តគោលដៅដែលបានកំណត់នៅក្នុងធម្មនុញ្ញរបស់សមាគម ។ វាប្រាកដជាមិនអាចចៀសផុតពីការមិនយល់ស្របគ្នាផ្នែកនយោបាយថាតើនឹងត្រូវរួមបញ្ចូលប្រធានបទបែបណានិងថាតើត្រូវពិភាក្សាអំពីបញ្ហាជាច្រើនដែលទាក់ទងនៅនឹងសិទ្ធិមនុស្សដែលកើតឡើងនៅក្នុងតំបន់ដោយរបៀបណា ។ ទោះបីជាយ៉ាងណាក៏ដោយ វានៅតែមានចំណុចល្អសម្រាប់ចាប់ផ្តើមដែរ ។

នៅក្នុងប្រទេសកម្ពុជា ការបង្កើតសាលាក្តីខ្មែរក្រហមបានជួយជំរុញឲ្យមានតម្រូវការសម្រាប់សាធារណៈនិងបង្កើតជាចំណុចមួយសម្រាប់ការអប់រំសាធារណជនពីអំពើប្រល័យពូជសាសន៍និងការរំលោភបំពានទៅលើសិទ្ធិមនុស្ស ។ ប្រជាជនកម្ពុជាភាគច្រើនគ្រាន់តែបានចាប់ផ្តើមសិក្សាពីគោលការណ៍សិទ្ធិមនុស្សដែលអាចទប់ស្កាត់មិនឲ្យមានអំពើសាហាវឃោរឃៅនៅពេលអនាគតតែប៉ុណ្ណោះ ។ គណៈកម្មការអន្តររដ្ឋាភិបាលស្តីពីសិទ្ធិមនុស្សរបស់អាស៊ានអាចជួយដល់ប្រជាជនកម្ពុជាតាមរយៈកិច្ចខំប្រឹងប្រែងអប់រំនោះ ដោយធ្វើការជាមួយអ្នកជំនាញនិងអង្គការសង្គមស៊ីវិលជាច្រើននៅក្នុងតំបន់ ។ គោលដៅនៃការទប់ស្កាត់អំពើប្រល័យពូជសាសន៍ប្រាកដជានឹងត្រូវសម្រេចបាននៅក្នុងអាស៊ីអាគ្នេយ៍ ។

ប្រទេសកម្ពុជានិងប្រទេសនៅអាស៊ីអាគ្នេយ៍ផ្សេងទៀតមានឱកាសបង្កើតភាពជាអ្នកដឹកនាំនៅក្នុងតំបន់និងភាពជឿជាក់ ដោយធ្វើការជាមួយគណៈកម្មការអន្តររដ្ឋាភិបាលស្តីពីសិទ្ធិមនុស្សរបស់អាស៊ានទៅលើការអប់រំពីសិទ្ធិមនុស្ស ។ ការអប់រំអំពីសិទ្ធិមនុស្សដ៏ជោគជ័យនឹងផ្តល់ផលប្រយោជន៍ដល់អាស៊ានតាមរយៈការលើកកម្ពស់កេរ្តិ៍ឈ្មោះសាធារណៈនិងសារសំខាន់របស់ខ្លួន ការនាំយកផលប្រយោជន៍ក្នុងតំបន់សម្រាប់អនាគតនិងការជួយបង្កើតការយល់ដឹងពីសហគមន៍ក្នុងតំបន់ដែលសមាគមប្រាថ្នាចង់បាន ។

**ចន ឆរធីអារី និង ឆាំង យុ**

# គេចពីការសម្លាប់របស់ខ្មែរក្រហម

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនត្រូវតែធ្វើតាមបញ្ជារបស់កម្មាភិបាលខ្មែរក្រហម ។ ខុសប្លែកពីអ្នកទាំងនោះ លោក ខៀវ រិទ្ធី ដែលសព្វថ្ងៃជានាយករងវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែនរលាប្អៀរ បានរៀបរាប់ឲ្យដឹងថា ឪពុករបស់គាត់បែរជាហ៊ានរត់គេចខ្លួនក្រោយពីដឹងថាខ្មែរក្រហមនឹងចុះមកចាប់គាត់យកទៅសម្លាប់ ។ តើហេតុអ្វីបានជាឪពុករបស់ រិទ្ធី សម្រេចចិត្តបែបនេះ?

មុនឆ្នាំ១៩៧៥ គ្រួសាររបស់ រិទ្ធី រស់នៅភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ ។ ក្រោយពីខ្មែរក្រហមចូលមកដល់ក្រុងភ្នំពេញ គ្រួសាររបស់ រិទ្ធី ត្រូវបានជម្លៀសតាមរទេះភ្លើងរហូតទៅដល់ស្រុកភ្នំស្រុក ខេត្តបាត់ដំបង (សព្វថ្ងៃខេត្តបន្ទាយមានជ័យ) ។ តាមផ្លូវធ្វើដំណើរ គ្រួសាររបស់ រិទ្ធី បានឃើញកងឈ្លបជាច្រើននាក់ឈរយាមនៅតាមផ្លូវដែលមានចម្ងាយពីគ្នាប្រហែលជា១០ម៉ែត្រ ដើម្បីឆែកឆេរអីវ៉ាន់របស់ប្រជាជនជម្លៀស ។

ទៅដល់ទីនោះភ្លាម គ្រួសាររបស់ រិទ្ធី ដែលមានសមាជិកចំនួនប្រាំមួយនាក់ត្រូវបានចាត់តាំងឲ្យស្នាក់នៅក្នុងផ្ទះមួយ ។ បន្ទាប់មក ខ្មែរក្រហមក៏បែងចែកឲ្យប្រជាជនជម្លៀសទាំងអស់ធ្វើការនៅតាមកងរៀងៗខ្លួន ។ ម្តាយរបស់ រិទ្ធី បានរៀបរាប់ឲ្យគាត់ដឹងថា នៅទីនោះខ្មែរក្រហមបានបង្ខំឲ្យប្រជាជនធ្វើការស្ទើរគ្មានពេលសម្រាកនិងឲ្យហូបតែបបររាវដែលមានតែអង្ករបីបួនគ្រាប់ប៉ុណ្ណោះ ក្រោយមកធ្វើឲ្យអ្នកភូមិមួយចំនួនបានធ្លាក់ខ្លួនឈឺស្ទើរគ្រប់គ្នា ។ ចំណែកការព្យាបាលវិញ គឺមានតែថ្នាំអាចម៍ទន្សាយប៉ុណ្ណោះ ដូច្នេះ អ្នកដែលកើតជំងឺនេះភាគច្រើនត្រូវស្លាប់តែម្តង ។ លើសពីនេះទៅទៀត ទោះបីជាអ្នកទាំងនេះមិនស្លាប់ដោយសារជំងឺ ក៏ខ្មែរក្រហមយកទៅសម្លាប់ដែរ ។

នៅចុងឆ្នាំ១៩៧៦ ខ្មែរក្រហមបានចាប់ផ្តើមយកបុរសដែលពេញកម្លាំងជាមេគ្រួសារទៅសម្លាប់ចោលនៅពេលយប់ ។



លោក ខៀវ រិទ្ធី

រិទ្ធី បានបន្តថា ពេលនោះ ម្តាយរបស់គាត់បានឃើញខ្មែរក្រហមបីបួននាក់មានស្ពាយកាំភ្លើងផងដើរសំដៅមកផ្ទះប្រជាជន រួចប្រាប់ថាយកទៅរៀនសូត្រ ។ សកម្មភាពនេះមានបន្តរហូតដោយថ្ងៃបន្ទាប់មកកងឈ្លបទាំងនោះនឹងដើរមកយកមនុស្សនៅផ្ទះអ្នកបន្ទាប់ទៀត ដែលប្រជាជននៅក្នុងភូមិទាំងអស់សុទ្ធតែដឹងថាអ្នកទាំងនោះប្រាកដជាស្លាប់ហើយ ហើយគ្មាននរណាម្នាក់ហ៊ានសួរអង្គការទេ ។ រិទ្ធី នៅចាំបានថា ឪពុករបស់គាត់ក៏បានបាត់ខ្លួននៅពេលនោះដែរ ដោយនៅយប់ដល់វេនដែលខ្មែរក្រហមត្រូវមកយកឪពុករបស់គាត់ទៅរៀនសូត្រ គាត់បានជំនុំគ្នាជាមួយបងប្អូនប្រុសៗរបស់គាត់បីនាក់ទៀតថា «បើទៅតាមខ្មែរក្រហមមានតែស្លាប់ ដូច្នេះគឺមានតែរត់ទេទើបអាចមានជីវិតត្រឡប់មកវិញ» ។ ក្រោយពីពិភាក្សាគ្នារួច ម្តាយរបស់ រិទ្ធី បានដាំបបរដាក់កាមែលដើម្បីឲ្យឪពុករបស់គាត់រត់គេច ។ ប៉ុន្តែក្តីសង្ឃឹមថាពេលប្រទេសរំដោះហើយនឹងបានជួបគ្នាវិញ មកដល់ពេលនេះ រិទ្ធី មិនដែលបានទទួលដំណឹងពីគាត់ ព្រមទាំងបងប្អូនបីនាក់ទៀតរបស់គាត់បន្តិចឡើយ ។

ក្រោយហេតុការណ៍នេះ គ្រួសាររបស់ រិទ្ធី ត្រូវស្ថិតនៅក្រោមការតាមដានរបស់អង្គការជានិច្ច ហើយថែមទាំងត្រូវផ្លាស់ឲ្យទៅរស់នៅកន្លែងថ្មីមួយទៀត ។ នៅទីនោះ ខ្មែរក្រហមបានបញ្ជាឲ្យម្តាយរបស់ រិទ្ធី លើកទំនប់ ជីកប្រឡាយ តាំងពីព្រឹកព្រលឹមរហូតដល់ម៉ោងប្រាំល្ងាច ទើបអាចសម្រាកបាន ។ ក្រោយមក ដោយសារម្តាយរបស់ រិទ្ធី ធ្វើការបានល្អ គាត់ក៏ទទួលបានការទុកចិត្តពីអង្គការ ហើយថែមទាំងអនុញ្ញាតឲ្យគាត់បានមកលេងផ្ទះមួយថ្ងៃក្នុងមួយសប្តាហ៍ និងឲ្យបងស្រីរបស់គាត់មកសម្រាកព្យាបាលជំងឺនៅផ្ទះរហូតដល់ជាសះស្បើយទើបបញ្ជូនទៅកងវិញ ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏ខ្មែរក្រហមនៅតែដើរតាមដានតាមផ្ទះជារៀងរាល់យប់ ខ្លាចក្រែងប្រជាជនលួចហូបផ្លែឈើ ឬដំឡូងអង្គការ ។ រិទ្ធី បន្តថា យប់មួយពេលដែលម្តាយរបស់គាត់លួចកាស់ដំឡូងជ្វាយកមកស្ងោរហូប ស្រាប់តែឈ្លបមកឃើញ ។ ដោយសារតែភ័យខ្លាំងពេក យប់នោះម្តាយរបស់គាត់សម្រាន្តមិនលក់ទេ ព្រោះគិតថាច្បាស់ជាអង្គការយកទៅសម្លាប់ជាមិនខាន ។ ប៉ុន្តែ ព្រលឹមឡើង អង្គការបែរជាមិនយកទោសពៃរ៍អ្វីឡើយ ដោយគ្រាន់តែហៅទៅកសាងបំណោះ រួចនិយាយថា «របស់ទាំងអស់ហ្នឹងជារបស់អង្គការមិនមែនជារបស់យើងទេ មានការអីត្រូវសុំអង្គការ ប្រសិនបើហាមហើយ នៅតែមិនស្តាប់ នោះនឹងយកទៅសម្លាប់ចោលជាមិនខាន» ។ ចំណែកក្មួយរបស់ម្តាយ រិទ្ធី ឈ្មោះ កាន បានលួចកាប់អំពៅនៅពេលថ្ងៃ ពេលដែលអង្គការចាប់បាន ក៏យកគាត់ទៅធ្វើទារុណកម្ម បន្ទាប់មកចងគាត់នៅចម្ការតែម្នាក់ឯងទៀត ។ ចាប់តាំងពីពេលនោះមក កាន មិនដែលហ៊ានលួចទៀតឡើយ ។

នៅឆ្នាំ១៩៧៨ ដោយសារតែមេកងស្រឡាញ់ម្តាយរបស់ រិទ្ធី គាត់ស្រាប់តែត្រូវបានអង្គការតែងតាំងឲ្យធ្វើជាមេចុងភៅ ។ ការឡើងឋានៈនេះ បានធ្វើឲ្យម្តាយរបស់ រិទ្ធី មានការព្រួយបារម្ភជាខ្លាំងខ្លាចខ្មែរក្រហមយកគាត់ទៅសម្លាប់ ដោយសារតែគាត់មិនបានស្រឡាញ់មេកងនោះទេ ។ នៅឆ្នាំ១៩៧៩ គ្រួសាររបស់ រិទ្ធី នាំគ្នាធ្វើដំណើរត្រឡប់មករស់នៅក្រុងភ្នំពេញវិញ ។ ដោយសារតែផ្ទះរបស់ រិទ្ធី ត្រូវបានរុះរើអស់ ដូច្នេះម្តាយរបស់គាត់ក៏នាំកូនៗមករស់នៅស្រុកស្រីសន្ធរ ខេត្តកំពង់ចាមវិញ ។ តាមផ្លូវធ្វើដំណើរក្រុមគ្រួសារ របស់ រិទ្ធី នាំគ្នាស្វែងរកដំណឹងពីឪពុករបស់គាត់រហូត ប៉ុន្តែនៅតែគ្មានបានដំណឹងពីគាត់ទាល់តែសោះ ។

នៅឆ្នាំ១៩៨៥ រិទ្ធី ក៏ផ្លាស់មករៀននៅក្រុងភ្នំពេញវិញ ។ ដោយសារតែស្រឡាញ់មុខវិជ្ជាប្រវត្តិវិទ្យា និងចង់បង្រៀនឲ្យក្មេងជំនាន់ក្រោយដឹងអំពីប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួន ក្រោយពីប្រឡងជាប់សញ្ញាប័ត្រទុតិយភូមិ រិទ្ធី ក៏បានដាក់ពាក្យប្រឡងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញផ្នែកប្រវត្តិវិទ្យា ។ នៅឆ្នាំ១៩៩៨ រិទ្ធី ត្រូវបានចាត់តាំងឲ្យមកធ្វើគ្រូបង្រៀននៅវិទ្យាល័យប៊ុនរ៉ានី-ហ៊ុនសែន រលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ ដោយសារតែ រិទ្ធី បង្រៀនបានល្អ និងទទួលបានការស្រឡាញ់ពីគ្រូបង្រៀនផ្សេងទៀតនៅឆ្នាំ២០០៧ គាត់ត្រូវបានតែងតាំងឲ្យធ្វើជានាយករងនៅវិទ្យាល័យនេះតែម្តង ។ រិទ្ធី យល់ថា ការបង្រៀនអំពីរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់១៩៧៩ ពិតជាមានសារសំខាន់និងមានប្រយោជន៍ជាខ្លាំងសម្រាប់កូនខ្មែរជំនាន់ក្រោយ ដើម្បីកុំឲ្យប្រព្រឹត្តអំពើបែបនេះទៀត ជាពិសេសទន្ទឹមពេលដែលតុលាការកំពុងតែកាត់ទោសមេដឹកនាំខ្មែរក្រហមផង ។

**គាត លក្ខិណា**

# ណុប ប៊ុណ្ណា : ការចងចាំដែលមិនអាចបំភ្លេចបាន

*ទោះបីជារបបនោះបានកន្លងហួសជាងបីទសវត្សរ៍ទៅហើយក៏ដោយ ក៏ ណុប ប៊ុណ្ណា នៅតែមិនអាចបំភ្លេចនូវអ្វីដែលខ្លួនធ្លាប់បានជួបប្រទះដោយផ្ទាល់បានឡើយ ។*

*ណុប ប៊ុណ្ណា កើតនៅឆ្នាំ១៩៦០ នៅភូមិប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ ។ ដោយសារតែចង់សិក្សាឲ្យបានខ្ពស់ ប៊ុណ្ណា បានលាឪពុកម្តាយដើម្បីទៅរស់នៅវត្ត ដោយធ្វើជាកូនសិស្សលោកក្រោមការគ្រប់គ្រងរបស់ព្រះចៅអធិការវត្ត ឈ្មោះ ជួច និងលោកតា ជិន ជាគ្រូបង្រៀន ។ រហូតដល់ឆ្នាំ១៩៧០ នៅពេលដែលទាហានខ្មែរក្រហម និងរដ្ឋាភិបាល លន់ នល់ ប្រយុទ្ធគ្នាយ៉ាងខ្លាំងនៅក្នុងភូមិ ប៊ុណ្ណា ក៏ត្រូវគ្រាប់ផ្លោងធ្លាក់ចំធ្វើឲ្យខ្លួនរបស់គាត់មានរបួសជាទម្ងន់ ។ នៅពេលនោះ ខណៈពេលដែលរដ្ឋាភិបាល លន់ នល់ ដកទ័ពទៅទីរួមខេត្ត ប៊ុណ្ណា ក៏សុំរួមដំណើរជាមួយអ្នកទាំងនោះដើម្បីទៅព្យាបាលនៅមន្ទីរពេទ្យខេត្តដែរ ។ បន្ទាប់ពីសម្រាកនៅពេទ្យចំនួនបីខែ ប៊ុណ្ណា បានទៅរស់នៅជាមួយគ្រួសាររបស់មីងដែលនៅទីរួមខេត្តនិងចូលរៀននៅសាលាបឋមសិក្សាមួយ ។ ការរស់នៅតំបន់ថ្មីមិនមានភាពងាយស្រួលប៉ុន្មានទេ ព្រោះ ប៊ុណ្ណា ក៏ដូចជាប្រជាជនផ្សេងទៀតមិនអាចដើរហើរទៅណាឆ្ងាយបានឡើយ ដោយសារកងទ័ពខ្មែរក្រហមបានឡោមព័ទ្ធតំបន់ជាច្រើនដែលនៅក្នុងខេត្ត ។*



*ណុប ប៊ុណ្ណា*

*ដោយសារកម្លាំងរបស់រដ្ឋាភិបាល លន់ នល់ កាន់តែចុះខ្សោយទៅ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមក៏បានកាន់កាប់ខេត្តតាកែវទាំងមូល ។ ក្រោយមក ខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ចេញពីទីរួមខេត្តដោយបើកផ្លូវតែមួយប៉ុណ្ណោះសម្រាប់ឲ្យប្រជាជនធ្វើដំណើរ ។ នៅពេលយប់ ខ្មែរក្រហមបានដើរចាប់ប្រជាជនដែលមាននិន្នាការធ្លាប់ជាទាហានឬបម្រើរដ្ឋាភិបាល លន់ នល់ ដើម្បីសួរចម្លើយ ។ បន្ទាប់មក ខ្មែរក្រហមក៏ចងស្លាបសេកអ្នកទាំងនោះនឹងត្រកួនកន្ទេក ហើយក៏បណ្តើរចេញទៅ ដែលមនុស្សដប់នាក់ត្រូវបណ្តើរដោយទាហានខ្មែរក្រហមម្នាក់ស្លៀកពាក់ឯកសណ្ឋានពណ៌ខ្មៅនិងប្រដាប់ដោយកាំភ្លើង ដែលក្នុងចំណោមនោះក៏មានពូរបស់ ប៊ុណ្ណា ម្នាក់ដែរ ។ ចាប់ពីពេលនោះមក ប៊ុណ្ណា មិនដែលបានឮដំណឹងអ្វីពីគាត់ទៀតឡើយ ។ ចំណែកឯប្រជាជនដែលនៅសល់ត្រូវចាត់ទុកថាជាប្រជាជនថ្មី ឬប្រជាជន១៧មេសា ហើយត្រូវជម្លៀសបន្តទៅវត្តចំប៉ា ដែលនៅស្រុកត្រាំកក់ទៀត ។*

*ប្រហែលមួយសប្តាហ៍ក្រោយមក ប៊ុណ្ណា ត្រូវអង្គការចាត់តាំងឲ្យមករស់នៅភូមិកំណើតរបស់ខ្លួនវិញ ។ នៅទីនោះ ប៊ុណ្ណា បានជួបជុំជាមួយឪពុកម្តាយបានមួយរយៈពេលខ្លីដែរ ពីព្រោះ ប៊ុណ្ណា ត្រូវអង្គការរៀបចំឲ្យទៅនៅកងចល័តដែលមានសមាជិកប្រមាណ៣០-៤០នាក់ ស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានកងឈ្មោះ តុង ។ ដំបូង អង្គការបានចាត់តាំងឲ្យកងរបស់ ប៊ុណ្ណា លើកភ្លឺដើម្បីធ្វើជាប្រព័ន្ធប្រឡាយឲ្យបាន១៥ម៉ែត្រក្នុងមួយថ្ងៃ ក្រោយមកឲ្យបាន២៥ម៉ែត្រក្នុងមួយថ្ងៃ ។ ដោយសារខ្លាចធ្វើមិនទាន់តាមផែនការដែលកំណត់ ម្នាក់ៗខិតខំធ្វើការមិនដែលហ៊ានធ្មេចប្រហែលឡើយ ។ ប៉ុន្តែ ទោះបីខិតខំធ្វើយ៉ាងណាក៏ដោយក៏របបអាហារដែលទទួលបានគឺត្រឹមតែបបររាវបីកំប៉ុងសម្រាប់មនុស្សដប់នាក់ប៉ុណ្ណោះ ។*

*ថ្ងៃមួយបងរបស់ ប៊ុណ្ណា បានហៅគាត់ឲ្យទៅបាចត្រីជាមួយគាត់ ។ ពេលទៅដល់ទីនោះភ្លាម ប៊ុណ្ណា បានឃើញស្រូវជាច្រើន*

ដែលគេប្រមូលរួចនៅពាសវាលពាសកាល ។ ដោយភាពស្រេកឃ្លាន និងអស់កម្លាំងខ្លាំង ប៊ុណ្ណា បានចុះទៅយកស្រូវនោះចំនួនបីកណ្តាប់ មកដាក់នៅក្នុងថ្នក់អាវ ។ ខណៈពេលនោះ ឈ្លបខ្មែរក្រហមក៏មកទាន់ ហើយចាប់ ប៊ុណ្ណា យកទៅដាក់គុក ។ ពេលបណ្តើរទៅ ប៊ុណ្ណា មានអារម្មណ៍តក់ស្លុតជាខ្លាំង គិតថាប្រហែលជាមិនអាចមានជីវិតត្រឡប់មកវិញទេ ។ ចូលទៅដល់ក្នុងគុកភ្លាម ប៊ុណ្ណា កាន់តែមានអារម្មណ៍ភ័យខ្លាចជាងមុនទៅទៀតពីព្រោះគាត់បានឃើញខ្មែរក្រហមធ្វើទារុណកម្មអ្នកទោស ដោយវាយតប់និងទាត់ធាក់យ៉ាងខ្លាំង ពេលខ្លះយកធាងត្នោតមកអារគន្ទាក់ដៃនិងគន្ទាក់ជើងអ្នកទោស ពេលខ្លះយកអ្នកទោសទៅដាក់ហាលថ្ងៃនៅក្នុងទ្រុងមាន់ ។ លើសពីនេះទៅទៀត ប៊ុណ្ណា បានឃើញអ្នកទោសបាត់ខ្លួនជាបន្តបន្ទាប់ក្រោយពីសួរចម្លើយរួច ។ ប៉ុន្តែក៏មានអ្នកទោសមួយចំនួនបានត្រឡប់មកវិញដែរ ដោយគ្រាន់តែបង្ខំឲ្យធ្វើការជាទម្ងន់ដូចជា ខ្លះឲ្យទៅបាចទឹកត្រពាំង ខ្លះរែកទឹកស្រោចចម្ការ ដាំដំណាំ លើកប្រឡាយប៉ុណ្ណោះ ។ ដោយសារ ប៊ុណ្ណា ទើបតែធ្វើខុសជាលើកទីមួយ ដូច្នេះខ្មែរក្រហមមិនបានធ្វើបាបគាត់ទេ ប៉ុន្តែបានបញ្ជាឲ្យគាត់រែកទឹកមួយថ្ងៃឲ្យបានពី៣០០-៤០០អម្រែកពីត្រពាំងដើម្បីយកទៅស្រោចដំណាំ រយៈពេលបីខែទើបដោះលែងឲ្យទៅរស់នៅសហករណ៍វិញ ។

ទោះបីជា ប៊ុណ្ណា មានសេរីភាពក៏ដោយ ប៉ុន្តែគាត់ស្ថិតនៅក្រោមការតាមដានរបស់អង្គការជានិច្ច ដោយខ្មែរក្រហមបានបញ្ជាឲ្យ ប៊ុណ្ណា រែកដីដោយប្រើដងចបរហូតដល់ក-របស់គាត់ឡើងហើម ។ ដោយសារតែម្នាក់ៗធ្វើការរហូតដល់ធ្លាក់ខ្លួនឈឺ ប្រជាជន១៧មេសាដទៃទៀតបានប្រកែកមិនធ្វើតាមបញ្ជានេះទេ ដែលធ្វើឲ្យខ្មែរក្រហមធ្វើទារុណកម្មពួកគាត់ដោយចាប់ក្បាលជ្រមុជទឹក ។ នៅពាក់កណ្តាលឆ្នាំ១៩៧៨ ប៊ុណ្ណា ស្រាប់តែទទួលដំណឹងអាក្រក់មួយថា ឪពុកម្តាយរបស់គាត់មានជំងឺជាទម្ងន់ ។ ដោយសារមិនមានការព្យាបាលឲ្យបានត្រឹមត្រូវ មួយរយៈក្រោយមកគាត់ក៏ទទួលមរណភាពទៅ ។

រហូតដល់ឆ្នាំ១៩៧៩ នៅពេលដែលរបបខ្មែរក្រហមដួលរលំទៅ ប៊ុណ្ណា បានទៅរស់នៅជាមួយបងប្រុសបង្កើតរបស់គាត់នៅស្រុកកំណើតវិញ ។ ដោយសារគ្រួសារមានជីវភាពក្រីក្រខ្លាំងពេក ប៊ុណ្ណា ក៏សម្រេចចិត្តទៅបួសនៅវត្តប្រាំបីមុំដែលខ្លួនធ្លាប់សិក្សាពីមុន ។ ប៉ុន្តែនៅក្នុងវត្តមានតែលោកតា ដូច និង ប៊ុណ្ណា ប៉ុណ្ណោះ ចំណែកសម្ភារៈសម្រាប់ប្រើប្រាស់ក៏គ្មានដែរ ។ ដូច្នេះលោកតា ដូច និង ប៊ុណ្ណា បានធ្វើដំណើរមកភ្នំពេញដើម្បីទិញសម្ភារៈមួយចំនួនដូចជា សៀវភៅសម្រាប់សិក្សាជាដើម ។ បន្ទាប់មក ប៊ុណ្ណា និង លោកតាដូច បានរកឃើញរបស់របរមួយចំនួននៅក្នុងបណ្ណាល័យមួយដែលគេទុកចោល ដូចជាសៀវភៅមួយពំនូកដែលរួមមានច្បាប់ គម្ពីរផ្សេងៗ រួចក៏យកមកទុកនៅក្នុងវត្តរបស់ខ្លួនស្នាក់នៅ ។


លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាមានមតិសំណេះសំណាលជាមួយគ្រូថ្នាក់មូលដ្ឋាន នៅខេត្តតាកែវ

ក្រោយមក ដោយប្រទេសជាតិមានស្ថិរភាពជាងមុន នៅឆ្នាំ១៩៨៣ ប៊ុណ្ណា បានចាប់ផ្តើមចូលរៀនបន្តនៅថ្នាក់ទី៤ ក្រោយមកក៏បន្តការសិក្សានៅអនុវិទ្យាល័យព្រៃសណ្តែក ក្នុងស្រុកទ្រាំង រួចចូលរៀនថ្នាក់គរុកោសល្យភូមិភាគ ។ បច្ចុប្បន្ន ប៊ុណ្ណា គឺជាគ្រូបង្រៀនប្រវត្តិវិទ្យានៅវិទ្យាល័យសន្ទុង ស្រុកទ្រាំង ខេត្តតាកែវ ។

**ថា ផល្លា**

# កូនស្រីអ្នកទោសស-២១ ដឹងពីដំណឹងឪពុក


ស្នាន់ ពុំ

ស្នាន់ ពុំ មានតួនាទីជាប្រធានមន្ទីរពេទ្យស្ទឹងត្រង់បាន បាត់ខ្លួនចាប់តាំងពីឆ្នាំ១៩៧៦ នៅពេលដែលអង្គការហៅមករៀនសូត្រនៅខេត្តកំពង់ចាម ។ ក្រោយរបបខ្មែរក្រហមដួលរលំ គ្រួសាររបស់ ពុំ សុគន្ធី ដែលជាកូនស្រីរបស់ ស្នាន់ ពុំ នៅតែ ទន្ទឹងរង់ចាំដំណឹងពីឪពុករហូត ។ ក្រោយមកនៅឆ្នាំ១៩៩៧ ទើប សុគន្ធី បានទទួលដំណឹងពីឪពុកតាមរយៈពូរបស់គាត់ឈ្មោះ ស្នាន់ ប៉ុន ដែលផ្នែកគម្រោងជំរុញឲ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានសម្ភាសន៍ជាមួយគាត់ ។ នៅខែធ្នូ ឆ្នាំ២០០៩ ពេល សុគន្ធី ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅខេត្តកំពង់ចាម គាត់បានស្នើសុំឲ្យមជ្ឈ-មណ្ឌលឯកសារកម្ពុជាជួយស្រាវជ្រាវរកឈ្មោះឪពុកគាត់ ។ រហូតមកដល់ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១០ នៅពេលប្អូនស្រីរបស់ សុគន្ធី ឈ្មោះ ពុំ ស្រីធន ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្រៀនប្រវត្តិសាស្ត្រនៅក្នុងខេត្តកំពង់ធំក៏បានស្នើសុំឲ្យលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរកឈ្មោះ ស្នាន់ ពុំ ដែរ ហើយក៏រកឃើញប្រវត្តិរូបនិងរូបថតរបស់គាត់ដូចបំណង ។


ពុំ ស្រីធន

សព្វថ្ងៃ ពុំ សុគន្ធី ជាគ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅវិទ្យាល័យកំពង់ឈើទាល ក្នុងស្រុកប្រាសាទសម្បូរណ៍ ខេត្តកំពង់ធំ ។ សុគន្ធី ជាកូនស្រីទីបួនក្នុងចំណោមបងប្អូន៧នាក់របស់ ស្នាន់ ពុំ ដែលជាប់នៅមន្ទីរឃុំឃាំងស-២១ បានរៀបរាប់រឿងរ៉ាវឪពុករបស់គាត់ដូចខាងក្រោមៈ

ឪពុកខ្ញុំមានស្រុកកំណើតនៅភូមិព្រៃតាត្រាវ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ (អតីតខេត្តកំពង់ចាម) ។ នៅសម័យសង្គមរាស្ត្រនិយម ឪពុកខ្ញុំប្រឡងជាប់សាលាពាណិជ្ជកម្មមធ្យម បន្ទាប់មកគាត់ប្រឡងចូលរៀននៅសាលាពេទ្យបន្ថែមទៀត ។ ក្រោយពីរៀននៅសាលាពេទ្យបានមួយឆ្នាំ គាត់ក៏ឈប់រៀន រួចផ្លាស់ទៅរៀនយកផ្នែកច្បាប់និងសេដ្ឋកិច្ចវិញ ។ ចំណែកម្តាយខ្ញុំនៅពេលនោះបានចូលបម្រើការងារជាបុគ្គលិកពេទ្យនៅមន្ទីរពេទ្យសូវៀត ហើយនៅពេលម្តាយខ្ញុំទៅលេងស្រុកកំណើតរបស់គាត់នៅភូមិបន្ទាយយមរាជ ឃុំប្រាសាទម្តងៗ គាត់តែងតែយកថ្នាំពេទ្យទៅចែកជូនអ្នកជំងឺក្នុងភូមិជានិច្ច ធ្វើឲ្យគ្រួសារខ្ញុំមានការគោរពរាប់អានពីប្រជាជនកាន់តែច្រើន ។ ឪពុកម្តាយខ្ញុំមានផ្ទះមួយស្ថិតនៅម្តុំបឹងទំពុនក្នុងទីក្រុងភ្នំពេញ ហើយឪពុកខ្ញុំមានបន្ទប់សម្រាប់ធ្វើការ និងអានសៀវភៅដាច់ដោយឡែក ដោយហាមគាត់មិនឲ្យម្តាយខ្ញុំនិងកូនៗចូលទៅមើលឡើយ ។ រហូតដល់ឆ្នាំ១៩៧០ ឪពុកខ្ញុំបានប្រមូលឯកសារ អត្តសញ្ញាណប័ណ្ណកាតសិស្សនៅក្នុងបន្ទប់របស់គាត់ដុតចោលទាំងអស់ រួចហើយនាំម្តាយខ្ញុំនិងបងៗខ្ញុំត្រឡប់ទៅស្រុកកំណើតម្តាយខ្ញុំទាំងយប់ដោយស្នាក់នៅផ្ទះជាមួយអ៊ីគាត់ ។ ឪពុកខ្ញុំប្រកបរបរជាអ្នកលក់ដូរនិងទិញជ្រូក ហើយគាត់តែងតែដើរឃោសនាពីចលនាបដិវត្តន៍នៅទីកន្លែងដែលគាត់ទៅដល់ជានិច្ច ។ ក្រោយមក ឪពុកម្តាយនិងបងប្អូនខ្ញុំប្រាំមួយនាក់បានផ្លាស់ទៅរស់នៅតំបន់រំដោះស្រែវាល ក្នុងខេត្តកំពង់ចាមវិញ នៅសល់តែបងប្រុសខ្ញុំម្នាក់ប៉ុណ្ណោះរស់នៅជាមួយមីងក្នុងភូមិ ។ អង្គការបានបែងចែកបងប្រុសខ្ញុំបីនាក់ឲ្យចូលមន្ទីរកុមារ ហើយខ្ញុំដែលមានអាយុទើបតែប្រាំឆ្នាំនិងប្អូនតូចៗពីរទៀតត្រូវរស់នៅជាមួយម្តាយនៅមន្ទីរពេទ្យដែលស្ថិតនៅភូមិស្រែវាល ។ ចំណែកឪពុកខ្ញុំនៅពេលនោះមិនសូវនៅជួបជុំជាមួយម្តាយទេ ព្រោះគាត់ត្រូវចេញទៅព្យាបាលឲ្យកងទ័ពខ្មែរក្រហមដែលត្រូវរបួសនៅសមរភូមិក្នុងស្រុកស្ទឹងត្រង់ និងតាមបណ្តោយដងទន្លេមេគង្គ

ក្នុងខេត្តកំពង់ចាម ។

នៅពេលកងទ័ពខ្មែរក្រហមទទួលជ័យជម្នះថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ឪពុកខ្ញុំបានឡើងជាប្រធានមន្ទីរពេទ្យស្រុកស្ទឹងត្រង់ រហូតដល់ឆ្នាំ១៩៧៦ អង្គការបានមកហៅឪពុកខ្ញុំទៅរៀនសូត្រនៅខេត្តកំពង់ចាម ។ ពេលឮដំណឹងនេះភ្លាម ឪពុកខ្ញុំដឹងថាអង្គការហៅទៅចាប់ខ្លួនហើយ ព្រោះគាត់មានទំនាស់ជាមួយនារីពេទ្យដែលជាអនុប្រធានរបស់គាត់ ហើយគាត់ក៏បាននិយាយផ្ដែផ្ដាំម្ដាយខ្ញុំថា «ខ្ញុំមិនវិលត្រឡប់មកវិញទេ សូមឯង (ម្ដាយខ្ញុំ) នាំកូនទាំងអស់ត្រឡប់ទៅរស់នៅស្រុកកំណើតវិញផង» ។ ក្រោយពីឪពុកខ្ញុំចេញទៅបាត់ អង្គការបានបញ្ជូនបងប្រុសខ្ញុំបីនាក់ដែលនៅមន្ទីរកុមារឲ្យទៅឃ្វាលគោ និងរកបន្លែឲ្យខាងរោងចក្រតម្បាញផ្ទល់បែកវិញ ចំណែកម្ដាយខ្ញុំស្នាក់នៅមន្ទីរពេទ្យស្ទឹងត្រង់ដដែល ។ រយៈពេលបីខែក្រោយមក អង្គការបានផ្ញើសំបុត្រមួយច្បាប់ទៀតឲ្យម្ដាយខ្ញុំដើម្បីយកទៅឲ្យកម្មាភិបាលខ្មែរក្រហមដែលគ្រប់គ្រងបន្ទាយផ្ទល់បែកដែលឪពុកខ្ញុំធ្លាប់ព្យាបាលជំងឺឲ្យ ។ បន្ទាប់ពីកម្មាភិបាលនោះទទួលសំបុត្ររួចហើយ ក៏ប្រាប់ម្ដាយខ្ញុំថា «ពេលមីងឮខ្ញុំអានសំបុត្រហើយ មីងកុំមានអារម្មណ៍ ភិតភ័យអី» សំបុត្រសរសេរថា «បើសំបុត្រមកដល់ពេលថ្ងៃ ត្រូវយកទៅសម្លាប់ចោលពេលថ្ងៃ បើសំបុត្រមកពេលយប់ ត្រូវយកទៅសម្លាប់ពេលយប់» ។ ដឹងរឿងនេះភ្លាម ម្ដាយខ្ញុំអស់សង្ឃឹម និង តក់ស្លុតយ៉ាងខ្លាំង ព្រោះដល់វេនអង្គការយកគាត់និងកូនតូចៗទៅសម្លាប់ហើយ ។ ប៉ុន្តែកម្មាភិបាលនោះបានប្រាប់ម្ដាយខ្ញុំវិញថា «មកដល់ទីនេះ មីងកុំបារម្ភអី ចាំខ្ញុំរកឡានជូនមីងនិងកូនត្រឡប់ទៅស្រុកកំណើតវិញ» ។ ខ្ញុំ ម្ដាយខ្ញុំ និងប្អូនពីរនាក់ទៀតបានត្រឡប់មករស់នៅជាមួយបងប្អូនជីដូនមួយនិងបងប្រុសខ្ញុំម្នាក់នៅភូមិបន្ទាយយមរាជ ឃុំប្រាសាទ ស្រុកសន្ទុកវិញ នៅសល់តែបងខ្ញុំបីនាក់ប៉ុណ្ណោះ ដែលជាប់នៅរោងចក្រតម្បាញ ។ ពេលនោះម្ដាយខ្ញុំក៏អង្វរកម្មាភិបាលនោះថា «មិត្តបានជូនខ្ញុំនិងកូនបីនាក់មកដល់ស្រុកកំណើតនេះវិញ ដូច្នេះសូមមិត្តជួយបញ្ជូនកូនខ្ញុំបីនាក់ទៀតក្នុងរោងចក្រតម្បាញត្រឡប់មកវិញផង» ។ រយៈពេលមួយខែក្រោយមក កម្មាភិបាលនោះក៏បញ្ជូនបងខ្ញុំទាំងបីនាក់តាមឡានដឹកខ្សាច់មកជួបជុំគ្នាវិញ ដោយយើងស្នាក់នៅក្នុងផ្ទះអ៊ំដែលជាអ្នកមូលដ្ឋាន ហើយម្ដាយខ្ញុំបានដូរឈ្មោះ ដាន ទៅជាឈ្មោះ សឿន ដើម្បីកុំឲ្យអង្គការសង្ស័យនិងតាមដាន ។ ក្រោយមក អង្គការបានចាត់តាំងម្ដាយខ្ញុំឲ្យចូលធ្វើការក្នុងកងចល័តចេញទៅធ្វើ



69

លេខទទៀង
ផ្នែក
មកពី

ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង

១- ឈ្មោះដើម ស្មាន់ ពុំ
- ឈ្មោះក្លែង ពុំ
២- អាយុ 36 ឆ្នាំ ជនជាតិ ខ្មែរ ភេទ ប្រុស
៣- ទីលំនៅកំណើតកើតនៅភូមិ [illegible]
ឃុំ បល្ល័ង្ក ស្រុក បារាយណ៍ ខេត្ត កំពង់ធំ
៤- ក្រសួងនិងនាទី មុនថ្ងៃរំដោះភ្នំពេញ (ក្នុង ឆ្នាំ ១៩៧៥) ពេទ្យ បដិវត្ត
៥- ក្រសួងនិងនាទី បច្ចុប្បន្ន ពេទ្យ បដិវត្ត
៦- ឪពុកឈ្មោះ ស្មាន់ចៅ ម្ដាយឈ្មោះ [illegible]
៧- ប្រពន្ធ ឬ ប្ដី ឈ្មោះដើម ដាន ឈ្មោះក្លែង ទិន
៨- ទីលំនៅកំណើត កើតនៅភូមិ បន្ទាយយមរាជ ឃុំ [illegible]
ស្រុក សន្ទុក តំបន់ 43 ខេត្ត កំពង់ធំ
៩- បច្ចុប្បន្ន នៅ
១០- មានកូនប្រុស ចំនួន ១ នាក់ កូនស្រី 4 នាក់
១១- ទីកន្លែងចាប់ខ្លួន ស្ទឹងត្រង់
១២- ចាប់ខ្លួន ថ្ងៃទី 25 ខែ 10 ឆ្នាំ ១៩៧៦ ។ ផ្ទះ [illegible] បន្ទប់ធំ 07 បន្ទប់តូច 5
លេខកំណត់ [illegible]
ហត្ថលេខា

ប្រវត្តិរូបរបស់ ស្មាន់ ពុំ នៅមន្ទីរស-២១

ស្រែនៅស្រែក្រោម និងដើររកត្រីមកដុតផ្តុំរោងបាយក្នុងភូមិ ។ ប៉ុន្តែដោយសារមិនមានមនុស្សនៅមើលថែខ្ញុំនិងប្អូនតូចៗ គាត់ក៏សុំអនុញ្ញាតពីអង្គការឲ្យទុកបងស្រីនៅផ្ទះ ចំណែកបងៗបីនាក់ទៀតត្រូវចេញទៅធ្វើការនៅកងចល័តកុមារទាំងអស់ ។

នៅក្នុងភូមិបន្ទាយយមរាជដែលគ្រួសារខ្ញុំរស់នៅមិនសូវតឹងតែងនិងខ្វះខាតរបបអាហារទេ គឺក្នុងមួយសប្តាហ៍ចុងភៅដាំបាយឲ្យហូបម្តង ។ យូរៗម្តងទើបខ្ញុំឃើញម្តាយខ្ញុំត្រឡប់មកសម្រាកនៅផ្ទះ មើលថែទាំបងប្អូនខ្ញុំ និងយកពងត្រី ក្បាលត្រីមួយចំនួនឲ្យយើងហូប រួចទើបគាត់ចេញទៅធ្វើការនៅកងវិញ ។ ចំណែកបងៗខ្ញុំដែលធ្វើការនៅកងចល័ត ហើយមានជំងឺតែងតែសុំច្បាប់ប្រធានកងដោយយកលេសថាមកមើលថែទាំខ្ញុំដើម្បីមកសម្រាកនៅផ្ទះវិញ ។ ទោះបីជាអង្គការមិនសូវមានការតឹងតែងចំពោះគ្រួសារខ្ញុំ និងគ្រួសារអ្នកមូលដ្ឋានក្នុងភូមិក៏ដោយ ក៏អ៊ំខ្ញុំដែលមានផ្ទះនៅមិនឆ្ងាយប៉ុន្មានពីទីកន្លែងសម្លាប់បានមកប្រាប់ខ្ញុំថា ជារឿយៗនៅពាក់កណ្តាលអធ្រាត្រ គាត់ឮសន្ធឹករថយន្តដឹកគ្រួសារជម្លៀសថ្មីជាច្រើនមកសម្លាប់នៅបឹងខាងក្រោយភូមិ ហើយពេលខ្លះឮសម្រែកអ្នកទោសគ្រលួច ដែលធ្វើឲ្យអ្នកភូមិមានការភិតភ័យយ៉ាងខ្លាំង ។ រហូតដល់របបខ្មែរក្រហមដួលរលំ ទើបម្តាយខ្ញុំសម្រេចចិត្តនាំកូនត្រឡប់មករស់នៅក្នុងខេត្តកំពង់ធំ ដើម្បីរកការងារធ្វើ ។ នៅពេលនោះ ម្តាយខ្ញុំចូលបម្រើការងារនៅមន្ទីរព័ត៌មាន ចំណែកខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាក្រុងកំពង់ធំ ហើយក្រោយមកក៏ផ្លាស់មករៀននៅសាលាអនុវត្តន៍វិញ ។

នៅឆ្នាំ១៩៩៣ ខ្ញុំជាប់សញ្ញាបត្រទុតិយភូមិ រួចក៏ប្រឡងចូលរៀនផ្នែកប្រវត្តិសាស្ត្រនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ នៅឆ្នាំ១៩៩៧ ខ្ញុំរៀនចប់គ្រូរួចចេញមកបង្រៀននៅវិទ្យាល័យកំពង់ធំ ប៉ុន្តែក្រោយមកដោយសារខ្វះគ្រូបង្រៀនទើបមន្ទីរអប់រំខេត្តសំណូមពរខ្ញុំឲ្យទៅបង្រៀននៅវិទ្យាល័យកំពង់ឈើទាលរហូតមកដល់សព្វថ្ងៃនេះ ។

ក្រោយមក មានអ្នកភូមិមួយចំនួនដែលធ្លាប់ចូលបម្រើបដិវត្តន៍ ហើយធ្លាប់ស្គាល់ឪពុកខ្ញុំបានមកប្រាប់ម្តាយខ្ញុំថា ឪពុកខ្ញុំនៅរស់រានមានជីវិត និងជាអ្នកបកប្រែភាសាចិនឲ្យខ្មែរក្រហម ។

នៅឆ្នាំ១៩៩៧ បុគ្គលិកមជ្ឈមណ្ឌលឯកសារបានយកឯកសារប្រវត្តិមួយសន្លឹកដែលមានសរសេរឈ្មោះឪពុកម្តាយនិងបងប្អូនខ្ញុំចំនួនប្រាំពីរនាក់មកប្រគល់ឲ្យពូរបស់ខ្ញុំឈ្មោះ ស្មាន់ ប៉ុន ។ រហូតដល់ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១០ ពេលប្អូនស្រីខ្ញុំឈ្មោះ ពុំ ស្រីធន ចូលរួមរៀនវគ្គបណ្តុះបណ្តាលគ្រូបង្រៀនប្រវត្តិសាស្ត្រនៅខេត្តកំពង់ធំក៏បានស្នើឲ្យលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរកឈ្មោះឪពុកខ្ញុំ ស្មាន់ ពុំ ម្តងទៀត ក៏ឃើញប្រវត្តិរូបនិងរូបថតរបស់គាត់ជាប់ឃុំឃាំងនៅមន្ទីរស-២១ ទើបបងប្អូនខ្ញុំទាំងអស់ជឿថាគាត់បានស្លាប់ហើយ ។

យោងតាមឯកសារប្រវត្តិរូបអ្នកទោសមន្ទីរស-២១ ឬ គុកទួលស្លែង ដែលរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាសរសេរថា ស្មាន់ ពុំ ជនជាតិខ្មែរ អាយុ៣៦ឆ្នាំ មានស្រុកកំណើតនៅភូមិព្រៃតាត្រាវ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ (អតីតខេត្តកំពង់ចាម) ។ ស្មាន់ ពុំ មានឪពុកឈ្មោះ ស្មាន់ ពៅ និងម្តាយឈ្មោះ កក់ នឹម ។ ស្មាន់ ពុំ មានប្រពន្ធឈ្មោះ ដាន ហៅ រិន មានកូនប្រុសពីរនាក់-ស្រីប្រាំនាក់ ។ នៅឆ្នាំ១៩៧៥ ស្មាន់ ពុំ មានតួនាទីជាពេទ្យបដិវត្តន៍ ។ ស្មាន់ ពុំ ត្រូវបានឃាត់ខ្លួននៅថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧៥ នៅស្រុកស្ទឹងត្រង់ រួចបញ្ជូនមកឃុំឃាំងនៅផ្ទះ «ក» បន្ទប់ធំលេខ ៧ បន្ទប់តូចលេខ ៥ ក្នុងមន្ទីរស-២១ ។


ពុំ សុគន្ធី

គន្ធី បន្តថា រហូតមកដល់សព្វថ្ងៃខ្ញុំនៅតែគិតថា ឪពុកខ្ញុំពិតជាទទួលរងទារុណកម្មធ្ងន់ធ្ងរ និងរយៈពេលយូរនៅមន្ទីរ ស-២១ ក្រោមការគ្រប់គ្រងរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច ព្រោះគាត់ជាប្រធានមន្ទីរពេទ្យ ។ ទោះបីជារឿងនេះកើតឡើងចំពោះឪពុកខ្ញុំក៏ដោយ ក៏ខ្ញុំមិនចង់សងសឹកជាមួយ ឌុច ដែរ ព្រោះធ្វើឲ្យការចងគំនុំនៅតែបន្តមានក្នុងប្រទេសកម្ពុជា ។ ខ្ញុំចង់ឲ្យមានការផ្សះផ្សានៅក្នុងសង្គម ចំណែកអ្នកដឹកនាំផ្សេងទៀតកុំប្រព្រឹត្តអំពើឃោរឃៅរបៀបនេះទៀត ព្រោះប្រវត្តិអាក្រក់របស់គាត់នឹងកត់ត្រាជាប់នៅក្នុងប្រវត្តិសាស្ត្រជារៀងរហូត ។ **សោម ប៊ុនថន**

# ខ្មែរក្រហម :
# ការកេណ្ឌទ័ព និងការជ្រើសរើស ការបណ្តុះបណ្តាល និងការអភិវឌ្ឍ

### *ខ្មែរក្រហមៈ ការកេណ្ឌទ័ព និង ការជ្រើសរើស*

### *ការកេណ្ឌទ័ពៈ មុនបដិវត្តន៍*

ប៉ុល ពត និងសមាជិកបក្សដទៃបានប្រព្រឹត្តនូវកំហុសឆ្គងដ៏ចម្បងមួយ ដោយអ្នកទាំងនោះមិនបានទទួលស្គាល់ថា ប្រជាជននៅតំបន់ខ្លះមានជីវភាពក្រីក្រជាងកន្លែងផ្សេងទេ ។ ជាក់ស្តែងមុនឆ្នាំ១៩៧៥ បើគិតជាមធ្យម កសិករដែលរស់នៅភូមិសប្បាយមានជីវភាពក្រីក្រជាងកសិករនៅភូមិដទៃទៀត ។ នេះបើយោងតាមនរវិទូ អាឡិច ហ៊ីនតុន បានបង្ហាញថា «កំហុសឆ្គងសំខាន់មួយដែលបានប្រព្រឹត្តនៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា ហើយប្រហែលជាមូលហេតុចម្បងមួយដែលធ្វើឲ្យខ្មែរក្រហមជួបប្រទះបញ្ហាដំបូងក្នុងការកេណ្ឌកសិករឲ្យចូលរួមចលនាបដិវត្តន៍» ។ មិនយូរប៉ុន្មានបន្ទាប់ពីការបំផ្លិចបំផ្លាញដោយសារតែសង្គ្រាមនៅប្រទេសវៀតណាម និងដោយសារការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិកនៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ខ្មែរក្រហមបានមើលឃើញពីការកើនឡើងនៃឥទ្ធិពលរបស់ខ្លួននៅក្នុងយុទ្ធនាការកេណ្ឌទ័ព ។ ដោយសារតែមានការបំផ្លិចបំផ្លាញទៅលើដីស្រែចម្ការរបស់កសិករ បានធ្វើឲ្យកសិករកម្ពុជាជាច្រើនជួបប្រទះបញ្ហាសេដ្ឋកិច្ច ។ មិនតែប៉ុណ្ណោះ ការចំណាយទៅការលើការកសាងឡើងវិញត្រូវចំណាយយ៉ាងច្រើន ។ ទាំងអស់នេះគឺជាហេតុបណ្តាលឲ្យកសិករជាច្រើនក្លាយជាកូនបំណុលរហូតដល់ជំរុញឲ្យគាត់លក់ទ្រព្យសម្បត្តិដែលមានដើម្បីសងបំណុលទាំងនោះ ។ កត្តាវិបត្តិសេដ្ឋកិច្ចរបស់កសិករមិនមែនជាមូលហេតុតែមួយដែលនាំឲ្យប្រជាជាតិទាំងមូលគាំទ្រខ្មែរក្រហមនោះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ មានអ្នកប្រាជ្ញជាច្រើនបានជជែកដេញដោលគ្នាអំពីទំហំពិតប្រាកដនៃយុទ្ធនាការកេណ្ឌទ័ព និងទំនាក់ទំនងទៅនឹងការបាត់បង់ដីស្រែរបស់កសិករ ។ ប៉ុន្តែ បើតាមការសន្និដ្ឋានរបស់សាស្ត្រាចារ្យប៉ែន ឃៀរនិន ទៅលើបញ្ហានេះគឺហាក់ដូចជាល្អជាង ដែលថាកសិករភាគច្រើននៅក្នុងប្រទេសមិនត្រូវបានអូសទាញដោយផែនការរបស់ខ្មែរក្រហមទេ ទោះបីជាចំនួននៃការកេណ្ឌទ័ពមានច្រើនគ្រប់គ្រាន់ដើម្បីបង្កើតយុទ្ធសាស្ត្រដ៏ជោគជ័យមួយសំដៅទៅរកកសិករក្រីក្រ និងជាពិសេសក្មេងៗជំទង់ក៏ដោយ ។ ទ័ពមួយចំនួនដែលបានចុះចូលជាមួយបក្សនៅដើមទសវត្សន៍៧០ ដោយសារតែការគុំកួន និងកំហឹងចំពោះរដ្ឋាភិបាល លន់ នល់ ។ ជាងនេះទៅទៀតយុទ្ធនាការឃោសនារបស់ខ្មែរក្រហមបានលើកឡើងថា លន់ នល់ និងបក្ខពួករបស់គាត់គឺជាអ្នកទទួលខុសត្រូវចំពោះការទម្លាក់គ្រាប់បែកបេ-៥២ របស់សហរដ្ឋអាមេរិកនៅតាមទីជនបទនៃប្រទេសកម្ពុជា ។ ទ័ពខ្មែរក្រហមដែលទើបនឹងកេណ្ឌបាននេះ មានការខឹងសម្បាយ៉ាងខ្លាំងចំពោះការបំផ្លិចបំផ្លាញផ្ទះសម្បែងនិង



**ការហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្ររបស់ខ្មែរក្រហម**

ការបាត់បង់មនុស្សជាទីស្រឡាញ់ ដោយបានបញ្ឆេះបញ្ឆូលឲ្យមានកំហឹង និងការអន់ចិត្តចំពោះអ្នកដែលទទួលខុសត្រូវ ។ ខៃល ដែលជាអ្នករស់រានមានជីវិតម្នាក់បាននិយាយនៅក្នុងបទសម្ភាសន៍មួយថា «សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកបេ-៥២ជាច្រើនគ្រាប់ ហើយប្រជាពលរដ្ឋមានការខឹងសម្បាយ៉ាងខ្លាំង ព្រមទាំងចង់ប្រយុទ្ធជាមួយរបបលន់ នល់ថែមទៀត» ។ រដ្ឋាភិបាលលន់ នល់បានធ្វើការព្រមព្រៀងជាមួយសហរដ្ឋអាមេរិកដើម្បីទម្លាក់គ្រាប់បែកតាមទីតាំងសំខាន់ៗមួយចំនួននៅតាមបណ្តោយព្រំដែនដែលមានវៀតណាមរស់នៅដើម្បីបណ្តេញវៀតណាមកុម្មុយនីស្តខាងជើងចេញ ។ ទ័ពដែលកេណ្ឌបានខាងលើបានជួបបញ្ហាសេដ្ឋកិច្ចដោយសារការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនេះនាំឲ្យមានប្រជាជនខ្មែរប្រហែល១៥០,០០០នាក់ស្លាប់ និងរាប់ពាន់នាក់ទៀតត្រូវផ្លាស់ទីលំនៅ ។ អ្នកទាំងអស់នោះមានការខឹងសម្បានឹងចក្រពត្តិអាមេរិក និងរបបលន់ នល់ ។ ការឃោសនារបស់ខ្មែរក្រហមបានបង្ហាញពីគោលបំណងចង់សងសឹក ។ របាយការណ៍មួយដែលបានចងក្រងឡើងដោយនាយកដ្ឋានប្រតិបត្តិនៃសេអ៊ីអាកាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៧៣ បានលើកឡើងពីយុទ្ធសាស្ត្រថ្មីមួយដែលខ្មែរក្រហមបានប្រើប្រាស់ដើម្បីកេណ្ឌទ័ពនៅខេត្តកណ្តាល (ភូមិភាគនិរតី) ដោយបានយកការបំផ្លិចបំផ្លាញដែលបានកើតឡើងដោយសារការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកធ្វើជាប្រធានបទចម្បងនៅក្នុងយុទ្ធនាការឃោសនារបស់ខ្លួន ។ កម្មាភិបាលរបស់បក្សបានដើរឃោសនាឲ្យប្រជាជនស្តីបន្ទោសរដ្ឋាភិបាលលន់ នល់ ដែលបានស្នើសុំឲ្យសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកនៅតាមទីជនបទនៃប្រទេសកម្ពុជា ហើយរដ្ឋាភិបាលលន់ នល់ ត្រូវតែទទួលខុសត្រូវចំពោះការខូចខាត និងសេចក្តីវិនាសទាំងឡាយដែលបានកើតឡើងចំពោះកសិករដែលគ្មានកំហុស ។ កម្មាភិបាលទាំងនោះបានបញ្ឆេះបញ្ឆូលប្រជាពលរដ្ឋឲ្យចូលធ្វើជាទាហានបដិវត្តន៍ដែលជាមធ្យោបាយតែមួយគត់ដើម្បីបញ្ឈប់ការបំផ្លិចបំផ្លាញទាំងនេះ ។ អ្នកទាំងនោះត្រូវការបង្រួបបង្រួមកម្លាំងបដិវត្តន៍ដ៏ធំមួយដើម្បីផ្តួលរំលំ លន់ នល់ ។ អ្នកដែលជ្រើសរើសបានជាច្រើនគឺជាបញ្ញវន្តដែលមិនពេញចិត្តនឹងរដ្ឋាភិបាល និងអ្នកមានឋានៈកណ្តាលនៅក្នុងសង្គមដែលត្រូវបានអូសទាញដោយសារការឃោសនារបស់ខ្មែរក្រហម ។ អ្នកទាំងនោះបានចូលបម្រើតាំងពីមុនពេលបដិវត្តន៍ ហើយប្រហែលជាភាគច្រើននៃអ្នកទាំងនោះត្រូវបានតែងតាំងឲ្យមានឋានៈខ្ពស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកដែលជ្រើសរើសបានមួយចំនួនចង់ឃើញ សម្តេច នរោត្តម សីហនុ កាន់អំណាចឡើងវិញ បន្ទាប់ពី លន់ នល់ បានបណ្តេញព្រះអង្គចេញនៅឆ្នាំ១៩៧០ ដែលក្រោយមក លន់ នល់ បានបង្កើតទៅជាសាធារណរដ្ឋខ្មែរ ។ បន្ទាប់មកទៀត សម្តេច សីហនុ បានចុះចូលជាមួយខ្មែរក្រហម ហើយទ្រង់បានប្រកាសហៅប្រជាជនដែលរស់នៅតំបន់ដាច់ស្រយាលឲ្យរត់ចេញពីរបបសាធារណរដ្ឋខ្មែរដែលមិនស្របច្បាប់ ។ ការគាំទ្ររបស់ទ្រង់បានអូសទាញកសិករជាច្រើនឲ្យចូលរួមចលនារបស់ខ្មែរក្រហម ។ ខៃល បានលើកឡើងបន្ថែមទៀតថា គាត់ហើយនិងអ្នកផ្សេងទៀតបានចូលរួមជាក្រុមយុវជន ក្នុងគោលបំណងចង់ឃើញសម្តេច សីហនុ ទទួលបានអំណាចវិញ ដោយគាត់បានបញ្ជាក់



ទៀតថា «ជាទូទៅ មនុស្សជាច្រើនស្រឡាញ់ចូលចិត្តទ្រង់ ហើយគាត់គឺជាប្រធានរណសិរ្សយោធាខ្មែរក្រហម» ។ ប្រសិនបើសម្តេចសីហនុ មិនមែនជាភាគីម្នាក់របស់ខ្មែរក្រហមនោះទេ ប្រហែលជាខ្មែរក្រហមមិនអាចកេណ្ឌទ័ពបានគ្រប់គ្រាន់ដើម្បីផ្តួលរំលំរបបលន់ នល់ បានទេ ។ ជាធម្មតា ទ័ពដែលកេណ្ឌបានជាច្រើនមិនពេញចិត្តនឹងទ្រព្យសម្បត្តិនិងឋានៈដែលអ្នកទីក្រុងមាន ហើយជាទូទៅដែលគេហៅថាអ្នកមាននោះទេ ។ អ្នកទាំងនោះមិនសប្បាយចិត្តនឹងអ្នកដែលមានសម្បត្តិស្តុកស្តម្ភដែលជាអ្នកកេងយកប្រយោជន៍ពីអ្នកក្រ ដោយផ្តល់ប្រាក់កម្ចាំងពលកម្មទាប ហើយជាអ្នកដែលត្រូវតែទទួលខុសត្រូវចំពោះការបន្ទាបបន្ថោកឋានៈ និងមើលស្រាលវណ្ណៈកសិករ ។ ទ័ពដែលកេណ្ឌទាំងអស់នោះបានដឹងអំពីឋានៈរបស់គាត់ ហើយជាអ្នកដែលប្រឆាំងចំពោះការបែងចែកឋានៈនៅក្នុងសង្គមកម្ពុជា ។ អ្នកទាំងអស់នោះពិបាកចិត្តនឹងបំណុល ការបាត់បង់ដីស្រែ និងភាពក្រីក្រ ។ រីឯការឃោសនារបស់ខ្មែរក្រហមបានសន្យាថានឹងធ្វើឲ្យកម្ពុជាក្លាយជាប្រទេសមួយដែលមានសុខក្សេមក្សាន្តនិងស្មើភាពគ្នា ។ ហើយអ្នកទាំងនោះគឺជាផ្នែកមួយដែលមានចំនួនច្រើន ។

យុទ្ធនាការឃោសនាដំបូងដែលបង្កើតឡើងដើម្បីបញ្ចុះបញ្ចូលឲ្យកសិករចូលរួមបដិវត្តន៍ដោយកម្មាភិបាលខ្មែរក្រហមតាមតំបន់មិនមានលក្ខណៈស្មុគស្មាញទេ ។ ជាទូទៅ កម្មាភិបាលខ្មែរក្រហមតាមតំបន់បញ្ចុះបញ្ចូលក្រុមកសិករឲ្យចូលរួមបដិវត្តន៍ដោយការចុះឈ្មោះតាមរយៈប្រធានភូមិ ប្រធានឃុំ និងគណៈស្រុក ។ នៅតំបន់ខ្លះ ការកេណ្ឌទ័ពមិនត្រូវបានបង្ខិតបង្ខំទេ ។ ជាក់ស្តែង នៅក្នុងបទសម្ភាស៍ជាមួយលោក សួ ប៊ុនស៊ូ, សុខា បានបង្ហាញថា «គ្មាននរណាម្នាក់បង្ខំពួកយើងនោះទេ ។ ពួកគេគ្រាន់តែមកឃោសនាធម្មតា ហើយយើងជឿជាក់ថាវាល្អ ដូច្នេះយើងក៏សម្រេចចិត្តចូលរួមបដិវត្តន៍» ។ កម្មាភិបាលទាំងនោះបានសន្យាថានឹងផ្តល់នូវស្តង់ដារនៃការរស់នៅមួយដែលល្អប្រសើរសម្រាប់កសិករដែលចូលរួមបដិវត្តន៍ ហើយនិងលុបបំបាត់ចោលវណ្ណៈមូលធននិយមនិងចក្រពត្តិនិយម ។ ការលើកទឹកចិត្ត និងការគាំទ្ររបស់កសិករដែលបានចូលរួមបដិវត្តន៍ត្រូវបានខ្មែរក្រហមសន្យាថានឹងតបស្នងមកវិញនៅពេលដែលសង្គ្រាមត្រូវបានបញ្ចប់ ។ កសិករទាំងនោះភាគច្រើនមានជីវភាពក្រីក្រ ហើយអ្នកទាំងនោះសង្ឃឹមចង់បានជីវភាពមួយដែលល្អប្រសើរជាងនេះ ។ នៅក្នុងផ្នែក «គ» (ក្នុងផ្នែកទីបី) នៃផែនការបួនឆ្នាំ បានលើកឡើងពីភាពចាំបាច់ឲ្យមានការបង្កើត ពង្រីក និងពង្រឹងឋានៈនៅក្នុងជួរកម្មាភិបាលដែលមានការអប់រំ «យើងត្រូវតែជ្រើសរើសអ្នកដែលមានប្រវត្តិប្រកាន់ខ្ជាប់នូវចលនាបដិវត្តន៍ ហើយនិងមានសមត្ថភាពគ្រប់គ្រាន់ដែលអាចយល់ដឹងពីខ្សែបន្ទាត់អប់រំរបស់បក្ស ព្រមទាំងអាចអនុវត្តដោយមុតមាំ និងបន្តពង្រីក និងពង្រឹងសមត្ថភាពរបស់ខ្លួននៅក្នុងចលនារបស់បក្ស» ។ ការរំពឹកដូចគ្នានេះត្រូវបានលើកយកមកនិយាយម្តងទៀតនៅក្នុងផ្នែកបន្ទាប់នៃឯកសារនេះ៖ «យើងត្រូវតែមានការប្រុងប្រយ័ត្នក្នុងការកសាង ពង្រឹង និងពង្រីកជួរបក្ស ដោយជ្រើសរើសអ្នកដែលមានប្រវត្តិជិតដិតជាមួយចលនាបដិវត្តន៍អាចអនុវត្តគោលនយោបាយរបស់បក្សក្នុងការអប់រំណែនាំផ្សព្វផ្សាយការឃោសនា និងចែកចាយព័ត៌មាន» ។

## ទ្រឹស្តីនៃការសងសឹកដែលមិនស្មើភាពគ្នារបស់ ហ៊ីនតុន

នៅក្នុងភាសាខ្មែរ គុំ មានន័យថា «ចង់ធ្វើអាក្រក់ ឬធ្វើអ្វីមួយទៅលើនរណាម្នាក់» ដោយមានចិត្តថា ព្យាបាទនរណាម្នាក់ ចងគំនុំដែលនាំនរណាម្នាក់ទៅ «រៀបចំសងសឹកវិញ» ។ ខ្មែរក្រហមបានបង្កើតការអន់ចិត្តនៅក្នុងប្រជាជនខ្មែរ ដោយជំរុញឲ្យពួកគេមានកំហឹង ហើយស្វែងរកការសងសឹកប្រឆាំងនឹងអ្នកមាន ។ យោងទៅតាម អាឡិច ហ៊ីនតុន ប្រជាជនកម្ពុជាដែលមានការគុំកួនខ្លាំងជួនកាលនិយាយថាចង់ «ស៊ីសាច់ ហុតឈាម» សត្រូវរបស់ខ្លួន ។ ការបកប្រែជាភាសាខ្មែរអំពីការសងសឹក គឺ «ការសងសឹក» ដែលមានន័យថា «សងត្រឡប់ទៅវិញ» ។ នេះដូចជារបៀបមនុស្សម្នាក់នៅក្នុងវប្បធម៌ខ្មែរត្រូវគេរំពឹងថាធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ។ សម្រាប់ អាឡិច ហ៊ីនតុន នេះនឹងអនុវត្តនៅក្នុង «របៀបមិនស្មើភាពគ្នាដែលថា បង្ក្រាបជនល្មើស ហើយលើកតម្កើងកិត្តិយសនរណាម្នាក់» កិត្តិយសដែលថាត្រូវបានបញ្ចុះតម្លៃដោយសារភាគីបង្កបញ្ហា ។ កម្មាភិបាលខ្មែរក្រហមដែលត្រូវទទួលខុសត្រូវចំពោះការសម្លាប់ «ប្រជាជនថ្មី» ដោយគ្មានការវិនិច្ឆ័យបានស្តារឡើងវិញនូវកិត្តិយសរបស់ខ្លួនដែលបាត់បង់ពីមុនមក ប៉ុន្តែនៅក្នុងករណីជាក់លាក់មួយ ។ កម្មាភិបាលខ្មែរ

ក្រហមទាំងនោះបានរកឃើញនូវការសងសឹកទៅលើជនដែលត្រូវទទួលខុសត្រូវផ្ទាល់ចំពោះភាពអាម៉ាស់របស់ពួកគេ និងទៅលើជនទាំងឡាយណាដែលមានភ័ស្តុតាងបង្ហាញស្រដៀងគ្នា នៅក្នុងការគោរពកម្មាភិបាលខ្មែរក្រហម មើលឃើញពីពួកមូលធននិយមទាំងអស់ថាជាពួកលោភលន់ និងកេងប្រវ័ញ្ចដូចគ្នា ។ សម្រាប់កម្មាភិបាលខ្មែរក្រហម អ្នកទាំងនេះចង់សងសឹក កម្ទេច និងបំផ្លាញទាំងស្រុងទៅលើគោលដៅក្រុមដែលបានរៀបរាប់ខាងលើតាមរយៈការចោទប្រកាន់ដែលមិនមែនជាការសងសឹក ។ កម្មាភិបាលខ្មែរក្រហមគិតថា ពួកគេត្រូវតែសម្រេចឲ្យបានដើម្បីកម្ទេចខ្មាំង និងខ្សែស្រឡាយអ្នកទាំងនោះ ។ ការកេណ្ឌទ័ពថ្មីទាំងនេះបានធ្វើឲ្យកម្មាភិបាលខ្មែរក្រហមមានឱកាសនិងមធ្យោបាយតាមរយៈបក្សដើម្បីបញ្ជាក់ថាសកម្មភាពសងសឹករបស់ពួកគេជារឿងត្រឹមត្រូវ ។

## ការកេណ្ឌទ័ព : ក្នុងអំឡុងពេលបដិវត្តន៍

### កុមារ

នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ឪពុកម្តាយមិនត្រូវបានអនុញ្ញាតឲ្យមើលថែកូនៗរបស់ខ្លួនតទៅទៀតឡើយ ចំណែកទំនាក់ទំនងគ្រួសារក៏លែងមានតម្លៃនៅក្នុងជីវភាពរស់នៅដែរ ។ កម្មាភិបាលខ្មែរក្រហមដែលត្រូវទទួលខុសត្រូវចំពោះការកេណ្ឌទ័ពនៅតាមជនបទបានស្នើឲ្យកុមារមកពីគ្រួសារក្រីក្រក្នុងប្រទេសកម្ពុជា ដែលមានបំណងចង់បំផ្លាញសង្គមចាស់ឲ្យរួចផុតពីភាពជូរចត់ដើម្បីទទួលបានផលប្រយោជន៍ ។ ប៉ុល ពត បានយកលំនាំទ្រឹស្តីភាគច្រើនមានលក្ខណៈដូចទៅនឹងការដឹកនាំរបស់ ម៉ៅ សេទុង ដែលបានកែប្រែកម្មាភិបាលវ័យក្មេងនិងកងកម្លាំងនិយមកុម្មុយនីស្តដើម្បីអនុវត្តលទ្ធិមហាលោតផ្លោះ និងបដិវត្តន៍វប្បធម៌ ។ ការជ្រើសរើសកម្មាភិបាលវ័យក្មេង និងយោធាជាច្រើនគឺដើម្បីធ្វើជាឧបករណ៍បដិវត្តន៍យោរយៅដែលខ្លួនមាន ។ សម្តេច សីហនុ មានព្រះបន្ទូលថា ក្មេងៗទាំងនេះត្រូវបានចុះឈ្មោះក្នុងបញ្ជីកងទ័ពបដិវត្តន៍ម្តងហើយ ដោយក្មេងទាំងនោះត្រូវបានបំបែកពីឪពុកម្តាយ និងគ្រួសារ ដែលត្រូវយកមកពីស្រុកកំណើតនិងដាក់ឲ្យនៅជំរុំហ្វឹកហ្វឺនភ្លាមៗ ។ យុវជនភាគច្រើនចាប់ផ្តើមធ្វើជាយោធានៅអាយុ១២ឆ្នាំ ។ បក្សកុម្មុយនីស្ត (ខ្មែរក្រហម) បានឲ្យតម្លៃជាយ៉ាងសំខាន់ទៅលើអ្វីដែលយុវជនវ័យក្មេងទាំងនោះបានគិតគឺជាមហាកិត្តិយស ហើយដែលមានឈ្មោះថា «ឧបករណ៍ផ្តាច់ការរបស់បក្ស» ។ ឌិត ប្រ៊ែន បានលើកឡើងថា យុវជនខ្មែរក្រហមវ័យក្មេងទាំងនេះត្រូវបានបំពាក់បំប៉នធ្វើជាកម្មាភិបាលយោរយៅបំផុត ដែលភាគច្រើនពួកវាមានអាយុពី១២ ទៅ១៥ឆ្នាំ ។ ក្មេងៗទាំងនេះមើលទៅដូចជាត្រូវបានគេបំពាក់បំប៉នស្មារតីទាំងស្រុង ។ ក្មេងៗត្រូវបានគេយកទៅទាំងនៅវ័យក្មេង និងមិនបានបង្រៀនអ្វីក្រៅពីវិន័យនិងសេចក្តីស្អប់នោះទេ ។ ជាញឹកញយ ក្មេងៗទាំងនេះកត់សម្គាល់គ្រួសាររបស់ខ្លួនជាសត្រូវ ។ ជាឧទាហរណ៍ ឌិត ប្រ៊ែន រំឭកពីកម្មាភិបាលវ័យក្មេងម្នាក់ដែលត្រូវបានគេប្រាប់ឲ្យសម្លាប់ឪពុករបស់ខ្លួន ។ ក្មេងនោះបានសម្លាប់ឪពុករបស់ខ្លួនមែន ប៉ុន្តែក្រោយមកក៏បាញ់សម្លាប់ខ្លួនឯងដែរ ។ កម្មាភិបាលវ័យក្មេងទាំងនេះបានប្រើអំពើសាហាវនិងហិង្សាដើម្បីអនុវត្តទៅតាមបញ្ជាដាច់ខាតពីថ្នាក់លើរបស់ខ្លួន ។ ខ្មែរក្រហមសង្ឃឹមថានឹងប្រើប្រាស់ក្មេងៗធ្វើជាមូលដ្ឋាននៃសង្គមថ្មីមួយដោយគ្មានសតិសម្បជញ្ញៈ ។

## អ្នកក្រីក្រមិនចេះអក្សរ

ហេតុផលសំខាន់មួយក្នុងចំណោមហេតុផលសំខាន់បីរបស់សម្តេច សីហនុ គឺថាហេតុអ្វីបានជាខ្មែរក្រហមជោគជ័យក្នុងការបង្កើនកម្មាភិបាលយោរយៅសម្រាប់យុត្តិសាស្ត្រនៃការកេណ្ឌទ័ព ។ មូលហេតុពីរទៀតនឹងត្រូវពិភាក្សានៅអត្ថបទក្រោយ ។ ការពិពណ៌នារបស់សម្តេច សីហនុ ក្នុងការកេណ្ឌកម្មាភិបាលរាប់បញ្ចូលទាំងកសិករក្រីក្រ ប្រជាជនតំបន់ភ្នំ អ្នករស់នៅក្នុងព្រៃ និងប្រជាជនតាមទីជនបទដាច់ស្រយាល ។ ការកេណ្ឌទ័ពទាំងនេះគឺជាការធ្វេសប្រហែលជាទីបំផុតរបស់របបចាស់ ។ កម្មាភិបាលទាំងនេះជាអ្នកដែលគ្មានចំណេះដឹង និងឆាប់ជឿការឃោសនាដ៏ឆ្លាតវៃរបស់ពួកខ្មែរក្រហម ហើយការឃោសនាបានជ្រាបចូលទៅក្នុងចិត្ត និងគំនិតរបស់កសិករក្រីក្រឲ្យមានការស្អប់ខ្ពើមវណ្ណៈសក្តិភូមិគ្រប់ជាន់ថ្នាក់ ។ ក្រុមដែលត្រូវបានកេណ្ឌនេះមិនចូលចិត្តអ្នកដែលមានសម្លៀកបំពាក់ស្អាត មានផ្ទះ និងក្មេងដែលមានការអប់រំខ្ពស់ អ្នកដែលមិនត្រូវបានគេតម្រូវឲ្យធ្វើការនៅស្រែចម្ការក្នុងថ្ងៃឈប់សម្រាក និងអ្នកដែលមានលុយសម្រាប់បង់ពន្ធ ។ ប៉ុល ពត បានចម្រាញ់មនុស្សដែល «ចេញពីសង្គមថ្នាក់ទាប» ស្អប់ខ្ពើមអ្នកមាន និងអាចសម្លាប់មនុស្សដោយមិនខ្វល់ពីអ្វីឡើយ ។

ប៉ុល ពត បានរកឃើញថា ប្រជាជនដែលមានដីធ្លី និងប្រជាជនក្រីក្រដែលកំពុងរស់ភាគឦសាននៃប្រទេសកម្ពុជានឹងជាកម្មាភិបាលដែលមានឧត្តមគតិដើម្បីកេណ្ឌជាកម្មាភិបាលបក្សថ្មីរបស់គាត់ ។ អ្នកក្រមានការអប់រំតិច ចេះអក្សរតិចតួច និងមិនសូវចេះដឹង គឺជាកម្មាភិបាលល្អដែលអាចធ្វើតាមបញ្ជាដោយមិនពិចារណាទៅលើភាពត្រឹមត្រូវនៃសកម្មភាពនោះ ។ ប៉ុល ពត បានបញ្ជាក់ក្នុងបទសម្ភាសន៍ថា «មូលដ្ឋានបង្អែករបស់ខ្ញុំគឺនៅក្នុងតំបន់ជនជាតិភាគតិចដែលស្ថិតនៅក្នុងតំបន់ភាគឦសាន ។ ខ្ញុំដឹងយ៉ាងច្បាស់ថាជនជាតិភាគតិចទាំងនោះមានការលំបាកវេទនា» ។ ប៉ុល ពត រៀបរាប់ពីពួកគេថាជា «មនុស្សល្ងង់មិនចេះអក្សរ ដែលសូម្បីទីក្រុងឡាននិងសភា មិនស្គាល់ដែរ ប៉ុន្តែហ៊ានប្រយុទ្ធប្រឆាំងសត្រូវក្រោមការដឹកនាំរបស់បក្ស» ។ ពាង សុភី ជាជនភៀសខ្លួនកម្ពុជាដែលរស់រានមានជីវិតនិងដែលគេចទៅប្រទេសថៃបាននិយាយថាភាពល្ងង់ខ្លៅបាននាំមកនូវការមិនពេញចិត្តចំពោះបច្ចេកវិទ្យាមូលដ្ឋានឧទាហរណ៍ កម្មាភិបាលខ្មែរក្រហមជាច្រើនមិនដែលដឹងសូម្បីតែដប ឬកំប៉ុងស្រាបៀរ ហើយពេលខ្លះស៊ីថ្នាំដុះធ្មេញទៀតផង ។ នៅក្នុងសេចក្តីណែនាំរបស់ ជីរេត ប្រ៊ីស អំពីសៀវភៅរបស់សម្តេច សីហនុ ដែលមានចំណងជើងថា «សង្គ្រាម និងក្តីសង្ឃឹម» បានអះអាងថា ប្រជាជនដែលនៅតំបន់ខ្ពង់រាបមានការលំបាកច្រើន និងធ្វើការងារច្រើនផ្សេងៗគ្នា ហើយពួកគេបានប្រមែប្រមូលប្រជាជនទាំងនោះដែលខ្មែរក្រហមគិតថាជាអនាគតកម្មា-ភិបាលរបស់គេ ។ អ្នកទាំងនេះជាកម្មាភិបាលដែលមិនមានការអប់រំ ចល័តទៅវិញទៅមក ។ ខ្មែរក្រហមអប់រំឲ្យពួកគេស្អប់ខ្ពើម និងមានចរិតដូចជាសត្រូវតិរច្ឆាន ។

ការកេណ្ឌទ័ពគឺនៅតែអនុវត្តពីរ-បីឆ្នាំដំបូងក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែមានការអះអាងថា នៅក្នុងឆ្នាំ១៩៧៧ បានធ្វើខ្លាំងជាងមុនទៅទៀត ។ សមាជិកថ្មីជាច្រើនរបស់បក្សតម្រូវឲ្យមាន «លក្ខណៈសម្បត្តិល្អមានបទពិសោធន៍ពីការធ្វើបដិវត្តន៍និងប្រវត្តិរូបល្អដែលត្រូវបានត្រួតពិនិត្យយ៉ាងខ្ជាប់ខ្ជួន» ។ តាមកាសែតនៅចុះថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ និយាយថា អ្នកមានការអប់រំខ្ពស់មិនត្រូវបានជ្រើសរើសឲ្យចូលក្នុងថ្នាក់ខ្ពស់របស់បក្សទេ ។ តួនាទីដឹកនាំថ្នាក់កណ្តាល និង ថ្នាក់ទាបភាគច្រើនដែលបានថ្លែងនៅខែ មេសា ឆ្នាំ១៩៧៥ គឺសុទ្ធតែជាទាហានដែលត្រូវបានបណ្តេញចេញពីកងពល ទាហានទាំងនោះភាគច្រើនមានរបួស ឬពិការដៃជើងដោយសារតែសកម្មភាពបដិវត្តន៍ ។ ជនភៀសខ្លួនដែលរួចរស់ជីវិតបានកត់សម្គាល់ថាប្រធានសហករណ៍ទូទាំងប្រទេសគឺជាអតីតយោធា ។ អ្នកកេណ្ឌទ័ពត្រូវតែធានាថា កម្មាភិបាលរបស់បក្សត្រូវតែមានប្រវត្តិត្រឹមត្រូវ ។ ការធ្វើមិនត្រឹមត្រូវរបស់បក្សកម្ពុជាប្រជាធិបតេយ្យនេះធ្វើឲ្យការកេណ្ឌនេះមានការលំបាក ។ សមាជិកបក្សត្រូវបានបង្ខឹកឲ្យទៅជាមនុស្សប្រឹងប្រែងធ្វើការអស់ពីកម្លាំងកាយចិត្តដើម្បីឲ្យការជ្រើសរើសពីឋានៈកម្មករទៅជាកម្មាភិបាល ។ នេះគឺជាកន្លែងដែល ប៉ុល ពត មានបំណងចង់ងាករេចេញពីគោលនយោបាយរបស់ម៉ៅក្នុងការកេណ្ឌទ័ព ។ នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតចិន ក្រោយពីជ័យជម្នះនៅក្នុងឆ្នាំ១៩៤៩ បក្សប្រជាជនកុម្មុយនីស្តចិនបានធ្វើការផ្លាស់ប្តូរគោលនយោបាយកេណ្ឌទ័ពដែលសង្កត់ធ្ងន់ទៅលើការធ្វើឲ្យអ្នកស្រែចម្ការទៅជាកម្មករ ជាបញ្ញវន្ត និងប្រជាជនទីក្រុង ដោយភ្ជាប់នូវកម្មវិធីអភិវឌ្ឍឧស្សាហកម្មជនបទ ដែលជាការកត់ត្រារបស់ លោក ស្ទួរមេន ដែល «ជាការផ្ទុយទៅនឹងអ្វីដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ» ។

## ខ្មែរក្រហម ៖ ការបណ្តុះបណ្តាល និង ការអភិវឌ្ឍ

បដិវត្តន៍ដំបូងរបស់កម្មាភិបាលខ្មែរក្រហមបានទទួលការបណ្តុះបណ្តាលពីវៀតណាមខាងជើងនិងផ្តល់គ្រឿងសព្វាវុធដោយប្រទេសចិននិងសូវៀត ដើម្បីក្លាយជាកម្លាំងដ៏រឹងមាំមួយនៅតាមទីជនបទ ។ ការផ្សព្វផ្សាយថ្នាក់ជាតិត្រូវបានទទួលយ៉ាងទូលំទូលាយនៅគ្រប់តំបន់ទាំងអស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយបង្ហាញពីមូលហេតុដើម្បីបណ្តុះបណ្តាល កែលម្អ និងកសាងអនាគតសម្រាប់កម្មាភិបាល ។ កម្មវិធីសិក្សាអប់រំនិងការកសាងកម្មាភិបាលកើតឡើងដោយសារការប្រជុំជាប្រចាំ ការប្រជុំទិតៀន និងការអប់រំជាផ្លូវការ ។ នៅក្នុងអំឡុងពេលបដិវត្តន៍ដំបូង កម្មាភិបាលថ្នាក់ខ្ពស់របស់បក្សបានសង្កត់ធ្ងន់ជាសំខាន់ទៅលើការបណ្តុះបណ្តាលកម្មាភិបាលជួរមុខ និងការបណ្តុះបណ្តាលជាសម្ងាត់សម្រាប់សមាជិកបក្ស ។ សមាជិកបក្សខ្លួនឯងបានទទួលនូវមនោគមន៍វិជ្ជាជាបន្ត

បន្ទាប់ និងអនុវត្តជាក់ស្តែងដើម្បីឲ្យមានការអប់រំល្អក្នុងការដឹកនាំ ។ កម្មាភិបាលត្រូវតែធ្វើជាគំរូគ្រប់ផ្នែកដែលពួកគេដឹកនាំ ។ នេះជាមូលហេតុដែលរដ្ឋាភិបាលខ្មែរក្រហមបានសង្កត់ធ្ងន់ទៅលើការបណ្តុះបណ្តាលនិងការអភិវឌ្ឍដល់កម្មាភិបាលថ្នាក់ក្រោមដែលជាអ្នកដឹកនាំការផ្លាស់ប្តូរនេះ ។ បន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ សាលានយោបាយរបស់មជ្ឈិមបក្សក្រោមការគ្រប់គ្រងដោយអនុលេខាបក្ស នួន ជា បានប្តូរទៅដាក់នៅវិទ្យាស្ថានបច្ចេកវិជ្ជាសូវៀត ។ ក្រសួងនីមួយៗនៅក្នុងទីក្រុងភ្នំពេញមានសាលាផ្ទាល់ខ្លួនដែរ ។

## ការអប់រំក្រោមរបបខ្មែរក្រហម

ប្រទេសកម្ពុជាបានមើលឃើញការជឿនលឿនចម្បងៗក្នុងការស្តារនិងពង្រីកវិស័យអប់រំក្រោយទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ ។ រដ្ឋាភិបាល សម្តេច សីហនុ ជាញឹកញយកំណត់យកថវិកាជាតិ២០ភាគរយនៃថវិកាជាតិទាំងអស់ដើម្បីពង្រីកការអភិវឌ្ឍលើវិស័យអប់រំសម្រាប់ប្រជាជនកម្ពុជា ។ នៅឆ្នាំ១៩៦៩ មានសកលវិទ្យាល័យចំនួន៩ សាលាបឋមសិក្សាចំនួន ៣២០០ និងអនុវិទ្យាល័យ១៦១ ត្រូវបានបង្កើតឡើង ដែលត្រូវបានទទួលស្គាល់ថាពិតជាបានពង្រីកលើវិស័យអប់រំដែលប្រទេសកម្ពុជាបានធ្វើចាប់តាំងពីទទួលបានឯករាជ្យពីប្រទេសបារាំងមក ។ យោងទៅលើមតិរបស់ ដេវីដ អេរ៉េស ថានេះជា «ការកើនឡើងជារួមដល់ទៅជាង១៣០ភាគរយលើចំនួនដែលបន្សល់ទុកពីបារាំងកាលពី១៥ឆ្នាំមុន» ។ ការធ្លាក់ចុះយ៉ាងខ្លាំងនៅតាមសាលាបានចាប់ផ្តើមស្ទើរតែភ្លាមៗបន្ទាប់ពីរដ្ឋាភិបាល លន់ នល់ ទម្លាក់រដ្ឋាភិបាលសីហនុ ក្នុងឆ្នាំ១៩៧០ ។ នៅក្នុងឆ្នាំ១៩៧១ មួយឆ្នាំបន្ទាប់ពីការដណ្តើម... ជំនួសអំណាចមុនរដ្ឋាភិបាល លន់ នល់ បានគ្រប់គ្រងសាលាបឋមសិក្សា១០៦៤ និងស្ទើរតែពាក់កណ្តាលនៃវិទ្យាល័យចំនួន ១៤៨ របស់ប្រទេសត្រូវបានបិទទ្វារ ។ ប៉ុល ពត បានដឹងពីប្រព័ន្ធអប់រំទាំងរបបសីហនុ និងរបបលន់នល់ថាជាការបង្កើតរបៀបសក្តិភូមិ ។ រវាងឆ្នាំ១៩៧៥ និង១៩៧៩ ខ្មែរក្រហមបានបំផ្លាញអគារសិក្សាទាំងអស់ បណ្ណាល័យ និងឧបករណ៍ប្រើប្រាស់អស់៩០ភាគរយ ។ ស្ថាប័នអប់រំជាន់ខ្ពស់ចំនួនប្រាំពីរនៃស្ថាប័នអប់រំជាន់ខ្ពស់ចំនួន៩ត្រូវបានលុបបំបាត់ចោលទាំងស្រុង ។ មានការបានប៉ាន់ប្រមាណថា ៧៥ភាគរយនៃគ្រូបឋមសិក្សានិងអនុវិទ្យាល័យ ៩១ភាគរយ និង ៦៧ភាគរយនៃសិស្សសកលវិទ្យាល័យបឋមសិក្សានិងអនុវិទ្យាល័យត្រូវបានសម្លាប់ក្នុងអំឡុងពេលដឹកនាំដោយ ប៉ុល ពត ។ សាលារៀនភាគច្រើនត្រូវបានប្តូរទៅជាកន្លែងស្នាក់នៅ ឬជាគុកសម្រាប់កងទ័ពរបស់កងកម្លាំងប្រដាប់អាវុធកុម្មុយនីសកម្ពុជា និងកងកម្លាំងសាធារណរដ្ឋ លន់ នល់ ។ ការអប់រំតែមួយគត់ដែលផ្តល់ដោយរបបសាធារណរដ្ឋ ឬរបបកុម្មុយនីស្តកើតឡើងធំបំផុតគឺនៅក្រោលគោ ក្រោមដើមឈើ ឬនៅរោងបាយ ។ នៅពេលខ្មែរក្រហមបានឡើងកាន់អំណាចទាំងស្រុងក្នុងខែមេសា ឆ្នាំ១៩៧៥ ពួកគេបានលុបបំបាត់ចោលនូវទម្រង់អប់រំរបស់របបមុនដែលនៅសល់ ដោយសារការភ័យខ្លាចកម្មវិធីសិក្សាបែបសក្តិភូមិ និងសៀវភៅអាន សៀវភៅសរសេរ និងអត្ថបទផ្សេងៗដែលបោះពុម្ពដោយពួកបស្ចិមប្រទេស ។ សៀវភៅទាំងអស់នោះត្រូវបានប្រមូលចេញពីបណ្ណាល័យ សាលារៀនហើយដាក់គរទុកនៅក្រោមដើមឈើដើម្បីឲ្យខូចទៅតាមអាកាសធាតុ ហើយខ្មែរក្រហមបានបំផ្លិចបំផ្លាញចោលដោយយកទៅដុតដើម្បីចម្អិនអាហារ ឬក៏ប្រើដើម្បីមូរបារីជក់ ។ ខ្មែរក្រហមក៏បានធ្វើបាបអ្នកដែលបង្រៀននៅសាលា ឬអ្នកមានចំណេះដឹងខ្ពស់ ។ តាមការសន្និដ្ឋានបង្ហាញថា សិស្សដែលរៀនចាប់ពីអនុវិទ្យាល័យ ៩៦ភាគរយ និងគ្រូ៧៥ភាគរយត្រូវបានសម្លាប់ បន្ថែមពីលើនោះមានចំនួនដ៏លើសលប់នៃគ្រូបង្រៀនដែលបានភៀសខ្លួនពីប្រទេសកម្ពុជាដោយជោគជ័យមុនពេលការឡើងកាន់អំណាចដោយកម្ពុជាប្រជាធិបតេយ្យ ។ ដេវីដ អេរ៉េក បានធ្វើការអះអាងយូរណាស់មកហើយថា ខ្មែរក្រហមគឺជាអ្នកទទួលខុសត្រូវចំពោះការបំផ្លាញវិស័យអប់រំនៅកម្ពុជា ប៉ុន្តែក៏មានមនុស្សជាច្រើនមិនឯកភាពជាមួយនឹងគំនិតនេះទេ ។ សាលារៀននៅតែមាន ហើយទំនាក់ទំនងរវាងគ្រូនិងសិស្សក៏នៅតែមានដែលមានហេតុផលតែមួយប៉ុណ្ណោះ គឺថាប្រជាជនមិនអើពើនឹងការអប់រំនេះ ពីព្រោះសូម្បីតែការអប់រំរបស់ពួកគេក៏មិនដូចការអប់រំរបស់ពួកបស្ចិមប្រទេសដែរ ហើយទ្រឹស្តីនៃការណែនាំគឺមានតាំងពីដើមមកឧទាហរណ៍ ភាពអាក្រក់របស់សាលា ។ ខ្មែរក្រហមចង់ឲ្យវិស័យអប់រំអាក្រក់នៅតែជាវិស័យអប់រំដែលមានប្រសិទ្ធភាពដល់ប្រជា

ជនកម្ពុជា ដែលរដ្ឋាភិបាលខ្មែរក្រហម និងក្រសួងអប់រំមើលឃើញថាស័ក្តិសមដែលសិស្សគួរតែរៀន ។

សហគមន៍អន្តរជាតិបានដឹងតិចតួចចំពោះការអប់រំក្រោមរបបខ្មែរក្រហម ឬសកម្មភាពផ្សេងៗរបស់ក្រសួងអប់រំ ហើយអ្វីដែលអន្តរជាតិបានដឹងគឺសៀវភៅនិងការចែកចាយទៅដល់គ្រូ ។ ភាពច្រើនដែលយើងបានដឹងគឺតាមរយៈសក្ខីកម្មរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម សុន្ទរកថានយោបាយ និងការកត់ត្រាដែលធ្វើឡើងដោយកម្មាភិបាលថ្នាក់ខ្ពស់របស់បក្ស ។ នៅពេលដែលខ្មែរក្រហមបានបាត់បង់អំណាចដោយសារការចូលវាយលុករបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ឯកសាររបស់ក្រសួងអប់រំភាគច្រើនត្រូវបានបំផ្លាញ និងបាត់បង់ ហើយស្ថិតិបន្ថែមមិនត្រូវបានចងក្រងទេ ។

ទោះបីជាមនុស្សភាគច្រើនជឿជាក់ថាអ៊ីចឹងក៏ដោយ ក៏ខ្មែរក្រហមមិនបានលុបបំបាត់ទម្រង់នៃការអាន និងការសរសេរដែរ ។ ខ្មែរក្រហមបានបោះពុម្ពផ្សាយទស្សនាវដ្តីប្រចាំខែចំនួនបី ក្មេងត្រូវបានបង្រៀនពីរបៀបអាន និងសរសេរ ហើយកម្មាភិបាលខ្មែរក្រហមបានរក្សាទុកកំណត់ត្រាលម្អិតវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជា ។ ទោះបីជាប្រធានសហករណ៍តាមតំបន់មិនចេះអក្សរមានចំនួនច្រើនក៏ដោយ ក៏កម្មាភិបាលជាន់ខ្ពស់ចាំបាច់ត្រូវចេះអាន និងសរសេរ ចំណែកអ្នកមិនចេះអក្សរមិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងរចនាសម្ព័ន្ធរបស់មជ្ឈិមបក្សឡើយ ។

ដើម្បីឲ្យជួរបក្សរឹងមាំ និងប្រកាន់ខ្ជាប់ទ្រឹស្តីអ្នកសង្គមនិយមម៉ាក់ស៊ីសបានត្រឹមត្រូវ វប្បធម៌ និងបដិវត្តន៍អប់រំចាំបាច់ត្រូវកសាងសង្គមថ្មីមួយ ។ លោក ម៉ូសយ៉ាកូវ និង ជីហ្គា បានអះអាងថា «ដូច្នេះ វាច្បាស់ណាស់ថា ក្នុងគោលការណ៍ ខ្មែរក្រហមមិនមានការភ័យខ្លាចពីសមត្ថភាពរបស់មនុស្សដែលចេះអាន និងសរសេរទេ ។ ដូច្នេះ វាជាអ្វីនិងជារបៀបដែលអ្នកអានដឹងជាជាងសមត្ថភាពដើម្បីអាននិងសរសេរ ដែលធ្វើឲ្យមនុស្សមានការសង្ស័យគ្នា ។ ជាមួយនឹងទស្សនៈផ្សេងៗទៀតនៃជីវិតប្រចាំថ្ងៃ មជ្ឈិមបក្សចង់គ្រប់គ្រងទាំងស្រុងអំពីរបៀបណា វេលា និងអ្វីដែលមនុស្សសរសេរ អាន និង បានគិត ។

ការអប់រំត្រូវបានផ្តល់នៅក្នុងផែនការបួនឆ្នាំរបស់មជ្ឈិមបក្ស ។ ផែនការនេះត្រូវបានធ្វើឡើងនៅក្នុងកិច្ចប្រជុំបក្សដែលចូលរួមដោយកម្មាភិបាលថ្នាក់ខ្ពស់ទាំងអស់របស់បក្សចាប់ពីថ្ងៃ ២១ ខែកក្កដា ដល់ ថ្ងៃទី ២ ខែសីហា ឆ្នាំ១៩៧៦ ។ នយោបាយថ្មីមួយទៅលើការកែទម្រង់វិស័យអប់រំនៅក្នុងម្ភៃទំព័រចុងក្រោយក្នុងឯកសារដែលមាន១១០ទំព័រ មានចំណងជើងថា «វប្បធម៌ ស្រែចម្ការ អក្សរសាស្ត្រ សិល្បៈ បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងការអប់រំមនុស្ស ការឃោសនា និង ព័ត៌មាន» ដែលបានអះអាងលើសថា បក្សកំពុងធ្វើការឃោសនា និងអប់រំនៅក្នុងកិច្ចប្រឹងប្រែងមួយដើម្បីកសាងសង្គម និងស្មារតីបដិវត្តន៍នៅក្នុងក្រុមមនុស្សជាយុវជនសំខាន់ និងមនុស្សក្រីក្រ ។ វាគឺជំហើរការពីរដែលបានផ្តល់ជាលើកដំបូងដល់បក្សដើម្បី «លុបបំបាត់ ដកទាំងឫស បំផ្លាញវប្បធម៌ បណ្ណាល័យ កាកសំណល់ចក្រពត្តិនិយម អាណានិគមនិយម និង វណ្ណៈជិះជាន់ផ្សេងទៀត ។ ជំហានទីពីរគឺដើម្បីពង្រឹង និងបង្កើនការកសាងវប្បធម៌បដិវត្តន៍ អក្សរសាស្ត្រ និងសិល្បៈនៃវណ្ណៈកម្មករ កសិករ ឲ្យស្របទៅនឹងគោលជំហររបស់បក្ស ។ គោលបំណងរបស់បក្សគឺដើម្បីជំនួសរបបបញ្ញវន្តចាស់ជាមួយបញ្ញវន្តដែលអប់រំដោយសង្គមនិយមថ្មីមួយ ដោយបង្កើតនូវរបបថ្មីមួយ ដោយប្រើចម្រៀងបដិវត្តន៍ និងកំណាព្យដែលជំរុញឲ្យអ្នកក្រស្អប់ការកេងប្រវ័ញ្ច ។

***(នៅមានត)***

**ហ្គ្រីហ្គោរី ប្រកណ្វ**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

*វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ថតចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ http://www.voanews.com/ khmer/democratic-kampuchea.cfm របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។* **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# សំ សុវណ្ណដារ៉ា ៖ គ្រូបង្រៀនមុខសញ្ញារបស់អង្គការ

សំ សុវណ្ណដារ៉ា សព្វថ្ងៃរស់នៅ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ។ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើង ខ្មែរក្រហមបានដាក់គ្រួសាររបស់ ដារ៉ា នៅក្នុងការតាមដានរហូត ដោយសារតែឪពុករបស់គាត់ធ្វើជាគ្រូបង្រៀន។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏គ្រួសាររបស់ ដារ៉ា នៅតែអាចរួចជីវិតត្រឡប់មកស្រុកកំណើតវិញដែរដោយសារតែគាត់ខិតខំធ្វើការដើម្បីឲ្យអង្គការទុកចិត្ត។

នៅពេលមានអាយុ១០ឆ្នាំ ដារ៉ា បានចូលរៀននៅវិទ្យាល័យទន្លាប់ខេត្តតាកែវ។ ក្រោយមក ដោយសារតែឮដំណឹងថាបន្តិចទៀតខ្មែរក្រហមនឹងវាយចូលមកដល់ ឪពុកម្តាយ ដារ៉ា ក៏ឲ្យគាត់ឈប់រៀនរួចរៀបចំអីវ៉ាន់នាំគ្នាចាកចេញពីស្រុកកំណើតទៅរស់នៅទីក្រុងភ្នំពេញវិញ។ បន្ទាប់មក ឪពុកម្តាយរបស់ ដារ៉ា បាននាំគាត់ទៅចុះឈ្មោះចូលរៀននៅវិទ្យាល័យឥន្ទ្រទេវីដែលនៅក្នុងថ្នាក់របស់គាត់មានសិស្សចំនួន៤០នាក់។ ចំណែកឪពុករបស់ ដារ៉ា បានធ្វើជាគ្រូបង្រៀននៅសាលាវត្តសន្សំកុសល។ រស់នៅមិនបានយូរប៉ុន្មានផង ខ្មែរក្រហមក៏បានចូលមកគ្រប់គ្រងទីក្រុងភ្នំពេញទៀត រួចប្រកាសជម្លៀសប្រជាជនទាំងអស់ឲ្យចាកចេញពីផ្ទះ ដោយប្រាប់ថាទៅរយៈពេលតែបីថ្ងៃប៉ុណ្ណោះនឹងត្រឡប់មកវិញហើយ ព្រោះអង្គការត្រូវការបោសសម្អាតក្រុង។ ក្រោយពីបានឮដំណឹងនេះភ្លាម ឪពុកម្តាយរបស់ ដារ៉ា បានប្រមែប្រមូលរបស់ប្រើប្រាស់មួយចំនួនមានដូចជា ខោអាវ ចាន ឆ្នាំង អង្ករបន្តិចបន្តួច រួចធ្វើដំណើរទៅកាន់ទិសខាងជើងតាមផ្លូវរទេះភ្លើង។ ធ្វើដំណើរតាមផ្លូវជាតិលេខ២រហូតមកដល់ថ្នល់ទទឹង ឪពុកម្តាយរបស់ ដារ៉ា បានឃើញឈ្លបខ្មែរក្រហមម្នាក់ដែលកំពុងតែស្ពាយកាំភ្លើងនិយាយប្រាប់ឪពុកម្តាយរបស់គាត់ថា «មិនចាំបាច់ចូលខេត្តតាកែវទេ ព្រោះខេត្តនេះកំពុងតែរៀបចំបោសសម្អាតដែរ»។ ឮដូច្នេះ ឪពុកម្តាយរបស់ ដារ៉ា សម្រេចចិត្តត្រឡប់ទៅផ្លូវជាតិលេខ៣កាត់តាមអង្គតាសោមរហូតទៅដល់ថ្នល់បែកឃុំគុសវិញ។



សំ សុវណ្ណដារ៉ា

ចំណាយពេលប្រហែល២០ថ្ងៃ គ្រួសាររបស់ ដារ៉ា បានមកដល់ស្រុកកំណើត។ ប៉ុន្តែធ្វើការបានពីរខែ ខ្មែរក្រហមក៏ផ្លាស់គ្រួសាររបស់ ដារ៉ា ឲ្យទៅរស់នៅជិតព្រំដែនវៀតណាមវិញ។ នៅទីនោះ ដោយសារតែគ្រួសាររបស់ ដារ៉ា ជាប្រជាជន១៧ មេសា ដូច្នេះប្រជាជនមូលដ្ឋានមិនសូវមានទំនាក់ទំនងជាមួយគ្រួសាររបស់ ដារ៉ា ឡើយ។ ប៉ុន្តែក្រោយមក អ្នកទាំងនេះស្រឡាញ់និងរាប់អាន

គ្រួសាររបស់ ដារ៉ា យ៉ាងជិតស្និទ្ធក្រោយពីដឹងថា គ្រួសារគាត់ក៏ជាជនរងគ្រោះដែរ ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ខ្មែរក្រហមនៅតែដាក់គ្រួសាររបស់ ដារ៉ា នៅក្នុងការតាមដានដដែល ដោយសារតែឪពុករបស់ ដារ៉ា ជាគ្រូបង្រៀន ។ ដារ៉ា បានរៀបរាប់ទាំងទឹកមុខស្រងូតស្រងាត់ថា «ថ្ងៃមួយកងឈ្លបខ្មែរក្រហមនិងប្រធានភូមិស្រាប់តែមកដល់ផ្ទះឪពុកម្តាយរបស់ខ្ញុំដើម្បីសុើបសួរអំពីប្រវត្តិរូបគាត់» ។ ក្រោយពីឪពុករបស់ ដារ៉ា និយាយចម្លើយដដែលទើបអង្គការជឿ ហើយក៏លែងតាមដានតទៅទៀត ។

នៅក្នុងឆ្នាំ១៩៧៦ អង្គការបានចាត់តាំង ដារ៉ា ឲ្យចូលកងចល័តនៅសហករណ៍ស្រុក១០៩ (ស្រុកគិរីវង្ស) ។ នៅទីនោះគ្មានប្រជាជនណាម្នាក់ហ៊ានប្រឆាំងនឹងបញ្ជារបស់អង្គការឡើយ ព្រោះពីមួយថ្ងៃទៅមួយថ្ងៃឃើញតែបាត់មនុស្សពីកង និងព្រោះតែប្រធានសហករណ៍ប្រាប់ថា «ប្រសិនបើមិនខំធ្វើការឲ្យទាន់ផែនការទេនឹងយកទៅសម្លាប់ចោលជាមិនខាន» ។ លើសពីនេះទៅទៀត ពេលខ្លះទោះបីជាខំធ្វើការយ៉ាងណាក៏ដោយ ក៏អង្គការនៅតែយកប្រជាជនទៅសម្លាប់ដែរ ។ ដារ៉ា បានរំឭកអំពីព្រឹត្តិការណ៍នៅពេលនោះថា ថ្ងៃមួយប្រធានអង្គការបានហៅមិត្តភក្តិរបស់ឪពុកគាត់ទៅដងទឹកស្រោចសំណាបនៅវាលស្រែ ។ ពេលដែលទៅដល់ខ្មែរក្រហមបាននាំគ្នាសម្លាប់គាត់ចោលតែម្តង ។ ក្រោយពីឃើញព្រឹត្តិការណ៍បែបនោះ ដារ៉ា មានការភ័យតក់ស្លុតយ៉ាងខ្លាំង ហើយគិតថា «ថ្ងៃណាមួយប្រាកដជាដល់វេនគាត់ដែរហើយ» ។ ដូច្នេះទោះបីជា ដារ៉ា មានជំងឺធ្ងន់យ៉ាងណាក៏ដោយ ក៏គាត់នៅតែខិតខំធ្វើការងារដែរ ដើម្បីឲ្យទាន់តាមផែនការ ។

នៅឆ្នាំ១៩៧៧ ដោយសារតែខ្លាចប្រជាជនរត់គេចខ្លួនទៅប្រទេសវៀតណាម ខ្មែរក្រហមបានផ្លាស់ ដារ៉ា និងប្រជាជនជាច្រើនគ្រួសារទៀតឲ្យទៅរស់នៅក្នុងស្រុកត្រាំកក់វិញ ។ នៅទីនេះខ្មែរក្រហមបានបង្ខំឲ្យប្រជាជនធ្វើការស្ទើរតែគ្មានពេលសម្រាកឡើយ ហើយថែមទាំងឲ្យហូបតែបបររាវប៉ុណ្ណោះស្ទើរតែមិនអាចទប់នឹងការងារធ្ងន់ៗបាន ។ ដូច្នេះ ទោះបីជាដឹងច្បាស់ថាប្រឆាំងនឹងវិន័យរបស់អង្គការក៏ដោយ ក៏ ដារ៉ា នៅតែហ៊ានទៅលួចដំឡូងដុតហូបទាំងយប់ដែរ ។

ធ្វើការបានមួយរយៈ អង្គការបានផ្លាស់ ដារ៉ា ឲ្យទៅឃុំពពេលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រធានយុវជនឈ្មោះ នុច វិញ ។ ដោយសារការរស់នៅកាន់តែមានការលំបាកជាងមុន ដារ៉ា បានសុំអង្គរ តានុច ទៅជួបឪពុកម្តាយនៅភូមិត្រពាំងកក់ ។ គ្រាន់តែដឹងដំណឹងនេះភ្លាម ស្រាប់តែប្រធានសហករណ៍បានស្រែកសម្លុតដាក់ ដារ៉ា ថា «តើឯងបានដំណឹងពីណាមកថាឪពុករបស់អ្នកឯងរស់នៅត្រពាំងកក់?» ដារ៉ា ភ័យតក់ស្លុតជាខ្លាំងរួចបានឆ្លើយប្រាប់ថា «ខ្ញុំដឹងតាមរយៈពូរបស់ខ្ញុំដែលគាត់បានមកឃុំពពេល» ។ បន្ទាប់មក ប្រធានសហករណ៍បានប្រាប់ថា «នាំគ្នារៀបចំអីវ៉ាន់ទៅទាំងអស់គ្នាទៅ» ។ ក្រោយពីបានឮភ្លាមនោះ ដារ៉ា សប្បាយចិត្តជាខ្លាំងដោយនឹកក្នុងចិត្តថានឹងបានជួបឪពុកម្តាយក្នុងពេលឆាប់ៗ ។ ភ្លាមៗ ស្រាប់តែឡើង កងឈ្លបពីរនាក់មានស្ពាយកាំភ្លើងចំនួនប្រាំដើមដើរមកយក ដារ៉ា និងមនុស្សចំនួន១៨នាក់ទៀតធ្វើដំណើរទៅឃុំពពេល ។ ពេលមកដល់ ប្រធានឃុំឈ្មោះ តាកេះ ចិត្តល្អចំពោះប្រជាជនជាខ្លាំងដោយគាត់បានប្រាប់អ្នករោងបាយថា «កុំដាំបាយឲ្យក្មេងទាំងនេះហូបអី ព្រោះបើហូបច្រើនអាចបណ្តាលឲ្យស្លាប់» ។ ក្រោយពីស្តាប់ឮភ្លាម ដារ៉ា មានការខឹងសម្បាយ៉ាងខ្លាំង ។ ប៉ុន្តែក្រោយមកទើប ដារ៉ា ដឹងថា គាត់បារម្ភខ្លាចមានគ្រោះថ្នាក់ ព្រោះហូបច្រើនអាចហល់បណ្តាលឲ្យស្លាប់ ។ ដោយសារតែគាត់ចិត្តល្អបែបនេះ ក្រោយមកខ្មែរក្រហមក៏យកគាត់ទៅសម្លាប់ដោយផ្លាស់ សឿន ឲ្យមកគ្រប់គ្រងជំនួសវិញ ។

នៅឆ្នាំ១៩៧៩ ពេលដែលវៀតណាមវាយមកដល់ឃុំពពេល ប្រជាជនទាំងអស់មានការសប្បាយរីករាយជាអនេក រួចក៏នាំគ្នាធ្វើដំណើរត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន ។ ចំណែក ដារ៉ា បានសម្រេចចិត្តធ្វើដំណើរត្រឡប់ស្រុកកំណើតវិញដែរ ។ បន្ទាប់ពីស្រុកមានសន្តិភាព ដារ៉ា បានសម្រេចចិត្តដាក់ពាក្យធ្វើជាគ្រូបង្រៀន ។ នៅឆ្នាំ១៩៨៣ ដារ៉ា បានមករៀនបន្តផ្នែកទស្សនវិជ្ជានៅសាកលវិទ្យាល័យភ្នំពេញ ។ ក្រោយពីរៀនចប់ ដារ៉ា បានមកបង្រៀននៅវិទ្យាល័យមួយ បន្ទាប់មកបានប្តូរមកបង្រៀននៅវិទ្យាល័យទន្លាប់ស្រុកគិរីវង្សវិញ ។ នៅឆ្នាំ១៩៩៨ ដារ៉ា បានផ្លាស់មកធ្វើការនៅនាយកដ្ឋានបណ្តុះបណ្តាលវិក្រឹត្យការរហូតមកដល់សព្វថ្ងៃ ។

**ស៊ិន សុធីតា**

# ធ្វើបដិវត្តន៍ដើម្បីរំដោះប្រទេសជាតិ



នាវ ចំរើន

នាវ ចំរើន បានចូលបម្រើបដិវត្តន៍ចាប់តាំងពីឆ្នាំ១៩៧៤ ក្នុងគោលបំណងដើម្បីរំដោះប្រទេសជាតិនិងធ្វើឲ្យប្រទេសមានភាពរីកចម្រើន ។ ប៉ុន្តែទោះបីជា ចំរើន បានខិតខំធ្វើការងារយ៉ាងណាក៏ដោយ ក៏គាត់នៅតែទទួលការស្តីបន្ទោសនិងដាក់កំហិតយ៉ាងធ្ងន់ធ្ងរពីខ្មែរក្រហមដដែល ។ ចំណែកបងប្អូនរបស់ ចំរើន បីនាក់បានបាត់ដំណឹងរហូតមកដល់សព្វថ្ងៃនេះ ។

ចំរើន ជាកូនទីពីរក្នុងចំណោមបងប្អូនប្រាំមួយនាក់ (ស្រី២ ប្រុស៤) មានស្រុកកំណើតនៅ ឃុំរលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ នៅឆ្នាំ១៩៧៤ ក្រោយពីយោធាខ្មែរក្រហមចូលគ្រប់គ្រងភូមិនេះភ្លាម ពួកវាក៏បានប្រកាសប្រាប់ប្រជាជនទាំងអស់ឲ្យចាកចេញពីលំនៅឋាន ។ ដោយសារស្ថានភាពច្របូកច្របល់និងភ័យខ្លាចខ្លាំងពេក គ្មាននរណាម្នាក់ហ៊ានជំទាស់នឹងបញ្ជានេះឡើយដោយគ្រួសារនីមួយៗនាំគ្នារៀបចំអីវ៉ាន់ត្រៀមចាកចេញ ។ បន្ទាប់មក ខ្មែរក្រហមបានបញ្ជាឲ្យគ្រួសាររបស់ ចំរើន ធ្វើដំណើរទៅវត្តអង្គក្រូច ស្រុកបាទី ខេត្តតាកែវ ។ នៅទីនោះ ក្មេងស្រីៗដែលមានអាយុប្រហែលនឹងគាត់ត្រូវបានបញ្ជូនឲ្យចូលកងចល័តធ្វើស្រែនៅស្រុកកណ្តាលស្ទឹងក្រោមការគ្រប់គ្រងរបស់ប្រធានកងឈ្មោះ សំបួរ ។ ចំណែកក្មេងប្រុសៗត្រូវចាត់តាំងឲ្យចូលកងឈ្លបនៅតាមភូមិនិងឃុំផ្សេងៗ ។ ទោះបីជា ចំរើន រស់នៅបែកពីឪពុកម្តាយក៏ដោយក៏ ចំរើន មិនសូវនឹកផ្ទះប៉ុន្មានដែរ ព្រោះការងារមិនសូវមានការរឹតបន្តឹងខ្លាំងហើយពេលឈឺថែមទាំងមានពេទ្យព្យាបាលត្រឹមត្រូវទៀតផង ។ ប៉ុន្តែគាត់ស្ទើរតែមិនជឿថា ការរស់នៅរបស់ឪពុកម្តាយគាត់ជាមួយនិងប្រជាជនដទៃទៀតមានការខុសគ្នានោះទេ ព្រោះពេលដែលគាត់ទទួលការអនុញ្ញាតឲ្យមកលេងផ្ទះម្តង គាត់បានឃើញឪពុកម្តាយរបស់គាត់ធ្វើការស្ទើរគ្មានពេលសម្រាក ហើយហូបចុកមិនគ្រប់គ្រាន់ទៀត ។

### ការងារនៅទួលទំពូង

នៅឆ្នាំ១៩៧៥ អង្គការចាប់ផ្តើមជ្រើសរើសអ្នកដែលមានប្រវត្តិរូបល្អឲ្យទៅធ្វើការនៅតាមកន្លែងផ្សេងៗ ។ ពេលនោះ ចំរើន រួមទាំងសមាជិកកងរបស់គាត់ជាច្រើននាក់ទៀតត្រូវបានជ្រើសរើសឲ្យទៅធ្វើការនៅរោងចក្រកាត់ដេរនៅទួលទំពូងដែលនៅទីនេះមានបែងចែកជាពីរផ្នែក គឺផ្នែកដេរមុង និងដេរសម្លៀកបំពាក់ ។ ក្រោយពីទទួលការបង្ហាត់បង្រៀនអំពីរបៀបដេររយៈពេលពីរបីខែ អង្គការបានចាត់តាំងឲ្យកម្មករទាំងអស់ធ្វើការទៅតាមជំនាញរៀងៗខ្លួន ។ ដោយសារតែ ចំរើន ដេរបានស្អាតគាត់ត្រូវបានចាត់តាំងឲ្យធ្វើការនៅក្នុងផ្នែកដេរសម្លៀកបំពាក់ក្រៅពីនេះគឺធ្វើការនៅក្នុងផ្នែកកាត់និងតម្រៀបក្រណាត់ ។ បន្ទាប់មក អង្គការបានកំណត់ឲ្យកម្មករទាំងអស់ដេរសម្លៀកបំពាក់មួយថ្ងៃឲ្យបាន១៥កំប្លេ ចាប់ពីព្រឹកព្រលឹមរហូតដល់ម៉ោង៩យប់ ។ ក្រោយពីដេរបានចំនួនច្រើនហើយនឹងមានកងដឹកជញ្ជូនសម្លៀកបំពាក់ទាំងនេះយកទៅដាក់ឃ្លាំងដែលមានទីតាំងស្ថិតនៅជិតកន្លែងដេរដែរ ។ បន្ទាប់មក រថយន្តនឹងមកដឹកបន្តយកទៅកន្លែងផ្សេងទៀត ។ ដូច្នេះ ដោយសារតែខំសម្រុកឲ្យទាន់តាមផែនការ មួយរយៈក្រោយមកកម្មករមួយចំនួនបានធ្លាក់ខ្លួនឈឺ ។ ទោះបីយ៉ាងនេះក៏ដោយ ក៏គ្មាននរណាម្នាក់ហ៊ានសុំច្បាប់ឈប់ដែរ លុះត្រាតែអង្គការប្រាប់ឲ្យឈប់សម្រាកតែម្តង ទើបហ៊ានឈប់ ។ ចំរើន នៅចាំបានថា ពេលនោះគាត់ក៏កើតជំងឺគ្រុនចាញ់ដែរ ។ ក្រៅពីបើកថ្នាំឲ្យគាត់លេបជារៀងរាល់ថ្ងៃ អង្គការគ្រាន់តែអនុញ្ញាតឲ្យគាត់ឈប់សម្រាកមួយថ្ងៃប៉ុណ្ណោះនៅពេលគាត់ក្តៅខ្លួនខ្លាំងរហូតដល់ក្រោកទៅធ្វើការមិនបាន ។ ចំណែកកម្មករផ្សេងទៀតបែរជារាយការណ៍ទៅប្រធានរោងចក្រថាម៉ាស៊ីនខូចទៅវិញ ។ ដូច្នេះ អ្នកទាំងនោះត្រូវអង្គការហៅទៅកសាងជាច្រើនលើកច្រើនសាក្រោយពីដឹងថាបានរាយការណ៍កុហក ។

## ធ្វើស្រែនៅអូរបែកក្អម

ដោយសារតែការខិតខំប្រឹងប្រែងធ្វើការរហូតដល់ក្រណាត់បញ្ជូនមកមិនទាន់ អង្គការបានសម្រេចបញ្ជូនកម្មករដែលទំនេរទាំងអស់ឲ្យទៅធ្វើស្រែនៅអូរបែកក្អមវិញ ។ ការងារនេះមានការលំបាកជាងមុនបន្តិច ដោយសារតែនៅវេលាម៉ោងបីទៀបភ្លឺ អង្គការដើរផ្លុំកញ្ចែដើម្បីដាស់កម្មករទាំងអស់ឲ្យរៀបចំខ្លួនធ្វើដំណើរចេញទៅដោយមានកាន់ចប បង្គី និងកណ្ដៀវទៅដល់យប់ឡើង ទើបដើរត្រឡប់មកសម្រាកនៅទួលទំពូងវិញ ។ នៅទីនោះ ចំរើន មានការងឿងឆ្ងល់ជាខ្លាំងព្រោះពេលដែលប្រមូលទិន្នផលស្រូវឃើញតែរថយន្តមកដឹកស្រូវទាំងនោះចេញទៅដោយប្រាប់ថាដឹកដាក់ឃ្លាំងរដ្ឋ ។

## ការងារឡអិដ្ឋ ( អ-៤)

នៅឆ្នាំ១៩៧៨ អង្គការបានផ្លាស់កម្មករទាំងអស់ឲ្យទៅធ្វើការនៅរោងចក្រឡអិដ្ឋ (អ-៤) ដែលស្ថិតនៅបឹងជើងឯកវិញ ដោយទុកតែប្រធានគ្រប់គ្រងប៉ុណ្ណោះ ។ នៅទីនោះមានបែងចែកជាច្រើនក្រុមដូចជាក្រុមកាប់ខស កាត់អិដ្ឋ ហាលអិដ្ឋ ដុតភ្លើងនិងបញ្ចូលអិដ្ឋក្នុងឡជាដើម ។ ចំរើន ស្ថិតនៅក្នុងក្រុមហាលអិដ្ឋដែលមានសមាជិកប្រហែលជា៣០នាក់ត្រូវធ្វើការចាប់ពីព្រឹកព្រលឹមរហូតដល់ម៉ោង៩យប់ ។ ទោះបីជាការងារនេះមិនមានគ្រោះថ្នាក់ក៏ដោយ ប៉ុន្តែ ចំរើន តែងតែព្រួយបារម្ភពីសុវត្ថិភាពរបស់គាត់ជានិច្ច ព្រោះគាត់តែងតែឃើញមនុស្សបាត់ពីកងជាញឹកញាប់ ។ ចំរើន នៅចាំបានថា ថ្ងៃមួយគាត់បានឃើញឡានឃ្លូបមួយគ្រឿងបានចុះមកដល់កន្លែងគាត់ រួចប្រាប់ថាឲ្យទៅប្រជុំដោយក្នុងនោះក៏មានប្រធានរបស់គាត់ផងដែរ ។ បន្ទាប់មក អ្នកទាំងនោះក៏បាត់ខ្លួនរហូត ។

នៅទីនេះ ចំរើន ធ្លាប់ឃើញមេដឹកនាំខ្មែរក្រហមនិងគណៈប្រតិភូចុះមកត្រួតពិនិត្យការងារចំនួនពីរដងដោយប្រាប់ថា «មួយសប្ដាហ៍ទៀតនឹងមានគណៈប្រតិភូចុះមកហើយ ដូច្នេះត្រូវរៀបចំនិងបោសកន្លែងឲ្យស្អាតមិនត្រូវឲ្យមានសំរាមទេ» ។ ដោយសារតែបានត្រៀមទុកមុនរួចហើយ ពេលគណៈប្រតិភូមកដល់ កម្មករទាំងអស់នាំគ្នាធ្វើការយ៉ាងមមាញឹកគ្មានហ៊ានឈប់សម្រាកទេ ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏គ្មាននរណាម្នាក់ហ៊ានខ្ជិលឬសុំច្បាប់ឈប់សម្រាកដែរព្រោះប្រធានកងឈ្មោះ រ៉េន តែងតែរំពុកប្រាប់កម្មករទាំងអស់ថា «ពួកមិត្តឯងបើមិនខំធ្វើការទេនឹងត្រូវចាប់ទៅដាក់នៅស-២១ហើយ» ។ ដូច្នេះ ក្រោយពីពាក្យទាំងនេះម្នាក់ៗខិតខំធ្វើការយ៉ាងយកចិត្តទុកដាក់តាមក្រុមរបស់ខ្លួនយ៉ាងសស្រាក់សស្រាំ ។

## រត់ទៅរស់នៅជំរំ

ពេលវៀតណាមចូលមករំដោះនៅឆ្នាំ១៩៧៩ ចំរើន និងកម្មករផ្សេងទៀតបាននាំគ្នាត្រឡប់មកលំនៅឋានរៀងៗខ្លួនវិញ ។ នៅតាមផ្លូវធ្វើដំណើរ ចំរើន មិនដែលបោះបង់គំនិតក្នុងការតាមរកក្រុមគ្រួសាររបស់គាត់ទេ ។ ប៉ុន្តែ ដោយសារតែគ្មានដឹងដំណឹងអ្វីទាំងអស់ ដូច្នេះ ចំរើន បានបន្តដំណើរតាមគ្នារបស់គាត់រហូតដល់ជំរំស្រះកែវដែលមានទីតាំងនៅក្នុងប្រទេសថៃ ។ នៅទីនោះ ចំរើន និងប្រជាជនរាប់រយគ្រួសារបានរស់នៅក្រោមជំនួយឧបត្ថម្ភរបស់ថៃនិងអង្គការសហប្រជាជាតិដោយមានផ្ដល់ជាស្បៀងអាហារដូចជាអង្ករ ត្រី ខ្លាញ់ សាច់ និង ត្រីខកំប៉ុងជាដើម ។ មួយរយៈក្រោយមក ជំរំស្រះកែវនេះត្រូវផ្លាស់មកជំរំមួយផ្សេងទៀតនៅព្រំដែនខ្មែរ-ថៃវិញ ប៉ុន្តែស្ថិតក្រោមការជួយឧបត្ថម្ភរបស់បរទេសដដែល ។

ដោយសារគិតថា ការរស់នៅមានមានលក្ខណៈស្ថិតស្ថេរបន្តិចហើយ នៅឆ្នាំ១៩៨៦ ចំរើន បានសម្រេចចិត្តរៀបការជាមួយបុរសម្នាក់ដែលជាប្រជាជនធម្មតា ។ នៅខែកុម្ភៈ ឆ្នាំ១៩៩០ ក្រោយពីមានការអនុញ្ញាតឲ្យប្រជាជនទាំងអស់ធ្វើមាតុភូមិនិវត្តន៍ ចំរើន ក៏ដាក់ពាក្យមកស្រុកកំណើតខាងប្ដីរបស់គាត់នៅស្រុកកោះអណ្ដែត ខេត្តតាកែវ ។ ទោះបីជាទីនោះឆ្ងាយពីស្រុកកំណើតខ្លួនក៏ដោយ ប៉ុន្តែ ចំរើន តែងតែមកសួរសុខទុក្ខឪពុកម្ដាយរបស់គាត់ជានិច្ច ។ នៅឆ្នាំ១៩៩៧ ដោយសារតែប្ដីរបស់គាត់ត្រូវផ្លាស់មកធ្វើការនៅខេត្តកោះកុង ចំរើន ក៏ផ្លាស់មករស់នៅខេត្តកោះកុងដែរ ។ នៅទីនេះ រដ្ឋាភិបាលបានចែកដីមួយកន្លែងឲ្យគាត់ដែលមានទទឹង ១៥ម៉ែត្រនិងបណ្ដោយ៤០ម៉ែត្រ ។

សព្វថ្ងៃនេះ ចំរើន រស់នៅយ៉ាងមានសុភមង្គលជាមួយក្រុមគ្រួសារ ហើយប្រកបរបរធ្វើស្រែចម្ការនិងធ្វើអំបោសលក់ដើម្បីចិញ្ចឹមកូនស្រីពីរនាក់ ។

**គាត លក្ខិណា**

# សាំង សារិនៈ ខ្មែរក្រហមសម្លាប់ឪពុកខ្ញុំ

*សាំង សារិន អាយុ៤១ឆ្នាំ មានស្រុកកំណើតនៅភូមិប្រឡាយមាស ឃុំប្រឡាយមាស ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។ ឪពុករបស់ សារិន ត្រូវខ្មែរក្រហមយកទៅសម្លាប់ដោយចោទថាជាមេ៥០ខ្នង ចំណែកម្តាយស្លាប់ដោយសារកើតជំងឺដុំពោះព្រោះគ្មានការព្យាបាលដិតដល់ ។ សារិន ជាក្មេងកំព្រាតាំងពីអាយុ ១១ឆ្នាំ ក្រោយមកគាត់បានមករស់នៅជាមួយយាយ ។*

*នៅឆ្នាំ១៩៧៤ សារិន បានចូលរៀនថ្នាក់ទី១២ (សង្គមចាស់) នៅសាលាបឋមសិក្សាដែលស្ថិតនៅក្នុងភូមិ ។ សារិន រៀនបានមួយរយៈក៏ឈប់ព្រោះនៅក្នុងភូមិចាប់ផ្តើមមានភាពច្របូកច្របល់ដោយសារមានយោធាខ្មែរក្រហមលួចចូលមកឃោសនាឲ្យប្រជាជនងើបឡើងប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែររបស់លោក លន់ នល់ វិញ ។ ពេលនោះ នៅផ្ទះរបស់ សារិន មានកាំភ្លើងជាច្រើនដើមព្រោះឪពុករបស់គាត់ធ្វើជាមេ៥០ខ្នង ហើយរៀងរាល់យប់ សារិន តែងតែឃើញមនុស្សជាច្រើនដែលរស់នៅក្នុងភូមិប្រឡាយមាសចូលមកយកកាំភ្លើងនៅផ្ទះរបស់គាត់ដើម្បីចេញទៅយាមការពារភូមិស្រុក ។*

*ក្រោយមក នៅខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានចូលមកគ្រប់គ្រងភូមិនេះទាំងស្រុង ហើយភ្លាមនោះយោធាខ្មែរក្រហមឃោសនាឲ្យប្រជាជនចេញពីផ្ទះរយៈពីរ-បីថ្ងៃសិន ទើបអនុញ្ញាតឲ្យត្រឡប់មកវិញ ដោយមិនបាច់យកសម្ភារៈប្រើប្រាស់ច្រើនទៅជាមួយទេ ។ បន្ទាប់មក ខ្មែរក្រហមបានជម្លៀសគ្រួសាររបស់ សារិន ដែលមានយាយ ឪពុក-ម្តាយ បងប្រុស និងបងជីដូនមួយឲ្យទៅភូមិពោធិ ឃុំពោធិ ដោយគ្រួសារគាត់យកទៅជាមួយតែ ចាន ឆ្នាំង អង្ករ និងខោអាវបន្តិចបន្តួចប៉ុណ្ណោះ ។ នៅទីនោះ មានប្រជាជនរាប់រយគ្រួសារមកពីភូមិតាដោក ភូមិថ្មី និងភូមិប្រឡាយមាសមករស់នៅប្រមូលផ្តុំគ្នា ។ បានមួយរយៈ អង្គការក៏បែងចែកអ្នកជម្លៀសទាំងនេះរួមទាំងគ្រួសាររបស់ សារិន ផងឲ្យទៅរស់នៅសហករណ៍ឈើអក់ ចំណែកយាយរបស់ សារិន ត្រូវអង្គការជ្រើសរើសឲ្យធ្វើការងារជាពេទ្យឆ្មបនៅក្នុងឃុំពោធិដដែល ។ នៅពេលនោះ ដោយសារមានការអាណិតអាសូរចៅ យាយរបស់ សារិន ក៏បានសុំអនុញ្ញាតពីអង្គការដើម្បីឲ្យ សារិន មករស់នៅជាមួយគាត់នៅមន្ទីរពេទ្យឃុំដែរ ។ រៀងរាល់ថ្ងៃ អង្គការបានចាត់តាំង*



ឲ្យ សារិន ជួយធ្វើការងារបិទស្រា សូនថ្នាំ បន្ទាប់មកយកទៅហាលថ្ងៃឲ្យស្ងួត ។

ឪពុកម្តាយរបស់ សារិន ដែលទើបទៅដល់សហករណ៍ឈើអក់ ឃុំពោធិ ត្រូវអង្គការបែងចែកឲ្យរស់នៅដោយឡែកពីអ្នកមូលដ្ឋានចាស់ ប៉ុន្តែរាល់កិច្ចការងារត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រជាជនមូលដ្ឋានចាស់ ។ ដំបូង អង្គការបានបែងចែកជាកងកុមារ កងនារី និងកងយុវជនឲ្យធ្វើការងារនៅក្នុងភូមិ ប៉ុន្តែនៅពេលធ្វើការងាររួច អង្គការបានអនុញ្ញាតឲ្យកងនីមួយៗវិលត្រឡប់មកជួបជុំជាមួយបងប្អូន និងឪពុកម្តាយ នៅផ្ទះវិញ ។ មួយរយៈក្រោយមក អង្គការចាប់ផ្តើមដាក់ផែនការបំបែកកុមារចេញពីឪពុកម្តាយ រួចហើយប្រមូលឲ្យទៅរស់នៅក្នុងមណ្ឌលកុមារ ចំណែកកុមារដែលមានមាឌធំអង្គការបានបញ្ចូលទៅក្នុងកងចល័តយុវជនឬកងចល័តនារី ។ ខណៈនោះ អង្គការបានចាត់តាំងឲ្យឪពុកម្តាយរបស់ សារិន ធ្វើការងារស្រែចម្ការនៅក្នុងភូមិ ប៉ុន្តែមិនយូរប៉ុន្មាន ម្តាយរបស់គាត់មានជំងឺដុំពោះត្រូវមកសម្រាកព្យាបាលនៅពេទ្យឃុំពោធិ ។ ក្រោយមក ដោយសារជំងឺម្តាយរបស់ សារិន កាន់តែមានសភាពធ្ងន់ធ្ងរហើយត្រូវការវះកាត់ គ្រូពេទ្យក៏បញ្ជូនបន្តទៅព្យាបាលនៅមន្ទីរពេទ្យស្រុកកំពង់លែង និងពេទ្យតំបន់ក្នុងទីរួមខេត្តកំពង់ឆ្នាំង ។ ចាប់តាំងពីពេលនោះមក សារិន លែងដឹងដំណឹងពីម្តាយរហូត ហើយក្រោយមកទើបបានទទួលព័ត៌មានពីបងប្អូនជីដូនមួយដែលធ្វើការនៅពេទ្យតំបន់ប្រាប់ថាម្តាយគាត់ស្លាប់ ។

បន្ទាប់ពីម្តាយស្លាប់ សារិន មិនបានវិលត្រឡប់មកជួបជុំឪពុក និងបងវិញទេ ព្រោះអង្គការបានបញ្ជូនកុមារដែលរស់នៅក្នុងពេទ្យទាំងអស់ឲ្យទៅរស់នៅការដ្ឋានផ្សេង ដោយទុកតែបុគ្គលិកពេទ្យឲ្យរស់នៅ និងធ្វើការងារប៉ុណ្ណោះ ។ សារិន ត្រូវទៅធ្វើស្រែប្រដេញទឹកនៅការដ្ឋានព្រៃចង្អៀង ស្ថិតនៅក្នុងឃុំដារ ។ នៅទីនោះ សារិន ត្រូវទៅដកសំណាប ស្ទូងស្រូវ និងឃ្វាលគោ-ក្របី នៅក្នុងកងកុមារដែលមានក្មេងៗសរុបទាំងអស់ប្រមាណជា៥០នាក់ ចំណែករបបអាហារគាត់បានទទួលត្រឹមតែបបរពីរបីវែកប៉ុណ្ណោះ ។ រយៈពេលកន្លះខែ ឬមួយខែម្តង អង្គការតែងតែផ្លាស់ សារិន ឲ្យទៅធ្វើការនៅតាមការដ្ឋាននានាក្នុងស្រុកកំពង់លែង ដោយមិនអនុញ្ញាតឲ្យមកជួបគ្រួសារឡើយ ។ ទោះជាមានការតឹងតែងដូច្នេះក៏ដោយ ក៏ឪពុករបស់ សារិន តែងតែលួចយកចំណិតដូងដែលអង្គការផ្តល់ឲ្យគាត់មកឲ្យ សារិន ហូបជានិច្ច ។

នៅថ្ងៃមួយ ពេលឪពុករបស់ សារិន កំពុងធ្វើការនៅក្នុងសហករណ៍ឈើអក់ ឈ្លបខ្មែរក្រហមបានទៅចាប់ចងគាត់ដោយចោទថាជាខ្មាំង (នៅក្នុងរបប លន់ នល់ គាត់ធ្វើជាមេ៥០ខ្ទង) រួចបណ្តើរយកទៅសម្លាប់នៅមន្ទីរឃុំឃាំងល្បាន ស្ថិតក្នុងស្រុក១៦ (ស្រុកកំពង់លែង) ។ បន្ទាប់ពីសម្លាប់ឪពុករបស់ សារិន រួចមក ឈ្លបខ្មែរក្រហមបានទៅប្រាប់ប្រធានកងឲ្យស្រាវជ្រាវ និងពិនិត្យក្នុងបញ្ជីដើម្បីរកឈ្មោះ សុគា (បងប្រុសរបស់ សារិន) ដែលកំពុងអង្គុយហូបបាយទៀត ។ ប៉ុន្តែដោយសារមុននោះបងប្រុសរបស់ សារិន បានប្តូរពីឈ្មោះ សុគា ទៅជា ឈ្មោះ ស៊ីន ទើបប្រធានកងរកមិនឃើញ ។ ក្រោយពីឈ្លបចេញទៅបាត់ សុគា ចាប់ផ្តើមភិតភ័យរហូតធ្លាក់ខ្លួនគ្រុនក្តៅហូបបាយពុំបាន ។ ឃើញដូច្នេះ បងប្អូនជីដូនមួយម្នាក់ដែលធ្វើការនៅក្នុងកងជាមួយបានណែនាំ សុគា កុំឲ្យមានការបារម្ភ និងខិតខំធ្វើការងារបន្ថែមទៀតដើម្បីកុំឲ្យអង្គការសង្ស័យ ។ ចំណែក សារិន ដែលមានវ័យក្មេង និងធ្វើការនៅសហករណ៍ផ្សេង អង្គការមិនបានតាមដានទេ ។

នៅពេលកងទ័ពវៀតណាមចូលមកដល់ខេត្តកំពង់ឆ្នាំង ឆ្នាំ១៩៧៩ សារិន បងប្រុស និងយាយត្រូវខ្មែរក្រហមកៀរឲ្យទៅរស់នៅក្នុងព្រៃ ។ ទោះបីដឹងថាមានការរំដោះហើយក៏ដោយ ក៏គ្រួសាររបស់ សារិន មិនហ៊ានត្រឡប់មកភូមិកំណើតវិញដែរ ព្រោះខ្លាចខ្មែរក្រហមបាញ់សម្លាប់ ។ ក្រោយមក ទើបគ្រួសារ សារិន សម្រេចចិត្តទៅរស់នៅក្រុងកំពង់ឆ្នាំងរហូតមកដល់សព្វថ្ងៃ ។

សារិន បានបញ្ជាក់ថា «ដោយសារខ្ញុំបានជួបប្រទះ ហើយជារឿងរ៉ាវរបស់ខ្ញុំផ្ទាល់ ដែលឪពុកម្តាយធ្លាប់ផ្តល់ភាពកក់ក្តៅឲ្យខ្ញុំ ហើយត្រូវខ្មែរក្រហមយកទៅសម្លាប់ បានធ្វើឲ្យខ្ញុំស្រក់ទឹកភ្នែកនៅពេលរំឭករឿងនេះឡើងវិញ ។ នៅពេលបង្រៀន សារិន តែងតែយករឿងរ៉ាវផ្ទាល់របស់គាត់ប្រាប់ទៅសិស្សក្នុងថ្នាក់ជានិច្ច ប៉ុន្តែក៏មានសិស្សមួយចំនួនមិនជឿដែរ ដូច្នេះគាត់សំណូមពរឲ្យមានការចងក្រងឯកសារខ្មែរក្រហមឲ្យបានសព្វគ្រប់ដើម្បីបង្ហាញប្រាប់សិស្សឲ្យជឿនិងយល់ដឹងពីរបបខ្មែរក្រហមឲ្យបានទូលំទូលាយ» ។ **សោម ប៊ុនថន**

# ការរំឭកពីការអប់រំអំពើប្រល័យពូជសាសន៍ : ពាក្យស្លោកប្រឆាំងនឹងអំពើប្រល័យពូជសាសន៍

ការរំឭកពីសោកនាដកម្មមួយដែលមានប្រជាជនរាប់លាននាក់ស្លាប់មិនចាំបាច់ត្រូវចំណាយថវិការាប់លាន រាប់ពាន់ ឬរាប់រយដុល្លារនោះទេ ។ ហើយការរំឭកនោះក៏មិនចាំបាច់ត្រូវតែធ្វើជាសារមន្ទីរ វិមានដែលមានការទាក់ទាញ ឬជារូបសំណាកតំណាងអ្វីមួយនោះឡើយ ។ ជាងនេះទៅទៀត ទីតាំងនៃកន្លែងរំឭកមិនចាំបាច់ត្រូវតែនៅជាកន្លែងដែលមានទំហំធំទូលាយដែលមានភាពទាក់ទាញ ឬនៅកន្លែងដែលទើបតែបង្កើតឡើងថ្មីនោះទេ ។ ការរំឭកដ៏អស្ចារ្យមួយអាចជាទម្រង់នៃពាក្យស្លោកសាមញ្ញមួយដែលព្យួរនៅក្រៅសាលារៀន ។ នៅពេលដែលបដាបែបនោះត្រូវបានព្យួរនៅតាមវិទ្យាល័យនៅទូទាំងប្រទេសដែលធ្វើឲ្យសិស្សានុសិស្ស ឪពុកម្តាយរបស់អ្នកទាំងនោះ សមាជិកសហគមន៍ និងអ្នកធ្លាប់ឆ្លងកាត់អាចអានសារនោះ ឥទ្ធិពលជារួមនៃបដាទាំងនោះអាចនឹងមានភាពខ្លាំងក្លាជាងមុន ហើយអាចជួយធ្វើការផ្សព្វផ្សាយច្រើនជាងមុន គឺស្ទើរតែច្រើនជាងកន្លែងរំឭកតាមបែបប្រពៃណីផង ។

នេះជាក្តីសង្ឃឹមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលទទួលបានការអនុម័តនៅថ្ងៃទី១៧ ខែមិថុនា ពីក្រសួងអប់រំ យុវជន និងកីឡាឲ្យព្យួរពាក្យស្លោកប្រឆាំងនឹងអំពើប្រល័យពូជសាសន៍នៅតាមវិទ្យាល័យទាំង១៧០០ នៅក្នុងប្រទេសកម្ពុជា ។ បដាទាំងនេះរួមមានពាក្យស្លោកពីរដែលអាចរំឭកនូវសោកនាដកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យនិងជំរុញឲ្យមានការផ្សះផ្សានៅក្រោយអំពើប្រល័យពូជសាសន៍ ។ ពាក្យស្លោកទាំងនេះមានដូចតទៅ ៖ **១) «រៀបរាប់អំពីបទពិសោធន៍នៅអំឡុងរបបខ្មែរក្រហមគឺជាការជំរុញឲ្យមានការផ្សះផ្សានិងអប់រំក្មេងៗអំពីការអភ័យទោសនិងការអធ្យាស្រ័យគ្នា» ។ ២) «ការសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យគឺដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍» ។** ថ្លៃចំណាយទៅលើបដាត្រូវបានប៉ាន់ប្រមាណថាមានតម្លៃប្រហែល ៤០ដុល្លារអាមេរិក ។ បដាមួយដែលមានពាក្យស្លោកទាំងពីរនេះនឹងត្រូវយកទៅព្យួរនៅតាមសាលារៀនដែលទីតាំងសម្រាប់ព្យួរនឹងតម្រូវទៅតាមសាលា ។ ទីតាំងដែលនឹងត្រូវព្យួររួមមាន នៅខាងមុខជញ្ជាំងនៃអគារសាលារៀន នៅជិតដងទង់ជាតិនៅក្នុងសាលា ឬ នៅពីមុខទីធ្លាសាលារៀនឬសួនច្បារ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថាពាក្យស្លោកទាំងពីរនេះនឹងដើរតួនាទីជា «ពាក្យរំឭកពីការអប់រំអំពើប្រល័យពូជសាសន៍» ដែលជាសោកនាដកម្មរបស់កម្ពុជាដែលបានយកជីវិតប្រជាជនជិតពីរលាននាក់ពីឆ្នាំ១៩៧៥-១៩៧៩ ។ ពាក្យស្លោកទាំងនេះនឹងចាប់ផ្តើមចូលរួមជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងគម្រោងអប់រំពីអំពើប្រល័យពូជសាសន៍នៅទូទាំងប្រទេសដែលមានច្រើនដំណាក់របស់ក្រសួង និងដែលបានចាប់ផ្តើមនៅឆ្នាំ២០០៥ ។ កន្លងមកនេះ គម្រោងបានបោះពុម្ពសៀវភៅមេរៀនដំបូងបង្អស់ស្តីពីរបបកម្ពុជាប្រជាធិបតេយ្យប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និពន្ធដោយ ឌី ខាំបូលី សៀវភៅណែនាំគ្រូបង្រៀននិងសៀវភៅកិច្ចការសិស្ស ។ គម្រោងនេះក៏បានបង្កើតជាវគ្គបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់ជាតិដែលដឹកនាំដោយអ្នកជំនាញនិងបញ្ញវន្តកម្ពុជា និងអន្តរជាតិដែលល្បីឈ្មោះ ព្រមទាំងអនុវត្តវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្តនិងថ្នាក់មូលដ្ឋាននៅទូទាំងប្រទេស ។ វគ្គបណ្តុះបណ្តាលនេះត្រូវបានប្រព្រឹត្តឡើងស្ទើរតែនៅគ្រប់២៤ខេត្តក្រុងនៅក្នុងប្រទេសកម្ពុជា ហើយខេត្តបាត់ដំបង កំពង់ចាម កំពង់ស្ពឺ កណ្តាល និងភ្នំពេញកំពុងដំណើរការវគ្គបណ្តុះបណ្តាលនេះ ។ នៅរដូវក្តៅនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចាប់ផ្តើមជំហានបន្ទាប់នៃគម្រោង គឺធ្វើការវាយតម្លៃទៅលើគ្រូបង្រៀននៅវិទ្យាល័យនៅពេលដែលអ្នកទាំងនោះបង្រៀនសិស្សនៅក្នុងថ្នាក់រៀន ។

ទោះជាពាក្យស្លោកទាំងពីរនេះហាក់ដូចជាមិនមានសារសំខាន់បើប្រៀបធៀបទៅនឹងសៀវភៅមេរៀនដំបូងបង្អស់ស្តីពីរបបកម្ពុជាប្រជាធិបតេយ្យឬវគ្គបណ្តុះបណ្តាលគ្រូប្រវត្តិសាស្ត្រថ្នាក់ជាតិដោយមានការចូលរួមពីអ្នកជំនាញដែលសិក្សាផ្នែកអំពើ

ប្រល័យពូជសាសន៍ដ៏អសោចជាច្រើនកន្លែង ប៉ុន្តែតាមការពិតពាក្យស្លោកទាំងពីរនេះមានសារសំខាន់និងមានអត្ថន័យសម្រាប់ការទប់ស្កាត់និងកសាងប្រទេសក្រោយជម្លោះដូចជាគំនិតផ្តួចផ្តើមផ្សេងទៀតដែរ ។ ពាក្យស្លោកនេះមានសារសំខាន់ និងស៊ីជម្រៅ ។

ជាទូទៅ សាលារៀននិងការអប់រំត្រូវបានហាមឃាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចជាពាក្យស្លោករបស់ខ្មែរក្រហមដែលថា «មិនមានសញ្ញាបត្រ មានតែសញ្ញាឃើញ» និង «ចបជាដងស្វាបប៉ាកការរបស់អ្នក ហើយវាលស្រែគឺជាក្រដាសសរសេរ» ។ នៅក្នុងរបបនោះ ការអប់រំនៅប្រទេសកម្ពុជាត្រូវបានបន្ទាក់ដំណើរការនិងជំនួសដោយពាក្យឃោសនារបស់ខ្មែរក្រហមដែលកើតចេញពីគំនិតរួមបញ្ចូលគ្នារបស់លទ្ធិម៉ាស៊ីស លទ្ធិកុម្មុយនីស្តចិននិងគំនិតរបស់មេដឹកនាំផ្ទាល់ទៅលើពូជសាសន៍និងជាតិ ។ ដំណើរការអប់រំមិនល្អនេះនៅតែបន្តនៅកម្ពុជាសម័យបច្ចុប្បន្ននិងធ្វើឲ្យស្ថានភាពក្លាយជាអាក្រក់បំផុតនៅពេលដែលមានការអប់រំអំពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ពាក្យស្លោកដ៏ខ្លីប៉ុន្តែមានសារសំខាន់ទាំងពីរនេះតំណាងពីភាពផ្ទុយគ្នានៃការបន្ទាក់ការអប់រំដែលធ្វើឡើងដោយខ្មែរក្រហម ។

ពាក្យស្លោកទាំងពីរនេះមានសារសំខាន់ចំពោះករណីនេះ ។ សារដែលនៅក្នុងពាក្យស្លោកនេះគឺផ្ទុយស្រឡះពីអ្វីដែលខ្មែរក្រហមនិយាយ ។ ពាក្យស្លោកនៃកំហឹង ភាពភ័យខ្លាច ភាពតក់ស្លុត និងអំពើហិង្សារបស់ខ្មែរក្រហមត្រូវបានផ្សព្វផ្សាយតាមប្រដាប់បំពងសំឡេង ហើយពាក្យស្លោកទាំងអស់នោះត្រូវបានយកមកនិយាយម្តងទៀតនៅពេលប្រជុំតាមភូមិនៅពេលយប់ ។ លើសពីនេះទៅទៀត ទោះបីជាសារនៃកំហឹងនិងអំពើហិង្សាត្រូវបានបង្កើតឡើងនៅក្នុងរយៈពេលខ្លីក៏ដោយ ក៏អត្ថន័យរបស់វានៅតែដក់ជាប់នៅក្នុងចិត្តរបស់ប្រជាជនកម្ពុជា ជនដៃដល់ និងជនរងគ្រោះដូចគ្នា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ពាក្យស្លោកប្រឆាំងនឹងអំពើប្រល័យពូជសាសន៍នេះនឹងធ្វើជាសារដែលជំរុញឲ្យមានការអធ្យាស្រ័យគ្នា ការអភ័យទោស ការអប់រំ និង ការផ្សះផ្សា ។

ជាទីបញ្ចប់ ពាក្យស្លោកទាំងនេះនឹងរំឭកយើងទាំងអស់គ្នាអំពីទំនាក់ទំនងដ៏ស៊ីជម្រៅរវាងការអប់រំ ការចងចាំនិងប្រវត្តិសាស្ត្រដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ ។ ការចងចាំអំពីសោកនាដកម្មរបស់កម្ពុជាមិនត្រឹមតែត្រូវស្ថិតនៅក្នុងការចងចាំរបស់អ្នកនៅរស់ប៉ុណ្ណោះទេ វាត្រូវតែស្ថិតនៅក្នុងការចងចាំរបស់កូនចៅជំនាន់ក្រោយផងដែរ ។ អាស្រ័យហេតុនេះ ក្មេងជំនាន់ក្រោយរបស់កម្ពុជាចាំបាច់ត្រូវតែសិក្សាពីរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងសាលារៀន ។ ខណៈពេលដែលទាំងអ្នកដែលនៅរស់និងសៀវភៅមេរៀនមានផ្ទុកសេចក្តីលម្អិតពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងជួយជំរុញឲ្យមានការចងចាំនូវអ្វីដែលបានកើតឡើង ពាក្យស្លោកទាំងពីរដែលនឹងត្រូវព្យួរនៅតាមសាលារៀននឹងជួយរំឭកនូវការចងចាំអំពីសោកនាដកម្ម ។ ពាក្យស្លោកដែលត្រូវបានព្យួរនៅកន្លែងធម្មតា ប៉ុន្តែជាកន្លែងសាធារណៈដូចជាវិទ្យាល័យដែលក្មេងជំនាន់ក្រោយរបស់កម្ពុជានិងក្មេងជំនាន់ក្រោយរបស់អ្នកនៅរស់អាចមើលឃើញទាំងនេះនឹងផ្តល់ជាការរំឭកដែលអាចមើលឃើញដ៏ច្បាស់មួយថា ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យត្រូវតែយកមកបង្រៀនដើម្បីជាការផ្សះផ្សានិងការចងចាំ ។ ជាងនេះទៅទៀត ពាក្យស្លោកទាំងនេះនឹងតំណាងឲ្យការផ្លាស់ប្តូរដ៏សំខាន់មួយនៅកម្ពុជាគឺផ្លាស់ប្តូរពីការមិនអើពើចំពោះការអប់រំអំពីប្រវត្តិសស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

**កែវ ជាស៊ីល**

## ឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមគេហទំព័រ

ដើម្បីឲ្យសាធារណជនទូទៅមានលទ្ធភាពក្នុងការតាមដានមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា គេហទំព័រ *www.cambodiatribunal.org* ត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងសាលាច្បាប់នៃសាកលវិទ្យាល័យណតវេស្ទើន សហរដ្ឋអាមេរិក និងក្រោមសហប្រត្តិបត្តិការជាមួយ *Illinois Holocaust Museum and Educational Center* ។ មុននិងផ្សព្វផ្សាយគេហទំព័រនេះ ត្រូវបានត្រួតពិនិត្យដោយសាស្ត្រាចារ្យច្បាប់ *David Scheffer* អតីតឯកអគ្គរដ្ឋទូតគោចរណ៍របស់សហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មសង្គ្រាមកាលពីជំនាន់រដ្ឋការប្រធានាធិបតី ប៊ីល គ្លីនតុន និងលោកឆាំង យុ នាយក មជ្ឈមណ្ឌលឯកសារកម្ពុជា ។

# អ្នកជិតខាងរបស់ឃាតករមិនមានភាពអាម៉ាស់ទេ

*«ប្រសិនបើ ប៉ុល ពត នៅរស់ ខ្ញុំសូមឲ្យតុលាការកាត់ទោសគាត់ និង កម្មាភិបាលថ្នាក់ក្រោមរបស់គាត់»*

*នេះជាសម្តីរបស់ ម៉ារីណា ជាអ្នកជិតខាងម្នាក់របស់ ប៉ុល ពត នៅភូមិព្រែកស្បូវ ។*

ម៉ារីណា ជាស្ត្រីចំណាស់ម្នាក់ដែលរស់នៅក្នុងភូមិព្រែកស្បូវ មិនដែលបោះបង់គោលបំណងរបស់ខ្លួនក្នុងការសងសឹកជាមួយនឹង សាឡុត ស ដែលស្គាល់ថាជា ប៉ុល ពតទេ ទោះបីជាគាត់បានប្រកាន់ខ្ជាប់នូវពុទ្ធសាសនាដែលបង្រៀនពុទ្ធសាសនិកឲ្យចេះអត់ឱនទោស និងបំភ្លេចចោលអតីតកាលក៏ដោយ ។ ម៉ារីណា មានអាយុ៧៩ឆ្នាំ កើតនៅក្នុងភូមិព្រែកស្បូវ ។ ទោះបីជាគាត់មានជំងឺឈឺក្បាលជង្គង់រ៉ាំរ៉ៃក៏ដោយ ក៏គាត់នៅតែតស៊ូធ្វើនំអន្សមឲ្យកូនស្រីរបស់គាត់យកទៅលក់នៅក្នុងតូបតូចមួយនៅមុខផ្ទះគាត់ក្នុងភូមិព្រែកស្បូវដែរ ។ ម៉ារីណា រស់នៅក្នុងភូមិជាមួយនឹង សាឡុត ស ដែលផ្ទះរបស់គាត់មិនឆ្ងាយពីផ្ទះ សាឡុត ស ប៉ុន្មានទេ ។ ដោយសារតែពេលនោះ ម៉ារីណា មានអាយុក្មេងជាង សាឡុត ស ដូច្នេះ ម៉ារីណា មិនដែលមានភាពស្និទ្ធស្នាលជាមួយនឹង សាឡុត ស ឡើយ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏គាត់មានភាពស្និទ្ធស្នាលយ៉ាងខ្លាំងជាមួយប្អូនប្រុសរបស់ សាឡុត ស ឈ្មោះ សាឡុត ញឹប ដែលមានអាយុច្រើនជាងគាត់ប្រាំឆ្នាំដែរ ។


ប៉ុល ពត

ម៉ារីណា បានស្គាល់ឪពុកម្តាយរបស់ សាឡុត ស យ៉ាងច្បាស់នៅពេលគាត់នៅក្មេង ។ ម៉ារីណា បានរៀបរាប់ថា «យើងជាអ្នកជិតខាងនឹងគ្នា ហើយយើងធ្វើស្រែចម្ការជាមួយគ្នា យើងប្រារព្ធពិធីបុណ្យក្នុងភូមិជាមួយគ្នា ថែមទាំងជូនម្ហូបអាហារឲ្យគ្នាទៅវិញទៅមកនៅក្នុងពេលហូបបាយម្តងៗ» ។ ម៉ារីណា រំឭកថា សាឡុត ស ជាកូនប្រុសរបស់ ប៉ែន សាឡុត និង សុក ណែម ។ សាឡុត និង ណែម គឺជាគ្រួសារកសិករមានកេរ្តិ៍ឈ្មោះមួយនៅក្នុងភូមិ ។ ដោយសារតែ សាឡុត និង ណែម មានកូនស្រីម្នាក់ជាស្នំរបស់ព្រះបាទ មុនីវង្ស ដូច្នេះគាត់ទាំងពីរនាក់ទទួលបានកិត្តិយស និងការគោរពពីអ្នកភូមិយ៉ាងខ្លាំង ។ វត្តមានរបស់ប្អូនស្រីគាត់នៅក្នុងព្រះរាជវាំងទំនងជាផ្តល់ឱកាសដល់ សាឡុត ស បន្តការសិក្សានៅប្រទេសកម្ពុជា និងបន្ទាប់មកនៅប្រទេសបារាំង ។

គីន ឈឿន អាយុ៦៣ឆ្នាំ ដែលបានប្តូរទៅរស់នៅភូមិព្រែកស្បូវនៅដើមទសវត្សរ៍៧០ ហើយបច្ចុប្បន្នជាប្រធានភូមិព្រែកស្បូវបាននិយាយថា សាឡុត ស មិនសូវមានទំនាក់ទំនងជាមួយអ្នកភូមិទេ ។ អ្នកគ្រប់គ្នាបានដឹងថា សាឡុត ស កើតនៅទីនេះ ប៉ុន្តែ សាឡុត ស បានចាកចេញពីភូមិតាំងពីនៅក្មេង ។ ម៉ារីណា ក៏បានអះអាងដូច ឈឿន ដែរ ដោយគាត់បាននិយាយថា សាឡុត ស ចូលចិត្តរៀន ហើយគាត់បានមកលេងផ្ទះម្តងម្កាល ដែលក្នុងអំឡុងពេលនោះគាត់មិនដែលទាក់ទងជាមួយអ្នកដទៃទៀតឡើយ ។ សាឡុត ស បានមកលេងផ្ទះម្តងម្កាលនៅពេលគាត់ជាសិស្សនៅខេត្តកំពង់ចាមនិងក្រុងភ្នំពេញ ។ សាឡុត ស ផ្តាច់ខ្លួនពីអ្នកភូមិព្រែកស្បូវ បន្ទាប់ពីគាត់បានមកបន្តការសិក្សានៅទីក្រុង

ភ្នំពេញ ហើយចាកចេញពីភូមិជារៀងរហូតបន្ទាប់ពីគាត់បានសិក្សានៅប្រទេសបារាំង ។

ម៉ារីណា មិនបានដឹងច្រើនពី សាឡុត ស ទេ ក៏ដូចជាអ្នកភូមិផ្សេងទៀតដែលរស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិព្រែកស្បូវដែរ ។ សូម្បីតែ សាឡុត ញឹប ដែលជាប្អូនប្រុសរបស់ សាឡុត ស ក៏មិនបានដឹងថាមានអ្វីកើតឡើងចំពោះបងប្រុសរបស់គាត់ដែរ បន្ទាប់ពី សាឡុត ស ទៅបន្តការសិក្សានៅប្រទេសបារាំង ។ វាសនារបស់ សាឡុត ស មិនត្រូវបានគេដឹងឡើយ ។ នៅពេលដែលប្រទេសស្ថិតនៅក្នុងដំណាក់កាលអត់ឃ្លាននិងសម្លាប់ គ្មានបងប្អូនណាម្នាក់របស់ សាឡុត ស បានដឹងថាវាជាអំពើរបស់បងប្រុសរបស់ពួកគេទេ ។ ក្រោយមក នៅពេលដែល សាឡុត សេង ដែលជាបងប្រុសរបស់ សាឡុត ស បានរកឃើញការពិត គាត់ខឹង សាឡុត ស ចំពោះការស្លាប់របស់កូនប្រុសគាត់ឈ្មោះ គង់ កាលពីខែមេសា ឆ្នាំ១៩៧៥ នៅសម័យ ប៉ុល ពត ។

រំពឹកដល់ សាឡុត ស, ម៉ារីណា បានចាប់ផ្តើមរៀបរាប់ពីជីវិតស្ថិតក្រោមគោលនយោបាយដ៏ឃោរឃៅរបស់អង្គការខ្មែរក្រហម ។ ទោះបីជា សាឡុត ស មិនដែលមកលេងភូមិនេះក៏ដោយ ក៏ ម៉ារីណា មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបងប្អូនរបស់ សាឡុត ស ដែរ ជាពិសេស គឺ សាឡុត សេង និង សាឡុត ញឹប ។ ក្នុងនាមជាអ្នកជិតខាងម្នាក់ ម៉ារីណា បានលេង និងនៅជាមួយ សាឡុត សេង និង សាឡុត ញឹប រហូតដល់ឆ្នាំ១៩៧២-៧៣ នៅពេលដែលអ្នកភូមិព្រែកស្បូវត្រូវបានជម្លៀសដោយរដ្ឋាភិបាលសាធារណរដ្ឋខ្មែរនិងផ្លាស់ទីលំនៅទៅកន្លែងផ្សេងៗក្នុងខេត្តកំពង់ធំ ។ ម៉ារីណា បានបែកពីមិត្តរបស់គាត់ សាឡុត សេង និង សាឡុត ញឹប ពីព្រោះគាត់ត្រូវទៅជាមួយគ្រួសាររបស់គាត់ដើម្បីរស់នៅទីរួមខេត្តកំពង់ធំ ក្នុងអំឡុងសង្គ្រាមស៊ីវិលនេះ ។

បន្ទាប់ពីរដ្ឋាភិបាលសាធារណរដ្ឋខ្មែរត្រូវបានវាយឲ្យបរាជ័យដោយក្រុមកុម្មុយនីសខ្មែរនៅខែមេសា ឆ្នាំ១៩៧៥ ម៉ារីណា ត្រូវបានជម្លៀសឲ្យទៅរស់នៅឃុំសាលាវិស័យ ។ ចំណែកមិត្តចាស់របស់គាត់ សាឡុត សេង និង សាឡុត ញឹប ដែលគាត់មិនបានជួបអស់រយៈពេលពីរឆ្នាំហើយបានមករស់នៅឃុំព្រែកតាហ៊ូ ប្រហែលជា៣០គីឡូម៉ែត្រពីគ្នា ហើយអ្នកទាំងបីនៅមិនបានជួបគ្នាទេ ។ ដូចជាប្រជាជនថ្មីដទៃទៀតដែរ ម៉ារីណា បានតស៊ូនិងខិតខំធ្វើការយ៉ាងខ្លាំងដើម្បីជីវិតរស់នៅ ហើយកូនប្រុសពីរនាក់និងចៅរបស់គាត់ម្នាក់មិនបានរស់នៅជាមួយនឹងគាត់ទេចាប់តាំងពីពេលនោះមក ។

បទពិសោធន៍របស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានធ្វើឲ្យ ម៉ារីណា ស្អប់ សាឡុត ស ជាខ្លាំង ។ ម៉ារីណា បានបន្ទោសអ្នកខាងរបស់គាត់ពីការស្លាប់របស់កូនប្រុសគាត់ដែលម្នាក់ត្រូវបានបញ្ជូនឲ្យទៅសមរភូមិ ហើយបានបាត់ខ្លួនរហូតមកដល់ឥឡូវ ។ នៅពេលសួរគាត់ថាតើគាត់ខឹង សាឡុត ស ដែរឬទេ ម៉ារីណា បានឆ្លើយថា «ខ្ញុំមិនអាចរកពាក្យមកនិយាយថាខ្ញុំស្អប់គាត់ប៉ុនណាទេ» ។ ម៉ារីណា បានបន្ថែមថា កំហឹងដែលចង់សងសឹកនឹង សាឡុត ស គឺខ្លាំងជាងកាលពី៣០ឆ្នាំមុន បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំទៅ ។

ក្នុងនាមជាអ្នករាប់អានជាមួយ សាឡុត ស, ម៉ារីណា ខកចិត្តយ៉ាងខ្លាំងដែល សាឡុត ស បាននាំប្រទេសជាតិខ្លួនទៅរកភាពដ៏ងងឹតមួយ ។ ម៉ារីណា បាននិយាយថា «ឪពុកម្តាយរបស់ សាឡុត ស គឺជាមនុស្សល្អ ស្លូតបូតនិងជាអ្នកធូរធានៅក្នុងភូមិ ហើយ សាឡុត ស ជាមនុស្សមានការអប់រំ ។ គាត់មិនគួរណាធ្វើអំពើឃោរឃៅបែបនេះទៅលើប្រទេសរបស់ខ្លួនឡើយ» ។

ការអត់ឱនឲ្យ ប៉ុល ពត គឺមិនអាចទៅរួចទេសម្រាប់ ម៉ារីណា ។ ទោះបីជាដឹងថានេះការប្រឆាំងទៅនឹងព្រះពុទ្ធសាសនាក៏ដោយ ក៏គាត់ជឿជាក់ថា ប៉ុល ពត គួរតែត្រូវតែទទួលការកាត់ទោសពីព្រោះគាត់បានធ្វើឲ្យមនុស្សជាច្រើនទទួលរងនូវការឈឺចាប់ និងកម្មាភិបាលថ្នាក់ក្រោមដែលធ្វើបាបប្រជាជននៅតាមសហករណ៍ក៏គួរតែយកទៅកាត់ទោសផងដែរ ។

ដូចជាអ្នកភូមិផ្សេងទៀតដែរ ម៉ារីណា មិនមានភាពអាម៉ាស់ទេដែលគាត់បានរស់នៅក្នុងភូមិដែលឃាតករបានកើតនោះ ។ អ្នកភូមិមួយចំនួនចាត់ទុកភូមិនេះជាកន្លែងដែល សាឡុត ស បានកើត ប៉ុន្តែមិនមែនជាកន្លែង ដែល សាឡុត ស ស្រឡាញ់ទេ ។ សាឡុត ស បានចាកចេញពីភូមិព្រែកស្បូវនៅមុនពេលដែលប្រជាជនភាគច្រើននៅក្នុងភូមិនេះបានកើត ។

**ញាណ សុជាតិ**

# នៅតែល្អដូចជាមួយកូនរបស់ខ្លួនដែរ

ប្រវត្តិសាស្ត្រដ៏ជូរចត់របស់ប្រទេសកម្ពុជាដែលបានកើតឡើងក្នុងអំឡុងទសវត្សរ៍៧០ បានពង្រាត់ឪពុករបស់ លោក ហង្ស សុខសុភារ៉ា ឲ្យចាកឆ្ងាយពីរូបគាត់ជារៀងរហូត ។ សុភារ៉ា មិនដែលបានឃើញមុខឪពុករបស់គាត់ដោយផ្ទាល់ភ្នែកនោះទេ ក្រៅតែរូបថតកាតសិស្សមួយសន្លឹកប៉ុណ្ណោះ ដែលម្តាយគាត់បានលាក់ទុកនៅក្នុងបង្វេចខោអាវ ។

នៅថ្ងៃមួយនាពាក់កណ្តាលឆ្នាំ១៩៧៧ ឪពុករបស់ សុភារ៉ា ដែលជាអតីតគ្រូបង្រៀនមួយរូបត្រូវបានអ្នកជិតខាងរបស់គាត់ចាប់យកទៅដែលនៅពេលនោះកូនប្រុសរបស់គាត់នៅក្មេងទើបតែរៀននិយាយ និងមិនស្គាល់ពីការស្រឡាញ់នៅឡើយទេ ។ ពីរឆ្នាំមុន នៅខែកុម្ភៈ ឆ្នាំ១៩៧៥ កូនប្រុសរបស់គាត់បានកើតក្នុងផ្ទះមួយនៅជិតផ្សារស៊ីឡឹបក្នុងទីក្រុងភ្នំពេញ គឺបីខែមុនពេលដែលយោធាខ្មែរក្រហមស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅមួយក្រុមបានចូលមកកាន់កាប់ទីក្រុង ។ នៅដើមខែមេសា នៅពេលដែលស្ថានភាពនៅក្នុងទីក្រុងកាន់តែដុនដាបទៅៗ ដោយសារតែការវាយប្រហារពីសំណាក់ទ័ពខ្មែរក្រហមពីគ្រប់ច្រកល្ហក គ្រួសាររបស់ សុភារ៉ា ដែលមានសមាជិកបួននាក់ រួមទាំង សុភារ៉ា ដែលទើបតែមានអាយុពីរខែផង បាននាំគ្នាភៀសខ្លួនទៅឃុំតាំងក្រសាំង ខេត្តកំពង់ធំ ដើម្បីសុវត្ថិភាព ។ ៣៥ឆ្នាំក្រោយមក នៅក្នុងខ្ទមដ៏តូចមួយនៃបរិវេណវិទ្យាល័យមួយ លោក ហង្ស សុខសុភារ៉ា បានប្រាប់ថា ឃុំតាំងក្រសាំងគឺជាស្រុកកំណើតរបស់ម្តាយគាត់ ។ វាជាការពិត ហើយឃុំតាំងក្រសាំងនេះត្រូវបានខ្មែរក្រហមកាន់កាប់តាំងពីប៉ុន្មានឆ្នាំមុនការមកដល់របស់គ្រួសារគាត់ទៅទៀត ។

សុភារ៉ា បានដឹងអំពីរបបខ្មែរក្រហមតាមរយៈម្តាយរបស់គាត់ ។ ចំណែកឯបងស្រីរបស់គាត់ដែលមានអាយុច្រើនជាងគាត់បីឆ្នាំ បច្ចុប្បន្នរស់នៅសហរដ្ឋអាមេរិក បានដឹងតិចតួចណាស់អំពីរបបខ្មែរក្រហម និងអ្វីដែលកើតឡើងចំពោះឪពុកគាត់ ។

ទោះបីជាយ៉ាងណាក៏ដោយ អតីតគ្រូបង្រៀនម្នាក់ដែលបានស្លាប់បាត់បង់ជីវិតកាលពីឆ្នាំ១៩៧៧ បានជះឥទ្ធិពលដល់កូនប្រុសរបស់គាត់ដែលបច្ចុប្បន្ននេះបានក្លាយជាគ្រូបង្រៀនផ្នែកប្រវត្តិវិទ្យាម្នាក់នៅវិទ្យាល័យមួយជិតទីរួមខេត្តកំពង់ធំ ។ សុភារ៉ា និយាយដោយមុតមាំថា «កាលពីមុនសម័យខ្មែរក្រហម ឪពុករបស់ខ្ញុំគឺជាអតីតគ្រូប្រវត្តិវិទ្យានៅវិទ្យាល័យព្រៃវែង ។ គាត់ជាអ្នកដែលបានជួយជំរុញឲ្យខ្ញុំរៀនមុខវិជ្ជាប្រវត្តិវិទ្យា ហើយឲ្យខ្ញុំក្លាយទៅជាគ្រូប្រវត្តិវិទ្យាដែរ» ។ បច្ចុប្បន្ន សុភារ៉ា កំពុងបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅកូនសិស្សរបស់គាត់ជាក្មេងជំនាន់ក្រោយដែលជារបបមួយដែលឪពុករបស់គាត់បានឆ្លងកាត់ ។


ហង្ស សុខសុភារ៉ា

ម្តាយរបស់ សុភារ៉ា បានរំឭកប្រាប់គាត់ថា មុនរបបខ្មែរក្រហម គ្រួសាររបស់គាត់ជាគ្រួសារធូរធាមួយមានឪពុកគាត់ជាមេគ្រួសារនិងមិនដែលធ្លាប់បានធ្វើស្រែចម្ការនោះទេ ។ ដូច្នេះហើយ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅខែមេសា ឆ្នាំ១៩៧៥ ឪពុករបស់គាត់មិនចេះភ្ជួរស្ទូងស្រូវ ឬក៏បោកកណ្តាប់ទេ ។ ចំណែកម្តាយរបស់គាត់តែងតែជួយឪពុកគាត់ជានិច្ចដើម្បីចៀសវាងការស្តីបន្ទោស ។ រហូតដល់ឆ្នាំ១៩៧៦ ខ្មែរក្រហមបានបញ្ជាឲ្យឪពុកគាត់ទៅឃ្វាលក្របី ប៉ុន្តែគាត់បាន

ធ្វើឲ្យបាត់ក្របីមួយក្បាល ។ គ្រួសាររបស់គាត់ទាំងមូលមានការភ័យខ្លាចជាខ្លាំង រហូតទាល់តែពីរ-បីថ្ងៃក្រោយមកទើបរកឃើញក្របីដែលបាត់នោះ ។ ក្រោយមក ឪពុករបស់គាត់ត្រូវបានចាត់តាំងឲ្យទៅវេញខ្សែគោ ដែលវាជាការងារលំបាកមួយសម្រាប់គាត់ ។

ម្ដាយរបស់ សុភារ៉ា បាននិយាយប្រាប់ថា ឪពុករបស់សុភារ៉ា បានប្រព្រឹត្តកំហុសជាញឹកញាប់ ហើយគាត់មិនដែលសម្រេចការងារទាន់ពេលវេលាទេ ។ ម្យ៉ាងវិញទៀត ដោយសារប្រវត្តិរបស់គាត់ជាអតីតគ្រូបង្រៀនបានធ្វើឲ្យជីវិតរបស់គាត់ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ជានិច្ច ។ ចំណែក សុភារ៉ា វិញត្រូវបានបញ្ចូលនៅក្នុងក្រុមយាយៗ នៅពេលដែលឪពុកម្ដាយគាត់ទៅធ្វើការនៅវាលស្រែ ។ យោងតាមសម្ដីដែលម្ដាយ សុភារ៉ា បានប្រាប់គាត់យប់មុនពេលដែលខ្មែរក្រហមមកចាប់ឪពុកគាត់យកទៅ គាត់យំយ៉ាងខ្លាំង ។ យាយម្នាក់នៅក្នុងកងយាយៗ បានបីសុភារ៉ា យកមកផ្ទះវិញ ។ នៅល្ងាចថ្ងៃបន្ទាប់ ឪពុករបស់គាត់ត្រូវបានចាប់ខ្លួន ។ ម្ដាយរបស់ សុភារ៉ា បានរំឭកថា «ពេលនោះគឺចំពេលបាយល្ងាច ហើយគាត់កំពុងតែហូបបាយ» ។ ម្ដាយរបស់សុភារ៉ា សម្លឹងមើលប្ដីរបស់គាត់ដែលត្រូវខ្មែរក្រហមបណ្ដើរចេញទៅយ៉ាងស្ងាត់ស្ងៀម ខណៈពេលដែលចិត្តរបស់គាត់កំពុងតែក្ដុកក្ដួលយ៉ាងខ្លាំង ។ ឪពុករបស់ សុភារ៉ា បានសម្លឹងមើលទៅភ្នែកម្ដាយរបស់គាត់ជាលើកចុងក្រោយនិងគ្មានផ្ដែផ្ដាំអ្វីទេ ។ ប៉ុន្តែ គាត់បានដឹងខ្លួនគាត់ច្បាស់ថា គាត់មិនអាចត្រឡប់មកផ្ទះវិញឡើយ ។ ចាប់តាំងពីថ្ងៃនោះមក សុភារ៉ា និងបងស្រី ព្រមទាំងម្ដាយរបស់គាត់មិនដែលឃើញឪពុករបស់គាត់ជារៀងរហូត ។ ជាងនេះទៅទៀត អ្នកដែលចាប់ឪពុករបស់ សុភារ៉ា ទៅនោះ គឺជាអ្នកជិតខាងរបស់គាត់ម្នាក់ ។

នៅយប់ថ្ងៃដដែល គ្រួសាររបស់ សុភារ៉ា បានដឹងថា ឪពុករបស់គាត់ត្រូវបានខ្មែរក្រហមសម្លាប់បាត់ទៅហើយ នៅពេលដែលខ្មែរក្រហមបានត្រឡប់មកយកក្របីដែលឪពុករបស់គាត់ឃ្វាលទៅវិញ ។

បច្ចុប្បន្ន សុភារ៉ា ពុំមានបំណងចង់សងសឹកជាមួយក្រុមគ្រួសារដែលបានយកឪពុកគាត់ទៅសម្លាប់ទេ ។ គាត់យល់ពីស្ថានភាពនៅក្នុងរបបខ្មែរក្រហមយ៉ាងច្បាស់ ហើយគាត់បាននិយាយថា «ប្រសិនបើគាត់មិនសម្លាប់ឪពុករបស់ខ្ញុំ នោះគាត់នឹងត្រូវខ្មែរក្រហមដទៃទៀតសម្លាប់វិញដែរ» ។ វាជាការយល់ឃើញមួយដែលជំរុញឲ្យ សុភារ៉ា ស្ងប់អារម្មណ៍ចំពោះជនដែលបានសម្លាប់ឪពុករបស់គាត់ ។ សព្វថ្ងៃ សុភារ៉ា បានក្លាយជាមិត្តភក្តិកូនរបស់ជនដដែលដែលជាគ្រូបង្រៀនគណិតវិទ្យានៅវិទ្យាល័យមួយនៃខេត្តកំពង់ធំដែរ ។ ប៉ុន្តែ សុភារ៉ា ក៏បាននិយាយប្រាប់ទៅមិត្តរួមការងាររបស់គាត់អំពីរឿងរ៉ាវរបស់គ្រូបង្រៀនគណិតវិទ្យាដែលឪពុករបស់គាត់បានធ្វើឲ្យឪពុក សុភារ៉ា ស្លាប់ ដែរ ។ ចំណែកមិត្តភក្តិរបស់ សុភារ៉ា មានអារម្មណ៍អាម៉ាស់យ៉ាងខ្លាំងចំពោះទង្វើដែលឪពុករបស់គាត់បានធ្វើមកលើឪពុករបស់ សុភារ៉ា ។ សុភារ៉ា ជឿជាក់ថា ជនដដែលដែលក្រោយមកត្រូវជនរងគ្រោះសម្លាប់ដោយសារតែកំហឹងបន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅនោះគឺជាផលកម្មរបស់គាត់ដែលបានសាង ។

នៅក្នុងព្រះពុទ្ធសាសនា ជនដែលបានប្រព្រឹត្តអាក្រក់នឹងទទួលផលកម្មរបស់ខ្លួននៅក្នុងជាតិនេះ ឬជាតិខាងមុខជាមិនខាន ។ សុភារ៉ា ជឿជាក់ថា ជនដដែលដែលបានសម្លាប់ឪពុកគាត់នឹងទទួលផលកម្មនូវអ្វីដែលគាត់បានប្រព្រឹត្តកន្លងមក ។ ជាងនេះទៅទៀត សុភារ៉ា ចង់បានយុត្តិធម៌ ហើយចង់ឃើញតុលាការកាត់ទោសជនដែលបានបង្កើតឲ្យមានរបបឃោរឃៅនេះ ។ គាត់តែងតែតាមដានសវនាការ ឌុច នៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយគាត់ក៏ទន្ទឹងរង់ចាំមើលមេដឹកនាំខ្មែរក្រហមផ្សេងទៀតត្រូវតុលាការកាត់ទោសដែរឬយ៉ាងណា ។ ជាមួយនឹងការប្រកាសសាលក្រមរបស់ ឌុច នៅពេលខាងមុខនេះ សុភារ៉ា មិនអាចរង់ចាំបាននោះទេ ។ សុភារ៉ា សង្ឃឹមថា ឌុច នឹងត្រូវបានតុលាការដាក់ពន្ធនាគារជាច្រើនឆ្នាំ ។ ប៉ុន្តែ គាត់នឹងសោកស្ដាយប្រសិនបើតុលាការសម្រេចដោះលែង ឌុច ឲ្យមានសេរីភាពវិញ ។ គាត់ចង់ឲ្យ ឌុច ជាប់ពន្ធនាគារជារៀងរហូត ។ សុភារ៉ា បានបញ្ជាក់ថា «ប្រសិនបើសាលក្រមប្រកាសថា ឌុច គ្មានទោស នោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមគ្មានយុត្តិធម៌ទេ» ។ ចុងក្រោយនេះ សុភារ៉ា បានបន្ថែមទៀតថា ប្រជាពលរដ្ឋកម្ពុជាត្រូវការការផ្សះផ្សា «វាជាពេលវេលាមួយសម្រាប់ការផ្សះផ្សាដើម្បីប្រទេសជាតិរបស់យើងអាចដើរទៅមុខបាន» ។ **ញាណ សុខាតិ**

# ជំនួបរវាងសហព្រះរាជអាជ្ញា និងខ្មែរកម្ពុជាក្រោមនៅខេត្តពោធិ៍សាត់

*កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១០ លោក អេនទ្រូ ខាលី សហព្រះរាជអាជ្ញារបស់អង្គជំនុំជម្រះបាននិយាយសំណេះសំណាលជាមួយបងប្អូនខ្មែរក្រោមប្រមាណជា២០០នាក់នៅខេត្តពោធិ៍សាត់ ដើម្បីបង្ហាញពីចំណាប់អារម្មណ៍របស់គាត់ដែលប្រជាជនខ្មែរក្រោមត្រូវបានមើលរំលងដោយតុលាការខ្មែរក្រហម ហើយមិនត្រូវបានរាប់បញ្ចូលនៅក្នុងនីតិវិធីរបស់តុលាការ ។ វេទិកាពិភាក្សានេះត្រូវបានរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ ហើយគោលបំណងនៃវេទិកាពិភាក្សានេះគឺដើម្បីផ្តល់ឱកាសឲ្យបងប្អូនប្រជាជនខ្មែរក្រោមធ្វើការពិភាក្សាដោយផ្ទាល់ជាមួយនឹងមន្ត្រីតុលាការខ្មែរក្រហមដែលត្រូវបានស្គាល់ជាផ្លូវការថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។*

*វេទិកាពិភាក្សានេះត្រូវបានប្រារព្ធធ្វើឡើងនៅវត្តរំលេច ជាកន្លែងប្រវត្តិសាស្ត្រដ៏សំខាន់មួយដែលខ្មែរក្រហមបានហ៊ុមព័ទ្ធ ហើយបានសម្លាប់ប្រជាជនខ្មែរក្រោមអស់ជាច្រើនរយនាក់ ។*

### ប្រវត្តិខ្មែរក្រោមនៅខេត្តពោធិ៍សាត់

*ខ្មែរក្រោមគឺជាជនជាតិភាគតិចខ្មែរ ប៉ុន្តែមានប្រវត្តិសាស្ត្រចាក់ឫសនៅតំបន់ដែនដីសណ្តទន្លេមេគង្គក្រោមនៃប្រទេសវៀតណាម ។ ទឹកដីរបស់ប្រទេសវៀតណាមមួយផ្នែកនេះធ្លាប់ជាទឹកដីរបស់ប្រទេសកម្ពុជារហូតដល់អាណានិគមនិយមបារាំងបានកែប្រែបន្ទាត់ព្រំដែនប្រទេសទាំងពីរដោយឲ្យទឹកដីខ្មែរកម្ពុជាក្រោមទៅប្រទេសវៀតណាមវិញនៅចុងទសវត្សរ៍៤០ ។ ការផ្លាស់ប្តូរនេះបានធ្វើឲ្យខ្មែរក្រោមជាច្រើនគ្រួសារធ្វើអន្តោប្រវេសន៍ និងមកតាំងទីលំនៅបណ្តោះអាសន្ននៅតាមព្រំដែនរបស់ប្រទេសកម្ពុជា ។ នៅក្នុងរជ្ជកាលរបស់ព្រះបាទ មុនីវង្ស (១៩២៧-១៩៤១) ខ្មែរក្រោមមួយចំនួនបានធ្វើអន្តោប្រវេសន៍ទៅកាន់ស្រុកបាកាន ខេត្តពោធិ៍សាត់ ដើម្បីបង្កើតភូមិឋានមួយ បន្ទាប់ពីឃើញតំបន់នោះអាចប្រកបរបរកសិកម្មបាន ។ នៅឃុំរំលេចមានប្រជាជនខ្មែរក្រោមច្រើនគ្រួសារជាងឃុំដទៃទៀតនៅក្នុងស្រុកបាកាន ។*

*ទោះបីជាខ្មែរក្រោមមានអម្បូរជាតិសាសន៍ សាសនា*



*ប្រជាជនខ្មែរក្រោមកំពុងមើលទស្សនាវដ្តីស្វែងរកការពិត និងសៀវភៅណែនាំអំពីសំណុំរឿង០០២*

ប្រពៃណី និងវប្បធម៌ដូចជនជាតិខ្មែរក៏ដោយ ក៏ខ្មែរក្រោមត្រូវបានចាត់ទុកថាជាខ្មាំងដោយរបបខ្មែរក្រហមដែរពីព្រោះខ្មែរក្រោមត្រូវបានចាត់ទុកថាជា «ក្បាលយួន ខ្លួនខ្មែរ» ។ ទស្សនៈនិងចិត្តគំនិតដែលមានទាក់ទងនឹងប្រទេសវៀតណាមដែលជាសត្រូវនយោបាយចម្បងមួយរបស់ខ្មែរក្រហមគឺមិនអាចទទួលយកបានទេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលទោះបើជាមានការលើកមតិជំទាស់បន្តិចបន្តួចក៏ត្រូវយកទៅសម្លាប់ចោលដែរ ។

ខ្មែរក្រោមនៅក្នុងខេត្តពោធិ៍សាត់បានទទួលរងទារុណកម្មយ៉ាងសាហាវព្រៃផ្សៃដោយស្នាដៃរបស់ខ្មែរក្រហម ។ យោងតាមសម្តីរបស់លោក អ៊ុក មន ប្រធានឃុំរំលេចបានមានប្រសាសន៍នៅក្នុងវេទិកាពិភាក្សានោះថា មុនឆ្នាំ១៩៧០ ប្រជាជនខ្មែរក្រោមដែលរស់នៅក្នុងភូមិចំនួនបីរបស់ឃុំនេះមានទាំងអស់១៥០០គ្រួសារ ។ បន្ទាប់ពីការសម្លាប់ និងជម្លៀសរបស់ខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ សព្វថ្ងៃនេះប្រជាជនខ្មែរក្រោមនៅសល់តិចជាង៥០គ្រួសារប៉ុណ្ណោះ ។ លោកប្រធានឃុំ អ៊ុក មន បានបន្តទៀតថា «ប្រជាជនត្រូវបានសម្លាប់នៅក្នុងឃុំរំលេចនេះក៏ប៉ុន្តែប្រជាជនខ្មែរក្រោមទទួលរងនូវការជិះជាន់ធ្វើបាបខ្លាំងជាងប្រជាជនដទៃទៀត» ។ អ៊ុក មន បន្តទៀតថា «ក្មេងជំនាន់ក្រោយនៅក្នុងឃុំសព្វថ្ងៃនេះមិនជឿថាខ្មែរអាចសម្លាប់ខ្មែរបែបនេះទេ ។ ដូច្នេះវាកាតព្វកិច្ចរបស់មនុស្សចាស់ដែលត្រូវប្រាប់រឿងរ៉ាវរបស់ខ្លួននៅក្នុងរបបខ្មែរក្រហមទៅកាន់ក្មេងៗសម័យបច្ចុប្បន្ន» ។

## «ខ្ញុំយល់ពីការឈឺចាប់របស់ប្រជាជនខ្មែរក្រោម»

វេទិកាពិភាក្សារបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងឃុំរំលេចនេះនិងមតិសំណេះសំណាលរបស់លោក អេនទ្រូ ខាលី សហព្រះរាជអាជ្ញារបស់តុលាការខ្មែរក្រហមមានគោលបំណងដើម្បីទទួលស្គាល់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តលើប្រជាជនខ្មែរក្រោមនៅចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ។ លោក សៅ ដារឿន ចៅហ្វាយស្រុកបាកានបាននិយាយដោយសង្កត់ធ្ងន់ថា សារសំខាន់របស់វេទិកាពិភាក្សានេះជាឱកាសពិភាក្សារវាងប្រជាជនខ្មែរក្រោមនិងមន្ត្រីតុលាការដែលធ្វើឲ្យមន្ត្រីតុលាការនិងប្រជាជនខ្មែរក្រោមមានការយល់ដឹងពីគ្នាទៅវិញទៅមក ។

បន្ទាប់មក លោក អេនទ្រូ ខាលី បាននិយាយទៅកាន់អ្នកភូមិដោយគាត់បានទទួលស្គាល់ពីការឈឺចាប់របស់ខ្មែរក្រោម និងបានពន្យល់អំពីស្ថានភាពរបស់តុលាការខ្មែរក្រហមនៅពេលបច្ចុប្បន្ន និងដំណើរការទៅអនាគតដោយការគោរពទៅកាន់ខ្មែរក្រោម ។ លោក អេនទ្រូ ខាលី បាននិយាយថា «ខ្ញុំបានដឹងពីការឈឺចាប់របស់បងប្អូនខ្មែរក្រោមកាលពីរបបខ្មែរក្រហម ។ ខ្ញុំដឹងថាសហគមន៍ប្រជាជនខ្មែរក្រោមមានអារម្មណ៍ថា ប្រជាជនខ្មែរក្រោមមិនមានការយកចិត្តទុកដាក់ពីតុលាការ ។ ប៉ុន្តែខ្ញុំចង់និយាយដោយស្មោះត្រង់ទៅកាន់បងប្អូនខ្មែរក្រោមថា ខ្ញុំមកកាន់ទីនេះពីព្រោះខ្ញុំដឹងពីការឈឺចាប់ដែលបានកើតឡើងលើប្រជាជនខ្មែរក្រោម» ។


លោក អេនទ្រូ ខាលី និយាយអំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមទៅកាន់ប្រជាជនខ្មែរក្រោម

ការព្រួយបារម្ភរបស់ខ្មែរក្រោមទាក់ទងការមិនរាប់បញ្ចូលនៅក្នុងសេចក្តីសម្រេចដោយសហចៅក្រមស៊ើបអង្កេតរបស់តុលាការខ្មែរក្រហមកាលពីខែមករា ឆ្នាំ២០១០ គឺថាការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ និងបទល្មើសផ្សេងទៀតនឹងមិនបានយកមកចោទប្រកាន់លើមេដឹកនាំខ្មែរក្រហមបច្ចុប្បន្នកំពុងចាប់ឃុំឃាំងដោយសារអំពើឃោរឃៅនៃរបបនេះលើប្រជាជនខ្មែរក្រោមទេ ។ ជាលទ្ធផលនៃសេចក្តីសម្រេចនេះ ដើមបណ្តឹងរដ្ឋប្បវេណីជាប្រជាជនខ្មែរ

ក្រោមមួយចំនួនមកពីខេត្តពោធិ៍សាត់ដែលធ្លាប់ត្រូវបានទទួលស្គាល់ជាបណ្តោះអាសន្ននៅក្នុងសំណុំរឿង០០២ ប្រឆាំងនឹង (អៀង សារី, នួន ជា, អៀង ធីរិទ្ធិ និង ខៀវ សំផន) ត្រូវបានបដិសេធចោល ពីព្រោះការអះអាងរបស់ខ្មែរក្រោមត្រូវបានមើលឃើញថាស្ថិតនៅក្រៅយុត្តាធិការស៊ើបអង្កេតរបស់ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា សេចក្តីសម្រេចរបស់ពួកគេផ្អែកទៅលើមូលហេតុនីតិវិធីជាជាងការវិនិច្ឆ័យប្រវត្តិសាស្ត្រដែលខ្មែរក្រោមមិនមែនជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មផ្សេងទៀត ។ ក៏ប៉ុន្តែសមាជិកជាច្រើននៃសហគមន៍ខ្មែរក្រោមបានចាត់ទុកការសម្រេចចិត្តនេះថាការសម្រេចដ៏ត្រឹមត្រូវដោយតុលាការខ្មែរក្រហម ដោយសារការឈឺចាប់របស់ប្រជាជនខ្មែរក្រោមមិនធ្ងន់ធ្ងរ ឬក៏ទូលំទូលាយដូចក្រុមដទៃទៀត ជាពិសេសនៅក្នុងសេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតកាលពីខែធ្នូ ឆ្នាំ២០០៩ ថា ការចោទប្រកាន់ពីបទល្មើសប្រល័យពូជសាសន៍អាចយកមកប្រឆាំងនឹងការឃុំខ្លួនមេដឹកនាំខ្មែរក្រហមសម្រាប់ការប្រព្រឹត្តរបស់ពួកគេទៅលើក្រុមជនជាតិចាមនិងវៀតណាម ។

លោក អេនឌ្រូ ខាលី បានធានានៅចំពោះប្រជាជនខ្មែរក្រោមថា នេះមិនមែនជាករណីទេ ។ បន្ទាប់ពីបានពន្យល់អំពីសំណុំរឿង០០១ប្រឆាំងនឹងអតីតប្រធានមន្ទីរឃុំឃាំងស-២១ កាំង ហ្គេកអ៊ាវ ហៅ ឌុច ហើយនិងការបន្តការស៊ើបអង្កេតលើសំណុំរឿង០០២ លោក អេនឌ្រូ ខាលី បានបង្ហាញពីការតាំងចិត្តរបស់គាត់ក្នុងការបញ្ចូលភ័ស្តុតាងដែលបញ្ជាក់ពីការឈឺចាប់របស់ប្រជាជនខ្មែរក្រោមនៅក្នុងសំណុំរឿង០០២ ថាតើខ្មែរក្រោមត្រូវបានអនុញ្ញាតឲ្យក្លាយខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាផ្លូវការដែរឬអត់ ។ លោក អេនឌ្រូ ខាលី បានបង្ហាញយ៉ាងច្បាស់ថា មានប្រជាជនខ្មែរក្រោមជាបុគ្គលខ្លួនឯងផ្ទាល់និងជាក្រុមបានដាក់ពាក្យបណ្តឹងដើម្បីក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី ក៏ប៉ុន្តែមិនត្រូវបានទទួលស្គាល់ដោយតុលាការទេ ដោយសារភាពស្មុគស្មាញរបស់នីតិវិធានទទួលស្គាល់ ។ លោកបានបន្តថា «ប្រសិនបើប្រជាជនខ្មែរក្រោមមិនត្រូវបានទទួលស្គាល់ វាមិនមែនមានន័យថាការឈឺចាប់របស់ខ្មែរក្រោមមិនកើតឡើងនោះទេ ។ ដូចដែលបាននិយាយភ័ស្តុតាងរបស់ខ្មែរក្រោមនៅតែអាចជាផ្នែកមួយរបស់សំណុំរឿងនេះ ទោះបីពួកគាត់មិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ» ។

លោក អេនឌ្រូ ខាលី បានមានប្រសាសន៍ថា «យើងនៅក្នុងការិយាល័យព្រះរាជអាជ្ញាដឹងពីការឈឺចាប់របស់ខ្មែរក្រោមនៅក្នុងរបបខ្មែរក្រហម ហើយយើងទទួលស្គាល់ឧក្រិដ្ឋកម្មដែលបានកើតឡើងប្រឆាំងនឹងខ្មែរក្រោមដោយផ្អែកលើជាតិសាសន៍ និងទីតាំងពិសេសនៅក្នុងប្រទេស» ។ លោកនិយាយទៀតថា ប្រជាជនខ្មែរក្រោមនិងឧក្រិដ្ឋកម្មដែលប្រឆាំងនឹងប្រជាជនខ្មែរក្រោមនឹងត្រូវបានបញ្ចូលនៅក្នុងឯកសាររបស់ព្រះរាជអាជ្ញាដាក់ជូនទៅសហចៅក្រមស៊ើបអង្កេតនៅចុងបញ្ចប់សវនាការសំណុំរឿង ០០២ «ដូច្នេះចៅក្រមនិងពិភពលោកអាចឮពីអ្វីដែលកើតឡើងលើខ្មែរក្រោមដែរ» ។

ដើម្បីបង្ហាញពីការតាំងចិត្តយ៉ាងមុតមាំរបស់គាត់ដើម្បីបញ្ចូលខ្មែរក្រោមទៅក្នុងសំណុំរឿង ០០២ លោក អេនឌ្រូ ខាលី បានបញ្ចប់ការនិយាយរបស់គាត់ ដោយយកចំណាររមួយផ្ទាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រគល់ជូនប្រជាជនឃុំរំលេច ដើម្បីរំឭកអំពីដំណើរទស្សនកិច្ចរបស់គាត់ ។ នៅក្នុងចំណាររមួយផ្ទាំងនេះសរសេរថា «សូមឲ្យអ្នកដែលបានអានសំណេរ



អេនឌ្រូ ខាលី និយាយទៅកាន់អ្នកភូមិខ្មែរក្រោមម្នាក់នៅឃុំរំលេច

មួយផ្ទាំងនេះនៅពេលខាងមុខ ចងចាំការឈឺចាប់ និងសោកនាដកម្មទាំងឡាយដែលកើតមានឡើងចំពោះប្រជាជនខ្មែរកម្ពុជាក្រោមក្នុងរយៈកាលនៃរបបខ្មែរក្រហម ដើម្បីកុំឲ្យអំពើបែបនេះកើតមានឡើងសាជាថ្មីម្តងទៀត» ។

## សំណួរ និងចម្លើយ

បន្ទាប់ពីលោក អេនឌ្រូ ខាលី បញ្ចប់មតិសំណេះសំណាល ប្រជាជនខ្មែរក្រោមដែលមានវត្តមាននៅទីនោះត្រូវបានអញ្ជើញឲ្យសួរសំណួរនិងនិយាយរៀបរាប់អំពីជីវិតរបស់ពួកគាត់ ។ មានអ្នកចូលរួមម្នាក់បានសួរសំណួរថា ប្រសិនបើខ្មែរទាំងអស់និងសហគមន៍អន្តរជាតិដឹងថា ប៉ុល ពត និងរបបរបស់គាត់បានសម្លាប់ប្រជាជន ហេតុអ្វីចាំបាច់មានសាក្សីជាច្រើនមកធ្វើសក្ខីកម្មចោទថាមានបទឧក្រិដ្ឋនៅក្នុងរបបខ្មែរក្រហម? លោក អេនឌ្រូ ខាលី បានពន្យល់ថា ដំណើរការនីតិវិធីដែលបង្កើតដោយអង្គជំនុំជម្រះនឹងធានាថា អង្គហេតុនឹងត្រូវបានបង្កើតឡើងដោយយុត្តិធម៌ ហើយការពិតនឹងត្រូវបានរកឃើញ «ពិភពលោកត្រូវការដឹងអ្វីដែលកើតឡើងនៅក្រោមរបបខ្មែរក្រហម ហើយត្រូវតែធ្វើទៅតាមនីតិវិធីផ្លូវច្បាប់ ។ ពិភពលោកនិងប្រទេសកម្ពុជាចង់ឃើញសវនាការធ្វើដោយយុត្តិធម៌មួយ ដូច្នេះនៅថ្ងៃអនាគត គ្មាននរណាម្នាក់អាចនិយាយថា «មេដឹកនាំខ្មែរក្រហមទាំងនេះមិនទទួលបានការកាត់ក្តីដ៏ត្រឹមត្រូវទេ» ។ ប្រជាជនខ្មែរក្រោមបានទះដៃគាំទ្របន្ទាប់ពីសម្តីរបស់ លោក អេនឌ្រូ ខាលី បានបកប្រែរួច ។

បន្ទាប់មក លោក មាស ចាន់ថន ជាប្រធានឃុំរំលេច នៅពេលខ្មែរក្រហមឡើងកាន់អំណាចនិងជាខ្មែរក្រោមចំណាស់ជាងគេនៅក្នុងឃុំដែលនៅរស់រានមានជីវិតពីបន្សុទ្ធកម្មនៃរបបខ្មែរក្រហមបានឡើងមានមតិសំណេះសំណាល ។ លោក មាស ចាន់ថន បានសួរថា ហេតុអ្វីបានជាតុលាការខ្មែរក្រហមមិនបានបញ្ជូនបុគ្គលិកមកស៊ើបអង្កេតដើម្បីចោទប្រកាន់ពីបទប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅឃុំរំលេច ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានដឹងពីការឈឺចាប់របស់ខ្មែរក្រោមនៅក្នុងឃុំនេះហើយ? គាត់ក៏បានបន្តទៀតថា ហេតុអ្វីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទទួលស្គាល់ពីអំពើប្រល័យពូជសាសន៍លើជនជាតិចាម ប៉ុន្តែមិនមែនជាខ្មែរក្រោមទៅវិញ ។



អ្នកភូមិឡើងសួរសំណួរទៅលោក អេនឌ្រូ ខាលី

លោក ដែល លីសាក់ ដែលជាជំនួយការព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានឆ្លើយតបចំពោះសំណួរនេះថា ព័ត៌មានដែលអ្នកទាំងអស់គ្នាបានដាក់ជូនតុលាការអំពីបទពិសោធន៍និងហេតុការណ៍ដែលបានឃើញផ្ទាល់ភ្នែកនៅក្នុងរបបខ្មែរក្រហមនឹងត្រូវបានយកមកប្រើប្រាស់សម្រាប់មូលហេតុចម្បងពីរនៅក្នុងសំណុំរឿង០០២ ។ ទីមួយ វានឹងប្រើប្រាស់ជាភ័ស្តុតាងដើម្បីបង្កើតជាធាតុផ្សំនៃបទល្មើសប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម ។ លោក លីសាក់ បានបញ្ជាក់ថា «ខ្មែរក្រហមសង្ស័យអ្នករាល់គ្នាមានជាប់ពាក់ព័ន្ធជាមួយវៀតណាម ។ ដោយសារតែមានការយល់ឃើញបែបនេះទើបប្រជាជនខ្មែរក្រោមបានក្លាយទៅជាគោលដៅមួយរបស់ខ្មែរក្រហមនិងដោយសារតែអ្នកជាបុគ្គលមួយរូបជាប់ទាក់ទងនឹងក្រុមនេះ ដូច្នេះអ្នកគឺជាគោលដៅដែលត្រូវតាមចាប់ និងសម្លាប់នៅទីនេះ» ។

ទីពីរ លោក លីសាក បានបន្ថែមទៀតថា ព័ត៌មានទាំងអស់នេះមានសារសំខាន់សម្រាប់ព្រះរាជអាជ្ញាដើម្បីពិនិត្យមើលបទល្មើសដែលបានកើតឡើងនៅទីនេះ និងជាកន្លែងដែលវេទិកានេះកំពុងតែប្រព្រឹត្តទៅ ។ នៅពេលដែលរបបខ្មែរក្រហមជិតបញ្ចប់ ខ្មែរក្រហមបានដឹកមនុស្សជាច្រើនតាមរថភ្លើងសំដៅទៅឃុំរំលេច ហើយបានប្រមូលផ្តុំអ្នកទាំងអស់នោះនៅក្នុងវត្តរំលេច និងបានសម្លាប់អ្នកទាំងអស់នោះចោល ។ បច្ចុប្បន្ន មជ្ឈមណ្ឌលឯកសារកំពុងតែធ្វើការសាងសង់បូជនីយដ្ឋានអចិន្ត្រៃយ៍មួយនៅក្បែរវត្តដើម្បីរក្សាអដ្ឋិធាតុអ្នកដែលបានស្លាប់ ។

## *ការចែករំលែកបទពិសោធន៍*

*លោក វ៉ាន់ថាន់ ពៅដារ៉ា ដែលជាអ្នកសម្របសម្រួលនៅក្នុងវេទិកាបានស្នើឲ្យអ្នកចូលរួមក្នុងវេទិកានេះចែករំលែកនូវបទពិសោធន៍និងរឿងរ៉ាវដែលបានឃើញកាលពីរបបខ្មែរក្រហម ។ ភ្លាមៗនោះ មានស្ត្រីម្នាក់បានក្រោកឡើង ហើយនិយាយប្រាប់ថា សមាជិកក្រុមគ្រួសាររបស់គាត់ចំនួន៣៩នាក់ រួមទាំងឪពុកម្តាយរបស់គាត់ផងត្រូវបានខ្មែរក្រហមយកទៅសម្លាប់ទាំងអស់ ។ គាត់បាននិយាយទាំងទឹកភ្នែកថា នៅពេលដែលឪពុករបស់គាត់ត្រូវសម្លាប់ គាត់ក៏នៅទីនោះដែរ ហើយគាត់បានរួចរស់ជីវិតដោយសារតែឪពុករបស់គាត់បានសុំអង្វរកម្មាភិបាលខ្មែរក្រហមកុំឲ្យសម្លាប់កូនស្រីគាត់ ។ ចំណែកឯម្តាយរបស់គាត់វិញបានស្លាប់ដោយសារតែខ្មែរក្រហមបានយកទឹកមកធ្វើជាថ្នាំចាក់ឲ្យគាត់ ។ គាត់បានបន្តថា គាត់គឺជាមនុស្សតែម្នាក់ដែលអាចរស់រានមានជីវិតបានពីរបបខ្មែរក្រហម ដោយសារតែវៀតណាមបានចូលមកនៅឆ្នាំ១៩៧៩ ។*

*ផន សារ៉ាយ មានអាយុ៥៦ឆ្នាំ សព្វថ្ងៃរស់នៅភូមិពោធិ៍យំក៏បានរំឭកដែរថា៖ «ខ្ញុំរស់ដោយសារតែខ្ញុំខំធ្វើអ្វីៗជាច្រើនដើម្បីរស់នៅក្នុងរបបប្រល័យពូជសាសន៍នោះ ។ ខ្ញុំចង់ប្រាប់អ្នកទាំងអស់គ្នាពីរឿងរ៉ាវរបស់ខ្ញុំ» ។ ភូមិពោធិ៍យំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមតាំងពីមុនពេលដែលខ្មែរក្រហមកាន់កាប់អំណាចនៅទូទាំងប្រទេសនៅឆ្នាំ១៩៧៥មកម្ល៉េះ ។ នៅឆ្នាំ១៩៧៦ កូនប្រុសរបស់ ផន សារ៉ាយ បានស្លាប់បាត់បង់ជីវិតដោយសារតែអត់អាហាររហូប ។ បន្ទាប់មកទៀត គាត់និងអ្នកភូមិដទៃទៀតត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅនៅភូមិផ្សេងទៀត និងបញ្ជាឲ្យរស់នៅជាសហករណ៍ ។ ពេលខ្លះ ផន សារ៉ាយ ត្រូវបានប្រធានសហករណ៍បញ្ជាឲ្យធ្វើការកត់ត្រានៅពេលមានកិច្ចប្រជុំរវាងកម្មាភិបាលខ្មែរក្រហម ដោយសារតែគាត់ចេះអាននិងសរសេរអក្សរបាន ។*

*ផន សារ៉ាយ បានចូលរួមនៅក្នុងអង្គប្រជុំមួយ គាត់បានឮប្រធានសហករណ៍លើកឡើងពីខ្មែរក្រោមនិងទំនាក់ទំនងរបស់អ្នកទាំងនោះជាមួយជនជាតិវៀតណាម ។ ប្រធានសហករណ៍ក៏បានបញ្ជាក់ដែរថា មានប្រជាជនខ្មែរក្រោមប្រហែលពីរលាននាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយមេដឹកនាំខ្មែរក្រហមចង់ឲ្យអ្នកដែលរស់នៅក្នុងសហករណ៍ទាំងអស់ធ្វើប្រវត្តិរូបដើម្បីកំណត់និងបែងចែកប្រជាជនខ្មែរក្រោមចេញពីប្រជាជនខ្មែរ ។ ផន សារ៉ាយ បាននិយាយថា គាត់ចងចាំរឿងនេះ ក៏ព្រោះតែគាត់ជាខ្មែរក្រោម គាត់ក៏បានលាក់រឿងនេះពីខ្មែរក្រហមរហូតមុនពេលបញ្ជាឲ្យធ្វើប្រវត្តិរូបនេះ ។ ផន សារ៉ាយ បានបន្តទៀតថា បួន-ប្រាំថ្ងៃបន្ទាប់ពីការប្រជុំនោះ ប្រជាជនខ្មែរក្រោមទាំងអស់នៅក្នុងសហករណ៍ ព្រមទាំងគាត់ត្រូវបានអង្គការបញ្ជូនទៅសហករណ៍ផ្សេងទៀត ហើយបង្ខំឲ្យធ្វើការជាទម្ងន់ ។*

*នៅក្នុងបទសម្ភាសន៍មួយបន្ទាប់ពីការពិភាក្សា ផន សារ៉ាយ បានរៀបរាប់ប្រាប់ពីបទពិសោធន៍របស់គាត់បន្ថែមទៀតថា៖ «ខ្ញុំមានសំណាងដែលអាចនៅរស់ពីរបបនោះបាន ។ ខ្មែរក្រហមបានប្រើប្រាស់ការរៀបចំជាសហករណ៍ដើម្បីបំបែកប្រជាជនខ្មែរក្រោមដែលបម្រុងនឹងយកទៅសម្លាប់ចេញពីប្រជាជនដទៃទៀត» ។ គ្រួសាររបស់ ផន សារ៉ាយ នៅរស់រានមានជីវិតបាន ដោយសារតែឪពុករបស់គាត់ស្គាល់កម្មាភិបាលខ្មែរក្រហមម្នាក់ ។ កម្មាភិបាលមួយរូបនោះបានព្យាយាមបញ្ចុះបញ្ចូលកម្មាភិបាលដទៃទៀតថា ផន សារ៉ាយ និងក្រុមគ្រួសាររបស់គាត់មិនមែនជាខ្មែរក្រោមទេ ។ ចំណែកឪពុករបស់ ផន សារ៉ាយ ក៏បានក្រោកឈរឡើងយ៉ាងក្លាហាននៅចំពោះមុខខ្មែរក្រហម ហើយបានបដិសេធថា គាត់ទាំងអស់គ្នាមិនមានប្រវត្តិជាប់ទាក់ទងជាមួយខ្មែរក្រោមនោះទេ សូម្បីតែជីដូនជីតាក៏មិនមែនដែរ ។ តែតាមពិតទៅ ជីតារបស់ ផន សារ៉ាយ គឺជាខ្មែរក្រោម ហើយគាត់ទាំងអស់គ្នាជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងខ្មែរក្រោម ។ ជាងនេះទៅទៀត ប្រធានសហករណ៍ក៏បានជួយគ្រួសាររបស់គាត់ផងដែរ នៅពេលដែលមានការជម្លៀសចេញលើកដំបូងដោយបានបញ្ជូនគាត់ទាំងអស់គ្នាឲ្យទៅធ្វើការនៅក្នុងសហករណ៍ ដោយមិនបានបញ្ជូនទៅកន្លែងដែលប្រជាជនខ្មែរក្រោមត្រូវបានសម្លាប់នោះទេ ។*

*នៅពេលដែលសួរអំពីប្រតិកម្មរបស់គាត់ចំពោះវេទិកាពិភាក្សានេះ ផន សារ៉ាយ បាននិយាយថា៖ «ការប្រជុំនេះមានសារសំខាន់ណាស់សម្រាប់ខ្ញុំ ។ វាបានផ្តល់ឱកាសឲ្យខ្ញុំបានបង្ហាញពីអារម្មណ៍និងការចងចាំអំពីការឈឺចាប់របស់ខ្ញុំទៅកាន់មន្ត្រីដែល*

មកពីតុលាការ» ។ គាត់បានមានប្រសាសន៍បន្ថែមដែរថា ការប្រជុំនេះវាមានសារសំខាន់ផងដែរសម្រាប់អ្នកភូមិទាំងអស់គ្នាដែលពុំមានលទ្ធភាព និងមធ្យោបាយក្នុងការធ្វើដំណើរទៅទីក្រុងភ្នំពេញ ដើម្បីបានតាមដានពីដំណើរការរបស់តុលាការ ។ គាត់បាននិយាយថា វេទិកានេះបានអនុញ្ញាតឲ្យយើងទាំងអស់គ្នាបានចែករំលែករឿងរ៉ាវនិងបានផ្តល់ឱកាសដល់អ្នកដែលមិនបានចែករំលែករឿងរ៉ាវរបស់ខ្លួនបានស្តាប់ផងដែរ ។ ជាចុងបញ្ចប់ គាត់បានបញ្ជាក់ថា វេទិកានេះគួរឲ្យចាប់អារម្មណ៍ដោយសារតែបច្ចុប្បន្នគាត់ជឿជាក់ថា មន្ត្រីរបស់អង្គជំនុំជម្រះកំពុងស៊ើបអង្កេតឧក្រិដ្ឋកម្មប្រឆាំងនឹងខ្មែរក្រោមដែលបានកើតឡើងនៅក្នុងខេត្តពោធិ៍សាត់ ។ ជាងនេះទៅទៀត គាត់ចាប់អារម្មណ៍និងចង់ដឹងអំពីការឈឺចាប់របស់យើងដែលជាខ្មែរក្រោមផង ។

## ការចងចាំចំពោះការជម្លៀសនៅភូមិភាគបូព៌ា

លោក វ៉ាន់ថាន់ ពៅដារ៉ា ដែលជាអ្នកសម្របសម្រួលនៅក្នុងវេទិកាពិភាក្សាបានសួរអ្នកចូលរួមឲ្យជួយចែករំលែកពីបទពិសោធន៍ឬក៏ព្រឹត្តិការណ៍ដែលគាត់បានឃើញផ្ទាល់ភ្នែកអំពីការជម្លៀសរបស់ខ្មែរក្រហមចំពោះប្រជាជននៅភូមិភាគបូព៌ា ។ នៅឆ្នាំ១៩៧៨ ថ្នាក់ដឹកនាំមជ្ឈិមបក្សខ្មែរក្រហមដែលមានការភ័យខ្លាចអំពីភាពមិនស្មោះត្រង់នៅក្នុងចំណោមអ្នកគ្រប់គ្រងនិងសមាជិកយោធានៅភូមិភាគបូព៌ា ពីព្រោះយុទ្ធសាស្ត្រប្រឆាំងនឹងវៀតណាមរបស់ពួកគេមិនសូវខ្លាំងក៏បានធ្វើបន្សុទ្ធកម្មមេដឹកនាំនៅតាមតំបន់ ។ អ្នកនៅភូមិភាគបូព៌ាជាច្រើនត្រូវបានសម្លាប់នៅក្នុងបន្សុទ្ធកម្មនេះ ហើយមនុស្សជាច្រើនត្រូវបានខ្មែរក្រហមជម្លៀសទៅខេត្តផ្សេងៗនៅភាគខាងលិច ដើម្បីចៀសផុតពីការទទួលឥទ្ធិពលពីវៀតណាម ។ ខេត្តមួយក្នុងចំណោមខេត្តទាំងនោះដែលអ្នកបូព៌ាត្រូវបានជម្លៀសទៅគឺខេត្តពោធិ៍សាត់ ។ នៅទីនោះកម្មាភិបាលខ្មែរក្រហមបានស្រង់យកអ្នកដែលជាប់ពាក់ព័ន្ធនឹងខ្សែវៀតណាមយកទៅសម្លាប់ចោល ។

ផន សឿង មានអាយុ ៦០ឆ្នាំ មកពីភូមិពោធិ៍យំ គឺជាអ្នកដែលបានមើលឃើញផ្ទាល់ភ្នែកអំពីការសម្លាប់ទាំងនោះ ។ គាត់បានឃើញអំពីការសម្លាប់ប្រជាជនប្រហែល៧០០នាក់ដែលអ្នកទាំងនោះត្រូវបានជម្លៀសចេញពីភូមិភាគបូព៌ាមកកាន់ខេត្តពោធិ៍សាត់ ។ គាត់បានឃើញខ្មែរក្រហមប្រើកាំបិតផ្គាក់ និងដំបងវែងសម្លាប់អ្នកភូមិភាគបូព៌ាយ៉ាងព្រៃផ្សៃ ។ គាត់បាននិយាយថា «ពួកគេវាយអ្នកទាំងនោះដូចជាសត្វធាតុ» ។ គាត់បានបន្ថែមថា មើលឃើញទិដ្ឋភាពបែបនេះធ្វើឲ្យគាត់រន្ធត់ ដែលឪពុកម្តាយនិងសមាជិកនៅក្នុងក្រុមគ្រួសាររបស់គាត់ជាង២០នាក់ត្រូវបានសម្លាប់នៅក្នុងរូបភាពបែបនេះដែរ ។

ផន សឿង ក៏បានបញ្ជាក់បន្ថែមពីបទពិសោធន៍របស់គាត់នៅក្នុងរបបខ្មែរក្រហមក្រោយពីចប់វេទិកាពិភាក្សានេះថា គាត់បានបួសជាសង្ឃតាំងពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ។ ប៉ុន្តែក្រោយមកគាត់ត្រូវបានបង្ខំឲ្យសឹក បន្ទាប់ពីខ្មែរក្រហមបានឡើងកាន់អំណាច ។ គាត់ត្រូវបានបំបែកចេញពីក្រុមគ្រួសារ ហើយបញ្ជាឲ្យធ្វើការនៅក្នុងកងចល័ត ។ ខ្មែរក្រហមក៏បានបង្ខំគាត់ឲ្យរៀបការជាមួយស្ត្រីម្នាក់ដែលគាត់ទើបតែជួបមុខនៅយប់ដែលគាត់រៀបការប៉ុណ្ណោះ ។ ផន សឿង បានប្រាប់វេទិកាពិភាក្សានេះថា នៅឆ្នាំ១៩៧៧ គាត់បានឮជនដែលនិយាយអំពីចំនួនប្រជាជនខ្មែរក្រោមដ៏ច្រើនលើសលប់គឺថា «ពួកគេមានក្បាលយួន ខ្លួនខ្មែរត្រូវតែសម្លាប់» ។ ផន សឿង ក៏បានបញ្ជាក់ឡើងវិញថា កាលពីមុនរបបខ្មែរក្រហម នៅក្នុងខេត្តពោធិ៍សាត់មានប្រជាជនខ្មែរក្រោមរស់នៅរាប់រយគ្រួសារ និងគ្រួសារខ្មែរតែពីរ-បីគ្រួសារប៉ុណ្ណោះ ។ គាត់បានបន្តថា «ឥឡូវនេះវាមានភាពផ្ទុយគ្នា ។ ប្រជាជនខ្មែរក្រោមដែលរស់នៅទីនេះសព្វថ្ងៃគឺជាអ្នកដែលបានរួចរស់ជីវិតពីរបបខ្មែរក្រហមដោយសារតែពួកគេត្រូវបានជម្លៀសទៅកាន់តំបន់ផ្សេងទៀត ។ រីឯអ្នកដែលរស់នៅទីនេះនិងមិនបានជម្លៀសចេញត្រូវបានសម្លាប់ ។ ហើយអ្នកដែលរស់នៅទីនេះសព្វថ្ងៃគឺជាអ្នកដែលជម្លៀសចេញកាលពីមុន» ។

ចំពោះ ផន សឿង វេទិកានេះមានសារសំខាន់ «ដោយសារតែវាបានបង្ហាញពីការយកចិត្តដាក់របស់តុលាការចំពោះយើងទាំងអស់គ្នានិងការស្វែងរកយុត្តិធម៌ជូនប្រជាជន ។ វាក៏មានសារសំខាន់ផងដែរសម្រាប់ក្មេងជំនាន់ក្រោយក្នុងការដឹងអំពីរឿងរ៉ាវទាំងអស់នេះ ដើម្បីចៀសវាងការប្រព្រឹត្តខុសដូចខ្មែរក្រហម ហើយដើម្បីចៀសវាងប្រវត្តិសាស្ត្រដដែលកើតឡើងម្តងទៀត» ។

**ឡូរ៉ា ទីលីម**

# ទស្សនាខ្សែភាពយន្តអំពីរបបខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកម្ពុជា

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ផ្ទុកទៅដោយខ្សែភាពយន្តអំពីរបបខ្មែរក្រហមជាង២០០នៅក្នុងបណ្ណសារដ្ឋាន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានអាសយដ្ឋានដូចរៀបរាប់ខាងលើបានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមែប្រមូលឯកសារនានាទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យដែលបានបង្កវិនាសកម្មដ៏ធំធេងទាំងផ្លូវកាយនិងផ្លូវចិត្តដល់ពលរដ្ឋកម្ពុជាជាទូទៅ ។ ដើម្បីផ្តល់ឱកាសដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម អ្នកស្រាវជ្រាវ សិស្ស និស្សិត មន្ត្រីរដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាលនានាក្នុងការរៀនសូត្រពីរបបខ្មែរក្រហមតាមរយៈការមើលខ្សែភាពយន្ត មជ្ឈមណ្ឌលឯកសារកម្ពុជាសូមស្វាគមន៍ដល់អ្នកដែលចាប់អារម្មណ៍ទាំងអស់ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបើកទទួលអ្នកដែលមានចំណាប់អារម្មណ៍ទាំងអស់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង ៨ៈ០០ព្រឹក ដល់ម៉ោង ៥ៈ០០ ល្ងាច ។ បើសាធារណជនចង់ជ្រាប់ព័ត៌មានបន្ថែមសូមទាក់ទងឈ្មោះ ឡេង រតនៈ ឬ សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ មកទល់ពេលនេះមជ្ឈមណ្ឌលបានផលិតខ្សែភាពយន្តបានចំនួនបី ៖

**១) វាលស្រែខ្មែរក្រហមៈ** *រឿងរ៉ាវរបស់ស្ត្រីម្នាក់ឈ្មោះ តាំង គីម ត្រូវបានរំលោភដោយយោធាខ្មែរក្រហមៈ យប់មួយក្នុងឆ្នាំ ១៩៧៥ នារីវ័យក្មេងម្នាក់ឈ្មោះ តាំង គីម ដែលទើបតែរៀបការរួចថ្មីៗ ត្រូវបានយោធាខ្មែរក្រហមមកហៅឲ្យទៅជួបប្តីរបស់ខ្លួនដែលជាទាហាន លន់ នល់ ។ តែតាមពិត តាំង គីម គឺជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រីប្រាំបីនាក់ដែលត្រូវបានបញ្ជូនទៅកាន់វាលស្រែមួយនៅក្បែរភូមិដើម្បីសម្លាប់ចោល ។ ពេលដែលកំពុងយាមដោយយោធាខ្មែរក្រហមម្នាក់ តាំង គីម បានឮសំឡេងស្ត្រីដទៃទៀតស្រែកយំដោយក្តីឈឺចាប់ពេលស្ត្រីទាំងនោះត្រូវយោធាខ្មែរក្រហមមួយក្រុមកំពុងរំលោភ ។ ដោយដឹងថាគាត់គឺជាជនបន្ទាប់ក្នុងករណីរំលោភនេះ តាំង គីម បានសុំអង្វរយោធាម្នាក់ដែលកំពុងយាមគាត់ យោធាខ្មែរក្រហមឯទៀតបានចូលមករំលោភគាត់ដែរ ។ ខ្សែភាពយន្តនេះរៀបរាប់អំពីរឿងរ៉ាវរបស់ស្ត្រី តាំង គីម ដែលក្រោយមកបានបួសជាដូនជី និងបានតស៊ូជាមួយនឹងបច្ចុប្បន្នកាលនិងអតីតកាលដែលបានកើតឡើងពីជំនាន់ខ្មែរក្រហម ។*

**២) កៀនជញ្ជាំងនៃមន្ទីរស-២១ៈ** *ខ្សែភាពយន្តនេះបង្ហាញពីការរៀបរាប់ខ្សែជីវិតរបស់មនុស្សបីនាក់ ក្នុងនោះពីរនាក់គឺជាជនរងគ្រោះ និងម្នាក់ទៀតជាកម្មាភិបាលខ្មែរក្រហមនៅមន្ទីរស-២១ ដែលជាកន្លែងឃុំឃាំងអ្នកទោសដ៏ធំបំផុតក្នុងសម័យកាលរបបកម្ពុជាប្រជាធិបតេយ្យ១៩៧៥-១៩៧៩ ។ ខ្សែភាពយន្តនេះរៀបរាប់ពីដំណើរជីវិតមនុស្សទាំងបីនាក់ដែលចាប់កំណើតក្នុងទីកន្លែងផ្សេងគ្នា តែទីបញ្ចប់ទទួលនូវជោគវាសនាដូចគ្នានៅទីកន្លែងតែមួយគឺមន្ទីរស-២១ ។ ម្ភៃប្រាំឆ្នាំក្រោយពីរបបខ្មែរក្រហមដួលរលំអ្នកទាំងបីបានរៀបរាប់ពីដំណើរជីវិតមុននឹងក្លាយជាអ្នកទោស និងក្លាយជាកងការពារអ្នកទោសនៅមន្ទីរស-២១នេះ ។*

**៣) ត្រៀមខ្លួនស្វែងរកយុត្តិធម៌ៈ** *នៅឆ្នាំ២០០៦ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញអ្នកភូមិដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ហើយកំពុងរស់នៅតំបន់នានាទូទាំងប្រទេសដើម្បីមកទស្សនាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីអប់រំប្រជាជនកម្ពុជាអំពីដំណើរការងារនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងផ្តល់ឱកាសដល់អ្នករស់រានជីវិតពីរបបខ្មែរក្រហមចូលរួមចំណែកក្នុងដំណើរការយុត្តិធម៌ ។ ក្នុងដំណើរទស្សនកិច្ចនេះ អ្នកភូមិក៏បានទៅដល់ទីតាំងវាលពិឃាតនានា ដើម្បីគាត់អាចវិនិច្ឆ័យដោយខ្លួនឯងចំពោះបទឧក្រិដ្ឋដែលខ្មែរក្រហមបានប្រព្រឹត្ត ។ ដំណើរទស្សនកិច្ចនេះបានបញ្ចូលមនុស្សគ្រប់ស្រទាប់វណ្ណៈក្នុងសង្គមដូចជាដូនជី ជនជាតិ ខ្មែរអ៊ីស្លាម សិស្ស និស្សិត និងអ្នកភូមិដែលរស់នៅក្នុងតំបន់ក្រីក្រនានាទូទាំងប្រទេសដែលមិនមានលទ្ធភាពទទួលបានព័ត៌មានផ្សេងៗ ។ ដំណើរទស្សនកិច្ចនេះដើម្បីបង្ហាញថា តុលាការនឹងមានប្រសិទ្ធភាពបើសិនជាមានការចូលរួមពីជនរងគ្រោះ ។ ខ្សែភាពយន្តនេះបង្ហាញពីដំណើរទស្សនកិច្ចនេះនិងអំពីទស្សនៈយល់ឃើញរបស់អ្នកភូមិជុំវិញរបបខ្មែរក្រហមនិងដំណើរក្តីខ្មែរក្រហម ។*

**ញាណ សុជាតិ**

# របាយការណ៍អំពីវគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានក្នុងខេត្តស្វាយរៀង ថ្ងៃទី២៨-៣០ ខែមិថុនា ឆ្នាំ ២០១០


***សេចក្តីសង្ខេប***

ថ្មីៗនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានិងក្រសួងអប់រំ យុវជន និង កីឡា បានបើកវគ្គបណ្តុះបណ្តាលចំនួនមួយសប្តាហ៍ ដល់គ្រូថ្នាក់ខេត្តចំនួន១០០នាក់ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-៧៩ នៅទីរួមខេត្តស្វាយរៀង ។ ក្នុងអំឡុងពេលវគ្គបណ្តុះបណ្តាលនេះ គ្រូថ្នាក់មូលដ្ឋានបានទទួលនូវបទបង្ហាញពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» រួមជាមួយនឹងវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រនេះប្រកបដោយប្រសិទ្ធភាព ។

វគ្គបណ្តុះបណ្តាលនេះផ្តោតទៅលើសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ពីឆ្នាំ ១៩៧៥-១៩៧៩ ដែលនិពន្ធឡើងដោយលោក ឌី ខាំបូលី និងសៀវភៅណែនាំគ្រូបង្រៀនអំពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលរៀបរៀងដោយបណ្ឌិត ជា ផល្លា និង លោក គ្រីស ដៀរីង ។

វគ្គបណ្តុះបណ្តាលគ្រូគឺជាកម្មវិធីអប់រំអំពើប្រល័យពូជសាសន៍ដែលជាគម្រោងដ៏ធំមួយទទួលការអនុញ្ញាតដោយរដ្ឋាភិបាលកម្ពុជា ។ ក្រសួងអប់រំ យុវជន និងកីឡា ដែលជាដៃគូរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្នើឡើងថា រាល់វិទ្យាល័យនិងស្ថាប័នអប់រំជាន់ខ្ពស់នឹងត្រូវបានបញ្ចូលនូវកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍ក្នុងកម្មវិធីសិក្សានៅឆ្នាំ២០១១ ។ កម្មវិធីសិក្សាក៏បានស្នើឲ្យគ្រូប្រវត្តិវិទ្យានៅគ្រប់អនុវិទ្យាល័យទាំងអស់ចូលរួមវគ្គបណ្តុះបណ្តាលគ្រូស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ និង វិធីសាស្ត្របង្រៀនដើម្បីទទួលបាននូវវិញ្ញាបនបត្រដែលអាចយកទៅបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបាន ។ របាយការណ៍នេះនឹងនិយាយលម្អិតអំពីការរៀបចំវគ្គបណ្តុះបណ្តាលគ្រូថ្នាក់ខេត្តដែលបានធ្វើចាប់តាំងពីថ្ងៃទី២៨ ដល់៣០ ខែមិថុនា ឆ្នាំ២០១០ នៅទីរួមខេត្តស្វាយរៀង ។


ក្នុងអំឡុងពេលវគ្គសិក្សានេះ គ្រូថ្នាក់មូលដ្ឋានទទួលបាននូវគរុកោសល្យក្នុងការបង្រៀននិងបទបង្ហាញពីប្រវត្តិសាស្ត្រដោយគ្រូថ្នាក់ខេត្តចំនួនដប់រូបនិងថ្នាក់ជាតិចំនួនពីររូប ។ គ្រូថ្នាក់ជាតិគឺជាគ្រូដែលបានទទួលវគ្គបណ្តុះបណ្តាលមុនគ្រូថ្នាក់ខេត្ត ។ គ្រូថ្នាក់ខេត្តទាំងអស់ទទួលបាននូវសម្ភារៈឧបទេ្ទសដូចជា សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ សៀវភៅណែនាំគ្រូ សៀវភៅលំហាត់សិស្ស សទ្ទានុក្រមទាក់ទងទៅនឹងរបបខ្មែរក្រហម កាលប្បវត្តិតុលាការខ្មែរក្រហម បញ្ជីគុកខ្មែរក្រហម ផែនទីកម្ពុជាប្រជាធិបតេយ្យ ផែនទីរណ្តៅសាកសព ល្ខោននិយាយរឿងទម្លាយភាពស្ងប់ស្ងាត់ ទស្សនាវដ្តីស្វែងរកការពិត និងសៀវភៅណែនាំសំណុំរឿង០០២ និងកាលបរិច្ឆេទ និងរបៀបវារៈនៃវគ្គបណ្តុះបណ្តាលនេះ ។

នៅអំឡុងពេលវគ្គសិក្សា សិក្ខាកាមជាច្រើនបានរៀបរាប់ពីបទពិសោធន៍តាមរយៈការចងចាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងខណៈពេលដែលសិក្ខាកាមខ្លះទន្ទឹងរង់ចាំស្តាប់នូវរឿងរ៉ាវរបស់សិក្ខាកាមផ្សេងទៀត ។ ការរៀបរាប់រឿងរ៉ាវដែលបានជួបប្រទះទាំងអស់នេះបង្ហាញឲ្យឃើញនូវសារប្រយោជន៍នៃវគ្គសិក្សាដើម្បីជួយទៅដល់ការផ្សះផ្សាជាបុគ្គលនិងជារួម ។ ចំណែកទិសដៅចុងក្រោយ គឺការបង្រៀនសិស្សអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ គ្រូជាច្រើនបានមកចូលរួមវគ្គសិក្សាជាមួយនឹងបទពិសោធន៍តិចតួចអំពីរបបកម្ពុជាប្រជាធិបតេយ្យ ។ កម្មវិធីសិក្សានេះបានផ្តល់ឲ្យអ្នករស់រានមានជីវិតនិងកូនរបស់ជនរងគ្រោះនូវចំណេះដឹងផ្នែកប្រវត្តិសាស្ត្រដើម្បីគិតពិចារណានូវបទពិសោធន៍ផ្ទាល់ខ្លួន រួមគ្នា ឬ គិតពិចារណាដល់រឿងរ៉ាវសាច់ញាតិរបស់គេ ។

សកម្មភាពដំបូងមុនពេលរៀបចំវគ្គបណ្តុះបណ្តាលនៅខេត្តស្វាយរៀងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូខ្លះៗរួចមកហើយ ។ វគ្គបណ្តុះ

បណ្តាលថ្នាក់ជាតិលើកដំបូងគឺមានចំនួន៤៩រូបក្នុងនោះរួមមាន មន្ត្រីមកពីក្រសួងអប់រំ និង បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ រយៈពេលប្រាំពីរថ្ងៃនៃវគ្គបណ្តុះបណ្តាលដែលធ្វើនៅខែកក្កដា ឆ្នាំ ២០០៩ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលនូវគរុកោសល្យនៃការបង្រៀនពីសាស្ត្រាចារ្យអន្តរជាតិដែលជាអ្នកមានចំណេះដឹងជ្រៅជ្រះពីរបបខ្មែរក្រហមនិងការអនុវត្តជាក្រុមតូចៗនូវមេរៀនគម្រូដែលយកចេញមកពីសៀវភៅណែនាំគ្រូបង្រៀន ដើម្បីបម្រើតួនាទីជាមេក្រុម ឬដើរតួនាទីជាគ្រូថ្នាក់ជាតិនៅក្នុងវគ្គបណ្តុះបណ្តាល ។

នៅខែធ្នូ ឆ្នាំ២០០៩ គ្រូបង្គោលថ្នាក់ជាតិបានទៅបណ្តុះបណ្តាលបន្តដល់គ្រូថ្នាក់ខេត្តផ្នែកប្រវត្តិសាស្ត្រ សីលធម៌ពលរដ្ឋ និងអក្សរសាស្ត្រចំនួន១៨០រូប បន្ទាប់មកបានបែងចែកក្រុមការងារ ដោយបានធ្វើនៅប្រាំមួយទីតាំងដូចជា បាត់ដំបង ភ្នំពេញ កណ្តាល ព្រៃវែង កំពង់ចាម និង តាកែវ ។ អនុលោមទៅតាមទម្រង់បែបបទនៃការបង្រៀនស្រដៀងគ្នានៃវគ្គបណ្តុះបណ្តាលគ្រូថ្នាក់ជាតិ គ្រូថ្នាក់ខេត្តបានធ្វើបទបង្ហាញនូវចំណុចសំខាន់ៗដល់គ្រូថ្នាក់មូលដ្ឋាននូវមេរៀនដែលដកស្រង់មកពីសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» បង្រៀននូវមេរៀនគំរូចេញពីសៀវភៅណែនាំគ្រូ និងសម្របសម្រួលសកម្មភាពក្រុម ។ រៀងរាល់រសៀល គ្រូថ្នាក់មូលដ្ឋានបំបែកគ្នាជាក្រុមតូចៗដើម្បីឡើងអនុវត្តមេរៀននៅក្នុងសៀវភៅណែនាំគ្រូបង្រៀន ។ ការបញ្ចាំងកុន ចម្រៀង ល្បែងកំសាន្ត និង បទបឋកថា ត្រូវបានអនុវត្តនៅក្នុងវគ្គសិក្សានេះដែរ ។ គ្រូបង្គោលថ្នាក់ជាតិបានបន្តការបណ្តុះបណ្តាលទូទាំងប្រទេស ។ វគ្គបណ្តុះបណ្តាលក្នុងខែមិថុនាក៏បានធ្វើនៅក្នុងខេត្តសៀមរាប និងខេត្តពោធិ៍សាត់ផងដែរ ។

## ការរៀបចំវគ្គបណ្តុះបណ្តាលគ្រូ

### ក) វគ្គណែនាំពីកិច្ចការមួយចំនួន

វគ្គបណ្តុះបណ្តាលនៅក្នុងខេត្តស្វាយរៀងបានចាប់ផ្តើមដោយមានការគោរពពិធីបើកវគ្គ ។ វគ្គមានអ្នកបណ្តុះបណ្តាលរួមមានគ្រូថ្នាក់ជាតិពីរនាក់ គ្រូថ្នាក់ខេត្តដប់នាក់ គ្រូថ្នាក់មូលដ្ឋាន ១០០នាក់ ។ នៅក្នុងពិធីបើកវគ្គនោះ មានការចូលរួមពីប្រធានមន្ទីរអប់រំយុវជននិងកីឡាលោក កែវ ចាន់ និងលោក សោ ស៊ីថា ព្រមទាំងតំណាងមជ្ឈមណ្ឌលឯកសារកម្ពុជាពីរនាក់គឺលោក វ៉ាន់ថាន់ ពៅដារ៉ា និង លោក ញាណ សុជាតិ ។

នៅក្នុងសេចក្តីថ្លែងសុន្ទរកថា លោក វ៉ាន់ថាន់ ពៅដារ៉ា បានរៀបរាប់ដោយសង្ខេបពីគម្រោងនៃវគ្គបណ្តុះបណ្តាលនិង ការរំពឹងទុកចំពោះវគ្គបណ្តុះបណ្តាលនេះ ។ លោក វ៉ាន់ថាន់ ពៅដារ៉ា បានសំណូមពរឲ្យសិក្ខាកាមដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាលយកចិត្តទុកដាក់ដើម្បីទទួលបានវិញ្ញាបនបត្រ ហើយលោក ដារ៉ា បន្ថែមទៀតថា គ្រូថ្នាក់មូលដ្ឋានម្នាក់ៗត្រូវឡើងបង្រៀនមេរៀនគំរូពីរ ដើម្បីបង្ហាញពីចំណេះដឹងរបស់ខ្លួនជាមួយសម្ភារៈឧបទេស និង វិធីសាស្ត្រ ហើយទីបញ្ចប់លោកបានរៀបរាប់ពីប្រវត្តិដែលនាំទៅដល់កម្មវិធីអប់រំអំពើប្រល័យពូជសាសន៍នៅពេលនេះ ។ គាត់បានលើកឡើងថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការបណ្តុះបណ្តាលគ្រូថ្នាក់ជាតិរួចហើយដែលមួយចំនួននៃពួកគាត់នឹងទទួលខុសត្រូវចំពោះវគ្គបណ្តុះបណ្តាល រួចបន្តដល់គ្រូថ្នាក់មូលដ្ឋានក្នុងពេលឥឡូវនេះ ។ លោក វ៉ាន់ថាន់ ពៅដារ៉ា ក៏បានប្រាប់ដល់គ្រូអំពីពាក្យស្លោកដែលរៀបរាប់អំពីវិធានការទប់ស្កាត់អំពើប្រល័យពូជសាសន៍ដែលក្រសួងអប់រំបានអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាបង្រៀនតាមសាលារៀន ។ មិនតែប៉ុណ្ណោះ គាត់បានបញ្ជាក់ទៅលោកគ្រូអ្នកគ្រូទាំងអស់ថា ទិសដៅនៃវគ្គបណ្តុះបណ្តាលនេះគឺដើម្បីបង្រៀនដល់ក្មេងជំនាន់ក្រោយអំពីរបបកម្ពុជាប្រជាធិបតេយ្យ ជំរុញដល់ការផ្សះផ្សាជាតិ និងការពារអំពើប្រល័យពូជសាសន៍មិនឲ្យកើតឡើងម្តងទៀតនៅពេលអនាគត និងសំណូមពរឲ្យលោកគ្រូអ្នកគ្រូយកចិត្តទុកដាក់និងខិតខំរៀនសូត្រអស់ពីសមត្ថភាព ។

បន្ទាប់មក លោក កែវ ចាន់ ប្រធានមន្ទីរអប់រំខេត្តបានឡើងមានមតិថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាក៏ដូចជាគ្រូថ្នាក់មូលដ្ឋានដែលបានចូលរួមនៅថ្ងៃនេះ ហើយលោកក៏បានធ្វើការសង្កត់ធ្ងន់ពីតម្រូវការចាំបាច់នូវការរៀនសូត្រពីប្រវត្តិពិតរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ លោក កែវ ចាន់ បានមានប្រសាសន៍ថា គ្រូភាគច្រើនបានដឹងពីរបបកម្ពុជាប្រជាធិបតេយ្យតាមរយៈឪពុកម្តាយ ឬយាយតា លោកក៏បានណែនាំដល់គ្រូថ្នាក់មូលដ្ឋានទាំងអស់កុំឲ្យងាករេចេញពីសៀវភៅសិក្សា

និងខិតខំយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្ន ។ បន្ទាប់មក លោក សោ ស៊ីថា ក៏ឡើងមានមតិចុងក្រោយដោយប្រាប់អំពីសារសំខាន់នៃការបង្រៀនដោយធ្វើយ៉ាងណាអោយមានភាពងាយស្រួលនៅពេលបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនិងអំពីគុលាការខ្មែរក្រហម ហើយលោក សោ ស៊ីថា ក៏បានបន្ថែមទៀតថា លោកគ្រូ-អ្នកគ្រូត្រូវតែចូលរួមវគ្គសិក្សានេះឲ្យបានរៀងរាល់ថ្ងៃដើម្បីទទួលបានសញ្ញាបត្របញ្ចប់ការសិក្សា ។

### ខ) គម្រោងកម្មវិធីនៃវគ្គបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលនៅក្នុងខេត្តស្វាយរៀងនេះបានអនុលោមទៅតាមទម្រង់បែបបទដូចវគ្គបណ្តុះបណ្តាលមុនៗដែរ ។ ជារៀងរាល់ព្រឹក គ្រូថ្នាក់មូលដ្ឋានចំនួន១០០នាក់ត្រូវបានបំបែកចេញជាពីរក្រុមដែលមួយក្រុមមានចំនួន៥០នាក់ ហើយការសិក្សាត្រូវបានចែកចេញជាពីរពេល ។ គ្រូបង្គោលថ្នាក់ជាតិចំណាយពេលវេលាពេញមួយព្រឹកដើម្បីធ្វើបទបង្ហាញសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងអំពីវិធីសាស្ត្រនៃការបង្រៀនសៀវភៅប្រវត្តិសាស្ត្រ ។ គ្រូបង្គោលថ្នាក់ជាតិធ្វើការជាមួយគ្រូថ្នាក់ខេត្តពីការឡើងបង្រៀនមេរៀនគំរូដែលដកស្រង់ពីសៀវភៅណែនាំគ្រូបង្រៀន ។

នៅពេលរសៀល គ្រូមូលដ្ឋានទាំងអស់ត្រូវបានរៀបចំឲ្យទៅជាក្រុមតូចៗចំនួន១០ក្រុម ។ គ្រូថ្នាក់មូលដ្ឋានបួននាក់ក្នុងមួយថ្ងៃតម្រូវឲ្យធ្វើការបង្រៀនមេរៀនប្រវត្តិសាស្ត្រ ដោយចាត់ទុកលោកគ្រូ-អ្នកគ្រូដ៏ទៃទៀតជាកូនសិស្ស ។ បន្ទាប់ពីអនុវត្តបង្រៀនមេរៀនគំរូ សមាជិកនៅក្នុងក្រុមតូចៗតម្រូវឲ្យផ្តល់ការរិះគន់និងកែលម្អ ។ គ្រូបង្គោលថ្នាក់ជាតិនិងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាត្រួតពិនិត្យទៅលើការបង្រៀនមេរៀនគំរូនីមួយៗនិងធ្វើការសង្កេតពីសកម្មភាពបង្រៀនរបស់សិក្ខាកាមដើម្បីផ្តល់មតិកែលម្អ ។

នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល មានការជួបប្រជុំគ្នាទាំងគ្រូថ្នាក់ជាតិនិងថ្នាក់ខេត្ត ហើយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាសួរនាំទៅគ្រូទាំងអស់នោះដើម្បីរកចំណុចខ្លាំងនិងខ្សោយសម្រាប់ថ្ងៃនីមួយៗ ។

### សកម្មភាពនៃវគ្គបណ្តុះបណ្តាល

#### ក) មេរៀនប្រវត្តិសាស្ត្រ

ជារៀងរាល់ព្រឹក គ្រូថ្នាក់ជាតិឬថ្នាក់ខេត្តម្នាក់នៃគ្រូថ្នាក់ជាតិឡើងធ្វើបទបង្ហាញពីរមេរៀននៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ មាតិកានៃសៀវភៅមេរៀនត្រូវបានបង្ហាញជាច្រើនដងក្នុងមួយថ្ងៃៗ និងពេញមួយសប្តាហ៍ ។ សៀវភៅមេរៀនផ្តល់នូវរឿងរ៉ាវប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបានយ៉ាងក្បោះក្បាយ ។ សៀវភៅប្រវត្តិសាស្ត្របានបញ្ជាក់ពីរបបកុម្មុយនីស្ត តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា? រចនាសម្ព័ន្ធរដ្ឋបាលខ្មែរក្រហម ជីវិតរស់នៅប្រចាំថ្ងៃនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទារុណកម្មនៅក្នុងមន្ទីរស-២១ ការទំនាក់ទំនងរបស់វៀតណាម និងការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

#### ខ) មេរៀនផ្នែកគរុកោសល្យ

ការផ្តោតជាសំខាន់នៅក្នុងវគ្គបណ្តុះបណ្តាលនេះគឺទេពកោសល្យក្នុងការបង្រៀន ។ គោលដៅនៃកម្មវិធីសិក្សាគឺដើម្បីភ្ជាប់សិស្សានុសិស្សនិងបង្រៀនសិស្សឲ្យចេះត្រិះរិះពិចារណា ។ គ្រូថ្នាក់ជាតិបានមានប្រសាសន៍ថា គ្រូថ្នាក់មូលដ្ឋានទាំងអស់បង្ហាញសិស្សពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដោយប្រើប្រាស់វិធីសាស្ត្របីជំហានគឺ រំឭកមេរៀន ស្រាវជ្រាវ និងសង្ខេប ។ ការរំឭកមេរៀនជាការបង្ហាញជាទូទៅឬមូលដ្ឋានគ្រឹះដល់សិស្ស ។ ស្រាវជ្រាវគឺជាការផ្តល់សិស្សនូវឱកាសដើម្បីអានសៀវភៅ និងចែករំលែកគំនិតផ្ទាល់ខ្លួន និងបទពិសោធន៍នានា ។ សរុបសេចក្តីនេះជាការរួមផ្សំនូវគំនិតដ៏ធំនិងដើម្បីវាយតម្លៃនូវអ្វីដែលកូនសិស្សបានរៀន ។

គ្រូអនុវត្តន៍វិធីសាស្ត្របង្រៀនដោយការប្រើប្រាស់សៀវភៅលំហាត់សិស្ស ។ ឧទាហរណ៍មួយទាក់ទងនឹងការប្រើប្រាស់រូបថតរបស់ អៀង ធិរិទ្ធ ។ គ្រូអានសក្ខីកម្មផ្សេងគ្នាដែលបង្ហាញពីបទពិសោធន៍ផ្សេងគ្នា និងគំនិតរបស់មនុស្សម្នាក់ៗចំពោះ អៀង ធិរិទ្ធ ។ បន្ទាប់មក គ្រូថ្នាក់ខេត្តទាំងអស់តម្រូវឲ្យធ្វើការប្រៀបធៀបគំនិត និងសរសេរនូវការគិតរបស់ខ្លួនលើសក្ខីកម្មទាំងពីរ ។ គោលដៅរបស់មេរៀនគឺធ្វើឲ្យសិស្សយល់ពីប្រវត្តិសាស្ត្រផ្សេងគ្នាទៅតាមមនុស្សម្នាក់ដែលបានជួបហេតុការណ៍ផ្សេងគ្នា ។

វិធីសាស្ត្រផ្សេងទៀតដើម្បីពន្យល់អំពីវិធីសាស្ត្រនៃការបង្រៀន គឺការប្រើប្រាស់តារាង *K W L* ។ *K* មានន័យថាអ្វីដែលយើងបានដឹងពីមុន។ *W* មានន័យថាអ្វីដែលយើងចង់ដឹង និង *L* មានន័យថាអ្វីដែលយើងបានរៀនរួចហើយ ។ នៅក្នុងថ្នាក់ គ្រូសួរទៅកាន់សិស្សរបស់ខ្លួននូវអ្វីដែលពួកគេបានដឹងរួចហើយអំពីពាក្យឬបុគ្គលណាមួយនិងសួរទៅកាន់សិស្សថាអ្វីទៀតដែលសិស្សចង់ដឹងទាក់ទងទៅនឹងមេរៀន ហើយបន្ទាប់មកគ្រូនិងសិស្សធ្វើការវាយតម្លៃពីអ្វីដែលគេបានរៀនពីមេរៀន ។

គ្រូថ្នាក់មូលដ្ឋានបានអនុវត្តនូវវិធីសាស្ត្រនេះដដែលៗ ។ គ្រូថ្នាក់មូលដ្ឋានមានការព្រួយបារម្ភពីបញ្ហាមួយចំនួន។ ទីមួយ គ្រូថ្នាក់មូលដ្ឋានមានការបារម្ភថាត្រូវធ្វើយ៉ាងដូចម្តេចដើម្បីឲ្យសិក្ខាកាមផ្សេងទៀតរក្សាប្រធានបទនៃការពិភាក្សារបស់ខ្លួន ដើម្បីកុំឲ្យមានការប្រាកចាកពីប្រធានបទ។

### ក) ក្រុមតូចៗបង្រៀនមេរៀនគំរូ

គ្រូទាំងអស់ត្រូវបំបែកឲ្យទៅជាក្រុមតូចៗ ។ គ្រូចំនួនបួននាក់ក្នុងចំណោមគ្រូដប់នាក់នឹងត្រូវឡើងបង្រៀនមេរៀនតូចដល់មិត្តភក្តិរួមក្រុមដែលយកចេញពីសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ហើយមេរៀននីមួយៗមានរយៈពេល ៣០នាទី។ មុនពេលការបង្រៀនមេរៀនតូចៗ គ្រូថ្នាក់មូលដ្ឋានត្រូវប្រាប់ពីរបៀបដែលពួកគាត់ធ្វើការវាយតម្លៃ ។ គ្រូថ្នាក់មូលដ្ឋានត្រូវបានស្នើឲ្យផ្តល់ការទិតៀន និងបំពេញលើតារាងវាយតម្លៃបន្ទាប់ពីចប់ការបង្រៀនមេរៀននីមួយៗ ។ បន្ថែមពីលើនោះទៀត ក្នុងការត្រួតពិនិត្យឡើងវិញដោយមិត្តភក្តិរួមក្រុម គ្រូថ្នាក់ជាតិ និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជានឹងត្រួតពិនិត្យមើលលើការបង្រៀនមេរៀននីមួយៗដែរ ។ នៅថ្ងៃដំបូងនៃការឡើងបង្រៀនមេរៀនតូចៗ គ្រូថ្នាក់ជាតិម្នាក់នឹងចុចគ្រូថ្នាក់ខេត្តម្នាក់ឲ្យឡើងបង្រៀន។

គ្រូថ្នាក់ជាតិបាននិយាយអំពីការគ្រប់គ្រងថ្នាក់ ការផ្សព្វផ្សាយព័ត៌មានជាក់លាក់ ការសម្របសម្រួលការទំនាក់ទំនងសិស្ស និងការវាយតម្លៃចំណេះដឹង និងសកម្មភាពសិស្ស ។

### ឃ) សកម្មភាពបង្រៀនតាមរយៈរូបភាព និង វាគ្មិន

រូបថត កុន និងចម្រៀងត្រូវបានបញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលនេះ ។ កុនមួយចំនួនដែលត្រូវបានបញ្ចាំងរួមមាន មន្ទីរស-២១ បន្ទាប់ពីឆ្នាំ១៩៧៩ ថតនៅភ្នំបាសិត និង ព្រៃវែង និងកៀនជញ្ជាំងនៃមន្ទីរស-២១ ។ ការបញ្ចាំងកុននេះកាន់តែធ្វើឲ្យវគ្គបណ្តុះបណ្តាលមានប្រសិទ្ធភាពថែមទៀត ។ ឧទាហរណ៍ ការបង្រៀនមេរៀនចុងក្រោយអំពីការដួលរលំរបស់ខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ចាំងកុនពីកុមារក្រោយរបបខ្មែរក្រហម ។ គ្រូថ្នាក់មូលដ្ឋានបានផ្តោតអារម្មណ៍យ៉ាងខ្លាំងជាមួយនឹងសាច់រឿងនៅក្នុងកុន។ គ្រូថ្នាក់ជាតិ និងថ្នាក់ខេត្តសម្តែងពីការអាណិតអាសូរ និងសោកស្តាយនូវអ្វីដែលបានឃើញពីការតស៊ូរបស់កុមារតូចដែលបានប្រឈមមុខនៅពេលនោះ ។ ការបញ្ចាំងកុននេះមានបំណងចង់ឲ្យសិក្ខាកាមទាំងអស់គិតពិចារណាមិនត្រឹមតែទៅលើការប្រឈមមុខរបស់កុមារតូចៗក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ថែមទាំងគិតដល់ការប្រឈមមុខដែលបានបន្សល់ទុករហូតមកដល់សព្វថ្ងៃនេះទៀត ។ នេះជាហេតុផលមួយនៃការជំរុញគ្រូ និងកូនសិស្សគួរតែយកចិត្តទុកដាក់ និងសិក្សាអំពីប្រវត្តិសាស្ត្រនេះ ។

លោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាបានសំណេះសំណាលជាមួយលោកគ្រូ-អ្នកគ្រូនៅថ្ងៃចុងក្រោយនៃវគ្គសិក្សា ។ គាត់បាននិយាយអំពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រ និងផលលំបាកផ្សេងៗដែលអាចកើតមានឡើង ។ ឧទាហរណ៍នៅពេលដែលឪពុកម្តាយរបស់សិស្សគឺជាខ្មែរក្រហម ពេលនោះសិស្សនោះនឹងនិយាយថាការបង្រៀនរបស់គ្រូខុស ហើយគ្រូត្រូវរកវិធីដោះស្រាយ ។ ពេលនោះ លោក ឆាំង យុ បានផ្តល់នូវអនុសាសន៍ភ្លាមថា លោកគ្រូ-អ្នកគ្រូត្រូវផ្អែកលើប្រវត្តិសាស្ត្រពិត និងប្រើប្រាស់នូវឯកសារដើម្បីគាំទ្រនូវប្រវត្តិសាស្ត្រពិតនោះ ។ គាត់បានសង្កត់ធ្ងន់ផងដែរថា វាមានសំខាន់ណាស់សម្រាប់លោកគ្រូ-អ្នកគ្រូដើម្បីកុំឲ្យមានការសងសឹកចំពោះខ្មែរក្រហមដែលបានធ្វើអំពើអាក្រក់ ពីព្រោះកូនសិស្សខ្លះអាចមានឪពុកម្តាយជាអតីតកម្មាភិបាលខ្មែរក្រហម ។ ចុងក្រោយ គាត់បានណែនាំថា ធ្វើយ៉ាងណាកុំឲ្យប៉ះពាល់ដល់អារម្មណ៍សិស្ស ។ គាត់បន្ថែមទៀតថា ទិសដៅនៃការបង្រៀនប្រវត្តិសាស្ត្រនេះមិនមែនជាការដាក់ទោសទេ ប៉ុន្តែជាការផ្សះផ្សា ។ **អេមី ហេះណាស**

# តើមានការជ្រៀតជ្រែកផ្នែកនយោបាយនៅអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជាដែរឬទេ?

នៅថ្ងៃទី ២៦ កក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) គ្រោងនឹងធ្វើការប្រកាសសាលក្រមជាលើកដំបូងបង្អស់ក្នុងតុលាការកាត់ទោសខ្មែរក្រហម ។ សាលក្រម កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាអតីតប្រធានមន្ទីរស-២១ ដែលជាគុកដ៏មានលក្ខណៈព្រៃផ្សៃបំផុតក្រោមការដឹកនាំរបស់ខ្មែរក្រហមគឺជាឱកាសប្រវត្តិសាស្ត្រមួយសម្រាប់ប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិ ។ នេះមិនគ្រាន់តែជាសញ្ញាណនៃភាពរីកចម្រើនទៅមុខក្នុងនាមប្រទេសដែលធ្លាប់ញាំញីដោយសង្គ្រាមប៉ុណ្ណោះទេ ប៉ុន្តែនេះជាកំណត់ហេតុប្រវត្តិសាស្ត្រសម្រាប់អ្នកសិទ្ធិមនុស្សអន្តរជាតិដែលបានធ្វើការដោយមិនខ្វាចនឿយហត់ដើម្បីបង្កើតឲ្យមានតុលាការកូនកាត់ពិសេសមួយនេះ ។

កិច្ចការរបស់ អ.វ.ត.ក គឺជាពិសោធន៍ថ្មីមួយក្នុងច្បាប់អន្តរជាតិ ហើយតាមរយៈកិច្ចការនេះក៏បានទទួលការរិះគន់ផងដែរ ។ ថ្មីៗនេះ អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សម្រាប់សង្គមបើកចំហបានចេញរបាយការណ៍មួយដោយចោទថា មានការជ្រៀតជ្រែកផ្នែកនយោបាយពីសំណាក់រដ្ឋាភិបាលកម្ពុជានៅក្នុងដំណើរការតុលាការ ។ របាយការណ៍នោះបានចោទប្រកាន់ទៅលើករណីពីរប្រការ ១) ភាពចម្រូងចម្រាសទៅលើករណីចោទប្រកាន់ជនជាប់ចោទប្រាំនាក់បន្ថែមទៀតសម្រាប់ករណី០០៣ និង ០០៤ និង ២) ការបដិសេធរបស់មន្ត្រីរដ្ឋាភិបាលចំនួនប្រាំមួយនាក់ក្នុងការចូលមកឆ្លើយសំណួរនៅការិយាល័យសហចៅក្រមស៊ើបអង្កេត ។

នៅពេលការរិះគន់ខ្លះចំពោះប្រព័ន្ធស្វែងរកយុត្តិធម៌របស់កម្ពុជា និងចំពោះ អ.វ.ត.ក ខ្លួនឯង អាចនឹងមានការត្រឹមត្រូវហើយក៏មានប្រយោជន៍ដែរនោះ របាយការណ៍របស់អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សម្រាប់សង្គមបើកចំហមានលក្ខណៈមិនច្បាស់លាស់មួយចំនួនផងដែរ ។ ទីមួយ របាយការណ៍នោះបានសម្អាងថា ការជ្រៀតជ្រែកផ្នែកនយោបាយនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺអាចមើលឃើញច្បាស់ក្រឡែតដោយផ្អែកលើការសិក្សានិងផ្តោតទៅលើប្រព័ន្ធតុលាការក្នុងស្រុក ។ ទីពីរ ការវិវាទគ្នាទៅលើករណី០០៣ និង ០០៤ បានផ្តល់ភស្តុតាងថា វិធានផ្ទៃក្នុងរបស់តុលាការមានប្រសិទ្ធភាពក្នុងការបញ្ជាក់ថាមានការជ្រៀតជ្រែកផ្នែកនយោបាយ ។ ទីបី ការបដិសេធពីសំណាក់មន្ត្រីរដ្ឋាភិបាលកម្ពុជាក្នុងការសហការជាមួយតុលាការគឺជាឧទាហរណ៍មួយដ៏ច្បាស់អំពីភាពអសកម្មរបស់អង្គការសហប្រជាជាតិជាជាងការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាល ។ ហើយទីបញ្ចប់ របាយការណ៍របស់អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សម្រាប់សង្គមបើកចំហបានមើលរំលងភាពមានសារសំខាន់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងក្នុងការអភិវឌ្ឍច្បាប់កម្ពុជា និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។

ការសម្អាងរបស់អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សម្រាប់សង្គមបើកចំហអំពីការជ្រៀតជ្រែកផ្នែកនយោបាយដោយផ្អែកទៅលើការសិក្សារបាយការណ៍របស់អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សម្រាប់សង្គមបើកចំហបានប្រើប្រាស់ការសិក្សាលើភាពខ្វះខាតរបស់តុលាការក្នុងស្រុករបស់កម្ពុជាជាភស្តុតាងចំពោះភាពខ្វះខាតរបស់ អ.វ.ត.ក ។ របាយការណ៍មិនបានដកស្រង់ចំណុចសំខាន់ករណីសិក្សាដែលគាំទ្រការចោទប្រកាន់អំពីការជ្រៀតជ្រែកផ្នែកនយោបាយនៅក្នុងដំណើរការរបស់ អ.វ.ត.ក នោះទេ ។ តាមពិតការសិក្សាភាគច្រើនដែលបានដកស្រង់នៅក្នុងរបាយការណ៍ផ្អែកទៅលើប្រព័ន្ធតុលាការក្នុងស្រុកតែមួយគត់ ហើយត្រូវបានសរសេរឡើងមុនខែកុម្ភៈ ឆ្នាំ២០០៩ នៅពេលដែលសវនាការឌុច ចាប់ផ្តើម ។ ឧទាហរណ៍ របាយការណ៍របស់សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្សលីកាដូបានបញ្ចប់នៅក្នុងឆ្នាំ២០០៧ ។ របាយការណ៍ពីរទៀត មួយមកពីអង្គការឃ្លាំមើលសិទ្ធិមនុស្ស និងមួយទៀតមកពីអង្គការលើកលែងទោសអន្តរជាតិត្រូវបានបោះពុម្ពក្នុងខែមេសា ឆ្នាំ២០០៣ ។

លើសពីនោះទៅទៀត គ្មានរបាយការណ៍ណាមួយមកពីការិយាល័យសហរដ្ឋអាមេរិកសម្រាប់លិទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងពលកម្មទេ ដែលរបាយការណ៍ចំនួនពីរត្រូវបានដកស្រង់ដោយបានចោទប្រកាន់ពីភាពលម្អៀងឬការជ្រៀតជ្រែកផ្នែកនយោបាយ នៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ របាយការណ៍របស់សហរដ្ឋអាមេរិកក្នុងឆ្នាំ២០០៨ បានរៀបរាប់អំពី អ.វ.ត.ក ត្រឹមតែមួយកថាខ័ណ្ឌប៉ុណ្ណោះនៅក្នុងផ្នែកតុលាការសាធារណៈ ។ របាយការណ៍ឆ្នាំ ២០០៩ បានរៀបរាប់ក្បោះក្បាយជាងមុនដោយអះអាងថា ការចោទប្រកាន់អំពីការជ្រៀតជ្រែកផ្នែកនយោបាយ នៅក្នុង អ.វ.ត.ក គឺគ្មានមូលដ្ឋានច្បាស់លាស់ ៖

*គ្មានការចោទប្រកាន់ពីករណីពុករលួយ នៅក្នុងរដ្ឋបាលតុលាការទេនៅក្នុងឆ្នាំនេះ ។ អ្នកសង្កេតការខ្លះមានជំនឿថា ការបញ្ចេញយោបល់ជាសាធារណៈដោយថ្នាក់ដឹកនាំរដ្ឋាភិបាលអំពីបញ្ហាផ្សេងៗទាក់ទងទៅនឹងអាណត្តិផ្លូវច្បាប់របស់អ.វ.ត.ក បានបង្កើតទម្រង់បែបបទនៃការជ្រៀតជ្រែកផ្នែកនយោបាយ ។ ប៉ុន្តែ គ្មានភ័ស្តុតាងណាបង្ហាញថា កិច្ចការរបស់តុលាការបានបង្អាក់តាមមធ្យោបាយណាមួយនោះទេ ហើយបុគ្គលិកជាតិបានបំពេញការងារនិងភារកិច្ចរបស់ខ្លួនបានដោយជោគជ័យ ដើម្បីអនុវត្តនិងប្រគល់ទៅតុលាការនូវជនត្រូវចោទដោយអង្គជំនុំជម្រះ ។*

របាយការណ៍របស់អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សម្រាប់សង្គមបើកចំហក៏បានស្រង់ការវាយតម្លៃរបស់ អ.វ.ត.ក ដោយលោកស្រី ខារ៉ូលីន ឌូបៃ ដែលជាអ្នកត្រួតពិនិត្យរបស់សារព័ត៌មាន *International Judicial Reporter* ។ ដូចគ្នាទៅនឹងរបាយការណ៍របស់អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សម្រាប់សង្គមបើកចំហដែរ លោកស្រី ឌូបៃ បានផ្តោតការរិះគន់របស់គាត់ចំពោះអ.វ.ត.ក ពីករណីរបាយការណ៍ដែលទាក់ទងទៅនឹងភាពមិនគ្រប់លក្ខណៈរបស់ប្រព័ន្ធតុលាការក្នុងស្រុករបស់កម្ពុជានាពេលបច្ចុប្បន្ន ។ អត្ថបទរបស់លោកស្រីបានបញ្ជាក់យ៉ាងច្បាស់អំពីកង្វះខាតនៃការអនុវត្តប្រព័ន្ធច្បាប់និងយុត្តិធម៌នៅក្នុងតុលាការក្នុងស្រុកនិងជះឥទ្ធិពលដល់អ.វ.ត.ក ។ ជាការពិត ការចោទប្រកាន់ចំពោះករណីពុករលួយយ៉ាងជាក់ច្បាស់នៅ អ.វ.ត.ក គឺសំដៅទៅលើការធ្វើសវនកម្មផ្ទៃក្នុងពីខែមករា ឆ្នាំ២០០៧ ដោយស៊ើបអង្កេតអំពីការប្រើប្រាស់ថវិការបស់ភាគីអង្គការសហប្រជាជាតិជាសំណូកសម្រាប់បុគ្គលិកតុលាការ ។ លោកស្រី ឌូបៃ ក៏បានសន្និដ្ឋានរបាយការណ៍របស់គាត់ដោយទទួលស្គាល់ថា ទោះជាមានឧបសគ្គផ្ទៃក្នុងដែលនឹងអាចកើតមានក៏ដោយ «ផលប៉ះពាល់យ៉ាងជាក់ច្បាស់នៃវត្តមានតុលាការខ្មែរក្រហមក្នុងលក្ខណៈជាតិនិងអន្តរជាតិផ្តោតជាសំខាន់ទៅលើដំណើរការស្វែងរកការទទួលខុសត្រូវនិងការប្រតិបត្តិក្នុងវិស័យកំណែទម្រង់វិស័យយុត្តិធម៌គឺមានលក្ខណៈវិជ្ជមាន» ។

ជាការខុសឆ្គងក្នុងការអះអាងអំពីការជ្រៀតជ្រែកផ្នែកនយោបាយ នៅក្នុងអ.វ.ត.ក ថាមានលក្ខណៈច្បាស់លាស់ព្រោះការជ្រៀតជ្រែកដូច្នេះមានលក្ខណៈជាទូទៅនៅក្នុងប្រពន្ធ័តុលាការក្នុងស្រុករបស់កម្ពុជាដែរ ។

ទោះបីជាផ្នែកបច្ចេកទេស អ.វ.ត.ក គឺជាផ្នែកមួយនៃប្រព័ន្ធតុលាការក្នុងស្រុកក៏ដោយ តែការអនុវត្តមិនមានលក្ខណៈដូចគ្នាទាំងស្រុងនោះទេ ។ ចំណុចសំខាន់នៃការបង្កើត អ.វ.ត.ក នេះគឺដើម្បីធ្វើឲ្យប្រព័ន្ធតុលាការនេះមានលក្ខណៈដាច់ដោយឡែកពីប្រព័ន្ធតុលាការក្នុងស្រុក ។

ដូចទៅនឹងរបាយការណ៍ដែលទទួលស្គាល់ ដោយអង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សម្រាប់សង្គមបើកចំហផងដែរ មានការត្រួតពិនិត្យមើលយ៉ាងត្រឹមត្រូវចំពោះការជ្រែកជ្រែកផ្នែកនយោបាយដែលបានសរសេរនៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។ ជាពិសេស របាយការណ៍នេះបានលើកយកចំណុចសំខាន់បីយ៉ាង ១) ការដែលតម្រូវឲ្យសេចក្តីសម្រេចផ្លូវច្បាប់ត្រូវធ្វើឡើងដោយយកមតិភាគច្រើនតាមរយៈការបោះឆ្នោត ២) ទម្រង់បែបបទនៃការដោះស្រាយជម្លោះត្រូវដោះស្រាយចំពោះការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេត និង ៣) ការផ្តល់ជូនដែលមានលក្ខណៈច្បាស់លាស់អនុញ្ញាតដល់អង្គការសហប្រជាជាតិក្នុងការដកជំនួយរបស់ខ្លួនប្រសិនបើរដ្ឋាភិបាលកម្ពុជាមិនបានធ្វើតាមកិច្ចព្រមព្រៀង ។

របាយការណ៍របស់អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សម្រាប់

សង្គមបើកចំហបន្តទៀតថា ចំណុចសំខាន់ៗទាំងបីខាងលើនេះនៅតែមិនមានលក្ខណៈគ្រប់គ្រាន់នៅឡើយទេ ។ ការពិត របាយការណ៍នោះក៏ទទួលស្គាល់ផងដែរថា ការបោះឆ្នោតយកមតិភាគច្រើនដែលតម្រូវឲ្យយ៉ាងហោចណាស់ក៏មានចៅក្រមអន្តរជាតិម្នាក់ដែរជាមួយនិងចៅក្រមជាតិលើសពីមួយគឺមិនមែនជាបញ្ហាចោទនោះទេ ។ របាយការណ៍នោះបានអះអាងថា អំឡុងពេលសវនាការកាត់ទោស ឌុច តម្រូវការចំពោះមតិភាគច្រើន «មិនទំនងជាការរាំងស្ទះនៅក្នុងដំណើរការកាត់សេចក្ដីនេះទេ» ។ លើសពីនេះទៅទៀត នៅពេលដែលចៅក្រមវិនិច្ឆ័យមិនបានធ្វើសេចក្ដីសម្រេចជាឯកច្ឆ័នទៅលើរឿងរ៉ាវដែលទាក់ទងទៅនិងដំណើរការសវនាការនេះ នោះនឹងឃើញមានគម្លាតរវាងភាគីជាតិនិងអន្តរជាតិ ដែលអាចនិយាយបានថា ការជ្រៀតជ្រែកផ្នែកនយោបាយដោយរដ្ឋាភិបាលកម្ពុជាមិនមែនជាបញ្ហាសំខាន់នោះទេ ។

## **ភាពចម្រូងចម្រាស់ទាក់ទងនឹងសំណុំរឿង ០០៣ និង ០០៤**

របាយការណ៍របស់អង្គការគំនិតផ្ដួចផ្ដើមយុត្តិធម៌សម្រាប់សង្គមបើកចំហគឺមានលក្ខណៈត្រឹមត្រូវទាក់ទិននឹងការអះអាងដែលថា សភាពនៃភាពចម្រូងចម្រាស់ក្នុងការដេញដោលឲ្យមានករណីសំណុំរឿង០០៣ និង ០០៤ គឺពិតជាមានការជ្រៀតជ្រែកពីផ្នែកនយោបាយមែន ។ សេចក្ដីថ្លែងការណ៍របស់សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងមន្ត្រីក្នុងជួររដ្ឋាភិបាលផ្សេងៗទៀតទាក់ទិនទៅនឹងការគាំទ្រចំពោះការបដិសេធរបស់សហព្រះរាជអាជ្ញាជាតិក្នុងការដេញដោលករណីសំណុំរឿង ០០៣ និង០០៤ និងការពន្យារពេលរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចាប់ផ្ដើមធ្វើការស៊ើបអង្កេតទៅលើករណីសំណុំរឿងទាំងនោះ គឺពិតជាអំណះអំណាងមួយដែលគាំទ្រការចោទប្រកាន់នេះមែន ។

ប៉ុន្តែ ការជះឥទ្ធិពលនៃការជ្រៀតជ្រែកនេះដូចជាត្រូវបានកាត់បន្ថយដោយសារតែវិធានដែលបង្កើតឡើងក្នុងការបម្រុងភាពចម្រូងចម្រាស់បែបនេះ ។ វិធាន៧២របស់វិធានផ្ទៃក្នុងនៃ អ.វ.ត.ក បានចែងថា នៅពេលដែលមានការចម្រូងចម្រាស់មិនស្របមតិគ្នារវាងសហចៅក្រមស៊ើបអង្កេត «កិច្ចឬសេចក្ដីសម្រេចដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នាត្រូវតែយកទៅអនុវត្ត» ។ ទោះបីជាលោក យូ ប៊ុនឡេង ដែលជាសហចៅក្រមស៊ើបអង្កេតជាតិមិនទាន់ធ្វើការងារអ្វីទាក់ទិននឹងសំណុំរឿង០០៣ និង ០០៤ ក៏ដោយ ក៏លោក ម៉ាសែ្សល ឡឺម៉ុង ដែលជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំពុងតែដំណើរការទៅមុខទាក់ទិននឹងករណីសំណុំរឿងនេះដែរ ។ ការសម្រេចចិត្តនិងសមត្ថភាពក្នុងការស៊ើបដេញដោលលើករណីសំណុំរឿង០០៣ និង០០៤របស់លោក ឡឺម៉ុង នេះសម្ដែងឲ្យឃើញថា ការត្រួតពិនិត្យរបស់សាលាក្ដីទៅលើការជ្រៀតជ្រែកផ្នែកនយោបាយនោះគឺពិតជាមានប្រសិទ្ធភាពមែន ។

វាក៏មានសារសំខាន់ណាស់ដែរក្នុងការវិនិច្ឆ័យឲ្យបានត្រឹមត្រូវនូវភាពចម្រូងចម្រាសទាក់ទិននឹងករណីសំណុំរឿង០០៣ និង ០០៤នេះ ។ វាគឺគ្មានការសម្ងាត់អ្វីនោះទេដែលថាយើងធ្លាប់មាននូវការមិនយល់ស្របគ្នាដ៏ធំមួយរវាងរដ្ឋាភិបាលកម្ពុជានិងសហគមន៍អន្តជាតិទាក់ទងនឹងវិសាលភាពរបស់សាលាក្ដីនេះ ។ ខណៈពេលដែលអង្គការសហប្រជាជាតិបានអះអាងជាផ្លូវការថា ខ្លួនចង់ធ្វើការចោទប្រកាន់ទៅលើអតីតមេដឹកនាំខ្មែរក្រហមឲ្យបានច្រើនរហូតដល់ម្ភៃនាក់ក៏ដោយ ក៏រដ្ឋាភិបាលកម្ពុជាបានអះអាងមកវិញថា ខ្លួនមានបំណងកំណត់នូវការកាត់ទោសត្រឹមតែប្រាំនាក់ប៉ុណ្ណោះ ។ ដូចនេះ ការបដិសេធរបស់មន្ត្រីជាតិនៅសាលាក្ដីក្នុងការចោទប្រកាន់ឬក៏ស៊ើបអង្កេតទៅលើជនជាប់សង្ស័យបន្ថែមនោះហាក់ដូចជាមិនមែនជារឿងដែលគួរឲ្យភ្ញាក់ផ្អើលនោះទេ ។

តែអ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះគឺថា លោក យូ ប៊ុនឡេង កាលពីដំបូងបានចុះហត្ថលេខាលើការស៊ើបអង្កេតលើករណីសំណុំរឿង ០០៣ និង ០០៤ នេះ ។ ទោះបីជាការមិនធ្វើសកម្មភាពអ្វីទាំងអស់ចំពោះអ្វីដែលគាត់បានយល់ព្រមនោះគឺជារឿងអកុសលមួយក៏ដោយ ក៏ការសុខចិត្តយល់ព្រមរបស់គាត់កាលពីដំបូងបានបញ្ជាក់ឲ្យឃើញថាគាត់ប្រហែលជាយល់ស្របទៅនឹងការស៊ើបអង្កេតលើឧក្រិដ្ឋកម្មនេះ ។ នៅក្នុងលិខិតមួយផ្ញើជូនលោក ឡឺម៉ុង លោក យូ ប៊ុនឡេងមិនបាននិយាយថាខ្លួនប្រឆាំងទៅនឹងការស៊ើបអង្កេតនេះនោះទេ ប៉ុន្តែគឺគាត់មិនទាន់រួចរាល់ក្នុងការធ្វើសម្រេចចិត្តរហូតដល់ខែកញ្ញា ឆ្នាំ២០១០ ដែលជាពេលដែលដីកាដំណោះស្រាយទាក់ទិននឹងករណីសំណុំរឿង ០០២ ត្រូវបាន

បញ្ចប់រួចរាល់ ។ ការសម្រេចចិត្តរបស់លោក យូ ប៊ុនឡេង នៅក្នុងខែកញ្ញា នេះគឺជាការសាកល្បងដ៏សំខាន់មួយអំពីប្រសិទ្ធភាពនៃវិធានផ្ទៃក្នុងរបស់សាលាក្តី ។

## ការមិនអនុវត្តតាមរបស់មន្ត្រីរដ្ឋាភិបាល

សេចក្តីរាយការណ៍របស់អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សម្រាប់សង្គមបើកចំហមានភាពត្រឹមត្រូវចំពោះការអះអាងដែលថាការបដិសេធរបស់មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ទាំងប្រាំមួយនាក់ក្នុងការមិនសហការជាមួយសហចៅក្រមស៊ើបអង្កេតគឺជាបញ្ហាមួយពិបាកនឹងដោះស្រាយ ។ សេចក្តីរាយការណ៍នោះក៏ត្រឹមត្រូវផងដែរក្នុងការទិតៀនរដ្ឋាភិបាលកម្ពុជាចំពោះការគាំទ្រជាផ្លូវការមកលើមន្ត្រីរាជការរបស់ខ្លួន ។ ប៉ុន្តែការជ្រៀតជ្រែកបែបនេះគឺអាចនិងគួរតែត្រូវបានទទួលការត្រួតពិនិត្យពីសំណាក់អង្គការសហប្រជាជាតិ និងមន្ត្រីតុលាការអន្តរជាតិផ្សេងៗទៀត ។ ឧទាហរណ៍ដូចជានៅក្នុងវិធាន៦០ (៣) បានអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតអាចធ្វើការបញ្ជាលើប៉ូលិសតុលាការដើម្បីទៅបង្ខំឲ្យសាក្សីចេញមុខ ។ តែគ្មាននរណាម្នាក់បានអំពាវនាវលើកឡើងពីបទបញ្ញត្តិបែបនេះនោះទេ ។

របាយការណ៍របស់អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សម្រាប់សង្គមបើកចំហបានទម្លាក់កំហុសមួយផ្នែកមកលើអង្គការសហប្រជាជាតិនិងការមិនមានសកម្មភាពអ្វីទាំងអស់របស់អង្គការសហប្រជាជាតិផងដែរ ។ ប៉ុន្តែអ្វីដែលរបាយការណ៍នេះមិនបានធ្វើការទទួលស្គាល់ឲ្យបានគ្រប់គ្រាន់នោះគឺថា ការជ្រៀតជ្រែកផ្នែកនយោបាយជាផ្លូវមួយដែលមានមធ្យោបាយពីរ ៈ ប្រសិនបើ ឬក៏នៅពេលដែលរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងរបៀបនៃដំណើរការនីតិវិធីរបស់ អ.វ.ត.ក នោះសហគមន៍អន្តរជាតិជាពិសេសមន្ត្រីតុលាការរបស់ អ.វ.ត.ក នឹងគោរពទៅតាមហើយប្រើប្រាស់ធនធានដែលបានផ្តល់ឲ្យនៅក្នុងសេចក្តីព្រមព្រៀងនិងវិធានផ្ទៃក្នុងដើម្បីធ្វើការលើកឡើងនូវបញ្ហានោះ ។ ដូចដែលបានអះអាងខាងលើ ទាំងនេះដើម្បីការពារថា អ.វ.ត.ក គួរតែមានលក្ខណៈខុសពីតុលាការក្នុងស្រុកនៅកម្ពុជា ។

## ការដាក់ឲ្យ អ.វ.ត.ក នៅក្នុងបរិបទ

ប្រទេសកម្ពុជាជាជាតិមួយដែលព្យាយាមតស៊ូដើម្បីកសាងខ្លួនឯង ។ អាស្រ័យហេតុនេះ ចំពោះប្រព័ន្ធតុលាការវិញក៏ដូចគ្នាផងដែរ ។ អ្វីដែលគួរឲ្យមិនពេញចិត្តស្តីពីរបាយការណ៍របស់អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សម្រាប់សង្គមបើកចំហនិងរបាយការណ៍ផ្សេងទៀតដែលមានលក្ខណៈស្រដៀងគ្នានេះគឺថា របាយការណ៍ទាំងនេះពឹងផ្អែកទៅលើការវាយតម្លៃលើឧទាហរណ៍ទស្សន៍ទាយមួយចំនួនដែលមិនមានអំណះអំណាងពិតប្រាកដនិងពឹងផ្អែកផងដែរទៅលើអតីតកាលមិនពេញលេញរបស់កម្ពុជាយកមកធ្វើការវិភាគ ។ ខណៈពេលដែលមានពាក្យពេចន៍រិះគន់ខ្លះអាចមានលក្ខណៈជាការស្ថាបនាយ៉ាងណាក្តី វាក៏ជាការចាំបាច់ដែរក្នុងការចងចាំថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមួយផ្នែកធំគឺជាការពិសោធន៍នៅក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ។

ចាប់តាំងពីចុងទសវត្សរ៍៩០ សហគមន៍ច្បាប់អន្តរជាតិកំពុងតែធ្វើការគាំទ្រឲ្យមានការប្រែប្រួលពីតុលាការដែលមានលក្ខណៈធំនិងចំណាយថវិការច្រើនលើសលុបមកជាតុលាការដែលមានលក្ខណៈតូចនិងជាតុលាការកំពូលដូចជា អ.វ.ត.ក ដែលបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ។ ចលនានេះត្រូវបានគាំទ្រឡើងដោយលក្ខន្តិកៈទីក្រុងរ៉ូម ដែលមិនត្រឹមតែគាំទ្រឲ្យមានការចូលរួមពីសំណាក់ជនរងគ្រោះនោះទេ ថែមទាំងធ្វើការកំណត់ទៅលើយុត្តាធិការនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិដើម្បីធ្វើការលើកទឹកចិត្តដល់តុលាការក្នុងស្រុកក្នុងការចាប់យកតួនាទីដ៏សំខាន់ទៀត ។ ជាពិសេស យុត្តាធិការរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិកំណត់ត្រឹមតែធ្វើការចោទប្រកាន់ទៅលើឧក្រិដ្ឋជនសង្គ្រាមដែលជាប់ចោទប៉ុណ្ណោះ ។ ប្រសិនបើករណីដែលតុលាការក្នុងស្រុកមិនព្រមឬក៏មិនអាចធ្វើការចោទប្រកាន់ទៅលើឧក្រិដ្ឋជនទាំងអស់នោះបានទេ នោះមធ្យោបាយគឺថា ត្រូវកំណត់ទីតាំងដើម្បីបង្កើតតុលាការឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងសង្គមដែលទើបតែបញ្ចប់ជម្លោះនោះ ហើយតុលាការនោះមិនត្រឹមតែផ្តល់ឱកាសដល់ប្រជាជនក្នុងស្រុកក្លាយទៅជាអ្នកចូលរួមមួយដ៏សកម្មនោះទេ ថែមទាំងធ្វើការផ្តល់នូវជំនួយដូចជាអ្នកអនុវត្តន៍ ចៅក្រម និងមេធាវីជាដើម និងឱកាសក្នុងការបញ្ចូលនូវបទដ្ឋានអន្តរជាតិទៅក្នុងច្បាប់ក្នុងស្រុកដែលកំពុងតែអភិវឌ្ឍន៍ ។

ដូចគ្នាទៅនឹងការពិសោធន៍ទូទៅ អ.វ.ត.ក គឺពិតជាមាន

បញ្ហាមួយចំនួនដែលរារាំងខ្លួនមិនឲ្យមានការរីកចម្រើនដូចជា ការពន្យារពេលអស់រយៈពេល៣០ឆ្នាំក្នុងការស្វែងរកយុត្តិធម៌ ការអាក់ខានកិច្ចចរចាររវាងអង្គការសហប្រជាជាតិជាមួយនឹងរដ្ឋាភិបាលកម្ពុជា ជម្លោះផ្ទៃក្នុងរវាងសហចៅក្រមស៊ើបអង្កេតនិងសហព្រះរាជអាជ្ញា ។ ប៉ុន្តែ ការពិសោធន៍នេះបាននាំមកនូវសក្តានុពលដ៏អស្ចារ្យដែលថា វាអាចទៅរួចដែលថា អ.វ.ត.ក អាចធ្វើការផ្លាស់ប្តូររបៀបនៃការគិតរបស់សហគមន៍អន្តរជាតិទាក់ទិននឹងតួនាទី និងមុខងាររបស់សាលាក្តីឧក្រិដ្ឋកម្មសង្គ្រាមនាពេលបច្ចុប្បន្ន និងទៅថ្ងៃអនាគតផងដែរ ។

អ្វីដែលកំពុងតែកើតឡើងនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះគឺជាបដិវត្តន៍ប្រែប្រួលមួយដែលថា តាំងតែពីមុនមកមិនដែលមានជនរងគ្រោះមានឱកាសក្នុងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីនោះទេ ហើយក៏មិនដែលមានអ្នកទស្សនាជាតិជាង៣០.០០០ នាក់មកចូលរួមទស្សនានៅក្នុងតុលាការឧក្រិដ្ឋរបស់ជាតិខ្លួនឯងនោះទេ ជាពិសេសតាំងតែពីមុនមកក៏មិនដែលមានប្រជាជនក្នុងស្រុកជាងពីរលាននាក់ធ្វើការតាមដាននូវដំណើរការនីតិវិធីរបស់តុលាការតាមរយៈទូរទស្សន៍នោះដែរ ។ ប៉ុន្តែ អ.វ.ត.ក មានសក្តានុពលបែបនោះគឺមិនត្រឹមតែដើម្បីផ្តល់នូវយុត្តិធម៌ផ្លូវច្បាប់នោះទេ ថែមទាំងដើម្បីការស្តារឡើងវិញនូវយុត្តិធម៌សង្គមមកដល់ប្រទេសកម្ពុជាក៏ដូចជាប្រជាជនទាំងអស់ផងដែរ ។

**ដេឡា សេនធីលឡេស**

# ដំណឹងស្វែងរកគ្រួសារ

នាងខ្ញុំឈ្មោះ អ៊ីង ម៉ីហា អាយុ៣៩ឆ្នាំ មានបងប្អូន៣នាក់ ទី១) បងប្រុស អ៊ីង សេងសាំង «ស្លាប់» ទី២) នាងខ្ញុំ និងទី៣) ប្អូនប្រុសឈ្មោះ អ៊ីង ម៉ីហុង សព្វថ្ងៃមានអាយុប្រហែល៣៧ឆ្នាំ ។ ឪពុកឈ្មោះ អ៊ីង សេង ជាមន្ត្រីសង្គមកិច្ច និងម្តាយមិនចាំឈ្មោះ ។ នៅក្នុងរបបខ្មែរក្រហម គ្រួសាររបស់ខ្ញុំមានសមាជិក៦នាក់ត្រូវបានជម្លៀសទៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

ដោយសារតែហូបចុកមិនគ្រប់គ្រាន់ ក្រោយមកឪពុកអ្នកម្តាយនិងយាយរបស់ខ្ញុំក៏បានស្លាប់នៅជំនាន់នោះទៅ ។ ក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ ខ្ញុំនិងប្អូនប្រុសរបស់ខ្ញុំបានភៀសខ្លួនទៅរស់នៅព្រំដែនថៃ រួចក៏វិលត្រឡប់មករស់នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ នៅឆ្នាំ១៩៨៣ ខ្ញុំបានធ្វើដំណើរទៅក្រុងភ្នំពេញតែម្នាក់ឯង ដោយទុកប្អូនប្រុស អ៊ីង ម៉ីហុង ដែលទើបតែមានអាយុ១០ឆ្នាំឲ្យនៅជាមួយមីងឈ្មោះ ភាព ។ ចាប់ពីពេលនោះមក ខ្ញុំបានបែកពីប្អូនប្រុស អ៊ីង ម៉ីហុង រហូតមកដល់សព្វថ្ងៃ ។ តាមរយៈការស៊ើបសួរដំណឹងពីអ្នកភូមិដែលធ្លាប់រស់នៅជាមួយគ្នាបានប្រាប់ថា ពួកគាត់ក៏មិនដឹងថា អ៊ីង ម៉ីហុង រស់នៅទីណាដែរ ។

ដូច្នេះ បើសិនបងប្អូនបានស្គាល់ឬបានជួបឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ដំណឹងមកខ្ញុំតាមអាសយដ្ឋាននៅភូមិថ្មី សង្កាត់ស្ទឹងត្រែង ខណ្ឌស្ទឹងត្រែង ក្រុងស្ទឹងត្រែង ឬទូរស័ព្ទលេខ ០៩២ ៤០ ៥៨ ៧៣ ផង ។

# សេចក្តីប្រកាសរកបងប្រុសឈ្មោះ មាស ពន្លក

នាងខ្ញុំឈ្មោះ ស្វាយ វ៉ាន់ថង រស់នៅស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ ស្វាយ សារិន (ស្លាប់) ធ្វើពេទ្យ ម្តាយឈ្មោះ ឌី យ៉ាត (ស្លាប់) ស្រុកកំណើតនៅក្នុងភូមិកំពង់សំណាញ់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ សូមស្វែងរកបងប្រុសឈ្មោះ មាស ពន្លក ដែលបានបាត់ខ្លួននៅឆ្នាំ១៩៧៥ ។ មុនពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះ ពន្លក ធ្វើជាទាហានលន់ នល់ ឈរជើងនៅក្នុងខេត្តពោធិ៍សាត់ ។ ប្រសិនបើបងបានឃើញសេចក្តីប្រកាសនេះ ឬបងប្អូនបានស្គាល់ឈ្មោះខាងលើនេះ សូមទាក់ទងមកខ្ញុំតាមរយៈទូរស័ព្ទលេខ ០៩២ ៦៩៩ ០៣៨ ។

# ការបង្ហាញអំពីគោលបំណងនៃអំពើប្រល័យពូជសាសន៍ ៖ យុត្តិសាស្ត្រអន្តរជាតិ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើសំណុំរឿង០០២

***(តពីលេខមុន)***

### ៣) រ៉្វាន់ដា

ទោះបីជាធ្លាប់មានការពិភាក្សាកាលពីមុនក្តី មានការបង្ហាញយ៉ាងច្បាស់ថា បន្ទុកនៃភស្តុតាងសម្រាប់បង្ហាញពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍របស់ជនជាប់ចោទនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាមានសភាពធូរស្រាលដែរ ដោយសារតែលទ្ធភាពដែលព្រះរាជអាជ្ញាចង្អុលបង្ហាញពីសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ជនជាប់ចោទដែលធ្វើឡើងនៅក្នុងអំឡុងពេលប្រល័យពូជសាសន៍ ។ នៅក្នុងប្រទេសរ៉្វាន់ដា កន្លែងដែលសាធារណជនត្រូវបានកំណត់ថា ជាគម្រោងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍របស់ជនដែលដល់ មេដឹកនាំ ហ៊ូទូ ជាច្រើនរូបបានប្រកាសជាសាធារណៈទៅកាន់អ្នកដែលនៅក្រោមបង្គាប់របស់ខ្លួនឲ្យ «សម្លាប់បំផុតពូជសត្វកន្លាត» ។ ដូច្នេះ ការប្រកាសជាសាធារណៈអំពីគោលបំណងក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍អាចធ្វើនៅទីសាធារណៈ ការជួបជុំរបស់គណបក្សនយោបាយ និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ។

វត្តមាននៃសេចក្តីថ្លែងការណ៍ដាក់បន្ទុកហាក់ដូចជាមានជាប់ទាក់ទងជាមួយនឹងចរិតលក្ខណៈនៃចលនាអំណាចរបស់ហ៊ូទូដែលមានឈ្មោះថា របនាសម្ព័ន្ធថ្នាក់មូលដ្ឋាន ។ មូលហេតុដែលគួរឲ្យកត់សម្គាល់នៃអំពើប្រល័យពូជសាសន៍នៅប្រទេសរ៉្វាន់ដាគឺមនុស្សម្នាក់ត្រូវតែមានការប្រុងប្រយ័ត្ន ដោយផ្អែកតាមតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ដែលជឿជាក់ទៅលើសេចក្តីថ្លែងការណ៍ដែលចោទប្រកាន់ធ្វើឡើងដោយចុងចោទនិងបក្សពួករបស់គេ ដែលអាចសន្និដ្ឋានថាជាគោលបំណងនៃការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ប៉ុន្តែជាការចំបាច់ ភស្តុតាងនៃសេចក្តីថ្លែងការណ៍ទាំងនោះត្រូវតែបង្ហាញអំពីចេតនាពិរុទ្ធនៃអំពើប្រល័យពូជសាសន៍ ។ ជាក់ស្តែង តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីដែលទទួលបានផលប្រយោជន៍ពីភស្តុតាងនៃការសន្ទនារបស់ជនដែលដល់តាមទូរសព្ទដែលត្រូវបានគេបន្លាក់និងធ្វើឡើងនៅក្នុងអំឡុងពេលមានជម្លោះនៅបាល់កង់បានទទួលស្គាល់ថា ភស្តុតាងនៃសេចក្តីថ្លែងការណ៍ដាក់បន្ទុករបស់ជនត្រូវចោទ មិនអាចទាញពីចេតនាប្រល័យពូជសាសន៍នោះទេ ។

### ក) ទំហំនៃអំពើឃោរឃៅដែលបានប្រព្រឹត្ត

វាហាក់ដូចជាថា នៅក្នុងករណីនីមួយៗដែលតុលាការអន្តរជាតិបានពិចារណាដើម្បីទាញពីចេតនាប្រល័យពូជសាសន៍មានការសង្កត់ធ្ងន់អំពីសារសំខាន់នៃការសន្និដ្ឋានលើ «ទំហំនៃអំពើឃោរឃៅ» ។ ទំហំដែលអំពើពិរុទ្ធបានប្រព្រឹត្តគឺទាក់ទងនឹងកត្តាជាក់ស្តែង និងកត្តាដែលជាប់ពាក់ព័ន្ធ ឧទាហរណ៍ដូចជា ចំនួនសរុបនៃជនរងគ្រោះពីក្រុមណាមួយនិងចំនួនសមាមាត្រនៃក្រុមដែលបានសម្លាប់ ។ ដើម្បីទាញទៅដល់ចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដែលចេញពីទំហំនៃអំពើឃោរឃៅនិងដកស្រង់ចេញពីទស្សនៈច្បាប់បានបង្ហាញនៅក្នុងយុត្តាធិការក្នុងស្រុកជាច្រើនថាបុគ្គលនោះមានបំណងនិងអាចប៉ាន់ប្រមាណពីលទ្ធផលដែលបានគិតទុកមុនដែលកើតចេញពីសកម្មភាពរបស់អ្នកទាំងនោះ ។ អត្ថន័យមួយទៀត ការពិតដែលបុគ្គលម្នាក់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការប៉ាន់ប្រមាណពីលទ្ធផលដែលធ្វើឲ្យខូចខាតដល់ការរស់នៅរបស់សហគមន៍ណាមួយ (ឧទាហរណ៍ ការសម្លាប់ចំនួនប្រជាជនច្រើន) «ជាមួយនឹងចំណេះដឹងគ្រប់គ្រាន់ដែលជាលទ្ធផលធ្វើឲ្យខូចប្រយោជន៍ ហើយធ្វើឲ្យប៉ះពាល់ដល់ការរស់រានមានជីវិតរបស់សហគមន៍ជាក់លាក់ណាមួយ» នេះគឺជាសំណួរសាកល្បងមួយថាតើឧក្រិដ្ឋជនមានបំណងជាក់លាក់មួយដើម្បីសម្រេចឲ្យបានលទ្ធផលនេះ ។

ការវិភាគបន្ថែមទៀតបានលើកជាសំណួរថា «តើអ្វីទៅបង្កើតជាអំពើឃោរឃៅដែលមានទំហំទូលាយធំ?» ជាថ្មីម្តងទៀត អំពើប្រល័យពូជសាសន៍នៅប្រទេសរ៉្វាន់ដាអាចយកមកធ្វើជាឧទាហរណ៍គំរូបាន ។ ទោះបីជាការរកឃើញជាក់លាក់អំពីចំនួន

ពិតប្រាកដនៃចំនួនដែលពាក់ព័ន្ធនឹងចំនួននៃការស្លាប់ជនជាតិទុតស៊ីនៅក្នុងអំឡុងពេលអំពើប្រល័យពូជសាសន៍នឹងមិនកើតឡើងក៏ដោយ ក៏អ្នកជំនាញមួយចំនួនប៉ាន់ប្រមាណថា ចំនួនអ្នកត្រូវបានសម្លាប់ចាប់ពីប្រាំម៉ឺននាក់ដល់ពីរលាននាក់ ដែលគិតមិនដល់រយៈពេលបួនខែផង ចំនួននៃការស្លាប់នេះស្មើនឹង៧៥ភាគរយទៅ៨០ភាគរយ នៃប្រជាជនទុតស៊ីទាំងមូលដែលកំពុងរស់នៅក្នុងប្រទេសរ៉្វាន់ដានៅពេលនោះ ។ ក្រោយមកទៀត យុត្តិសាស្ត្របានកំណត់អត្ថន័យច្បាស់លាស់មួយថា អំពើឃោរឃៅមិនចាំបាច់មានទ្រង់ទ្រាយធំនោះទេក្នុងការបង្ហាញពីបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍នោះ ។ ឧទាហរណ៍ នៅក្នុងករណី ក្រាទីក តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានរកឃើញថា ឃាតករសម្លាប់បុរសជនជាតិមូស្លីមនៅប៊ូស្នៀចាប់ពី៧០០០នាក់ ទៅ៨០០០នាក់ អាចចាត់ទុកជាការសម្លាប់ដែលមានទំហំគ្រប់គ្រាន់ក្នុងការបង្ហាញពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ហើយ ។

ម្យ៉ាងវិញទៀត វត្តមាននៃអំពើឃោរឃៅមានទ្រង់ទ្រាយធំដែលអាចឲ្យជឿបានដែលបានប្រព្រឹត្តដោយជនដៃដល់ ឬក៏អ្នកផ្សំគំនិតរបស់គេគឺមិនអាចយកមកសន្និដ្ឋានថាជាចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទេ ។ ជាក់ស្តែង នៅក្នុងការទទួលស្គាល់អំពីលទ្ធភាពតាមទ្រឹស្តីនៃ «ព្រឹត្តិការណ៍ប្រល័យពូជសាសន៍តែមួយ» (Lone genocidaire scenario) ដែលថា «ជនដៃដល់ម្នាក់ក៏អាចប្រព្រឹត្តអំពើប្រល័យពូជសាសន៍» ដែរ ដោយផ្អែកទៅលើចំនួនតូចនៃការសម្លាប់ដាច់ដោយឡែកដែលសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានទទួលស្គាល់ថា ទំហំនៃអំពើឃោរឃៅនោះមិនអាចសម្រេចនៅក្នុងការទាញទៅរកចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទេ ។ នៅក្នុងន័យម៉្យាងទៀត «គ្មានចំនួនជាក់លាក់នៃជនរងគ្រោះដើម្បីបង្កើតឲ្យមានអំពើប្រល័យពូជសាសន៍នោះទេ» ។

## ឃ) គោលដៅជាប្រព័ន្ធ

ចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដើម្បីសម្លាប់ក្រុមមនុស្សណាមួយដែលត្រូវបានសន្និដ្ឋានចេញមកពី «ការប្រព្រឹត្តដែលជាបទល្មើសព្រហ្មទណ្ឌមានគោលដៅជាប្រព័ន្ធប្រឆាំងនឹងក្រុមមនុស្សដូចគ្នា» ។ ឧទាហរណ៍ នៅក្នុងករណី អាកាយេស៊ុ និងក្នុងករណីផ្សេងទៀត តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានរកឃើញថា ជនជាតិទុតស៊ីទូទាំងប្រទេសត្រូវបានធ្វើការចោទប្រកាន់និងថ្កោលទោស ទោះបីជាចុងចោទទាំងនោះមិនបានចូលរួមដោយផ្ទាល់ក្នុងសកម្មភាពចោទប្រកាន់និងផ្តន្ទាទោសជនជាតិទុតស៊ី ឬនិយាយនៅក្នុងសេចក្តីថ្លែងការណ៍ដែលបានពិភាក្សាក៏ដោយ ។ តុលាការនេះបានរកឃើញថា គោលដៅសម្លាប់ជាប្រព័ន្ធទៅលើជនជាតិទុតស៊ីកាលពីអំឡុងអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសរ៉្វាន់ដាកើតឡើងដោយសារហេតុផលបីយ៉ាងៈ ទីមួយ ការបិទផ្លូវដែល «អនុញ្ញាតឲ្យទាហានកងកម្លាំងការពារប្រធានាធិបតីធ្វើការឆែកកាតអត្តសញ្ញាណប័ណ្ណជាប្រព័ន្ធ ដើម្បីបញ្ជាក់ពីជាតិសាសន៍នៃបុគ្គលដែលកាន់កាតនោះ» ។ នរណាក៏ដោយដែលជាជនជាតិទុតស៊ី «ត្រូវចាប់ចង និងសម្លាប់ភ្លាមៗ» ។ ទីពីរ ការផ្សព្វផ្សាយ «បញ្ជីសម្លាប់» ដោយមានសុទ្ធតែជនជាតិទុតស៊ី ហើយចាត់ទុកជនជាតិទុតស៊ីថាជាអ្នកគាំទ្រដែលមានភ័ស្តុតាងនិងគោលដៅយ៉ាងច្បាស់ក្នុងការសម្លាប់ជនជាតិទុតស៊ី ហើយទុកជីវិតឲ្យជនជាតិដទៃ ។ ទីបី «យុទ្ធនាការឃោសនាធ្វើឡើងនៅមុនពេលនិងអំឡុងពេលសោកនាដកម្ម» តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងការបោះពុម្ពផ្សាយ និងការផ្សព្វផ្សាយព័ត៌មានដើម្បីសម្លាប់ជនជាតិទុតស៊ីជាក្រុម ។ នៅក្នុងករណីមួយចំនួនទៀត យុទ្ធនាការឃោសានានេះបានពង្រីកលើសពីប្រពន្ធ័ផ្សព្វផ្សាយទៅទៀត ដោយតុលាការថែមទាំងរកឃើញថាសំបុត្រមួយ «ក៏អាចមានបំណងផ្សព្វផ្សាយយ៉ាងធំទូលាយបំផុតតាមដែលអាចទៅទៅបាន» ចាប់ពី «បញ្ជាការដ្ឋាន» តំបន់ ហើយចុះហត្ថលេខាដោយឧត្តមសេនីយ៍យោធា ។ នៅក្នុងសំបុត្រនោះបានកំណត់ពាក្យ «សត្រូវ» គឺជា «ពួកជ្រុលនិយមទុតស៊ី ដែលស្ថិតនៅក្នុងប្រទេស ឬក៏នៅក្រៅប្រទេស ដែលមិនទទួលស្គាល់ ឬនៅតែមិនទទួលស្គាល់ការពិតនៃបដិវត្តន៍សង្គមនៅឆ្នាំ១៩៥៩ ដែលធ្វើឲ្យមានការធ្លាក់ចុះនៃការដឹកនាំនយោបាយរបស់ជនជាតិទុតស៊ីនៅរ៉្វាន់ដា) ក៏ដូចជា «អ្នកដែលជួយសត្រូវ» ។

ស្រដៀងគ្នានេះដែរ ទោះបីជាវិវាទទៅលើធាតុផ្សំនៃបទល្មើសផ្សេងទៀតបានបន្សល់ទុកនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ

នៅតែមានមន្ទិលចំពោះអំពើប្រល័យពូជសាសន៍របស់មេដឹកនាំស៊ូដង់ក៏ដោយ ក៏គ្រប់ភាគីទាំងអស់ហាក់ដូចជាទទួលស្គាល់ថា មានការដាក់គោលដៅយ៉ាងខ្លាំងទៅលើ «ភូមិអាហ្វ្រិក» ដែលមានឧក្រិដ្ឋជនតែងតែទុកជីវិតឲ្យភូមិអារ៉ាប់ជានិច្ច ទោះបីភូមិអារ៉ាប់មួយនេះស្ថិតនៅជិតភូមិដែលជាមុខសញ្ញាក៏ដោយ ។ ទោះបីជាចំណុចនេះមិនអាចយកមកធ្វើសេចក្តីសម្រេចបានក៏ដោយ ប៉ុន្តែវាក៏បញ្ជាក់ពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដែរ ។ បន្ថែមទៅលើគោលដៅនៃការសម្លាប់ភូមិអាហ្វ្រិចរបស់ក្រុមយោធា ព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ថា ជនជាតិស៊ូដង់បានចាប់រំលោភស្ត្រី និងកុមារជនជាតិអាហ្វ្រិក បង្ខំឲ្យផ្លាស់ប្តូរកន្លែងរស់នៅ សម្លាប់នៅក្នុងគុក ហើយនិងរឹបអូសយកទ្រព្យសម្បត្តិរបស់អ្នកទាំងនោះ ។

## ១) បែងចែកធាតុចេតនាពីអំពើពិរុទ្ធរបស់អំពើប្រល័យពូជសាសន៍

ទោះបីការកំណត់គោលដៅជាប្រព័ន្ធនៃជនជាតិទុតស៊ីជាផ្នែកមួយនិងជាធាតុមួយនៃអំពើពិរុទ្ធរបស់អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសរ៉ូវ៉ាន់ដាក៏ដោយ (ការសម្លាប់ជនជាតិទុតស៊ី) ក៏ការកំណត់គោលដៅនេះមិនមានភាពចាំបាច់សម្រាប់សកម្មភាពនៃពិរុទ្ធភាពអំពើប្រល័យពូជសាសន៍ដែលតម្រូវឲ្យមានការបកស្រាយអំពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ឲ្យបានច្បាស់លាស់ដែរ ។ ជាឧទាហរណ៍ នៅក្នុងករណី ក្រាទីក តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានរកឃើញថា ការជម្លៀសដោយបង្ខំនូវផ្នែកមួយនៃក្រុមដែលជាមុខសញ្ញានោះអាចធ្វើការសន្និដ្ឋានបានថាមានចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ទោះបីជាការជម្លៀសនោះមិនមែនជាធាតុនៃអំពើប្រល័យពូជសាសន៍ដែលមាននៅក្នុងច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីក៏ដោយ ។ ក្រាទីក មានការពាក់ព័ន្ធជាមួយនឹងយោធាស៊ែប ស្របពេលជាមួយនឹងការសម្លាប់រង្គាលទៅលើបុរសជនជាតិមូស្លីមនៅប៊ូស្នៀ ហើយក៏ជម្លៀសដោយបង្ខំចំពោះស្ត្រីនិងកូនក្មេងនៅប៊ូស្នៀមកពី Srebrenica ដែរ ។ បដិសេធទៅនឹងការលើកឡើងរបស់ ក្រាទីក ដែលថា ការសម្រេចចិត្តរបស់ជនដៃដល់ដោយបែងចែកក្រុមតាមគោលដៅដែលបានកំណត់ដោយផ្អែកទៅលើអាយុ និងភេទរបស់គេបានអះអាងថាមិនមានចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍នោះទេ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានលើកឡើងថា «កងកម្លាំងស៊ែបនៅប៊ូស្នៀប្រាកដជាបានដឹងច្បាស់ពីលទ្ធផលនៃការសម្លាប់បុរសជាមួយនិងការជម្លៀសស្ត្រី កុមារ និងមនុស្សចាស់ថាអាចនឹងធ្វើឲ្យបាត់បង់ពូជសាសន៍របស់ក្រុមដែលជាមុខសញ្ញានោះទាំងមូល» ។ នៅករណីក្រាទីកនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានអះអាងពីស្ថានទម្ងន់ដែលយោងដើម្បីបង្កើតគោលដៅដែលមិនសូវមានជាប់ពាក់ព័ន្ធជាមួយនឹងអំពើប្រល័យពូជសាសន៍ជាជាងការជម្លៀសដោយបង្ខំ ដូចជា «បំផ្លាញផ្ទះ» របស់ជនជាតិមូស្លីមនៅប៊ូស្នៀ ដោយបំផ្លាញ «វិហារសំខាន់ៗ» នៅទីក្រុង ហើយ «ទប់ស្កាត់ភាពសាហាវឃោរឃៅ (ការស្លាប់) ដោយយោងទៅលើទំនៀមទម្លាប់ជាតិសាសន៍ និងសាសនា» ។ ទោះបីបទល្មើសទាំងនោះមិនមែនជាអំពើប្រល័យពូជសាសន៍ក៏ដោយ ក៏តុលាការបានបង្ហាញថា «ភ័ស្តុតាងដែលទាក់ទងនឹងអំពើទាំងនេះបានពាក់ព័ន្ធជាមួយនឹងការបំផ្លាញវប្បធម៌និងស្មារតីរបស់ក្រុមមួយនោះ» គឺអាចបញ្ជាក់បានយ៉ាងច្បាស់អំពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍របស់ជនដៃដល់ ។

«ការដាក់គោលដៅនៃទ្រព្យសម្បត្តិរបស់ក្រុម» អាចធ្វើការបកស្រាយបានតាមអត្ថន័យជាច្រើន បើយោងទៅតាមបរិបទនិងកាលៈទេសៈដែលបានកើតឡើង ។ ឧទាហរណ៍ នៅក្នុងករណីក្រាទីក តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីមានទស្សនៈថា ការបំផ្លាញទ្រព្យសម្បត្តិ ហាក់ដូចជាបំផ្លាញវប្បធម៌ដែរ ដូចជាបំផ្លាញជំនឿរបស់ក្រុមដែលជាមុខសញ្ញា និងបំផ្លាញទ្រព្យសម្បត្តិរបស់អ្នកទាំងនោះ ។ ម្យ៉ាងវិញទៀត នៅក្នុងករណី កាយីហ្ស៊ីម៉ា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដាបានចាត់ទុកថា ការលួចទ្រព្យសម្បត្តិរបស់ជនជាតិទុតស៊ីមានជាប់ពាក់ព័ន្ធទៅនឹងការពិតជាក់ស្តែងដែលថា «អាជ្ញាធរធានាថាជនជាតិហ៊ូទូសម្លាប់ជនជាតិទុតស៊ីគ្មានទោសនោះទេ» ។ បន្ថែមពីលើនេះទៀត នៅក្នុងករណីទាំងពីរនេះ ការដាក់គោលដៅនៃក្រុមដែលត្រូវបានការពារចំពោះការបំផ្លាញទាំងផ្លូវកាយ និងផ្លូវចិត្តបានធ្វើឲ្យតុលាការអាចទាញទៅដល់ចេតនាប្រព្រឹត្តអំពើ

ប្រល័យពូជសាសន៍របស់ជនដៃដល់ ទោះបីគ្មានសកម្មភាពណាមួយបានបង្ហាញជាផ្លូវការថាជាអំពើប្រល័យពូជសាសន៍ក៏ដោយ ។

## ២) គោលដៅជាប្រព័ន្ធ ៖ មិនមែនជាលក្ខខណ្ឌដាច់ខាត

មិនមានតុលាការអន្តរជាតិណាមួយបានពិចារណាលើភ័ស្តុតាងនៃការដាក់គោលដៅជាប្រព័ន្ធរបស់ក្រុមដែលត្រូវបានការពារដើម្បីកំណត់ចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដែលបានលើកឡើងថា ការដាក់គោលដៅទាំងនេះត្រូវតែមានគោលបំណងទៅលើក្រុមដែលទទួលបានការការពារដើម្បីជាភ័ស្តុតាងមួយ ។ ជាឧទាហរណ៍ នៅប្រទេសរ៉្វាន់ដា លិខិតជាសាធារណៈទាក់ទងនឹងបញ្ហាយោធាដែលបានរៀបរាប់ខាងលើបានកំណត់ថា «សត្រូវ» រួមមានក្រុមជនជាតិ និងក្រុមសង្គមដែលមិនមែនជាជនជាតិទុតស៊ីមួយចំនួនដែលក្នុងនោះរួមមាន «ជនជាតិហ៊ូទូដែលមិនពេញចិត្តនឹងរបបបច្ចុប្បន្ន» «ជនបរទេសដែលរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីជនជាតិទុតស៊ី» និង«កុលសម្ព័ន្ធនីឡូទិក-ហាមីទិកក្នុងតំបន់» ។ ក្រុមដែលដាក់គោលដៅនៅក្នុងបញ្ហានេះមិនមែនមានតែជនជាតិទុតស៊ីនោះទេ ទោះបីជាយ៉ាងណាក៏មិនប៉ះពាល់ដល់ការទាញពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍របស់ជនដៃដល់ទៅលើជនជាតិទុតស៊ីឡើយ ។ ដូចគ្នាដែរ នៅក្នុងតំបន់ដាហ្វួរ ការដាក់គោលដៅលើកុលសម្ព័ន្ធ «អាហ្វ្រិក» និងបុគ្គលមួយចំនួនក៏មិនទាំងស្រុងនោះទេ ។ យោងទៅតាមដីកាចាប់ខ្លួនរបស់ព្រះរាជអាជ្ញាដែលបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍ គឺមានសិទ្ធិចោទប្រកាន់នូវរាល់គោលដៅដែលបានកំណត់ ដោយលើកឡើងថា ភាគច្រើននៃគោលដៅរបស់ពួកគេគឺជាសមាជិកក្រុមដែលទទួលបានការការពារ ។

ទោះបីជាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសរ៉្វាន់ដាមិនបានគិតទៅដល់ចំណុចសំខាន់ផ្សេងទៀតនៅក្នុងការវិភាគរបស់ខ្លួនក៏ដោយ ក៏មានកត្តាបីដែលធ្វើឲ្យតុលាការកាត់បន្ថយភាពចាំបាច់ដែរ ។ ហេតុផលទីមួយគឺ ភាគច្រើននៃក្រុមដែលជាមុខសញ្ញាទាំងនោះជាជនជាតិទុតស៊ី ។ ហេតុផលទីពីរ ជនជាតិទុតស៊ីភាគច្រើនជាក្រុមមុខសញ្ញាត្រូវសម្លាប់ ។ ហើយហេតុផលទីបីគឺអ្នកដែលមិនមែនជាជនជាតិទុតស៊ីត្រូវបានគេកំណត់គោលដៅដោយសារតែជននោះមានចិត្តអាណិតនិងជួយជនជាតិទុតស៊ី ។

បន្ថែមពីលើនេះទៅទៀត មានការពិចារណាទូទៅពីរដែលប្រឆាំងនឹងចំណុចសំខាន់ដើម្បីទាញទៅដល់បំណងប្រល័យពូជសាសន៍ ។ ទីមួយ នៅក្នុងករណីដែលជនដៃដល់បង្ហាញពីសកម្មភាពដាក់គោលដៅទៅលើក្រុមដែលទទួលបានការការពារ ។ ចំពោះចំណុចនេះ ថ្វីបើឧក្រិដ្ឋជនមានចេតនាចំពោះក្រុមណាមួយជាក់លាក់ក៏ដោយ ក៏ក្រុមដែលជាមុខសញ្ញានោះមិនបានយកមកសម្លាប់ទាំងអស់ដែរ ។ ឈ្មោះ ហ៊ូទូ នឹងត្រូវបានបញ្ចូលក្នុងបញ្ជីដែលមាន បន្ទាប់មក «ជនជាតិអារ៉ាប់» នឹងត្រូវបានគេប្រឡំជាមួយ «ជនជាតិអាហ្វ្រិក» ។ ទីពីរ ចេតនានៃអំពើប្រល័យពូជសាសន៍មិនត្រូវបានជំរុញដោយកំហឹងដែលកើតឡើងដោយមូលហេតុសាសនា ជាតិសាសន៍ ឬពូជសាសន៍ឡើយ ។ ជាឧទាហរណ៍ ចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍របស់ឧក្រិដ្ឋជនចេញមកពីឆន្ទៈចង់កម្ទេចអ្នកដែលមកពីខាងក្រៅទឹកដីរបស់ខ្លួន ឬក៏អ្នកទាំងនោះជឿថា ការកម្ចាត់ក្រុមទាំងនោះអាចនឹងធ្វើឲ្យមានជោគជ័យខាងយោធា ។ ប្រសិនបើដូច្នេះ ក្រុមឧក្រិដ្ឋជននឹងកំណត់គោលដៅសម្លាប់ចំពោះក្រុមណាដែលអាចរាំងស្ទះដល់ជ័យជម្នះរបស់ខ្លួន ។ ការពិតដែលថា ការបំផ្លាញដោយចេតនាទៅលើក្រុមបែបនោះមិនអាចហៅថាជាចេតនាប្រល័យពូជសាសន៍បានទេ ពីព្រោះចំណុចទាំងនេះមិនមានចែងនៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឡើយ ។

ទោះបីជាយ៉ាងណាក៏ដោយ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានរកឃើញថា ស្ថានទម្ងន់នៃគោលដៅនឹងកើនឡើងប្រសិនបើជនដៃដល់ «មិនបានបញ្ចូលសមាជិកក្រុមផ្សេងទៀត» ហើយក្រុមផ្សេងទៀតក៏ត្រូវបានគេដាក់ជាគោលដៅដែរ ។

## ៣) ការយល់ដឹងពីការកំណត់ទិសដៅ ៖វត្តមាននៃជម្លោះប្រដាប់អាវុធ

ករណីភាគច្រើននៃអំពើប្រល័យពូជសាសន៍នៅសម័យទំនើបតែងតែកើតមាននៅក្នុងជម្លោះប្រដាប់អាវុធដែលកងកម្លាំងយោធាបានសម្លាប់ប្រជាជនដែលមានជាតិសាសន៍ដូចនឹងភាគីវិវាទយោធាម្ខាងទៀត ។ នៅក្នុងបរិបទនេះ ជនជាប់ចោទតែងតែ

ឆ្លើយតបនឹងការចោទប្រកាន់នេះ ដោយអះអាងថា ការដាក់មុខសញ្ញាទៅលើក្រុមដែលទទួលបានការការពារគឺដើម្បីយុទ្ធសាស្ត្រយោធា មិនមែនការចង់បំផ្លាញក្រុមទាំងនោះទេ ។

ទោះបីជាយ៉ាងណាក៏ដោយ តុលាការអន្តរជាតិបានបដិសេធជាសាកលនឹងសេចក្តីអះអាងដែលថា វត្តមាននៃជម្លោះយោធារវាងកងកម្លាំងពីរក្រុមដែលមានជាតិសាសន៍ផ្សេងគ្នាមិនអាចទាញទៅដល់បំណងប្រល័យពូជសាសន៍បានទេ ។ នៅក្នុងដំណាក់ដំបូង តុលាការបានចង្អុលបង្ហាញទៅប្រជាជនស៊ីវិលដែលត្រូវបានកំណត់ជាមុខសញ្ញាថាជាភ័ស្តុតាងជាក់លាក់ដែលបញ្ជាក់ថាការជំរុញឲ្យមានសកម្មភាពបែបនេះមិនមែនដោយសារតែហេតុផលយោធាទេ ។ ជាឧទាហរណ៍ នៅករណី អាកាយេស៊ុ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានលើកឡើងថា ស្ត្រី និង កុមារជនជាតិទុតស៊ីក៏ជាមុខសញ្ញាដូចបុរសដែរ ហើយក្រុមទាំងពីរនេះមិនមែនជាអ្នកប្រយុទ្ធនៅក្នុងសង្គ្រាមស៊ីវិលទេ ។ តុលាការក៏បានកត់សម្គាល់ផងដែរថា ជនជាប់ចោទបានប្រកាសជាសាធារណៈថា «ប្រសិនបើស្ត្រីជនជាតិហ៊ូទូមានទំនាក់ទំនងជាមួយបុរសជនជាតិទុតស៊ី នោះស្ត្រីជនជាតិហ៊ូទូដែលរកឃើញថា មានផ្ទៃពោះត្រូវពន្លូតកូនចេញជាដាច់ខាត» ។ «ទោះបីជាកូនក្មេង ដែលទើបនឹងកើតក៏មិនត្រូវទុកជីវិតឲ្យដែរ» ។ ហើយ «ស្ត្រីមានផ្ទៃពោះ រួមទាំងស្ត្រីជនជាតិហ៊ូទូត្រូវសម្លាប់ទាំងអស់ ដោយហេតុថាគភ៌នោះមានឪពុកជាបុរសជនជាតិទុតស៊ី» ។

ស្រដៀងគ្នានេះដែរ ទោះបីជាកងកម្លាំង ស៊ែប បានប្រកាសទុកជីវិតឲ្យស្ត្រី និងកុមារជនជាតិមូស្លីមពីការសម្លាប់នៅ ស្រ៊ីព្រីនីកាក៏ដោយ ក៏តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនៅក្នុងករណី ក្រាទីក បានបដិសេធនូវការលើកឡើងខាងលើ ។ ផ្ទុយទៅវិញ តុលាការកត់សម្គាល់ថា កងកម្លាំងស៊ែប មិនបានបែងចែកប្រភេទមនុស្សឡើយគឺសម្លាប់សមាជិកអនុក្រុមស្ទើរតែទាំងអស់ (រួមទាំងជនពិការ និងក្មេងប្រុស ព្រមទាំងមនុស្សចាស់) ដោយមិនគិតថា តើអ្នកទាំងនោះអាចចូលបម្រើយោធានៅសមរភូមិបានឬអត់ ។

ដើម្បីស្វែងយល់បន្ថែមអំពីការពិភាក្សានៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិស្តីពីការចោទប្រកាន់ ករណី អាល់បាសៀ ពីបទប្រល័យពូជសាសន៍ ការពិភាក្សាភាគច្រើនចាប់អារម្មណ៍ទៅលើតែអង្គហេតុដែលពាក់ព័ន្ធថា នៅពេលមានការវាយប្រហារទៅលើភូមិមួយដែលមានប្រជាជនភាគច្រើនជាក្រុមដែលត្រូវបានទទួលការការពារ «ទាំងកងកម្លាំងរបស់យោធានិងរដ្ឋាភិបាលមិនបានសម្លាប់ប្រជាជនទាំងអស់ទេ ក៏ប៉ុន្តែសម្លាប់តែក្រុមបុរសក្មេងៗ» ។ យោងទៅតាមគណៈកម្មាធិការអង្គការសហប្រជាជាតិប្រចាំតំបន់ដាហ្វ៊ួរបានឲ្យដឹងថា «ការអង្កេតនេះបានបង្ហាញពីចេតនារបស់ឧក្រិដ្ឋជនគឺមិនមែនសំដៅទៅលើក្រុមជនជាតិណាមួយទេ» គឺសំដៅទៅលើ «អ្នកដែលត្រូវបានចាត់ទុកជាក្រុមខ្មាំងតែប៉ុណ្ណោះ» ។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ព្រះរាជអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានបញ្ជាក់ថាជនដៃដល់ «មិនបានបែងចែកឲ្យបានច្បាស់រវាងប្រជាជនស៊ីវិល និងកងទ័ពទេ ។ អង្គបុរេជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនៅមិនទាន់សម្រេចថាតើការចោទប្រកាន់អាល់បាសៀពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍នឹងត្រូវដំណើរការឬក៏អត់ទេ ។

ខណៈមានភាពមិនច្បាស់លាស់ និងមានការចោទប្រកាន់ដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានធ្វើឲ្យពិបាកក្នុងការយកឧទាហរណ៍របស់ប្រទេសស៊ូដង់មកធ្វើជាមេរៀន ការពិភាក្សានេះបង្ហាញឲ្យឃើញថាបញ្ហានេះនៅមិនទាន់មានដំណោះស្រាយនៅឡើយទេ ។ ដើម្បីធ្វើការជំទាស់នឹងការចោទប្រកាន់ពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍នោះ ឧក្រិដ្ឋជនភាគច្រើននឹងអះអាងថា សកម្មភាពដែលធ្វើឡើងនោះគឺស្ថិតនៅក្នុងស្ថានភាពមានជម្លោះប្រដាប់អាវុធ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនូវករណី ក្រាទីក បានកំណត់ថា ការសម្លាប់រាល់មនុស្សទាំងអស់ដែលស្ថិតនៅក្រុមដែលត្រូវទទួលការការពារគឺត្រូវសន្មតថា មានចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ ទោះបីជាមានជាប់ពាក់ពន្ធ័ការសម្រេចបំណងយុទ្ធសាស្ត្រយោធាដើម្បីឈ្នះក៏ដោយ ។ នៅតែមានភាពមិនច្បាស់ថាតើការដាក់គោលដៅជាប្រព័ន្ធទៅលើក្រុមអ្នកតស៊ូ ដូចដែលបានកើតមាននៅ ដាហ្វ៊ួរ អាចយកមកគាំទ្រដល់ការទាញពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។

ជាថ្មីម្តងទៀត ចំណុចខុសគ្នារវាងមូលហេតុជំរុញនិងចេតនា

មានសារសំខាន់សម្រាប់ការវិភាគទៅលើដំណើរការនីតិវិធី ។ ដូចដែលបានពិភាក្សានៅចំណុចខាងលើ មូលហេតុជំរុញឲ្យមានការបំផ្លាញក្រុមដែលត្រូវការពារដោយផ្នែកប្អូនទាំងស្រុងរបស់ខក្រិដ្ឋជន គឺដើម្បីផលប្រយោជន៍ផ្នែកយោធា ។ ប៉ុន្តែ ចំណុចនេះអាចបង្ហាញពីភាពស្របគ្នាដែលថាជនដៃដល់មានគោលបំណងចង់សម្លាប់ក្រុមដែលត្រូវទទួលបានការការពារ ។ ការវែកញែកទៅលើមូលហេតុជំរុញនិងចេតនាបានបង្ហាញថា ការពិភាក្សានៅក្នុងករណី ក្រាទីក ដែលទាក់ទងនឹងការពិតនៃហេតុផលជំរុញឲ្យកងកម្លាំងយោធារបស់ជនជាតិស៊ែបសម្លាប់រង្គាលនៅស្រ៊ីព្រីនីកាប្រហែលជាមិនមានការជាប់ពាក់ព័ន្ធទេ ។ ទោះបីជាមានគម្រោងការច្បាស់លាស់អំពីការសម្លាប់រង្គាលចំពោះតែបុគ្គលនៃក្រុមណាមួយដែលបង្ហាញគំនិតប្រឆាំងក៏ដោយ ក៏អាចនិយាយបានថាមានទាំងចេតនាប្រព្រឹត្តអំពើប្រល័ពូជសាសន៍ ហើយអាចសន្និដ្ឋានថាមានបំណងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ផងដែរ ។

គួឲ្យកត់សម្គាល់ផងដែរតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសវ៉្ររ៉ាន់ដាបានទទួលស្គាល់ថា ការសម្លាប់រង្គាលនិងជម្លោះប្រដាប់អាវុធកើតឡើងដោយមានទំនាក់ទំនងគ្នា គឺថាអំពើប្រល័យពូជសាសន៍ប្រហែលជាកើតឡើងដោយសារតែចង់សម្រេចបំណងយោធា ហើយជម្លោះប្រដាប់អាវុធកើតឡើងដោយការញុះញង់ឲ្យមានផែនការប្រល័យពូជសាសន៍ ។ តាមការពិត តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសវ៉្ររ៉ាន់ដាបានរកឃើញថាអំពើប្រល័យពូជសាសន៍បានកើតឡើងដោយជម្លោះប្រដាប់អាវុធ នៅក្នុងន័យនេះ ជម្លោះប្រដាប់អាវុធនេះត្រូវបានប្រើសម្រាប់ឃោសនាឲ្យមានអំពើប្រល័យពូជសាសន៍ទៅលើជនជាតិទុតស៊ី រួមទាំងក្រុមអ្នកប្រឆាំងនឹងជនជាតិស៊ីវិលទុតស៊ីផង ទោះបីមានជាការសន្និដ្ឋានពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ចេញមកពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធរវាងខក្រិដ្ឋជននិងជនរងគ្រោះក៏ដោយ ។

## ឃ) ភ័ស្តុតាងបង្ហាញពីផែនការ

តុលាការអន្តរជាតិបានពិចារណាភ័ស្តុតាងដោយលើកឡើងថា សកម្មភាពនៃធាតុផ្សំបទឧក្រិដ្ឋ គឺជាលទ្ធផលដែលកើតចេញពីផែនការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ ដូចដែលតុលាការព្រហ្មទណ្ឌអន្តរជាតិប្រទេសវ៉ាន់ដានូវករណី កាយីហ្សីម៉ាថា «ថ្វីបើផែនការជាក់លាក់ដើម្បីបំផ្លាញមិនអាចត្រូវចាត់ទុកថាជាធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ ប៉ុន្តែវាមិនមែនជារឿងងាយស្រួលក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដោយគ្មានផែនការឬការរៀបចំទេ» ។ ម្យ៉ាងវិញទៀត «ខណៈដែលផែនការមិនមែនជាធាតុផ្សំនៃបទឧក្រិដ្ឋប្រល័យពូជសាសន៍» វាអាចជួយជា «ជំនួយភ័ស្តុតាងដើម្បីបង្ហាញពីបំណងរបស់ជនដៃដល់» ។ ដូច្នេះ តុលាការអន្តរជាតិតែងតែយកភ័ស្តុតាងនៃធាតុផ្សំចេតនាប្រព្រឹត្តដែលជាលទ្ធផលនៃផែនការមកទាញពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។

តុលាការបានជំទាស់ទៅនឹងការសន្និដ្ឋានស្មើគ្នាចំពោះភ័ស្តុតាងនៃការរៀបចំផែនការនិងភ័ស្តុតាងនៃចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដោយមិនមានផ្សារភ្ជាប់ការវិភាគសន្និដ្ឋានតាមផ្លូវច្បាប់ ។ ផ្ទុយទៅវិញ តុលាការបែរជាសន្និដ្ឋានថា «ភ័ស្តុតាងដែលបង្ហាញពីផែនការប្រព្រឹត្តអំពើប្រល័យពូជសាសន៍អាចបង្ហាញពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ហើយបន្ទាប់មកទៀតត្រូវបន្តធ្វើការស៊ើបអង្កេតថាតើភ័ស្តុតាងនៃការរៀបចំផែនការនេះអាចសន្និដ្ឋានពីអង្គហេតុបានដែរឬអត់ ។ អាស្រ័យហេតុនេះ ការកំណត់ប្រភេទនៃសកម្មភាពដែលអាចបង្ហាញថាភាពឃោរឃៅគឺជា «ការរៀបចំទុកមុន» យោងទៅតាមស្ថានភាពអង្គហេតុ ។ ជាឧទាហរណ៍ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសវ៉ាន់ដាបានបង្ហាញថា ភ័ស្តុតាងដែលបង្ហាញពីអំពើឃោរឃៅនៅប្រទេសវ៉ាន់ដាមានការរៀបចំទុកមុនពីព្រោះមាន «បញ្ជីសម្លាប់ជនជាតិទុតស៊ី» ដែលករណីមួយចំនួនត្រូវប្រើរយៈពេលមួយខែមុខពេលចាប់ផ្តើមធ្វើសកម្មភាពយុទ្ធនាការឃោសនាថ្កោលទោសជនជាតិទុតស៊ីដែលការជំរុញទឹកចិត្តប្រជាជនទាំងអស់សម្លាប់ជនជាតិទុតស៊ីនិងទីកន្លែងដែកឆេរដែលទីតាំងប្រមូលនិងសម្លាប់ជនជាតិទុតស៊ី ហើយការសម្លាប់នេះបានកើនឡើងជាខ្លាំង បន្ទាប់ពីការធ្លាក់យន្តហោះរបស់ប្រធានាធិបតី ។

## ១) ទម្រង់នៃការប្រព្រឹត្តដោយមានការប៉ុនប៉ងទុក

តុលាការអន្តរជាតិបានទទួលយកភ័ស្តុតាងដែលបានបង្ហាញអំពី «ទម្រង់នៃសកម្មភាពដែលបានប៉ុនប៉ងទុកដើម្បី

អះអាងពីផែនការដែលបានព្រាងទុក» ។ ឧទាហរណ៍ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវីបានរកឃើញថា ការសម្លាប់រង្គាលនៅស្រ៊ីព្រីនីកា ត្រូវបានគេរៀបចំផែនការទុកមុន ពីព្រោះមាន «កងកម្លាំងស្រ៊ីព្រីនីកា ជាច្រើនបានចូលរួមនិងមានការប្រើប្រាស់ភាសាសម្ងាត់ដើម្បីប្រាស្រ័យទាក់ទងគ្នានិងផ្តល់ព័ត៌មានអំពីការសម្លាប់» និងវិធីសាស្ត្រសម្លាប់ដូចគ្នា ។ ស្រដៀងគ្នានេះផងដែរ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានរកឃើញនូវសកម្មភាពផ្សេងៗគ្នាដែលជនដៃដល់ធ្វើការវាយប្រហារប្រឆាំងនឹងជនជាតិទុតស៊ីដើម្បីយកមកបង្ហាញពីភស្តុតាង ។

## ២) ទំហំ ការកំណត់គោលដៅ និងសេចក្តីថ្លែងការណ៍

នៅក្នុងករណីជាច្រើន ស្ថានភាពជាក់ស្តែងដែលតុលាការប្រើប្រាស់ដើម្បីទាញទៅដល់បំណងប្រល័យពូជសាសន៍អាចបង្ហាញពីអំពើពិរុទ្ធដែលបានគិតទុកមុនដោយយោងទៅតាមការស្វែងរកឃើញនិងធ្វើការកំណត់ឲ្យបានច្បាស់លាស់អំពីការសម្លាប់ដោយមានចេតនា ។ ឧទាហរណ៍ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីប្រទេសយូហ្គោស្លាវីបានលើកឡើង «ទំហំនៃការសម្លាប់» នៅឯស្រ៊ីព្រីនីកា ថាជាភស្តុតាងដែលអាចបង្ហាញពីការគ្រោងទុកមុននិងភស្តុតាងបញ្ជាក់ពីបំណងពិរុទ្ធប្រល័យពូជសាសន៍ ។ ស្រដៀងគ្នានេះដែរ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានរកឃើញកត្តាមួយចំនួនដែលជំរុញឲ្យមានការសម្លាប់ជនជាតិទុតស៊ី នៅក្នុងប្រទេសរ៉្វាន់ដា ដើម្បីអះអាងថាអំពើសាហាវឃោរឃៅទាំងនោះគឺជាការគ្រោងទុកមុនដែលការគ្រោងទុកនោះរួមមានវត្តមាននៃ «ការបង្កប់ទ័ព» នៅក្នុងក្រុង គីហ្កាលី រដ្ឋធានីរបស់ប្រទេសរ៉្វាន់ដា «ការចែកចាយកាំបិតដល់ប្រជាជនស៊ីវិល» «ការបណ្តុះបណ្តាលយោធាដោយកងទ័ពរបស់រ៉្វាន់ដា» និង «ទំនាក់ទំនងនៃការចែកកាំបិតដើម្បីប្រជាជនស៊ីវិលទុតស៊ី» ។ តុលាការតែងតែលើកឡើងពីការប្រាស្រ័យទាក់ទងគ្នាតាមរយៈការទំនាក់ទំនងនិងការសរសេរ ដែលអាចសន្និដ្ឋានពីផែនការប្រល័យពូជសាសន៍ ទោះបីជាមានការបកស្រាយពីសេចក្តីថ្លែងការណ៍នោះផ្សេងៗគ្នាក៏ដោយ ។ ជាឧទាហរណ៍ នៅក្នុងករណីស្វែងរកភាពសាហាវឃោរឃៅនៅក្នុងករណី កាយីហ្ស៊ីម៉ា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានលើកឡើងពី «ការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរជាមួយ កាយីហ្ស៊ីម៉ា ដែលរួមមានការប្រើប្រាស់ភាសាទាក់ទងនឹងថាតើការងារបានចាប់ផ្តើមហើយឬនៅ ត្រូវការកម្មករបន្ថែមដែរឬទេ និងសំបុត្រដែលផ្ញើទៅដោយ កាយីហ្ស៊ីម៉ា ដែលស្នើឲ្យអនុវត្តការបោសសម្អាតនៅទីកន្លែងសម្លាប់រង្គាលជនជាតិទុតស៊ី ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីក្រាទីក នៅសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានរកឃើញថា ការប្រាស្រ័យទាក់ទងគ្នាជាសំឡេងដែលស្នើជំនួយជាចាំបាច់នៅក្នុងការចែកចាយកញ្ចប់ចំនួន៣៥០០ មិនអាចអះអាងបញ្ជាក់ថា ក្រាទីកបានរួមគំនិតជាមួយមេដឹកនាំរបស់ខ្លួនបានទេ ។ ស្រដៀងគ្នានេះដែរ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានចាត់ទុកការសន្ទនារវាង ក្រាទីក និងអ្នកនៅក្រោមបង្គាប់ដែលកើតឡើងពីរម៉ោងបន្ទាប់ពីអ្នកនៅក្រោមបង្គាប់ដឹកនាំការសម្លាប់រង្គាលជនជាតិមូស្លីមនៅបូស្នៀចំនួន ពី១០០០ ទៅ ១៥០០ នាក់ ដែលនៅពេលនោះក្រាទីកបានសួរថា «វាដំណើរការយ៉ាងដូចម្តេចដែរ?» ហើយអ្នកនៅក្រោមបង្គាប់បានឆ្លើយថា «វាដំណើរការល្អ» បន្ទាប់មក ក្រាទីក ឆ្លើយតបថា «កុំប្រាប់ខ្ញុំថាអ្នកឯងមានបញ្ហា» ថាជាភស្តុតាងមិនផ្ទាល់ដែលអាចយកមកបញ្ជាក់ថា អ្នកនៅក្រោមបង្គាប់កំពុងតែរាយការណ៍ពីការសម្លាប់ដ៏ជោគជ័យដែលជាផែនការប្រល័យពូជសាសន៍ទូទៅ ។

## ៣) ភាពច្បាស់លាស់

នៅទីបំផុត ភាពច្បាស់លាស់ដែលថាជនដៃដល់មានបំណងពិរុទ្ធប្រព្រឹត្តអំពើប្រល័យពូជសាសន៍មានជាប់ទាក់ទងនឹងការរកឃើញថាដែលថាជនដៃដល់បានរៀបចំផែនការ ។ ដូច្នេះ ចំណុចនេះអាចយកមកបង្ហាញពីចេតនាប្រល័យពូជសាសន៍ ។ ជាឧទាហរណ៍ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា នៅក្នុងករណី កាយីហ្ស៊ីម៉ា បានចង្អុលបង្ហាញពីរយៈពេលបណ្តោះអាសន្នដែលអំពើប្រល័យពូជសាសន៍នៅប្រទេសរ៉្វាន់ដាត្រូវបានលាតត្រដាងឡើងដែលនៅពេលនោះមានជនជាតិទុតស៊ីប្រមាណពី៨សែននាក់ ទៅ ១លាននាក់ត្រូវបានសម្លាប់នៅក្នុងរយៈពេលតែ ១០០ ថ្ងៃប៉ុណ្ណោះ ថាជាផែនការប្រល័យពូជសាសន៍ ។ ជាងនោះ

ទៅទៀត តុលាការបានសង្កត់ធ្ងន់លើអង្គហេតុដែលថាអំពើសាហាវឃោរឃៅកើតឡើងបន្ទាប់ពីមានព្រឹត្តិការណ៍ដ៏ធ្ងន់ធ្ងរ (ការស្លាប់របស់នាយករដ្ឋមន្ត្រី) នៅពេលកំណត់ពីវត្តមាននៃផែនការប្រល័យពូជសាសន៍ ។ គួរកត់សម្គាល់ផងដែរថា ទោះបីជាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានបង្ហាញយ៉ាងច្បាស់នៅក្នុងករណី ក្រាទីកថា ភាពច្បាស់លាស់នោះគ្រាន់តែអាចបង្ហាញពីភ័ស្តុតាង មិនអាចកំណត់ពីផែនការប្រល័យពូជសាសន៍ទេ ។ ផែនការប្រល័យពូជសាសន៍ដែលមិនពេញលេញនិងមានប្រសិទ្ធភាពនៅតែជាផែនការប្រល័យពូជសាសន៍ដដែល ។

ដូចដែលឧទាហរណ៍ទាំងនេះបានបង្ហាញ ភ័ស្តុតាងដែលបញ្ជាក់ពីការរៀបចំផែនការគឺភ័ស្តុតាងបណ្តោះអាសន្ន ។ ដូចជាការសន្និដ្ឋានទៅលើការសម្លាប់ដោយមានចេតនាប្រល័យពូជសាសន៍ ការកំណត់ថាតើមានការរៀបចំផែនការប្រព្រឹត្តអំពើសាហាវឃោរឃៅឬក៏អត់ គឺទំនងជាផ្អែកទៅលើអង្គហេតុ ។ ហើយការសន្មតដោយយោងទៅតាមបរិបទដែលតុលាការជឿជាក់មិនទំនងជាមិនមានវត្តមាននៅក្នុងការរៀបចំដំបូងទេ ។ ដោយហេតុនេះហើយ មិនដូចជាកត្តាដែលរៀបរាប់ខាងលើអំពី ទំហំ គោលដៅ (សេចក្តីថ្លែងការណ៍) វាមានការលំបាកនៅក្នុងកំណត់ថាតើកត្តាជាក់លាក់នេះនឹងត្រូវយកទៅប្រើប្រាស់នៅក្នុងស្ថានភាពជាក់លាក់ដោយរបៀបណា ។

### ង) កត្តាផ្សេងៗទៀត

នៅក្នុងការស្វែងរកថាចេតនាប្រល័យពូជសាសន៍របស់បុគ្គលមានលក្ខណៈខុសប្លែកពីបរិបទនៃអង្គហេតុដែលជននោះបានប្រព្រឹត្តឬក៏អត់ តុលាការអន្តរជាតិបានលើកឡើងពីកត្តាបួនដែលបានពិភាក្សាខាងលើ ។ ជាការពិត មិនមានអ្វីរារាំងតុលាការក្រោយៗទៀតមិនឲ្យទទួលស្គាល់ការជាប់ទាក់ទងនៃកត្តាទាំងនេះឬលើកឡើងពីការពិចារណាផ្សេងទៀតទេ ។ ប៉ុន្តែវាជាធាតុផ្សំដែលបានពឹងផ្អែកដោយតុលាការមុនៗ ។ ខណៈពេលដែលតុលាការបានលើកឡើងពីកត្តាផ្សេងៗទៀត ការស៊ើបអង្កេតបន្ថែមបានបង្ហាញថា អ្នកទាំងនោះប្រើប្រាស់កាយវិការសម្រាប់ធ្វើការពិចារណាតែប៉ុណ្ណោះ ។ កត្តាទាំងពីរនេះ ពោលគឺ «លក្ខណៈទូទៅ» នៃបំណងពិរុទ្ធប្រល័យពូជសាសន៍និងការប្រព្រឹត្ត «សកម្មភាពបំផ្លាញនិងរើសអើង» ត្រូវបានបង្ហាញនៅក្នុងទស្សនៈនេះ ។

***(នៅមានត)*** **រីយ៉ាន អ៊ី.ផាក**

## គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩» និង «សៀវភៅណែនាំគ្រូបង្រៀន» ដែលមានជាភាសាខ្មែរ និងអង់គ្លេស ។ ប្រសិនបើសាធារណជនចង់អាន សូមមើលតាមរយៈគេហទំព័រ

*http://dccam.org/Projects/Genocide/Khmer.htm*

*http://dccam.org/Projects/Genocide/pdf/DC-Cam_%2 0Teacher_Guidebook_Kh.pdf*

## ដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ទោសមេដឹកនាំខ្មែរក្រហម

មកទល់នឹងពេលបច្ចុប្បន្ន គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជនមកចូលរួមស្វែងយល់ក្នុងដំណើរការស្វែងរកយុត្តិធម៌នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចំនួនប្រមាណ៦៩០០នាក់រួចមកហើយ ។ នៅដើមឆ្នាំ២០០៩ គម្រោងឯកសាររស់បានឈានមួយជំហានទៀតក្នុងការផ្តល់ឱកាសឲ្យប្រជាជនចូលរួមដោយផ្ទាល់នៅក្នុងដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ។ នៅរៀងរាល់ការបើកសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអញ្ជើញអ្នកតំណាងមកពីស្រុកភូមិនានាទូទាំងប្រទេសមកឃ្លាំមើលដំណើរការនេះ ។ បន្ថែមពីលើការចូលរួមស្តាប់សវនាការ អ្នកតំណាងទាំងនោះនឹងបានចូលរួមក្នុងវគ្គបំពាក់បំប៉នដើម្បីទទួលចំណេះដឹងផ្សេងៗទាក់ទងទៅនឹងទ្រង់ទ្រាយនៃតុលាការច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម តួនាទីនៃសហព្រះរាជអាជ្ញា ចៅក្រម និងចៅក្រមស៊ើបអង្កេត ភាពខុសគ្នានៃទម្រង់សវនាការព្រមទាំងទស្សនាខ្សែភាពយន្តឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហម ។ អាស្រ័យហេតុនេះ ប្រសិនបើអស់លោកអ្នកមានបំណងចូលរួមក្នុងកម្មវិធីអង្កេតមើលសវនាការឬដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ក្តីមេដឹកនាំខ្មែរក្រហម សូមទាក់ទងស៊ិរ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៦៨៨ ០៤៦ ។ **សូមអរគុណ**

# ផលប៉ះពាល់ចំពោះអាយុ និងសុខភាពរបស់ជនត្រូវចោទមុនពេលទទួលបាន ការជំនុំជម្រះក្ដីនៅមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) មានលក្ខណៈពិសេសខុសពីតុលាការអន្តរជាតិដទៃទៀត ក្នុងនោះដោយសារតែអាយុដ៏ចំណាស់របស់ជនត្រូវចោទនិងការធ្លាក់ដុនដាបនៃសុខភាពរបស់អ្នកទាំងនោះ ។ កាំង ហ្គេកអ៊ាវ (ហៅ «ឌុច») កើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នឹងទទួលបានការជំនុំជម្រះក្ដីនៅអាយុ៦៦ឆ្នាំ គាត់ជាបុគ្គលម្នាក់ដែលមានអាយុក្មេងជាងគេ ។ ជនត្រូវចោទផ្សេងទៀតយ៉ាងហោចណាស់ក៏មានអាយុចាស់ជាង ឌុច ដប់ឆ្នាំដែរ ។ ថ្ងៃខែឆ្នាំកំណើតរបស់អ្នកទាំងនោះមានដូចតទៅ ៖ អៀង ធីរិទ្ធ ថ្ងៃទី១០ មីនា ១៩៣២, ខៀវ សំផន ថ្ងៃទី២៧ កក្កដា ១៩៣១, នួន ជា ថ្ងៃទី៧ កក្កដា ១៩២៦, និង អៀង សារី ថ្ងៃទី២៤ តុលា ១៩២៥ ។ តុលាការអន្តរជាតិដែលកំពុងតែប្រឈមមុខជាមួយនឹងជនត្រូវចោទដែលមានអាយុជិត៧០, ជិត៨០ ឬ បច្ចុប្បន្ន៨០ ប្រឆាំងនឹងគោលបំណងរបស់ អ.វ.ត.ក ក្នុងការ «នាំយកមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត» ទៅកាត់ទោសចំពោះការរំលោភបំពានទៅលើច្បាប់កម្ពុជា ឬច្បាប់អន្តរជាតិនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយសារតែមានជនត្រូវចោទប្រាំនាក់ ការស្លាប់ ឬភាពអសមត្ថភាពរបស់ជនត្រូវចោទណាម្នាក់ឬជនត្រូវចោទទាំងអស់មុនពេលសវនាការកាត់សេចក្ដីត្រូវបានបញ្ចប់នឹងប៉ះពាល់ដល់ អ.វ.ត.ក និងបដិសេធវិធានច្បាប់មិនឲ្យវាដំណើរការទៅធម្មតា ។

អត្ថបទនេះនឹងធ្វើការសិក្សាទៅលើផលប៉ះពាល់នៃអាយុនិងសុខភាពរបស់ជនត្រូវចោទទាក់ទងនឹងភាពស័ក្ដិសមដែលជនត្រូវចោទអាចទទួលការកាត់ទោស ការឃុំឃាំងឬការចូលរួមក្នុងសវនាការ ព្រមទាំងដំណោះស្រាយឬវិធានការដែលថា អ.វ.ត.ក អាចអនុវត្តដើម្បីការពារនិងគោរពសិទ្ធិរបស់ជនត្រូវចោទដែលត្រូវទទួលបានការកាត់ក្ដីដ៏យុត្តិធម៌ ខណៈពេលដែលតុលាការអាចចេញសាលក្រមមុនពេលជនត្រូវចោទស្លាប់ឬអលទ្ធភាពរហូតដល់តុលាការមិនអាចកាត់ទោស ។

តុលាការអន្តរជាតិបានរកឃើញថា សិទ្ធិរបស់ជនត្រូវចោទដែលត្រូវបង្ហាញខ្លួនដោយមានសម្បទាផ្លូវចិត្តត្រូវបានការពារដោយការកំណត់ដែលតម្រូវឲ្យជនត្រូវចោទមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ចូលរួមក្នុងការជំនុំជម្រះក្ដី ។ ជាឧទាហរណ៍ មានសម្បទាផ្លូវចិត្តគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ឬបង្ហាញពីសិទ្ធិចូលរួមក្នុងដំណើរការនីតិវិធីដើម្បីការពារខ្លួនឯង ។ ដោយមានការកំណត់ពីភាពសមស្របសម្រាប់ចូលរួមក្នុងការជំនុំជម្រះក្ដី សេចក្ដីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ករណី ស្រ្ទូហ្គា ឆ្នាំ២០០៤ ក៏បានផ្ដល់បទដ្ឋានដែលមានការទទួលស្គាល់យ៉ាងទូលំទូលាយដើម្បីវាយតម្លៃទៅលើភាពសមស្របក្នុងការចូលរួមក្នុងការជំនុំជម្រះក្ដីរបស់ជនត្រូវចោទថា «ជនត្រូវចោទត្រូវបានចាត់ទុកថាស័ក្ដិសមនឹងចូលរួមក្នុងការជំនុំជម្រះក្ដីនៅពេលដែលជនត្រូវចោទមានលទ្ធភាពទាំងនោះដើម្បីចូលរួមក្នុងដំណើរការនីតិវិធីដោយមានជំនួយ (នៅក្នុងករណីខ្លះ) និងអាចប្រើប្រាស់សិទ្ធិដែលត្រូវបានកំណត់» ។ ការផ្ដោតសំខាន់ទៅលើភាពស្របទៅនឹងតម្រូវការដើម្បីចូលរួមក្នុងការជំនុំជម្រះក្ដីគឺលទ្ធភាពនិងផ្លូវចិត្តរបស់ជនត្រូវចោទ ។ វត្តមាននៃជំងឺផ្លូវកាយឬផ្លូវចិត្តតែមួយនិងលទ្ធភាពដែលថាវាអាចប៉ះទង្គិចទៅលើផ្លូវចិត្តរបស់ជនត្រូវចោទ ឬលទ្ធភាពផ្លូវចិត្តរបស់ជនត្រូវចោទមិនអាចត្រូវបានកំណត់ទុកមុនបានឡើយ ។ ជំងឺផ្លូវចិត្តឬផ្លូវកាយអាចនឹងមានជាប់ពាក់ព័ន្ធនឹងការវាយតម្លៃនៅពេលដែលវាប៉ះពាល់ទៅលើលទ្ធភាពក្នុងការប្រើប្រាស់សិទ្ធិចូលរួមក្នុងដំណើរការនីតិវិធីរបស់បុគ្គល ។ ស្រដៀងគ្នានេះដែរ តុលាការបានរកឃើញថាវាជាធម្មជាតិដែលថាបុគ្គលមានភាពខុសគ្នាផ្នែកការយល់ដឹងនិងភាពឆ្លាតវៃ ហើយភាពខុសគ្នាជាទូទៅនេះមិនបានផ្ដល់ជាការព្រួយបារម្ភដល់ភាពសមស្របសម្រាប់ចូលរួមក្នុងការជំនុំជម្រះក្ដីទេ ។ អាស្រ័យហេតុនេះ ការស្វែងរកភាពអសមត្ថភាពមិនអាចចូលរួមក្នុងការជំនុំជម្រះក្ដីត្រូវតែពឹងផ្អែកទៅលើអ្វីដែលសំខាន់

ជាងការត្រឹមតែបញ្ជាក់ពីកម្រិតទាបនៃភាពឆ្លាតវៃរបស់ចុងចោទ ឬការធ្លាក់ចុះនៃសមត្ថភាពរបស់ជននោះ ។

ប្រសិនបើបញ្ហានៃភាពសមស្របដើម្បីចូលរួមក្នុងការជំនុំជម្រះក្តីកើតឡើង អ.វ.ត.ក ប្រហែលជានឹងត្រូវប្រើប្រាស់បទដ្ឋានគំរូតាមករណី ស្ទ្រុហ្គា ។ នៅ អ.វ.ត.ក វ័យចំណាស់របស់ជនត្រូវចោទមិនគួរជះឥទ្ធិពល ឬផ្លាស់ប្តូរបទដ្ឋានគំរូ ស្ទ្រុហ្គា ដែលបានបង្កើតឡើងយ៉ាងច្បាស់លាស់នោះទេ ។ គំរូ ស្ទ្រុហ្គា អាចកំណត់ថាតើជនត្រូវចោទមានសមត្ថភាពអាចធ្វើការបកស្រាយ ឬប្រើប្រាស់សិទ្ធិចូលរួមក្នុងដំណើរការនីតិវិធីដើម្បីការពារក្តីឬទេ ។ ប្រភពដែលបានដាក់កំហិតដល់សមត្ថភាព ដូចជាផ្លូវកាយ ផ្លូវចិត្ត ទាំងផ្លូវកាយទាំងផ្លូវចិត្ត ឬវ័យចំណាស់គឺមិនមានជាប់ពាក់ព័ន្ធឡើយ ។ បញ្ហាដែលត្រូវបានកំណត់គឺសមត្ថភាពផ្លូវស្មារតីរបស់ជនត្រូវចោទ ។ ឧទាហរណ៍ ជនត្រូវចោទមានសមត្ថភាពស្មារតីនៅអំឡុងពេលរៀបចំការជំនុំជម្រះនិងនៅពេលជំនុំជម្រះ ។ ប្រសិនបើបុគ្គលដែលមានអាយុ១០០ឆ្នាំអាចប្រើប្រាស់សិទ្ធិចូលរួមក្នុងដំណើរការនីតិវិធីនិងចូលរួមដោយមានប្រសិទ្ធភាពនៅក្នុង អ.វ.ត.ក បុគ្គលនោះត្រូវបានចាត់ទុកថាមានសមត្ថភាពស្មារតីចូលរួមក្នុងការជំនុំជម្រះក្តី ។ ដូច្នេះ ដូចដែលបានរៀបរាប់ គំរូ ស្ទ្រុហ្គា គឺជាឧបករណ៍ដ៏សមស្របបំផុតសម្រាប់វាស់ពីសមត្ថភាពផ្លូវស្មារតីរបស់ជនត្រូវចោទក្នុងការប្រើប្រាស់សិទ្ធិចូលរួមក្នុងដំណើរការនីតិវិធី ។

មានបញ្ហាជាច្រើនកើតឡើងនៅ អ.វ.ត.ក ទាក់ទងនឹងថាតើនៅពេលណានិងនៅដំណាក់កាលនៃដំណើរការនីតិវិធីមួយណាដែលភាគីអាចស្នើឲ្យមានការវាយតម្លៃទៅលើភាពសមស្របរបស់ជនត្រូវចោទក្នុងការជំនុំជម្រះក្តី ។ ជនត្រូវចោទអាចស្នើឲ្យអង្គបុរេជំនុំជម្រះឬអង្គជំនុំជម្រះចាត់តាំងអ្នកជំនាញម្នាក់ដើម្បីវាយតម្លៃទៅលើភាពសមស្របរបស់ខ្លួនដើម្បីទទួលការជំនុំជម្រះក្តីនៅអំឡុងដំណាក់កាលស៊ើបអង្កេតឬដំណាក់កាលកាត់សេចក្តីនៅ អ.វ.ត.ក ។ ខណៈពេលដែល អ.វ.ត.ក បានបដិសេធនឹងសំណើដែលស្នើឲ្យមានការចាត់តាំងអ្នកជំនាញម្នាក់ដើម្បីវាយតម្លៃទៅលើភាពសមស្របទទួលការជំនុំជម្រះក្តីរបស់ នួន ជា និង អៀង សារី អ.វ.ត.ក មិនទាន់បានពិចារណាទៅលើយុត្តិសាស្រ្តដែលបង្កើតឡើងនៅពេលថ្មីៗនេះដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីដែលអះអាងថា វេជ្ជបណ្ឌិតនិងអ្នកជំនាញគួរតែផ្តល់យោបល់ទាក់ទងនឹងបញ្ហាដែលស្ថិតនៅក្នុងជំនាញរបស់ខ្លួនតែប៉ុណ្ណោះ ។ សវនាការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានផ្តល់ឧទាហរណ៍ដ៏សំខាន់មួយអំពីថាតើអ្នកជំនាញដែលត្រូវបានចាត់តាំងឲ្យផ្តល់យោបល់ទៅលើជំងឺទាក់ទងនឹងសម្បទាផ្លូវកាយគួរតែកុំផ្តល់យោបល់ទៅលើបញ្ហាផ្លូវចិត្តដោយរបៀបណា ។ «ស្ថានទម្ងន់តិចតួចនឹងត្រូវផ្តល់ឲ្យអ្នកជំនាញខាងជំងឺក្រពះដែលផ្តល់យោបល់ទៅលើសុខភាពផ្លូវចិត្តរបស់ជនត្រូវចោទ» ។ អ.វ.ត.ក ធ្លាប់បានអនុញ្ញាតឲ្យអ្នកជំនាញផ្នែកបេះដូងផ្តល់យោបល់ទៅលើបញ្ហាផ្លូវចិត្តរបស់ជនត្រូវចោទដែលចំណុចនេះមិនត្រូវបានអនុញ្ញាតឲ្យយកមកប្រើប្រាស់នៅក្នុងយុត្តិសាស្រ្តថ្មីៗរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីទេ ។ ជាងនេះទៅទៀត ប្រសិនបើ អ.វ.ត.ក អនុម័តតាមយុត្តិសាស្រ្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី អ.វ.ត.ក គួរតែពិចារណាផងដែរថាតើរបាយការណ៍វេជ្ជសាស្រ្តដែលផ្អែកទៅលើសេចក្តីសម្រេចនេះចេញពីអ្នកជំនាញខាងថតឬអ្នកជំនាញថែទាំសុខភាព ពីព្រោះមិនអាចឲ្យស្ថានទម្ងន់ស្មើគ្នាទៅលើប្រភពទាំងពីរនេះទេ ។

ប្រសិនបើបញ្ហានៃភាពសមស្របនឹងចូលរួមជំនុំជម្រះក្តីរបស់ជនត្រូវចោទកើតមាននៅ អ.វ.ត.ក ភាគីម្ខាងនឹងតម្រូវឲ្យមានភ័ស្តុតាងដាក់បន្ទុក ។ មានជម្រើសពីរចាំបាច់នៅពេលកំណត់មានភ័ស្តុតាងដាក់បន្ទុក ៖ ការដាក់បន្ទុកឲ្យព្រះរាជអាជ្ញាបង្ហាញថាជនត្រូវចោទសមស្របនឹងចូលរួមជំនុំជម្រះក្តី ឬការដាក់បន្ទុកឲ្យមេធាវីការពារក្តីបង្ហាញថាជនត្រូវចោទមិនសមស្របនឹងចូលរួមក្នុងការជំនុំជម្រះក្តីទេ ។ ដូចដែល អ.វ.ត.ក បានបង្ហាញនៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ អ.វ.ត.ក នឹងអនុម័តតាមយុត្តិសាស្រ្ត ស្ទ្រុហ្គា ដោយសន្មត ហើយអនុញ្ញាតឲ្យមេធាវីការពារក្តីរៀបចំពីភ័ស្តុតាងដាក់បន្ទុក ។ ទោះបីជាយ៉ាងណាក៏ដោយ យោងទៅតាមករណី ណាហាក់ ដែលខុសគ្នាបន្តិចបន្តួចតុលាការគួរតែពិចារណាថាថាតើអង្គបុរេជំនុំជម្រះឬអង្គជំនុំជម្រះ

បានចាត់តាំងអ្នកជំនាញម្នាក់ឬក៏អត់ និងថាតើព្រះរាជអាជ្ញាគាំទ្រ ឬមិនគាំទ្រទៅលើការចាត់តាំងបែបនោះ ។ ប្រសិនបើអង្គបុរេជំនុំជម្រះឬអង្គជំនុំជម្រះបានចាត់តាំងអ្នកជំនាញម្នាក់ដើម្បីវាយតម្លៃទៅលើស្ថានភាពរបស់ជនត្រូវចោទ នោះការបង្ហាញពីភស្តុតាងដាក់បន្ទុកត្រូវប្រគល់ឲ្យព្រះរាជអាជ្ញា ។ ស្រដៀងគ្នានេះដែរ ប្រសិនបើព្រះរាជអាជ្ញាជាអ្នកផ្តួចផ្តើមគំនិតឬគាំទ្រទៅលើសំណើរបស់មេធាវីការពារក្តីឲ្យមានការវាយតម្លៃទៅលើភាពសមស្រប នឹងចូលរួមការជំនុំជម្រះក្តីរបស់ជនត្រូវចោទ នោះការបង្ហាញពីភស្តុតាងដាក់បន្ទុកត្រូវប្រគល់ឲ្យព្រះរាជអាជ្ញាដែរ ។ វាប្រហែលជាស្រដៀងនឹងការបកស្រាយនៅក្នុងករណី ណាហាក់ ទៅលើករណី ស្រូហ្គា នៅ អ.វ.ត.ក សម្រាប់ដាក់បន្ទុកលើព្រះរាជអាជ្ញាឲ្យអះអាងលើភាពសមស្របក្នុងការទទួលការជំនុំជម្រះក្តីរបស់ជនត្រូវចោទនៅគ្រប់ករណី ទោះបីជានៅពេលដែលអង្គជំនុំជម្រះមិនបានចាត់តាំងអ្នកជំនាញ ហើយព្រះរាជអាជ្ញាមិនបានលើកគំនិតឬគាំទ្រការចាត់តាំងអ្នកជំនាញក៏ដោយ ។ ចំពោះករណីនេះ អង្គជំនុំជម្រះមិនអាចពឹងផ្អែកទៅលើភាសានិងរចនាសម្ព័ន្ធនៃការវាយតម្លៃទៅលើករណី ស្រូហ្គា ដើម្បីបកស្រាយពីសេចក្តីសម្រេចរបស់ខ្លួនក្នុងការដាក់បន្ទុកលើព្រះរាជអាជ្ញាបានឡើយ ។ ជាងនេះទៅទៀត អង្គជំនុំជម្រះអាចអះអាងថា ចាប់តាំងពីមានការចាប់ខ្លួននិងការឃុំខ្លួនជនត្រូវចោទ បញ្ហាដែលទាក់ទងនឹងភាពសមស្របក្នុងការទទួលការជំនុំជម្រះក្តីរបស់ជនត្រូវចោទដោយសារតែវ័យចំណាស់ និងសុខភាពចុះទ្រុឌទ្រោមតែងតែកើតមាន ។ បន្ថែមពីលើនេះទៅទៀត រាល់ការ «សន្មតទៅលើភាពសមស្របក្នុងការទទួលការជំនុំជម្រះក្តី» មិនបានលើកឡើងដែលនឹងកើតមាននឹងត្រូវទទួលបានស្ថានទម្ងន់តិចតួចប៉ុណ្ណោះបើពិចារណាទៅលើអាយុ និងសុខភាពរបស់ជនត្រូវចោទ ។

ខណៈពេលដែលកំពុងតែរង់ចាំការជំនុំជម្រះក្តី ជនត្រូវចោទទាំងអស់កំពុងស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន ។ មានការយល់ស្របគ្នានៅក្នុងតុលាការអន្តរជាតិទាក់ទងនឹងការដោះលែងជនត្រូវចោទនៃអង្គបុរេជំនុំជម្រះនៅពេលដែលអ្នកទាំងនោះកំពុងតែប្រឈមមុខនឹងការស្លាប់ ឬជំងឺដែលមិនអាចព្យាបាលបានដោយមូលហេតុមនុស្សធម៌ ។ លើសពីនេះទៅទៀត ជនត្រូវចោទអាចត្រូវបានដោះលែងដោយមូលហេតុសុខភាព ប្រសិនបើមិនមានការព្យាបាលដ៏មានប្រសិទ្ធភាពនៅក្នុងមន្ទីរឃុំឃាំងឬនៅក្នុងប្រទេស ។ ចំពោះករណីទាំងពីរនេះ មិនមានការចាំបាច់ត្រូវបញ្ជូនជនត្រូវចោទទៅមន្ទីរពេទ្យឬទីតាំងដែលជនត្រូវរស់នៅទេ ។ បច្ចុប្បន្ន មិនមានភស្តុតាងបញ្ជាក់ថាជនត្រូវចោទនៅ អ.វ.ត.ក មានជំងឺដែលមិនអាចព្យាបាលបាន ឬអាចប៉ះពាល់ដល់អាយុជីវិតនោះទេ ហើយបើយោងទៅតាមការអនុវត្តជាទូទៅនៅ អ.វ.ត.ក អ្នកទាំងនោះនឹងបន្តត្រូវបានឃុំខ្លួននៅដំណាក់កាលអង្គបុរេជំនុំជម្រះ ។ ទោះបីជាយ៉ាងណាក៏ដោយ មានករណីលើកលែងនៅតុលាការអន្តរជាតិ គឺថាជនត្រូវចោទអាចត្រូវបានដោះលែងជាបណ្តោះអាសន្នល្អិកណាមានការអះអាងច្បាស់លាស់ពីការឃុំខ្លួន ។ ការឃុំខ្លួនជនត្រូវចោទនៅ អ.វ.ត.ក អាចបណ្តាលឲ្យមានការប្រឆាំងមិនយល់ស្របពីព្រោះការឃុំខ្លួនជនត្រូវចោទដែលមានវ័យចំណាស់ និងសុខភាពខ្សោយនៅមន្ទីរពេទ្យ ឬទីលំនៅឯកជនក្នុងទម្រង់ជា «ការឃុំខ្លួននៅផ្ទះ» មានភាពស័ក្តិសមនិងស្របទៅតាមករណីលើកលែងដែលកើតមាននៅតុលាការអន្តរជាតិជាង ។

វត្តមាននៃសម្បទាផ្លូវចិត្តរបស់ជនត្រូវចោទនៅអំឡុងពេលដំណើរការនីតិវិធីដែលត្រូវបានការពារដោយតម្រូវការសមស្របដើម្បីចូលរួមក្នុងការជំនុំជម្រះនិងសិទ្ធិក្នុងការបង្ហាញខ្លួននៅអង្គជំនុំជម្រះ ដោយមានសម្បទាផ្លូវកាយសមរម្យសុទ្ធតែជាយន្តការដែលរារាំងដល់ការជំនុំជម្រះគឺបណ្តាលឲ្យមានអវត្តមានជនត្រូវចោទ ។ ការហាមឃាត់ជាទូទៅរបស់ច្បាប់អន្តរជាតិប្រឆាំងនឹងការកាត់ទោសដោយកំបាំងមុខនឹងខ្វះខាតធាតុមួយចំនួនប្រសិនបើការហាមឃាត់នោះតម្រូវឲ្យមានត្រឹមតែវត្តមានសម្បទាផ្លូវកាយមិនចាំបាច់ត្រូវមានសម្បទាផ្លូវចិត្តដើម្បីចូលរួមក្នុងការជំនុំជម្រះ ។ ប៉ុន្តែតើករណីដូចគ្នានឹងត្រូវយកមកប្រើប្រាស់ដែរឬទេប្រសិនបើជនត្រូវចោទមានសម្បទាផ្លូវចិត្តសមស្របនឹងចូលរួមក្នុងការជំនុំជម្រះក្តី ប៉ុន្តែមិនអាចចូលរួមក្នុងសវនាការដោយសារតែជំងឺ? នៅក្នុងករណីទាំងនោះ តុលាការត្រូវតែសម្រេចថាតើត្រូវដំណើរការដោយអវត្តមានរបស់ជនត្រូវចោទ (ឧទាហរណ៍ ការកាត់ទោសកំបាំងមុខ) អនុវត្តយុត្តិសាស្ត្រ

មួយដែលប្រហែលអាចប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទក្នុងការបង្ហាញខ្លួន (ឧទាហរណ៍ តម្រូវឲ្យជនត្រូវចោទចូលរួមដោយប្រើប្រាស់ការប្រាស្រ័យទាក់ទងគ្នាពីមន្ទីរពេទ្យបន្ទប់ឃុំឃាំង) ឬផ្អាកដំណើរការនីតិវិធី ។ តុលាការអន្តរជាតិបានជួបប្រទះនឹងបញ្ហានេះ ប៉ុន្តែមិនមានចម្លើយគួរឲ្យពេញចិត្តណាមួយកើតមានឡើយ ។

ច្បាប់អន្តរជាតិបានផ្តល់សិទ្ធិទូទៅដល់ជនត្រូវចោទដែលត្រូវទទួលបានការកាត់សេចក្តីដោយមានវត្តមានសម្បទាផ្លូវកាយ ។ សិទ្ធិក្នុងការបង្ហាញខ្លួនបានការពារសិទ្ធិរបស់ជនត្រូវចោទដែលចែងថា ត្រូវមានសម្បទាផ្លូវកាយដើម្បីចូលរួមក្នុងការជំនុំជម្រះ ។ ដូច្នេះសិទ្ធិនេះអាចនឹងត្រូវបានយកមកអះអាងជាមួយនឹងសាក្សី និងបង្កើនលទ្ធភាពដល់មេធាវីការពារក្តីក្នុងការប្រើប្រាស់សិទ្ធិចូលរួមដំណើរការនីតិវិធីនោះ ។ ជាងនេះទៅទៀត វត្តមាននៃសម្បទាផ្លូវកាយដើម្បីចូលរួមក្នុងការជំនុំជម្រះក្តីរបស់ជនត្រូវចោទមានសារសំខាន់មិនត្រឹមតែដោយសារតែវាគឺជាចំណុចមួយដ៏តូចដែលអាចធានានូវអនុសញ្ញាស្តីពីសិទ្ធិនយោបាយនិងស៊ីវិលទេ ថែមទាំងសម្រាប់ការពិចារណាបង្កើតអង្គហេតុសម្រាប់សំណុំរឿង និងជំរុញឲ្យមានការកាត់ទោសដ៏សមរម្យនិងស្របតាមច្បាប់ប្រសិនបើជនត្រូវចោទត្រូវបានកាត់ទោស ។

សិទ្ធិរបស់ជនត្រូវចោទដែលត្រូវមានសម្បទាផ្លូវកាយដើម្បីចូលរួមក្នុងការជំនុំជម្រះមិនមានភាពច្បាស់លាស់ ។ តុលាការអន្តរជាតិ និងអ.វ.ត.ក មានវិធានជាក់លាក់ដែលអាចដំណើរការនីតិវិធីដោយមិនមានវត្តមានជនត្រូវចោទប្រសិនបើជននោះមានចេតនារំខាន ឬបដិសេធមិនចូលសវនាការ ។ ទោះបីជាយ៉ាងណាក៏ដោយ ការវិភាគមានលក្ខណៈស្មុគស្មាញជាងមុននៅពេលដែលមានការពន្យារពេល ការបង្អាក់ដល់សវនាការ ឬអវត្តមានជនត្រូវចោទដោយមិនបានរំពឹងទុកមុន ឧទាហរណ៍ដូចជាស្ថានភាពសុខភាព ។ ប្រសិនបើអវត្តមានដោយបញ្ហាសុខភាព អ.វ.ត.ក នឹងជួបប្រទះនូវស្ថានភាពលំបាកពីព្រោះវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក តម្រូវឲ្យមានការយល់ស្របពីជនត្រូវចោទមុនពេលអង្គជំនុំជម្រះអាចចាត់វិធានការទប់ស្កាត់នូវវត្តមាននៃសម្បទាផ្លូវកាយរបស់ជនត្រូវចោទ ឬបន្តកាត់ទោសដោយកំបាំងមុខ ។ ខណៈពេលដែលអង្គជំនុំជម្រះអាចកែសម្រួលការគ្រប់គ្រងដើម្បីសម្របទៅតាមអសមត្ថភាពផ្លូវកាយរបស់ជនត្រូវចោទក្នុងការចូលរួមក្នុងសវនាការដ៏យូរនិងប្រព្រឹត្តឡើងជាច្រើនថ្ងៃក្នុងមួយសប្តាហ៍ អង្គជំនុំជម្រះអាចបង្រួមសវនាការដល់ចំណុចជាក់លាក់មួយចំនួន (ឧទាហរណ៍ បើកសវនាការតែកន្លះថ្ងៃ ឬមួយថ្ងៃក្នុងមួយសប្តាហ៍) ។ ស្រដៀងគ្នានេះដែរ ជនត្រូវចោទអាចបោះបង់សិទ្ធិចូលរួមក្នុងការជំនុំជម្រះ ប៉ុន្តែជនត្រូវចោទមិនគួរធ្វើបែបនេះដោយនិយាយថាខ្លួនមានជំងឺ បន្ទាប់មកលើកឡើងថា មធ្យោបាយដោះស្រាយដ៏សមរម្យគឺត្រូវផ្អាកដំណើរការនីតិវិធី ។ ប្រសិនបើបញ្ហានេះកើតមាន អ.វ.ត.ក នឹងត្រូវឲ្យស្ថានទម្ងន់ទៅលើរបាយការណ៍វេជ្ជសាស្ត្រ និងសម្រេចថាតើជំងឺរបស់ជនត្រូវចោទអាចរារាំងគេមិនឲ្យចូលរួមក្នុងការជំនុំជម្រះឬចូលរួមតាមរយៈការប្រើប្រាស់ការភ្ជាប់ដោយវីដេអូ ។ យ៉ាងហោចណាស់ក៏មានតុលាការមួយអះអាង ជនត្រូវចោទម្នាក់ដែលបានអះអាងថាខ្លួនមានសុខភាពមិនល្អមិនអាចចូលរួមក្នុងដំណើរការនីតិវិធីនៅថ្ងៃជាក់លាក់ណាមួយមានបន្ទុកត្រូវបង្ហាញថានោះពិតជាបញ្ហា ។

ប្រសិនបើអង្គជំនុំជម្រះរកឃើញថា ជនត្រូវចោទមានលទ្ធភាពអាចចូលរួមក្នុងការជំនុំជម្រះ ឬចូលរួមតាមរយៈការភ្ជាប់ដោយវីដេអូ ប៉ុន្តែជននោះបែរជាបដិសេធមិនព្រមចូលរួមក្នុងការជំនុំជម្រះក្តី អ.វ.ត.ក នឹងត្រូវបង្ខំចិត្តលើកលែងសិទ្ធិរបស់ជនត្រូវចោទដែលត្រូវបង្ហាញខ្លួននៅសវនាការ ។ ដើម្បីលើកលែងសិទ្ធិមូលដ្ឋាន អ.វ.ត.ក ត្រូវតែបង្ហាញថាខ្លួនមិនមានជម្រើសសមស្របផ្សេងទៀតទេ ឧទាហរណ៍ ផ្អាកដំណើរការនីតិវិធីដើម្បីរៀបចំ ។ ហើយការលើកលែងសិទ្ធិនេះអាចបម្រើដល់គោលបំណងដ៏សំខាន់មួយ គឺបញ្ចៀសនូវការពន្យារពេលសវនាការ ។ ប្រសិនបើការលើកលែងនេះពិតជាតម្រូវឲ្យមានមែន នោះត្រូវតែមានការលើកលែងសិទ្ធិមួយចំនួនដើម្បីសម្រេចនូវគោលបំណងនេះ ។

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះដើម្បីកំណត់ថាតើសកម្មភាព ឬស្ថានភាពរបស់ជនត្រូវចោទគឺជាចេតនាដែលធ្វើឡើងដើម្បីពន្យារពេលបដិសេធមិនចូលរួម ឬរំខានដល់ការជំនុំជម្រះក្តី ឬមិនមែនជាចេតនាមានសារសំខាន់ណាស់ ។ ខណៈពេលដែលសកម្មភាពអចេតនាត្រូវបានអនុវត្តឡើងដើម្បីបោះបង់សិទ្ធិ

ក្នុងការចូលរួមក្នុងការជំនុំជម្រះក្តី ស្ថានភាពឬសកម្មភាពអចេតនាដែលកើតឡើងមិនមែនដោយសារកំហុសរបស់ជនត្រូវចោទ ប៉ុន្តែបណ្តាលឲ្យមានការពន្យារពេលការជំនុំជម្រះ ជាទូទៅអាចបណ្តាលឲ្យសាលាឧទ្ធរណ៍ ឬអង្គជំនុំជម្រះសង្កត់ធ្ងន់ថា ការលើកលែងសិទ្ធិក្នុងការបង្ហាញខ្លួនគួរតែត្រូវបានបញ្ចៀសប្រសិនបើអាចធ្វើបាន។ អង្គជំនុំជម្រះរបស់ អ.វ.ត.ក ត្រូវជ្រើសរើស «រវាង» ការដាក់កំហិតទៅលើសិទ្ធិរបស់ជនត្រូវចោទក្នុងការបង្ហាញខ្លួននៅពេលជំនុំជម្រះ និងការសម្រេចនូវគោលដៅ ដែលជាដំណោះស្រាយដ៏មានប្រសិទ្ធភាពសម្រាប់ការជំនុំជម្រះនេះ។

ប្រសិនបើជំងឺអាចព្យាបាលបានឬមានលទ្ធភាពអាចជាសះស្បើយ អ.វ.ត.ក ទំនងជាត្រូវបង្ខំចិត្តតម្រូវឲ្យជនត្រូវចោទចូលរួមជាមួយការជំនុំជម្រះតាមរយៈការភ្ជាប់វីដេអូ។ ជាងនេះទៅទៀត ប្រសិនបើជនត្រូវចោទបដិសេធមិនចូលរួមក្នុងការជំនុំជម្រះតាមរយៈការភ្ជាប់វីដេអូ អ.វ.ត.ក នឹងត្រូវធ្វើការកាត់ទោសដោយកំបាំងមុខ។ អ.វ.ត.ក អាចបកស្រាយនូវការកាត់ទោសកំបាំងមុខដែលជាករណីលើកលែងមួយ នៅក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលអនុញ្ញាតឲ្យមានការកាត់ទោសកំបាំងមុខនៅពេលដែលជនត្រូវចោទបដិសេធមិនចូលរួមក្នុងការជំនុំជម្រះក្តី ពីព្រោះនៅពេលខ្លះ ជនត្រូវចោទដែលអះអាងថាមិនអាចចូលរួមក្នុងការជំនុំជម្រះក្តីដោយសារតែស្ថានភាពសុខភាពប្រហែលជាត្រូវតុលាការរកឃើញថាតាមពិតជនត្រូវចោទនោះបដិសេធមិនព្រមចូលរួមតាមរយៈការភ្ជាប់វីដេអូ។ ទោះបីជាអង្គជំនុំជម្រះអាចបកស្រាយនូវការកាត់ទោសកំបាំងមុខ ដោយប្រើប្រាស់មូលហេតុណាក៏ដោយ ក៏វានៅតែអាចជះឥទ្ធិពលដល់ការកាត់សេចក្តីដ៏មានយុត្តិធម៌ដែរ។ ខណៈពេលដែលមិនមានដំណោះស្រាយដែលល្អឥតខ្ចោះ ការបន្តការកាត់សេចក្តីដោយកំបាំងមុខប្រហែលជាជម្រើសតែមួយដែលអនុញ្ញាតឲ្យតុលាការអាចបន្តការកាត់សេចក្តី និងទប់ស្កាត់ការបង្អាក់ដល់ការកាត់សេចក្តី។

នៅទីបញ្ចប់ ខណៈពេលការជំនុំជម្រះក្តីដែលមានជនត្រូវចោទច្រើននាក់អាចចំណេញពេលវេលា យើងគួរតែធ្វើការកត់សម្គាល់ថាសិទ្ធិបង្ហាញខ្លួននៅតុលាការតម្រូវឲ្យមានវត្តមានសហជនត្រូវចោទទាំងអស់។ ប្រសិនបើអង្គជំនុំជម្រះធ្វើការបំបែកករណីនៃសហជនត្រូវចោទទាំងនោះដោយសារតែការពន្យារពេលដែលបណ្តាលមកពីបញ្ហាសុខភាព តុលាការអាចធ្វើការកែតម្រូវខ្លះ។ ឧទាហរណ៍ កាត់ទោសជនត្រូវចោទខ្លះនៅពេលព្រឹក បន្ទាប់មកកាត់ទោសសហជនត្រូវចោទផ្សេងទៀតនៅពេលរសៀល។

អាយុដ៏ចំណាស់និងសុខភាពទ្រុឌទ្រោមរបស់ជនត្រូវចោទប្រាកដជានឹងផ្តល់ការគំរាមកំហែងដល់ អ.វ.ត.ក។ ទោះបីជាយ៉ាងណាក៏ដោយ ការគំរាមកំហែងដែលមិនអាចចៀសផុតនេះ អាចនឹងត្រូវបានទប់ស្កាត់តាមរយៈការទទួលស្គាល់និងការអនុវត្តយន្តការដែលអាចកាត់បន្ថយលទ្ធភាពនៃការកាត់ទោសកំបាំងមុខដែលអាចកើតមាន។ ខណៈពេលដែលជនត្រូវចោទប្រហែលជាអាចនឹងឈានទៅដល់ដំណាក់កាលដែលមិនអាចចូលរួមក្នុងការជំនុំជម្រះក្តី គួរតែមានការរៀបចំវិធានការដើម្បីដោះស្រាយនូវអ្វីដែលមិនបានព្រាងទុកនេះ។ ទោះបីជាមានការតម្រូវឲ្យធ្វើការកាត់ទោសកំបាំងមុខនៅពេលដែលជនត្រូវចោទបដិសេធមិនព្រមចូលរួមក្នុងការជំនុំជម្រះក្តីក៏ដោយ ក៏ការផ្តល់យុត្តិសាស្ត្រដើម្បីដោះស្រាយនឹងបង្កើនរូបភាពពីខាងក្រៅនៃការកាត់សេចក្តីដ៏យុត្តិធម៌ និងឲ្យសញ្ញាណពីកិច្ចខំប្រឹងប្រែងរបស់ អ.វ.ត.ក ដើម្បីឲ្យតម្លៃទៅលើសិទ្ធិដែលត្រូវបង្ហាញខ្លួនរបស់ជនត្រូវចោទ។

**ស្បេនស៊ើ ខ្រាយឌឺ**

# ដំណឹងស្វែងរកឪពុក

ខ្ញុំបាទឈ្មោះ លាភ ចាន់ភារម្យ អាយុ៣៩ឆ្នាំ រស់នៅភូមិអ្នកលឿង ឃុំអ្នកលឿង ស្រុកពាមរ៍ ខេត្តព្រៃវែង។ ខ្ញុំបាទសូមប្រកាសស្វែងរកឪពុកឈ្មោះ ម៉ុច ចាន់ណារី ហៅ លាភ មានស្រុកកំណើតនៅភូមិបឹងព្រះ ឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង ដែលបានបាត់ខ្លួនពីស្រុកពាមជរ ឃុំកោះរកា នៅខែមេសា ឆ្នាំ១៩៧៧ ដោយសារអង្គការបញ្ជូនឲ្យទៅយកអង្ករ។ ចាប់តាំងពីពេលនោះមកគាត់បាត់ខ្លួនរហូត។

ដូច្នេះប្រសិនបើអ្នកណាបានដឹង ឬឮឈ្មោះខាងលើនេះ សូមទំនាក់ទំនងមកខ្ញុំបាទតាមអាសយដ្ឋានខាងលើ ឬទូរស័ព្ទលេខ ០១៥ ៦៧៣ ០០០ ឬ ០៩៧ ៨៧៧ ៧០០៦។ **សូមអរគុណ!**

# រំឭករឿងឈឺចាប់នៅក្នុងរបបខ្មែរក្រហមដើម្បីអ្វី?


សឹម ទីណា ក្នុងឆ្នាំ២០០៩

ចាប់តាំងពីខ្ញុំកើតមក ខ្ញុំតែង តែឮឪពុកម្តាយរបស់ខ្ញុំរៀបរាប់ ថាខ្មែរក្រហមជាមនុស្សសាហាវ ឃោរឃៅនិងសម្លាប់ជនជាតិខ្មែរ ដូចគ្នា ។ ខ្ញុំនៅចាំបានថា ថ្ងៃមួយ ស្រាប់តែគាត់និយាយប្រាប់ខ្ញុំថា «កូនឯងកើតមកនៅក្នុងសម័យ នេះពិតជាសំណាងណាស់ ព្រោះ មិនបានទទួលរងការលំបាកដូចជារូបម៉ែ ដែលត្រូវខ្មែរក្រហមបង្ខំឲ្យធ្វើការជាទម្ងន់និងរស់នៅក្នុងភាពភ័យខ្លាចរហូត» ។ ក្រោយពីបានឮសម្តីនេះ ខ្ញុំមានអារម្មណ៍អាណិតគាត់ទាំងពីរនាក់ជាខ្លាំង ហើយចាប់ផ្តើមមានចម្ងល់ថាហេតុអ្វីបានជាគាត់ទាំងពីរនាក់ទទួលរងនូវការលំបាកបែបនេះ? ខ្ញុំមិនដឹងថា ខ្មែរក្រហមជានរណា? ហើយហេតុអ្វីបានជាគេគ្រប់គ្នាហៅថាខ្មែរក្រហមទេ ប៉ុន្តែរឿងនេះបានដក់ជាប់នៅក្នុងអារម្មណ៍របស់ខ្ញុំរហូតនិងធ្វើឲ្យខ្ញុំចង់ដឹងនូវរឿងរ៉ាវជាច្រើនដែលបានកើតឡើងនៅក្នុងរបបនោះ ។

ថ្ងៃមួយ ម្តាយរបស់ខ្ញុំបានរំឭកអំពីរបបខ្មែរក្រហមទាំងអួលដើមកថា ដំបូងគាត់រស់នៅភូមិទួលផ្សោក ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល ។ នៅឆ្នាំ១៩៧៣ ក្រោយពីម្តាយរបស់ខ្ញុំរៀបការជាមួយឪពុកខ្ញុំបានបីខែ កងទ័ពខ្មែរក្រហមក៏បានចូលមកដល់ភូមិនេះ ហើយដុតផ្ទះរបស់ប្រជាជនស្ទើរគ្មានសល់ ។ ហេតុការណ៍នេះបានធ្វើឲ្យប្រជាជនភ័យខ្លាចគ្រប់គ្នា រួចក៏នាំគ្នាភៀសខ្លួនមករស់នៅសង្កាត់ច្រាំងចំរេះ ក្រុងភ្នំពេញវិញ ។

នៅឆ្នាំ១៩៧៥ ពេលដែលកងទ័ពខ្មែរក្រហមចូលមកកាន់កាប់ទីក្រុងភ្នំពេញបានទាំងស្រុង ប្រជាជនដែលរស់នៅច្រាំងចំរេះចាប់ផ្តើមនាំគ្នារៀបចំអីវ៉ាន់ចាកចេញពីលំនៅឋានទៀត ។ ចំណែកឪពុកម្តាយរបស់ខ្ញុំវិញបានប្រមូលសមាជិកគ្រួសារទាំងអស់រត់ទៅពួននៅបន្ទាយទាហានលេខប្រាំ (សព្វថ្ងៃនៅម្តុំបឹងអកមក) ដែរ ។ សម្រាកបានមួយថ្ងៃមួយយប់ កងទ័ពខ្មែរក្រហមក៏ចូលមកម្តុចដល់បន្ទាយនេះទៀត រួចបញ្ជាឲ្យធ្វើដំណើរត្រឡប់មកច្រាំងចំរេះវិញ ។ ដោយសារមានមនុស្សកកកុញខ្លាំងពេក ធ្វើដំណើរបានពាក់កណ្តាលផ្លូវ បងប្អូនខាងម្តាយមីងរបស់គាត់ទាំងអស់ត្រូវបែកគ្នា ដោយនៅជុំគ្នាតែលោកតា លោកយាយ ឪពុកម្តាយខ្ញុំ និងប្អូនស្រីពៅរបស់គាត់ម្នាក់ទៀតប៉ុណ្ណោះ ។ ចំណែកបងស្រីទាំងពីររបស់គាត់ត្រូវបានជម្លៀសទៅនៅខាងព្រែកកក់ ស្រុកស្ទឹងត្រង់ ។

រស់នៅច្រាំងចំរេះបានមួយរយៈ ខ្មែរក្រហមបានផ្លាស់ឪពុកម្តាយរបស់ខ្ញុំឲ្យទៅរស់នៅស្រុកចម្ការលើវិញ ។ នៅទីនោះឪពុកម្តាយរបស់ខ្ញុំត្រូវខ្មែរក្រហមបង្ខំឲ្យធ្វើការទាំងថ្ងៃ ទាំងយប់ ដូចជាធ្វើស្រែ រែកដី លើកទំនប់ និងជីកប្រឡាយជាដើម ។ ក្រោយមក ប្រធានកងបានអនុញ្ញាតឲ្យម្តាយរបស់ខ្ញុំឈប់សម្រាករយៈពេលបីខែ ក្រោយពីគាត់សម្រាលបានកូនប្រុសម្នាក់ឈ្មោះអារីហ៊ីន ។ ប៉ុន្តែ ខ្មែរក្រហមបានធ្វើបាបគាត់យ៉ាងខ្លាំង តាមរយៈការផ្តល់


សឹម ទីណា និងក្រុមគ្រួសារ ក្នុងឆ្នាំ១៩៩៧

សាច់ជ្រូកឲ្យគាត់ហូប ទោះបីជាដឹងថាជនជាតិចាមមិនហូបសាច់ជ្រូកក៏ដោយ ។ ដូច្នេះហើយ ម្តាយរបស់ខ្ញុំមានតែទៅសុំអាហារពីប្រធានកង តែអ្នកទាំងនោះឲ្យតែអំបិលនិងអម្ពិលបន្តិចបន្តួចប៉ុណ្ណោះ ។ ដោយសារតែឃើញម្តាយរបស់ខ្ញុំអស់កម្លាំង និងគ្មានអ្វីហូប ឪពុកខ្ញុំបានលួចទៅរកត្រីយកមកឲ្យគាត់ ។ ប៉ុន្តែក្រោយពេលដែលម្តាយខ្ញុំហូបរួច ស្រាប់តែគាត់ឈឺទាស់ ហើយហូរឈាមតាមមាត់និងច្រមុះចេញមក ។ ស្ថានភាពជំងឺរបស់គាត់មានសភាពធ្ងន់ធ្ងរជាខ្លាំងរហូតដល់ខ្មែរក្រហមបានបញ្ជូនគាត់ទៅព្យាបាលនៅមន្ទីរពេទ្យស្រុក ។ នៅទីនោះ គ្រូពេទ្យបានព្យួរសេរ៉ូម និងចាក់ថ្នាំបេខូដែលដាក់នៅក្នុងដបទឹកក្រូច ព្រមទាំងផ្តល់ថ្នាំអាចម៍ទន្សាយឲ្យម្តាយខ្ញុំលេប ។ ចំណែកការហូបចុកវិញ គឺទទួលបានតែសៀងប៉ុណ្ណោះ ដែលធ្វើឲ្យខ្លួនរបស់គាត់កាន់តែចុះខ្សោយទៅៗ ធ្វើឲ្យដៃជើងរបស់គាត់មិនអាចកម្រើកបាន ។

មួយរយៈក្រោយមក ខ្មែរក្រហមចាប់ផ្តើមយកប្រជាជនទៅសម្លាប់ជាបន្តបន្ទាប់ ដោយសារតែសង្ស័យថាក្បត់នឹងអង្គការ ។ ពេលនោះ ទាំងជនជាតិខ្មែរនិងជនជាតិចាមចំនួន៧០០គ្រួសារ នៅក្នុងភូមិពព្រេងត្រូវខ្មែរក្រហមសម្លាប់ចោលទាំងអស់ សូម្បីតែក្មេងក៏មិនលើកលែងដែរ ។ ចំណែកឪពុកម្តាយរបស់ខ្ញុំដែលកំពុងសម្រាកនៅមន្ទីរពេទ្យក៏ត្រូវខ្មែរក្រហមដឹកតាមឡានចេញពីមន្ទីរពេទ្យយកទៅសម្លាប់ដែរ ។ ប៉ុន្តែ គាត់ទាំងពីរនាក់សំណាងណាស់ ព្រោះធ្វើដំណើរបានពាក់កណ្តាលផ្លូវ ពេទ្យស្រុកស្រាប់តែបញ្ជូនគាត់ទៅព្យាបាលនៅខេត្តកំពង់ចាមវិញ ។ អ្នកបើកបរនោះបានប្រាប់ឪពុកខ្ញុំថា «ប្រសិនបើប្រពន្ធមិត្តស្លាប់ យើងនឹងទម្លាក់គាត់នៅចម្ការកៅស៊ូហើយ យើងមិនបានកប់ទេ» ។

ពេលមកដល់មន្ទីរពេទ្យខេត្តកំពង់ចាម សុខភាពរបស់ម្តាយខ្ញុំកាន់តែទ្រុឌទ្រោមជាងមុនទៅទៀត ព្រោះមិនមានថ្នាំសម្រាប់ព្យាបាលជំងឺទាស់របស់គាត់ទេ ។ ដូច្នេះ ខ្មែរក្រហមបានសម្រេចបញ្ជូនម្តាយរបស់ខ្ញុំមកព្យាបាលនៅពេទ្យរុស្ស៊ីវិញ ចំណែកឪពុកខ្ញុំនិងបងប្រុសឲ្យត្រឡប់ទៅភូមិពព្រេង ។ គ្រាន់តែឮថាទៅភ្នំពេញ ម្តាយរបស់ខ្ញុំព្រួយបារម្ភជាខ្លាំង ព្រោះដឹងច្បាស់ថានេះគ្រាន់តែជាលេសទេព្រោះខ្មែរក្រហមប្រាកដជាយកគាត់ទៅសម្លាប់ជាមិនខាន ។ ដោយសារតែម្តាយរបស់ខ្ញុំជាមនុស្សសកម្មនឹងការងារ ក្រោយពីស្តាប់ពាក្យការអង្វររបស់គាត់ ខ្មែរក្រហមទាំងនោះក៏សម្រេចចិត្តឲ្យគាត់មកស្នាក់នៅពេទ្យត្រើងជាកន្លែងសម្រាប់ដាក់អ្នកជំងឺឃ្លង់វិញ ។

នៅទីនេះ សុខភាពម្តាយរបស់ខ្ញុំស្រាប់តែបានធូរស្បើយជាងមុននិងអាចក្រោកដើរបានពីរ-បីជំហាន ។ ប៉ុន្តែបងប្រុសរបស់ខ្ញុំបែរជាកាន់តែខ្សោយទៅៗ ដោយខ្វាក់ភ្នែកម្ខាង ហើយសន្លប់មួយថ្ងៃបីដងទៀត ។ ដោយសារតែភ័យខ្លាចបងប្រុសខ្ញុំស្លាប់នៅក្នុងព្រៃ គាត់ក៏បានសុំលោកគ្រូពេទ្យត្រឡប់មកព្យាបាលនៅផ្ទះវិញ ។ ពេលនោះ គ្រូពេទ្យបានឃាត់ម្តាយរបស់ខ្ញុំមិនឲ្យទៅទេ ព្រោះភូមិនោះគ្មានមនុស្សរស់នៅ ។ ប៉ុន្តែ ម្តាយខ្ញុំមិនជឿ ដោយគាត់នៅតែទទូចសុំទៅដដែល ។ ក្រោយពីគ្រូពេទ្យត្រើងអនុញ្ញាតឲ្យគាត់ចាកចេញ ទើបគាត់ជឿថាវាជាការពិត ។

បន្ទាប់មក រថយន្តក៏បានធ្វើដំណើរមកដល់មុខវត្តស្ទឹងដែលជាផ្លូវចូលទៅកាន់ភូមិពព្រេង ហើយក៏ឈប់នៅថ្នល់ជាតិ ។ នៅពេលគាត់ទាំងពីរនាក់ចុះពីលើរថយន្ត ហើយក្រឡេកមើលទៅចំហៀងផ្លូវ គាត់ឃើញមានស្រាស់បុស្សរីព័ទ្ធជុំវិញ និងមានស្លាកសញ្ញាក្បាលខ្មោច ។ ដោយមិនដឹងថាត្រូវធ្វើដំណើរទៅកន្លែងណាទៀត គាត់ទាំងពីរនាក់ក៏នាំគ្នាអង្គុយយំ ហើយនាំគ្នាបួងសួងដល់ព្រះជាម្ចាស់ (អុលឡោះ) ឲ្យជួយបង្ហាញផ្លូវដល់គាត់ទាំងពីរនាក់ផង ។ បន្ទាប់មក គាត់ក៏នឹកឃើញថាត្រូវតែចូលទៅខាងភូមិអកមកវិញ ។ ម្តាយខ្ញុំបានដើរចូលទៅភូមិអកមកទាំងប្រថុយ ដោយទុកបងប្រុស និងឪពុកខ្ញុំឲ្យចាំនៅថ្នល់ជាតិសិន រួចផ្តាំថា «បើសិនជាខ្ញុំចូលទៅហើយអត់ឃើញចេញមកវិញទេ នោះបានន័យថាស្លាប់ហើយ» ។ ពេលចូលទៅដល់ភូមិ អ្នកស្រុកនិងឈ្លបស្មានថា ម្តាយរបស់ខ្ញុំជាអ្នកលើកទំនប់មកពីកំពង់ថ្មដែលឈឺ ហើយមកដល់ក្រោយគេ រួចក៏បានសួរថា មកពីកំពង់ថ្មមែនទេ? ពេលនោះ ម្តាយរបស់ខ្ញុំក៏ឆ្លើយទៅវិញថា ខ្ញុំមកពីកំពង់ថ្ម ។ បន្ទាប់មក គាត់ក៏បានដើរសំដៅទៅដល់ផ្ទះឪពុកម្តាយគាត់ ដោយគិតថាគាត់ទាំងពីរនាក់ស្លាប់អស់ហើយ ព្រោះឮថាខ្មែរក្រហមសម្លាប់ប្រជាជនភូមិពព្រេងអស់ហើយ ។ ពេលដែលឡើងទៅដល់ខាងលើផ្ទះ ស្រាប់តែគាត់ក្រឡេកទៅកៀនជញ្ជាំងឃើញម្តាយរបស់គាត់ឈឺហើមពេញខ្លួន ។ ម្តាយខ្ញុំមិនអាចទប់ទឹកភ្នែកបានក៏យំ

ហើយបានសួរទៅថា ឪពុកនិងយាយនៅដែរទេ? ម្ដាយគាត់ឆ្លើយថាឪពុកក្នុងនៅរស់ តែលោកយាយស្លាប់ហើយដោយសារជំងឺផ្ទុះគ្រាប់ភ្នែក ។ ក្រោយមក ម្ដាយខ្ញុំក៏ពឹងឲ្យគេដើរទៅហៅឪពុកគាត់នៅកន្លែងសិប្បកម្មដើម្បីនាំឪពុកខ្ញុំនិងបងប្រុសដែលចាំនៅថ្នល់ជាតិឲ្យមកជួបជុំគ្នា ។ សម្រាកមួយយប់នៅភូមិអកមក ព្រឹកឡើងឪពុកខ្ញុំក៏សម្រេចចិត្តចូលទៅរស់នៅភូមិពព្រេងវិញ ព្រោះនៅភូមិអកមកមិនទទួលគាត់ទាំងពីរឲ្យរស់នៅទេ ដោយសារតែគ្មានសំបុត្រអនុញ្ញាត ។ ពេលដែលចូលទៅដល់ភូមិពព្រេង មេកងឆ្ងល់ជាខ្លាំងថាហេតុអ្វីបានយកទៅសម្លាប់ចោលហើយបែរជានៅរស់ទៅវិញ ។ ពេលនោះ អ្នកស្រុកនៅភូមិពព្រេងគ្មាននរណាហ៊ាននិយាយជាមួយគាត់ទេ ព្រោះគេចាត់ទុកគាត់ថាជាខ្មាំង ។

ក្រោយពីស្ដាប់ការបកស្រាយរបស់ឪពុកខ្ញុំរួចមក ទើបប្រធានកងអនុញ្ញាតឲ្យគាត់ទាំងបីនាក់រស់នៅទីនេះ ។ បន្ទាប់មក ឪពុកខ្ញុំបានប្រាប់ប្រធានកងថា «ប្រពន្ធខ្ញុំដើរមិនរួចទេ ឥឡូវសម្រាកនៅភូមិអកមក» ។ ដោយសារប្រធានកងអាណិតឪពុកខ្ញុំ គាត់ក៏ប្រាប់ថា គាត់ផ្ញើសំបុត្រទៅប្រធានភូមិអកមកឲ្យគាត់នៅទីនោះមួយរយៈសិន ។ ប៉ុន្តែ ពេលដែលទទួលសំបុត្រពីភូមិពព្រេងបានហើយ ប្រធានភូមិអកមកនៅតែមិនទទួលគាត់ឲ្យរស់នៅដដែល ដោយបានចោទគាត់ទាំងពីរថាជាខ្មាំង ។ ក្រោយមក លោកតាម្នាក់ដែលធ្វើការជាមួយជីតារបស់គាត់ឈ្មោះ តារិន បានជួយយកសំបុត្រទៅដាក់ជាមួយនឹងក្រុមកងចាស់ៗរបស់គាត់ ។ ប៉ុន្តែ ម្ដាយខ្ញុំគាត់នៅតែមានការភ័យខ្លាចប្រធានភូមិរករឿងជានិច្ច ដូច្នេះ គាត់ក៏ទៅសុំលោក តារិន ធ្វើការជាមួយវិញ ។ ក្រោយពីបានរស់នៅក្នុងភូមិអកមកបានរយៈពេលមួយឆ្នាំ បងប្រុសខ្ញុំដែលទើបតែមានអាយុប្រាំពីរខែបានស្លាប់ទៅទៀត ។ ក្រោយមក តារបស់ខ្ញុំក៏ចាប់ផ្ដើមឈឺខ្លាំង ហើយចេះតែស្រែកថាឃ្លាន ។ ថ្ងៃមួយ មុនពេលដែលគាត់ជិតស្លាប់ គាត់ឃ្លានចង់ហូបទឹកត្នោតជាខ្លាំង ដូច្នេះម្ដាយខ្ញុំនិងប្អូនស្រីរបស់គាត់បាននាំគ្នាដើរទៅសុំទឹកត្នោតយកមកឲ្យគាត់ហូប ។ ម្ចាស់ទឹកត្នោតនិយាយថា «បើមិត្តឯងចង់បានក៏ទៅយកចុះ តែទទួលខុសត្រូវដោយខ្លួនឯង» ។ ពេលនោះ ម្ដាយខ្ញុំមិនខ្លាចស្លាប់ទេ ដោយគាត់ហ៊ានដួសទឹកត្នោតមួយដ្ពិលធំមកឲ្យលោកតាខ្ញុំ ។ បីថ្ងៃក្រោយមក តាខ្ញុំបានស្លាប់បាត់ទៅ ។ គ្រាន់តែតារបស់ខ្ញុំស្លាប់ភ្លាម អ្នកដែលនៅក្បែរផ្ទះគាត់ចេះតែរករឿងគាត់ ដោយនិយាយថា ម៉េចមិនយកពីរនាក់ប្ដីប្រពន្ធនេះទៅសម្លាប់ចោលទៅ? ព្រោះតែអាណិតឪពុកម្ដាយខ្ញុំ ប្រធានកងដែលនៅក្បែរផ្ទះលោកតាខ្ញុំមិនបានធ្វើតាមទេ ។

ក្រោយពីកងទ័ពវៀតណាមចូលមករំដោះនៅឆ្នាំ ១៩៧៩ គាត់ទាំងពីរនាក់ក៏បានត្រឡប់មកលំនៅឋានវិញ ។ បើទោះបីជារឿងរ៉ាវទាំងអស់បានកន្លងផុតទៅអស់រយៈពេលជាង ៣០ឆ្នាំហើយក៏ដោយ ក៏មិនអាចធ្វើឲ្យម្ដាយខ្ញុំបំភ្លេចនូវភាពឈឺចាប់ទាំងអស់នោះបានដែរ ។

ចំណែកខ្ញុំដែលកើតក្រោយរបបនេះពិតជាមានអារម្មណ៍ខ្លាចផ្សារក្រៃលែងដែលខ្មែរក្រហមសម្លាប់ប្រជាជនយ៉ាងសាហាវឃោរឃៅបែបនេះ ។ ដូច្នេះខ្ញុំសង្ឃឹមថា មានតែតុលាការខ្មែរក្រហមនេះហើយដែលអាចជួយរកយុត្តិធម៌ដល់ក្រុមគ្រួសាររបស់ឪពុកម្ដាយខ្ញុំ ក៏ដូចជាជនរងគ្រោះទាំងអស់ដែលបានស្លាប់នៅក្នុងរបបនេះបានស្ងប់ចិត្ត ព្រមទាំងអាចផ្សះផ្សារបួសផ្លូវចិត្តដែលមានពីមុនមកផង ។ **សឹម ធីណា**

# ដំណឹងស្វែងរកគ្រួសារ

ខ្ញុំបាទឈ្មោះ ស៊ុន ភី មានអាយុ៤៣ឆ្នាំ រស់នៅភូមិតាគង់ ឃុំណាតាវ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ មានឪពុកឈ្មោះ ស៊ុន ហួ និង ម្ដាយឈ្មោះ ធី ។ ខ្ញុំសូមប្រកាសស្វែងរកបងប្អូន៦នាក់ដែលបានបាត់ខ្លួននៅឆ្នាំ១៩៧៦ ៖ ១)បងប្រុស ស៊ុន ហួង ២) បងស្រី ស៊ុន រិន ៣) បងប្រុស ស៊ុន ពន្លក ៤) បងស្រី ស៊ុន នឿន ៥) ប្អូនប្រុស ស៊ុន ថៃ ៦) ប្អូនស្រី ស៊ុន ចុល ។ នៅឆ្នាំ១៩៧៦ រយៈពេលពីរទៅបីថ្ងៃក្រោយថ្ងៃដែលខ្មែរក្រហមចាប់ខ្លួនឪពុករបស់ខ្ញុំយកទៅ ខ្មែរក្រហមបានជម្លៀសគ្រួសាររបស់ខ្ញុំទៅកាន់ព្រៃស ។ ចាប់តាំងពីថ្ងៃនោះមក ខ្ញុំក៏បាត់ដំណឹងពីគាត់រហូត ដោយមិនដឹងថានៅរស់ឬក៏ស្លាប់ទេ ។

ប្រសិនបើបងប្អូនណាបានឃើញ ឬបានស្គាល់ សូមទាក់ទងមកអាសយដ្ឋានខាងលើ ឬតាមរយៈលេខទូរស័ព្ទ ០១២ ២៩០ ៨៨១ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ។ **សូមអរគុណ!**

# ដំណឹងស្វែងរកកូនស្រី

ខ្ញុំបាទឈ្មោះ អៀ យុនលី អតីតម្ចាស់ហាងឡាប៉ៃយុត្ត មានឪពុកឈ្មោះ សុក ហុក។ នៅឆ្នាំ១៩៧៥ ខ្ញុំបានបាត់កូនស្រីម្នាក់ឈ្មោះ អៀ សុវណ្ណនី នៅពេលដែលខ្មែរក្រហមជម្លៀសនាង ទៅភូមិសុភីក្លែង ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ។

ប្រសិនបើបងប្អូនណាបានឃើញ ឬបានស្គាល់ឈ្មោះខាងលើនេះ សូមទំនាក់ទំនងមកខ្ញុំបាទតាមទូរស័ព្ទលេខ ០១៦ ៨៧៨ ៣៧៧ ឬផ្ទះលេខ៨៨៧ ផ្លូវ៣៦៩ សង្កាត់ច្បារអំពៅ ២ ភូមិដើមចាន់ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

# ដំណឹងស្វែងរកបងប្រុសឈ្មោះ នឹម ណៃម

នាងខ្ញុំឈ្មោះ នឹម ផា សព្វថ្ងៃរស់នៅភូមិបឹងហឹង ឃុំត្រពាំងល្វា (សព្វថ្ងៃឃុំភ្នំតូច) ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ។ ខ្ញុំមានឪពុកឈ្មោះ នឹម (ស្លាប់) ម្តាយឈ្មោះ ឈឹម សែស (ស្លាប់) ។ ខ្ញុំមានបងប្អូន៣នាក់ ១) នឹម ណៃម ប្រុស ២) នឹម ផា ខ្ញុំ) និង ៣) នឹម ផុន ស្រី ។ ខ្ញុំសូមប្រកាសរកបងប្រុសឈ្មោះ នឹម ណៃម ដែលបានបែកពីផ្ទះតាំងពីឆ្នាំ១៩៧៥ ។

នៅពេលខ្មែរក្រហមទទួលជ័យជម្នះនៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសឪពុកម្តាយខ្ញុំពីភូមិបឹងហឹង ឲ្យទៅរស់នៅភូមិស្វាយ និងភូមិធំ ឃុំពញាពន់ ស្រុកពញាឮ ខេត្តកណ្តាល ។ ចំណែក បងប្រុសខ្ញុំ (នឹម ណៃម) ខ្មែរក្រហមបានជ្រើសរើសយកមកធ្វើការនៅក្រុងភ្នំពេញ ហើយចាប់តាំង ពីពេលនោះមក គ្រួសារខ្ញុំមិនដែលបានទទួលដំណឹងពីគាត់ទេ ។

រហូតមកដល់ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១០ អ្នករស់នៅក្នុងភូមិជាមួយខ្ញុំ មកប្រាប់ខ្ញុំថា បងប្រុសខ្ញុំឈ្មោះ នឹម ណៃម នៅរស់ ហើយបានប្រកាសស្វែងរកឈ្មោះឪពុកម្តាយខ្ញុំ, ខ្ញុំ និងប្អូនស្រី តាមវិទ្យុ (មិនចាំឈ្មោះប៉ុស្តិ៍វិទ្យុ) ។

ប្រសិនបើបងប្អូនណាបានឮ ឬស្គាល់ឈ្មោះ នឹម ណៃម សូមទាក់ទងមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ឬ តាមរយៈទូរស័ព្ទលេខ ០១៧ ៤១៩ ០៥៣ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# សំបុត្រពីអ្នកអាន

នាងខ្ញុំឈ្មោះ វ៉េនេសា គង់ ។ ឪពុកនិងម្តាយចំនួនបីនាក់របស់ខ្ញុំបានរស់រានពីរបបខ្មែរក្រហម ។ ជីដូនរបស់ខ្ញុំមានឈ្មោះថា ធូ មុី ហើយជីតារបស់ខ្ញុំមានឈ្មោះ គង់ ព្រឹន ។ ខ្ញុំគិតថា ឈ្មោះដែលខ្ញុំសរសេរខាងលើនេះពិតជាត្រឹមត្រូវដែលខ្ញុំមិនដែលស្គាល់ឈ្មោះម្តាយមីង និងឪពុកមាពីរនាក់របស់ខ្ញុំទេ ។ ឪពុករបស់ខ្ញុំបានប្រាប់ខ្ញុំថា ជីតារបស់ខ្ញុំជាប្រធានភូមិឬក្រុង ។ នៅក្នុងជីវិតរបស់ខ្ញុំ ខ្ញុំតែងតែចង់ដឹងឮពីអ្នកដែលនៅរស់ដើម្បីកាត់បន្ថយភាពស្ងប់ស្ងាត់នៃអ្វីដែលបានកើតឡើង ។ ខ្ញុំតែងតែសួរឪពុករបស់ខ្ញុំពីព័ត៌មានរបស់អ្នកទាំងនោះជាច្រើនលើកច្រើនសា ប៉ុន្តែគាត់បានរៀបរាប់នូវអ្វីដែលបានកើតឡើងតែបន្តិចបន្តួចប៉ុណ្ណោះ ហើយគាត់ព្យាយាមបង្វែរនូវកិច្ចសន្ទនានោះវិញ ។ ដោយដឹងពីភាពឈឺចាប់ដែលគាត់បានជួបប្រទះ ខ្ញុំមិនដែលបង្ខំសួរគាត់ឡើយ ។ ប៉ុន្តែ ដោយគ្រាន់តែស្គាល់ឈ្មោះជីដូនជីតា ខ្ញុំគិតថា យ៉ាងហោចណាស់ខ្ញុំគួរតែស្វែងរកនូវអ្វីដែលបានកើតឡើងចំពោះអ្នកទាំងនោះដែរ ។ ខ្ញុំទើបតែមានអាយុ ១៨ឆ្នាំ ។ ខ្ញុំទើបតែបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ ហើយខ្ញុំត្រូវបានកើតនិងធំធាត់នៅរដ្ឋកាលីហ្វ័រនីញ៉ា ។ ខ្ញុំមិនដឹងច្បាស់នូវអ្វីដែលគ្រួសាររបស់ខ្ញុំធ្លាប់បានឆ្លងកាត់ឡើយ ។ ដោយឃើញយុវជននិងសង្គមបច្ចុប្បន្ន ខ្ញុំចង់រំពុកខ្លួនឯងមិនឲ្យត្រឡប់ទៅអតីតកាលម្តងទៀតទេ ។ អតីតកាលដែលធ្វើឲ្យមានអ្នកនៅពេលបច្ចុប្បន្ន ។ មានរបស់ជាច្រើនដែលកប់យ៉ាងជ្រៅនៅក្នុងជីវិតដែលធ្វើឲ្យយើងមិនអាចបំភ្លេចបាន ។ ខ្ញុំមិនចង់ឲ្យរឿងរ៉ាវទាំងនេះ ឬព្រឹត្តិការណ៍ទាំងនេះត្រូវបានបំភ្លេចចោលនោះទេ ។ ខ្ញុំមិនចង់ស្លាប់ដោយមិនដឹងអ្វីទេ ខ្ញុំគ្រាន់តែចង់ស្តាប់ ចង់ឮ និងនិយាយជំនួសអ្នកទាំងនោះប៉ុណ្ណោះ ។ **វ៉េនេសា គង់**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាងមួយលាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល : truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោម:***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍: ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍: ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍: រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍: លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម:***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍: រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

◆ **រៀបរាប់អំពីបទពិសោធន៍នៅអំឡុងរបបខ្មែរក្រហមគឺជាការជំរុញឱ្យមានការផ្សះផ្សា និងអប់រំក្មេងៗអំពីការអភ័យទោសនិងការអធ្យាស្រ័យគ្នា។**

◆ **ការសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យគឺដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍**

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក នរវេ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 127, July 2010 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.